មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ សំ ភីន ភេទប្រុស អាយុ៩៦ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ "ប្រធានភស្តុភារប្រចាំកងពល១៦៤"**

**សព្វថ្ងៃរស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ខែកុម្ភៈ ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០៣:៥៥:៤២**

**១២៥ទំព័រ**

ដានី : ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូពេញ លោកពូឈ្មោះអីដែរ?

ភីន : សំ ភីន ។

ដានី : សព្វថ្ងៃអាយុប៉ុន្មានហើយ?

ភីន : ហោ៎! ខ្ញុំអាយុ៩៦ហើយ ។

ដានី : ស្រុកកំណើតកើតជានៅណាដែរ?

ភីន : ស្រុកកំណើតខ្ញុំនៅភូមិត្រឡាច ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ ។

ដានី : សព្វថ្ងៃនេះនៅភូមិអីដែរ?

ភីន : សព្វថ្ងៃនេះនៅភូមិជើងភ្នំ ។

ដានី : នេះជើងភ្នំ?

ភីន : បាទ!

ដានី : ឃុំអីដែរ?

ភីន : ឃុំត្រពាំងប្រិយ៍ ។

ដានី : ស្រុកអន្លង់វែង?

ភីន : បាទ!

ដានី : ឧត្តរមានជ័យនេះ?

ភីន : ឧត្តរមានជ័យ ។

ដានី : ពូសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

ភីន : ធ្វើស្រែៗ ធ្វើចំការតិចតួច ។

ដានី ៖ ធ្វើស្រែៗបានច្រើនទេ?

ភីន ៖ ហ៊ឺ! ស្រែនឹងបានមួយហូបៗទៀត កម្លាំងយើងតិច ធ្វើមិនបានច្រើនទេ ។

ដានី ៖ បានគ្រប់គ្រាន់ហូបដែរ?

ភីន ៖ គ្រប់ ។

ដានី ៖ ចុះចំការ?

ភីន ៖ ចំការយើងធ្វើបន្ទាប់បន្សំទេ ។

ដានី ៖ ដាំអីខ្លះនៅចំការ?

ភីន ៖ ចំការឆ្នាំនេះដាំដំឡូង យើងទើបចាប់ផ្ដើមដាំឆ្នាំនេះផង ។

ដានី ៖ ចុះគ្រួសារលោកពូគាត់ឈ្មោះអីដែរ?

ភីន ៖ ហៃ ណន ។

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ភីន ៖ អាយុ៥៥ ។

ដានី ៖ ៥៥ប្អូនលោកពូ១ឆ្នាំ?

ភីន ៖ ១ឆ្នាំ ។

ដានី ៖ លោកពូកូនចៅប៉ុន្មាននាក់ដែរ?

ភីន ៖ តែ៣ ។

ដានី ៖ កូនចៅ៣នាក់?

ភីន ៖ បាទ!

ដានី ៖ ទី១ឈ្មោះអីទៅ?

ភីន ៖ ឈ្មោះ ណាត ស្រី ។

ដានី ៖ គាត់មានគ្រួសារហើយ?

ភីន ៖ មានហើយ ។

ដានី ៖ ទី២?

ភីន ៖ ទី២ឈ្មោះ ម៉ៅ ។

ដានី ៖ ស្រី ឬប្រុស?

ភីន ៖ ប្រុស ។

ដានី ៖ ទី៣?

ភីន ៖ ទី៣ឈ្មោះ មាន ។

ដានី ៖ គាត់ស្រី ឬប្រុស?

ភីន ៖ ប្រុស ។

ដានី ៖ មានតែ៣នាក់ទេ?

ភីន ៖ តែ៣ ។

ដានី ៖ គាត់មានគ្រួសារអស់ហើយ ហើយក៏នៅ?

ភីន ៖ ៣នាក់នេះមានគ្រួសារ២នាក់ នៅម្នាក់នៅរៀន ។

ដានី ៖ នៅម្នាក់រៀនទី?

ភីន ៖ ទី៣នៅរៀន ។

ដានី ៖ រៀនដល់ថ្នាក់ណាហើយ?

ភីន ៖ ទៅរៀននៅភ្នំពេញ ។

ដានី ៖ ទៅរៀនភ្នំពេញ រៀននៅមហាវិទ្យាល័យ?

ភីន ៖ បាទ! រៀន ។

ដានី ៖ ខាងអីមហាវិទ្យាល័យណា?

ភីន ៖ វាទៅរៀនសាលាន័រតុន ។

ដានី ៖ រៀនផ្នែកអីទៅ?

ភីន ៖ វិស្វកម្ម ។

ដានី ៖ ឆ្នាំទីប៉ុន្មានហើយ?

ភីន ៖ ទី២ ។

ដានី ៖ មេចដែរលោកពូចំណាយអីៗ?

ភីន ៖ ហ៉ឺ! ចំណាយច្រើនណាស់អ្នករៀន ។

ដានី ៖ មួយខែៗអស់ប៉ុន្មានទៅ?

ភីន ៖ ហ៉ឺ!មួយខែពិបាកគិតណាស់ប្អូន បើវាយកសីងរាល់អាទិត្យយក ចុះមើលផ្ទះ ថ្ងៃទឹកថ្ងៃភ្លើង គេហ្នឹងវាធម្មតា យើងជួលគេទាំងអស់ ទៅមានតែពោះទឹកពោះបាយ ។

ដានី ៖ អស់ច្រើនដែរ?

ភីន ៖ ច្រើនណាសប្អូនមិនមែនតិចទេ លក់ស្រែលក់ភ្លឺឲ្យវារៀន ។

ដានី ៖ គាត់រៀនពូកែ?

ភីន ៖ គួរសមដែរ ។

ដានី ៖ ឪពុកលោកពូគាត់ឈ្មោះអីដែរ?

ភីន ៖ ឪពុកខ្ញុំគាត់ឈ្មោះ ខាន់ តែស្លាប់បាត់ហើយ ។

ដានី ៖ ស្លាប់តាំងពីអង្កាល់ទៅ?

ភីន ៖ ហ៊ើ! ស្លាប់មុនសម័យសង្គ្រាមទៀត ។

ដានី ៖ មុនសម័យសង្គ្រាម បានន័យថា មុនឆ្នាំ៧០ទៀត?

ភីន ៖ អឺ! មុន ។

ដានី ៖ ចុះម្ដាយលោកពូ?

ភីន ៖ ម្ដាយទើបតែស្លាប់ទេ ។

ដានី ៖ ឈ្មោះអីដែរ?

ភីន ៖ ម្ដាយឈ្មោះ មុត ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់?

ភីន ៖ មើលគាត់ស្លាប់តាំងពីឆ្នាំ ៨៤ ៨៥ហ្នឹងឯង ស្លាប់៨៥ ទាល់តែយូរពេកភ្លេចទៀតនឹង ។

ដានី ៖ ឪពុកម្ដាយលោកពូកាលពីមុននឹង គាត់ធ្វើអីដែរ ប្រកបមុខរបររកស៊ី?

ភីន ៖ អ! ឪពុកម្ដាយខ្ញុំធ្វើតែស្រែ យើងនៅស្រុកនឹងគ្មានស្អី ធ្វើតែស្រែសុទ្ធ ។

ដានី ៖ ធ្វើស្រែ នៅទ្រាំង?

ភីន ៖ អឺ! ស្រុកទ្រាំងអត់មានចំការមានអីទេ មានតែស្រែ ។

ដានី ៖ ចុះលោកពូបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

ភីន ៖ ខ្ញុំ៥ ។

ដានី ៖ បងប្អូន៥នាក់ ។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភីន ៖ ស្រី៣ ប្រុស២ ។

ដានី ៖ ទី១ឈ្មោះអីទៅ?

ភីន ៖ ទី១ឈ្មោះ ខែម ។

ដានី ៖ ឈ្មោះ ខែម គាត់ធ្វើអីដែរ?

ភីន ៖ ធ្វើស្រែដែរ ។

ដានី ៖ គាត់នៅនេះ ក៏នៅ?

ភីន ៖ អត់ទេ នៅស្រុកទាំងអស់ ។

ដានី ៖ ធ្វើស្រែនៅស្រុកកំណើត?

ភីន ៖ បាទ!

ដានី ៖ គាត់ខស្បាហ៍មកលេងនេះ ហើយលោកពូក៏?

ភីន ៖ មកបានម្ដងទេ មានតែខ្ញុំទេទៅ ។

ដានី ៖ ពូខស្សារហ៍ទៅ?

ភីន ៖ បាទ!

ដានី ៖ ទៅរាល់ឆ្នាំ ឬក៏ទៅយ៉ាងម៉េច?

ភីន ៖ ហ៊ើ! មិនបានរាល់ឆ្នាំទេ យើងមិនសូវមានលុយទៅញឹកពេកក៏មិនកើត ។

ដានី ៖ ចឹងគាត់ធ្លាប់មកលេងនេះម្ដង?

ភីន ៖ មក ។

ដានី ៖ គាត់ម៉េចដែរ គាត់ចាប់អារម្មណ៍នៅនេះ គាត់ចង់មកនៅនេះដែរ ហើយក៏អត់ទេ?

ភីន ៖ ហ៊ើ! គេអ្នកនៅស្រុកវាល គេមិនចង់នៅព្រៃ គេចង់នៅស្រុកវាលគេ ។

ដានី ៖ ទម្លាប់ខុសគ្នា?

ភីន ៖ ខុសគ្នា ហើយម្យ៉ាងគាត់ចោលស្រែចោលចំការគាត់មិនបានផង ។

ដានី ៖ អាយុប៉ុន្មានហើយគាត់?

ភីន ៖ ហ៊ើ! បងខ្ញុំអាយុមើលខ្ញុំហានេះហើយ បងអាយុ៦០ជិត៧០ហើយដឹង ។

ដានី ៖ គាត់ចាស់ហើយចឹង?

ភីន ៖ អាយុច្រើនហើយ ចាស់ ។

ដានី ៖ គាត់មកលេងបានយូរដែរ?

ភីន ៖ មកលេងកន្លះខែ មកបានម្ដងនឹង គាត់ចាស់ហើយ ។

ដានី ៖ ឆ្នាំណា គាត់មកលេង?

ភីន ៖ មកកាលយើងសមាហរណកម្មហើយ ។

ដានី ៖ គេធ្វើផ្លូវធ្វើអី?

ភីន ៖ នៅទេ មិនទាន់ធ្វើទេ នៅផ្លូវចាស់ ។

ដានី ៖ នៅមិនទាន់ដូចថានៅឃើញមានព្រៃស៊ុបទ្រុបច្រេន?

ភីន ៖ ហ្នឹងហើយព្រៃគួរឲ្យគាត់ខ្លាច មិនហ៊ានមកទេ ។

ដានី ៖ បើសិនជាគាត់មកឥឡូវមានអភិវឌ្ឍន៍អាចគាត់ចូលចិត្ត ។

ភីន ៖ ចង់ ។

ដានី ៖ ចុះលោកពូទៅលេងផ្ទះអីទៅម្ដងៗបានយូរទេ?

ភីន ៖ ខ្ញុំទៅបានមួយអាទិត្យយូរបំផុតហើយ ។

ដានី ៖ បានទៅលេងសាច់ញាតិ បងប្អូន?

ភីន : លេងបានស្គាល់គ្នាអស់ហើយ ដឹងអាណាងាប់អាណារស់អីដឹងអស់ហើយ ។

ដានី : បែកប៉ុន្មានឆ្នាំទៅ បានទៅលេងផ្ទះម្ដង?

ភីន : ចុះយើងបែកតាំងពីសង្គ្រាមមក ហើយខ្ញុំចេញពីផ្ទះតាំងពីអាយុ១៨មក ។ ចុះកាលសម័យនឹងគេមិនស្រុករដ្ឋប្រហារ ។ ហើយរដ្ឋប្រហារណាដែលស្គាល់សង្គ្រាមអត់ទេ គេប្រកាសក្នុងវិទ្យុឡោកៗហៅមនុស្សឲ្យចូលព្រៃម៉ាគីតស៊ូ មិនដឹងតស៊ូរឿងអីទៀតកាលនឹង បើយើងមិនដែលចេះ មិនដែលយល់អីនឹង ។

ដានី : ចឹងដល់ពេលឆ្នាំណាបានមកលេងផ្ទះលើកទី១ ?

ភីន : យើងសមាហរណកម្មនេះ ។

ដានី : សមាហរណកម្ម៩៨?

ភីន : អឺ!

ដានី : សមាហរណកម្មហើយទៅម៉ង?

ភីន : ទៅ ចុះបើយើងដាច់យូរហើយ នឹកបងនឹកប្អូន នឹកអី ។

ដានី : នៅចាំផ្ទះដែរ?

ភីន : ចាំ អត់ភ្លេចទេ ។

ដានី : ទៅដល់បងប្អូនស្គាល់?

ភីន : ស្គាល់ នៅស្គាល់ ប៉ុនគាត់បែកយូរចឹង ។

ដានី : គាត់ស្គាល់អ៊ំពូដែរ?

ភីន : ស្គាល់ ។

ដានី : ពេលទៅជំបូងចឹងនេះ?

ភីន : ជួបគ្នាយំ អាណិត នឹកឃើញចេះចុះទៅ ខ្ញុំពិបាកដាងគេគ្រាន់យើងចេញពីផ្ទះមកពីតូចៗ យើងអត់បាននៅស្រុកយូរដូចគេ ។ បើកើតមកចំអាសង្គ្រាមដែរ មានអ្នកណាឲ្យយើងនៅផ្ទះ គេប្រមូលមកធ្វើទាហានម៉ង ។ អឺ! ចូលព្រៃម៉ាគី តស៊ូ មិនធ្វើទាហាន ។

ដានី : ចុះទី២ឈ្មោះអីទៅ?

ភីន : ទី២ឈ្មោះ លីន ស្រី ។

ដានី : លីន ស្រី ។ គាត់នៅណាដែរ?

ភីន : នៅនឹងដែរ ស្រុក ។

ដានី : នៅស្រុកកំណើតដែរ?

ភីន : បាទ! ស្រុកកំណើត ។

ដានី ៖ គាត់ធ្វើការងារអីដែរ?

ភីន ៖ អ! ធ្វើស្រែដូចគ្នា មុខរបរតែមួយ ។

ដានី ៖ ទី៣?

ភីន ៖ ទី៣ឈ្មោះ ស៊ន ស្រី ។

ដានី ៖ គាត់នៅណាដែរ?

ភីន ៖ នៅស្រុក ។

ដានី ៖ គាត់នៅស្រុកដែរ?

ភីន ៖ អឺ!

ដានី ៖ ទី៤?

ភីន ៖ ទី៤ ស៊ុម ។

ដានី ៖ ទី៤ ស៊ុម ស្រី ហើយប្រុស?

ភីន ៖ ស្រី ។

ដានី ៖ គាត់នៅណាដែរ?

ភីន ៖ នៅស្រុកដែរ ។

ដានី ៖ ចឹងទី៥ លោកពូពៅគេ?

ភីន ៖ ទី៥ខ្ញុំ ពៅគេ បងៗចាស់អស់ហើយ ។

ដានី ៖ កូនពៅបែកពីផ្ទះតែម្តង?

ភីន ៖ អឺ! បែក ។ ម៉ែអត់ឲ្យមកទេ កាលនោះគាត់អាណិតៗដាងគេ បែកបានកាលនឹង ចឹងបើយើងវាគេចមិនរួច ។

ដានី ៖ ចុះបងលោកពូ បងស្រីៗគាត់ធ្លាប់មកលេងនេះដែរអត់?

ភីន ៖ មកៗទាំង៣ទាំង៤នេះឯង ។

ដានី ៖ មកជាមួយគ្នាក៏មកខុសគ្នា?

ភីន ៖ ជាមួយគ្នា ។

ដានី ៖ មកជាមួយគ្នា?

ភីន ៖ បាទ!

ដានី ៖ គាត់ចង់មកមើលស្រុកកំណើតរបស់ប្អូន?

ភីន ៖ ហ្នឹងហើយ ។

ដានី ៖ លោកពូកាលពីក្មេងៗបានទៅរៀនទៅអីទឹងគេដែរអត់?

ភីន ៖ ខ្ញុំរៀនបានថ្នាក់ទី១០ អាលែងនៅវត្តយូរពេក ។

ដានី ៖ ចឹងកាលពីតូចធ្លាប់ទៅនៅវតដែរ?

ភីន ៖ នៅវត្តឡើង៣ឆ្នាំ៤ឆ្នាំ ។

ដានី ៖ ទៅនៅវត្តតាំងពីអាយុប៉ុន្មានទៅ?

ភីន ៖ ហ៊េ! អត់ចាំអាយុទេប្អូន នៅវត្តនោះ ។

ដានី ៖ ទៅនៅវត្តអីគេទៅ?

ភីន ៖ វត្តត្រឡាចនៅជិតផ្ទះយើងនឹងឯង ។

ដានី ៖ ទៅនៅវត្តត្រឡាច៣-៤ឆ្នាំៗចេញពីវត្តទៅបានទៅរៀន?

ភីន ៖ ចេញពីវត្តបានរៀន នឹកឃើញថានៅវត្តអត់ចេះអក្សរ ចេះតែអក្សរវត្ត វាខុសពីអក្សរយើងនឹងទៅទៀត រៀនមកបានចេះមើលសរសេរអីបាន មើលរូប ប៉ុននឹងឯង ។

ដានី ៖ ទៅរៀននៅសាលាណាទៅ?

ភីន ៖ សាលាវត្ត នឹងម៉ងកាលនោះគ្មានសាលាឯណាទេ ។

ដានី ៖ សាលាវត្តត្រឡាចនឹងបណ្ដោយ?

ភីន ៖ អឺហ៊ឺ!

ដានី ៖ រៀនបានថ្នាក់ទី១០?

ភីន ៖ រៀនថ្នាក់ទី១០ ស្រុកគេកើតសង្គ្រាមទៅ ។

ដានី ៖ ប៉ុន្មានឆ្នាំទៅបានដល់ថ្នាក់ទី១០?

ភីន ៖ ចុះរៀនបានមួយឆ្នាំនឹង រៀនថ្នាក់ទី១០តែម្ដង ព្រោះយើងមើលរូបអីរូបខ្លះនៅវត្តនោះគេ ឲ្យចូលថ្នាក់ទី១០ ។

ដានី ៖ ទី១០ ចឹងរៀនដូចថាយើងធំដែរហើយយើងចូលរៀន?

ភីន ៖ ធំហើយ ខ្មាស់គេហើយ លែងចង់រៀន ប៉ុននឹកឃេ់ញថាបើមិនរៀន អត់ចេះទេ ។

ដានី ៖ តែថ្នាក់ទី១០រៀនបានមួយឆ្នាំ គេមានរដ្ឋប្រហារទៅ?

ភីន ៖ ស្រុករដ្ឋប្រហារ ។ រដ្ឋប្រហារ ខ្ញុំមើលស្រុករដ្ឋប្រហារខ្ញុំអាយុ១៨ ដែលបែកចេញពីផ្ទះមកអាយុ១៨ ។

ដានី ៖ ចឹងរដ្ឋប្រហារពេលអាយុ១៨នឹង បែកចេញភ្លាមម៉ង ហើយក៏យ៉ាងម៉េចទៅលោកពូអាចរៀបរាប់ព្រឹត្តិការណ៍នឹង ពេលរដ្ឋប្រហារយើងបែកចេញពីផ្ទះ?

ភីន ៖ រដ្ឋប្រហារហើយគេមិនច្បាំងគ្នាៗទាហានណា កាលនោះទាហានប្អូនឯងកើតមិនទាន់ គេហៅទាហានខ្មែរដូចគ្នានឹង ទាហានលោកលន់ នល់ នោះ ។ លោក លន់ នល់ មិនរដ្ឋប្រហារ

សម្តេចសីហនុៗ ហើយសម្តេចសីហនុមិនទៅណាទៅចិន គាត់មិនអំពាវនាវឲ្យយើងចូលព្រៃតស៊ូ ។ ហើយយើងអ្នកស្រុកស្រែមានបានធ្វើទាហានសម័យសម្តេចសីហនុអត់ទេ ក្មេងៗនោះ ។ ដូច្នេះ ទាហានសម័យសម្តេចសីហនុមិនចូលទៅខាងលោក លន់ នល់ ទាំងអស់នឹងចាប់ផ្តើមច្បាំងគ្នាជាមួយ ដែលដើមដំបូងយៀកកុងនឹងឯង យួនៗផ្តើមគំនិតវៃមុនគេ វៃតទល់ជាមួយពួកអាមេរិចកាំង ហើយនឹងទាហានខ្មែរ លន់ នល់ ។ ខ្ញុំមិនទាន់ចូលទៀត ឆ្នាំ៧១យើងទៅហើយ ។ ឆ្នាំ៧១ គេប្រកាសមែនទែន យើងត្រូវទៅ ។ គេមានបាតុកម្មហូរហែរគគ្រឹកគគ្រេងទៅ យើងនៅមិនបានទេតាមភូមិ ត្រូវទៅ ។

ដានី : ចឹងដំបូងពីឆ្នាំ៧១ យើងចេញទៅ យើងស្ម័គ្រចិត្តទៅទេ?

ភីន : ស្ម័គ្រទេ អត់មានអ្នកណាបង្ខំយើងទេ ។

ដានី : អត់មានបង្ខំ?

ភីន : ព្រោះចេះយើងឃើញថា យួន និង យួន គេច្បាំងគ្នានឹងស្រុកយើង យួនៗខាងត្បូងយួនមិនខាងអាមេរិចកាំង ហើយយួនយៀកកុងយើងមិនដឹងខាងណាទេ កាលនោះខ្ញុំនៅក្មេងប៉ុនគេចូលមកច្បាំងគ្នានៅស្រុកយើងដែរ ។ ដូច្នេះ២នាក់នឹងមកច្បាំងដីខ្មែរ ដល់ហើយសម្តេចសីហនុគាត់អំពាវនាវឲ្យយើងចូលព្រៃតស៊ូៗ យើងចូលទៅនៅតែខ្មែរគ្នាយើងទេមិនមានទៅនៅជាមួយយួនខាងជើងអីអត់ទេ នៅតែជាមួយខ្មែរយើង តស៊ូតែខ្មែរគ្នាយើង ។

ដានី : កាលនឹងដូចថាពេលដែលលោកពូចេញទៅ ចឹងទៅគ្នាច្រើនក៏ទៅម្នាក់ឯង?

ភីន : នេះទាំងភូមិៗទៅទាំងអស់ឲ្យតែក្មេងៗ អត់នៅបាន ព្រោះចេះបានទៅទាំងអស់ អត់ចង់ចូលធ្វើទាហានជាមួយលោក លន់ នល់ នឹងទេ កាលនឹងនោះ ។ ចះឃើញអាមេរិចកាំងឃើញយួនខាងត្បូងវាមកពេញទឹកពេញដី ស្រុកខ្មែរយើងវេទនាណាស់កាលនោះ យាប់មែន ។

ដានី : កាលនឹងអាយុស្របាលៗគ្នា ក៏មានអាយុដូចថាគេអាយុច្រើន?

ភីន : ខ្លះចាស់ជាងក៏មាន ។

ដានី : ចាស់ជាង ក្មេងជាង?

ភីន : ក្មេងជាងយើងក៏មាន ទៅទាំងភូមិៗ ។ សល់តែមនុស្សមានប្រពន្ធកូន២-៣សល់ខ្លះ បើថាក្មេងៗដូចយុវជនយើងឥឡូវនេះអត់មាននៅមួយទេ ។

ដានី : ពេលទៅដំបូងទៅកន្លែងណាទៅ?

ភីន ៖ គេមានកន្លែងគេទទួលយើង គេមានមន្ទីរគេ មានអីទទួលចិញ្ចឹមអីយើង មិនទាន់ឲ្យចូលធ្វើទាហានទេ យើងនៅហ្វឹកហ្វឺនរាប់ខែទៅទៀត ។ គេអប់រំយើង និយាយណែនាំយើងទម្រាំយើងយល់ពីការធ្វើសង្គ្រាមដែរ បានគេឲ្យយើងធ្វើបន្តទៀត ។

ដានី ៖ មន្ទីរគេនៅណាទៅ?

ភីន ៖ ហ៊ឺ! អាមន្ទីរៗនឹងវានៅតែក្នុងព្រៃ យើងកាលនឹងយើងក៏មិនស្គាល់ដែរ ។

ដានី ៖ នៅក្នុងស្រុកទ្រាំងនឹងដដែល?

ភីន ៖ អឺ! នៅក្នុងស្រុកនឹងឯង ប៉ុនវាមានភ្នំមានអីចឹង វាមានភ្នំម្តុំស្រុកត្រាំកក់ អានឹងមានភ្នំគ្រាន់ធ្វើកន្លែង ។

ដានី ៖ ដីររមាលអីនឹង?

ភីន ៖ បាទ! សម័យនឹងបើអត់មានកន្លែងព្រៃលាក់ពួកទេ នៅមិនបាននឹងយន្តហោះអាមេរិចកាំងទេ ។

ដានី ៖ ពីទ្រាំងទៅខាងដីររមាលឆ្ងាយដែរតើ?

ភីន ៖ អឺ! ដើរ ហើយកាលនោះគ្មានឡានគ្មានស្អីជិះ ដើររហូតនឹង ។

ដានី ៖ មកដល់មន្ទីរនឹងយើងមានហាត់ជាកងទ័ពអី?

ភីន ៖ មិនទាន់ទេ គេយកយើងមកចញ្ចឹមសិន ដូចថានិយាយឥឡូវនិយាយថាបំប៉ន ហូបបាយរួមបាយអីជាមួយគេនឹងទៅ ។

ដានី ៖ ចឹងកាលនឹង លោកពូនៅបំប៉ននៅមន្ទីរនឹងយូរដែរ?

ភីន ៖ គេបំប៉នយើង គេចិញ្ចឹមយើង៣ខែទៅ៦ខែកាលនោះ មុនយើង របៀបដូចថាគេអប់រំយើងកុំឲ្យយើងនឹកផ្ទះ នឹកអីចឹងទៅ ។ មុននឹងទៅធ្វើការនៅកន្លែងណា ទាល់តែគេអប់រំយើងចឹង ។ បើមិនចឹងនឹកផ្ទះយំស្រែក ខ្លះណាធ្វើមិនកើតរត់ទៅផ្ទះទៅអីដែរ ។ ចុះធម្មតាដូចប្អូនឯងបែកផ្ទះយូរនឹក ផ្គរលាន់ក្តិលមកស្រែកយំ ។

ដានី ៖ ហើយដល់ពេលបន្ទាប់ពី៣-៤ខែទៅ បានយើងហាត់?

ភីន ៖ ហ្នឹងហើយគេរើសចូលកងទ័ព តែគេមិនទាន់ឲ្យទៅភ្ជាមទេ គេបង្ហាត់យើងរាប់ខែទៅទៀត ។

ដាន់ ៖ បង្ហាត់អីខ្លះទៅ?

ភីន ៖ បង្ហាត់ក្បាច់លូនក្រាបអីចឹងទៅ បាញ់ចឹងទៅ ឲ្យយើងចេះឲ្យយើងនេះបានគេឲ្យយើងធ្វើទាហានបាន បើអត់ហាត់ទេ មិនបានឲ្យចូលកើតទេ ។

ដានី ៖ ឆ្នាំណាទៅ បានចូលធ្វើទាហាន?

ភីន ៖ យើងនៅមន្ទីរនឹងជាប់ជាងមួយឆ្នាំជាងបានយើងទៅចូលក្នុងអង្គភាពទាហាន ។

ដានី ៖ អគ្គិភាពអីទៅ?

ភីន ៖ ហ៎! អគ្គិភាពកាលនោះភ្លេចលេខភ្លេចអីអស់ហើយ គេប្រើលេខ។

ដានី ៖ មានជាកងពល មានជាវរៈអី?

ភីន ៖ កាលនោះមានជាកងវរៈហើយ មនុស្សច្រើនហើយចូលនោះ។ កងពលគេចាត់តាំងបាន តាមកន្លែង១ដែលមនុស្សច្រើន អានឹងគេរៀបរយបានហើយ។ កន្លែងតិចមិនទាន់រៀបរយកើតទេ គេរៀបវរៈ។

ដានី ៖ កន្លែងលោកពូជាវរៈ ជាកងពល?

ភីន ៖ វរៈទេ កន្លែងខ្ញុំ កាលនឹងនៅធ្វើទាហានតំបន់។

ដានី ៖ ទាហានតំបន់?

ភីន ៖ អានឹងទាហានខេត្ត។

ដានី ៖ កាលនឹងតំបន់?

ភីន ៖ បាទ! កាលនឹងគេហៅតំបន់។

ដានី ៖ តំបន់ប៉ុន្មានទៅកាលនឹង?

ភីន ៖ កាលនឹងតំបន់១៣។

ដានី ៖ តំបន់១៣?

ភីន ៖ ខេត្តតាកែវគេហៅតំបន់១៣។

ដានី ៖ ខេតតាកែវគេហៅតំបន់១៣ ខាងកំពត៣៥?

ភីន ៖ អឺ! កំពត៣៥ កំពង់ស្ពឺ៣៣ យូរភ្លេចអស់ អត់សូវចាំអស់។

ដានី ៖ ចឹងដំបូងយើងនៅកងទ័ពតំបន់ទេ?

ភីន ៖ តំបន់។

ដានី ៖ តំបន់វាមានតែជាវរៈ អត់មានជាកងពលទេ?

ភីន ៖ តំបន់១៣ ដែលក្រោយពីខ្ញុំចេញមកបានមានកងពលហើយ កាលយើងនៅនឹង មានត្រឹមវរសេនាធំ១បំផុតហើយអានឹង។

ដានី ៖ គ្នាច្រើន?

ភីន ៖ ហ៎! វរសេនាធំដល់ពាន់នាក់។

ដានី ៖ តែចេញទៅច្បាំង ចេញអីជាមួយលន់ នល់?

ភីន ៖ ហ៎! កាលហ្នឹងគេរៀបហើយ គេច្បាំងហើយប្អូន ពេញស្រុកតែម្តង គ្មានចន្លោះកន្លែងណាទេ។

ដានី : មានកាំភ្លើងមានអីគ្រប់គ្រាន់ទេ?

ភីន : កាំភ្លើងកាលនឹង យើងចូលដំបូងគេកំណត់ថា គេឲ្យប៉ុន្តែអត់ឲ្យគ្រប់គ្នាទេ បើយើងរើបាន អានឹងយកប្រើខ្លួនឯង ៗ ទាហានលន់ នល់ គេសំបូរកាំភ្លើងអាមេរិចឲ្យ ដឹកមកប្រើប ៗ ម៉ឺន ហើយខ្មែរយើងនេះអត់មានទេ មួយក្រុម ៗ មាន៣-៤ដើម ៗ តែបើរើបាននោះ យកប្រើ ខ្លួនឯង ៗ

ដានី : គ្រាន់កាលនោះយើងមានទឹកចិត្ត?

ភីន : មានទឹកចិត្តនឹងធ្វើ កាលនឹងគេថាពួកឈានពាន ចក្រពត្តិអីគេប្រជុំណែនាំយើងចឹង ហើយ យើងដឹងធ្វើតាមគេចឹង ៗ ហើយសមយើងឃើញសកម្មភាពរបស់គេចឹងមែន ទម្លាក់គ្រាប់ បែកងាប់វាលហើយមនុស្ស ៗ ហើយប្អូនឯងឃើញសម័យឥឡូវនេះថាយន្តហោះ សម័យ នោះយន្តហោះឥឡឹតថ្ងៃ ៗ ខ្ញុំនិយាយថ្ងៃស្មានេះ ស្រុកខ្ញុំ យន្តហោះអាមេរិចកាំងច្រើន ណាស់ ៗ បើប្អូនឯងឃើញសង្គ្រាមនៅអ៊ីរ៉ាក់ នៅអាប់កានីស្ថាន ថាយន្តហោះច្រើន សម័យនោះវាលើសលប់នឹងទៅទៀត ៗ

ដានី : ចុះពេលយន្តហោះនឹងមកទម្លាក់ ប៉ះពាល់យ៉ាងម៉េចខ្លះទៅ ដល់ផ្ទះសម្បែង អ្នកស្រុកអ្នក ភូមិជា មានលោកពូបានឃើញផ្ទាល់ភ្នែកដូចថាត្រូវឆេះផ្ទះ ត្រូវមនុស្សរបួសស្លាប់ ឬក៏ គោ ក្របី របស់របរអីទេ?

ភីន : មួយជំនាន់សង្គ្រាម៥ឆ្នាំ ខ្ញុំនៅស្រុកភូមិខ្ញុំ ទម្លាក់ចំម្តង គ្រាប់បែក ទម្លាក់ចំមនុស្សស្លាប់ផ្ទះ ឆេះ គោ ក្របី ងាប់ ៗ ចុះយន្តហោះ៣ទម្លាក់មកភូមិ ទម្រាំស្ទើរនឹងអស់នឹង ប៉ុនមនុស្ស ចេញធ្វើការអស់ដែរវាមិនសូវត្រូវប៉ុន្មាន បើមនុស្សមូលគ្នាមិនបាច់និយាយទេ ទម្លាក់ថ្ងៃ រសៀលម៉ោង៣ ៗ

ដានី : ប៉ុន្តែមានស្លាប់ដែរ?

ភីន : ស្លាប់ ៗ

ដានី : ស្លាប់ប៉ុន្មាននាក់?

ភីន : ស្លាប់ ផ្ទះឆេះ ៗ

ដានី : ស្លាប់ប៉ុន្មាននាក់?

ភីន : ចុះគាត់ទម្លាក់ធុងសាំងគ្មានស្អី ឈើរុះក៏ឆេះដែរ ធុងសាំងគេ ៗ

ដានី : ទម្លាក់ធុងសាំង?

ភីន : បាទ! នេះធុងប៉ុនៗពុយយើងនឹង ហើយធុងនឹងមិនមែនសាំងសុទ្ធទេ ជ័រទឹកយើងនឹង លាយជាមួយសាំង ទម្លាក់មកបែកពេញភូមិឆេះ ឲ្យតែទៅនៅដើមឈើចឹង ពេលព្រឹកចឹង

អត់ឆេះទេ ថ្ងៃក្ដៅឡើងវាឆេះ ដោយសារកម្ដៅថ្ងៃនឹងម៉ង ។ បើថាយើងមិនបេះចេញឲ្យអស់ទេ ឆេះអស់ផ្ទះអត់សល់ទេ ។

ដានី : ទម្លាក់នឹងច្រើនដែរ ២ឆ្នាំ តាំងពីឆ្នាំណាមកទៅ ទម្លាក់?

ភីន : ទម្លាក់រហូត សង្គ្រាម៥ឆ្នាំ ពីឆ្នាំ៧០មក៧៥ យន្តហោះបេ៥២អីនឹង ទម្លាក់អត់ទាន់បាត់រណ្ដៅទេឥឡូវនេះ ប្អូនឯងដើរគ្រប់កន្លែងទៅឃើញហើយ បើគេបង្ហាញឃើញ ។ អ! កម្មណាស់ស្រុកយើង មិនដូចឥឡូវនេះសប្បាយ ចប់សង្គ្រាម ។ ហើយបើសង្គ្រាមជាមួយយួននេះ អត់មានយន្តហោះទេ បើសង្គ្រាមជាមួយអាមេរិចកាំងមិនបាច់និយាយទេ ។

ដានី : សុទ្ធតែយន្តហោះ?

ភីន : យន្តហោះខ្ញុំថាហើរងងឹតមេឃហើយ ។

ដានី : ចុះលោកពូធ្វើជាកងទ័ពតំបន់បានរយៈប៉ុន្មាន បានយើងឡើងទៅជា?

ភីន : ធ្វើនឹងយើងធ្វើបានមួយឆ្នាំ អឺ!មួយឆ្នាំកន្លះបានយើងឡើងមក កាលនឹងយើងមានទ័ពតំបន់គេ ទ័ពភូមិភាគចឹងមក ។

ដានី : ឡើងភូមិភាគ?

ភីន : អឺ! ភូមិភាគនឹង គេដើរច្បាំង៣ខេត្តចឹងមក បើទ័ពតំបន់យើងនៅតែតាមខេត្តយើងទេ ។

ដានី : កាលនៅតំបន់យើងនៅតែតាកែវទេ?

ភីន : អឺ!

ដានី : ដល់ពេលភូមិភាគ យើងឡើង?

ភីន : ឡើងភូមិភាគ មកទៅកំពតក៏បាន មកកំពង់ស្ពឺក៏បាន ។

ដានី : ដល់ពេលមកដល់ភូមិភាគអានឹងមានជាកងពល?

ភីន : កងពលគេហើយ គេរៀបកងពល គេយកយើងពីតំបន់មក រៀបចូលភូមិភាគកើតជាកងពល ។

ដានី : ចឹងកងទ័ពតំបន់នឹងមកទាំងអស់ ហើយក៏?

ភីន : គេរើសទេ ស្រេចតែគេរើសទៀត ។

ដានី : ប្រធានស្រេចគេរើស?

ភីន : បាទ!

ដានី : ប្រធាននៅដដែលទេ?

ភីន : នៅដដែល ប៉ុន្តែគេរើសមក ។

ដានី : គេអត់មានមកជាមួយ?

ភីន ៖ បាទ! មិនមែនមកទាំងអស់ទេ យើងឡើងមកគេសម្រាប់បគ្រប់កន្លែងភូមិភាគនឹងទៅ មេគេភូមិភាគមានរបស់គេស្រេចហើយ យើងមក ។

ដានី ៖ ខាងភូមិភាគៗកងពលៗរបស់ពីណាគេ?

ភីន ៖ កងពល អ! កាលនឹងមនុស្សស្លាប់បាត់អស់ហើយ ភូមិភាគខ្ញុំវាភ្លេចទាំងឈ្មោះទៀត មេៗគេធំៗ សុទ្ធតែមនុស្សចាស់ មាននៅអីបានយូរ ។

ដានី ៖ ចឹងមកកងពលៗលេខប៉ុន្មាន?

ភីន ៖ កងពលលេខ ៣៣០ ១៨ អានឹងមកពីភូមិភាគ ។

ដានី ៖ កងពល១៨?

ភីន ៖ ១៨ៗ គេហៅលេខ១៨០ កង១៨០គេលេខ១៨ ប៉ុនចាស់គាត់នឹងស្លាប់បាត់អស់ហើយ ចាស់ៗមកពីហាណូយផង ពួកនឹង ។

ដានី ៖ ពួកខ្មែរហាណូយ?

ភីន ៖ បាទ! ពួកខ្មែរហាណូយគេធ្វើមេធំៗ កាលនោះ ។

ដានី ៖ កាលនឹងលោកពូនៅកងពលនឹង រហូតដល់បែក៧៥ ឬក៏មានផ្លាស់?

ភីន ៖ ហេ៎! ខ្ញុំត្រូវរបួសពិការហ្នឹងតាំងពី៧៤ ។

ដានី ៖ ចឹង?

ភីន ៖ អឺ! អត់បានរំដោះភ្នំពេញអីនឹងគេទេ ។

ដានី ៖ ចឹងឆ្នាំ៧៤ លោកពូវ៉ៃនៅកន្លែងណាបានត្រូវ?

ភីន ៖ វ៉ៃនៅកំពតដើងនេះ ។

ដានី ៖ កាលនឹងលោកពូមានតួនាទីអីដែរ?

ភីន ៖ ហេ៎! គ្មានធ្វើអីទេ ទាហាន ។

ដានី ៖ យើងធ្វើជាយុទ្ធជន?

ភីន ៖ អឺ!

ដានី ៖ កាលនឹងត្រូវយ៉ាងម៉េចទៅ លោកពូអាចរៀបរាប់ ពេលត្រូវពិការ?

ភីន ៖ ហេ៎! ឃើញទេ កន្លែងត្រូវត្រង់នេះ ។

ដានី ៖ ត្រូវត្រង់នឹង?

ភីន ៖ ត្រូវត្រង់នឹង ឆ្អឹងបែកអស់រលីង ទៅហើយត្រូវ២គ្រាប់ ១គ្រាប់វាដាច់សរសៃរឈាមអស់នេះ ដាច់សរសៃរឈាមបានគេវះៗម្តុំដេរចងដែរសម័យនោះ ប៉ុនឈាមយើងវាអស់ហើយគេធ់អត់កើត ។ គេថាបើនៅធ្វើនៅចងវាងាប់បាត់ហើយមនុស្សនេះមិនរស់ទេ វា

អស់ឈោម ។ ចឹងហើយបានខ្ញុំពិការគាំងពីនឹងមក ខ្ញុំធ្វើអីកើត បេះបានរស់ដល់សព្វថ្ងៃដែរ ។

ដានី : លោកពូពេលត្រូវនឹងអំបែងគ្រាប់អីគេ?

ភីន : គ្រាប់អៀកែង ។

ដានី : អៀកែងនេះនឹង?

ភីន : អឺ! អឹមស៊ីនឹង ។

ដានី : ត្រូវពីមុខមក ខាងនេះត្រូវអំបែង?

ភីន : នេះត្រូវពីនេះវាមកធ្លាយនេះ យើងបត់ជង្គង់នេះ បត់បេះត្រូវធ្លាយមកនៅបៀមនេះមួយគ្រាប់គ្រវាសបេញ ហើយអាម៉ាគ្រាប់ខាងនេះបេញផុតទៅ ។

ដានី : ត្រូវ២គ្រាប់តែម្ដងអាអៀកែងទាំងពីរ?

ភីន : ទាំងពីរគេបាញ់មកបេះ ។

ដានី : អាអៀកែងនឹងបានន័យថាត្រូវតូច បេញធំ?

ភីន : ហ្នឹងបេញប៉ុននេះ តែវាមានគ្រាប់វា អាគ្រាប់បេញតូចបេញធំ ។ បេញតូចនឹង ទាំងបេញទាំងចូល មើលអត់ចង់ឃើញទេគ្រាប់វា ដល់យកប៉ាន់ចាប់ហែកបេះ បានមើលឃើញរុញតែបើអាធំចូលតូច តែបេញវិញរីកអស់ ជើងខ្ញុំនេះគ្រោះថ្នាក់ត្រូវអាគ្រាប់រីកអានេះមួយមករីកចុងផុតឆ្អឹង បើសិនត្រូវឆ្អឹងដូចអាមួយគ្រាប់ខាងនេះដាច់បាត់ហើយ ។ មួយគ្រាប់វាត្រូវផ្ដាច់ជើង ឬដៃបានមួយអាគ្រាប់បែក ។ ហើយគ្រាប់ដូចគ្នា តូចៗដូចគ្នាប៉ុនវាមានរំសេវនៅក្នុងនឹង ។

ដានី : ដល់ពេលលោកពូត្រូវ ពី៧៤ មកសម្រាកនៅពេទ្យណា?

ភីន : ពេទ្យកាលនឹង ពេទ្យនៅជិតរោងចក្រចក្រីទីងកាលនឹង ។

ដានី : រោងចក្រីទីង?

ភីន : រោងចក្រីទីង រោងចក្រស៊ីម៉ង់ ប៉ុននៅក្នុងព្រៃដែរ ខ្ញុំមិនដឹងត្រង់ណាត្រង់ណាទេ ។

ដានី : ខែប៉ុន្មានដែលលោកពូត្រូវរបួសឆ្នាំ៧៤?

ភីន : ត្រូវខែ៤ ឆ្នាំ៧៤ ខែ៤ ថ្ងៃ២៨ ម៉ោង៨យប់ត្រូវ ។

ដានី : រួចចូលឆ្នាំបានតិច?

ភីន : អឺ! ទាហានយើងកាលនោះ ដែលបានចូលឆ្នាំចូលអីណា ។

ដានី : ដល់ពេលពូសម្រាកនៅពេទ្យរយៈពេលប៉ុន្មាន?

ភីន : ដេកពេទ្យមួយឆ្នាំ បានខ្ញុំដើររួចតិចៗ ។

ដានី ៖ មួយឆ្នាំ?

ភីន ៖ មួយឆ្នាំគត់ ។

ដានី ៖ ចឹងទាល់តែគេបែកភ្នំពេញហើយ ដើររួចតិចៗ?

ភីន ៖ គេបែកហើយបានដើររួច ។

ដានី ៖ អានោះពេទ្យរបស់ភូមិភាគ?

ភីន ៖ អឺ! ពេទ្យភូមិភាគ ដេកនៅជិតភ្នំពេញ ត្រូវកំពតមកដេកនៅជិតភ្នំពេញ ជិតភ្នំទត្តុង្គ ។

ដានី ៖ ចឹងដំបូងមកដេកនៅចក្រីទីង ហើយផ្លាស់ទៅទៀត?

ភីន ៖ ដេកបាន៣ខែ គេសម្រួលជើងយើងល្មមមនុស្សវាលែងរាប់ លែងអីហើយបាន គេសែង ចេញពីនឹងមក ។

ដានី ៖ មកខាងទត្តុង្គវិញ?

ភីន ៖ ហ្នឹងហើយ ។

ដានី ៖ មកពេទ្យរបស់មជ្ឈឹមវិញ?

ភីន ៖ មិនពេទ្យមជ្ឈឹមទេ ពេទ្យភូមិភាគ ប៉ុនគេធ្វើមកនៅជិតភ្នំពេញកាលនោះ ព្រោះគេធ្វើ សម្រាប់វ៉ៃភ្នំពេញដែរ ។

ដានី ៖ មិនមែនពេទ្យលោកជួន ជឿន ហ៎?

ភីន ៖ តា ជួន ជឿន គាត់នៅផ្សេង តែអានេះ កូនចៅរបស់គាត់ហ្នឹង ។

ដានី ៖ ព្រោះតាមខ្ញុំដឹង ដូចថាជិតវ៉ៃដល់ភ្នំពេញខ្លាំងទៅមានពេទ្យរបស់មជ្ឈឹមគេនៅខាងអមលាំង ខាង?

ភីន ៖ ហ្នឹងហើយជិតគ្នា ពេទ្យកាលនោះ ប៉ុនយើងមិនទៅដេកដល់មជ្ឈឹមពេទ្យទេ ។

ដានី ៖ ថ្នាំកាលនោះ យើងដូចថាព្យាបាល មានថ្នាំអីគ្រប់គ្រាន់ព្យាបាលយើងបានម៉ត់ចត់ដែរ?

ភីន ៖ ជើងទាំងមូលគឺ បានដាក់សារ៉ូដាក់ដបទឹកក្រូចបានតែ២ដងទេ ធ្វើខ្លួនឯងថ្នាំសារ៉ូមថ្នាំអីនឹង អត់មានទិញពីគេទេ ។ តាមមើលទិញពីគេដែរ ប៉ុនទិញរបៀបទិញមេៗថ្នាំ យើងយកមក ផលិតខ្លួនឯង ហើយចេះរស់ដែរ ។

ដានី ៖ អត់មានថ្នាំអីទំនើបដូចឥឡូវ?

ភីន ៖ ហ៎! ទំនើបមានរបស់ដែលគេទិញបាន ប៉ុនគេប្រើចំពោះជើងខ្ញុំចេះ ខ្ញុំនិយាយតែសារ៉ូមទេ បើថ្នាំចាក់ថ្នាំអីរបស់គេ ថ្នាំល្អដូចឥឡូវនឹងឯង ។

ដានី ៖ ចុះដល់ពេលគេបែកហើយយ៉ាងម៉េចទៀតទៅ ដល់ពេលពូដូចថាយើងសម្រាកពេទ្យមួយឆ្នាំ ដល់ពេលនឹងគេបែកហើយ?

ភីន ៖ បែក គេវៃបែក គេឲ្យទៅនៅតាមកងយើងវិញ គេឲ្យទៅនៅវិញ ។

ដានី ៖ គេឲ្យលោកពូទៅនៅតាមកង?

ភីន ៖ អឺ! តាមកង ព្រោះកាលនោះគេមិនទាន់រៀបចំមន្ទីរអីពិការអីទេ ឲ្យយើងទៅនៅតាមកង ព្រោះកងទ័ពគេកំពុងរៀបរយអ្នករបួសអ្នកពិការអី គេរៀបរយរកកន្លែងទុកដាក់ចិញ្ចឹមអីស្រួលបួល ។ ទៅនៅកងបានម៉ាឆ្នាំទៀត បានគេរៀបរយកន្លែងឲ្យយើងរស់នៅបានៗខ្ញុំចេញហើយ ។

ដានី ៖ ចឹងដល់ពេលទៅនៅកងវិញ នៅក្នុងកងពលដដែល?

ភីន ៖ កងពលដដែល ។

ដានី ៖ តែកងពលលោកពូកាលនោះនៅមជ្ឈិម ឬក៏នៅភូមិភាគ?

ភីន ៖ នៅភូមិភាគទេ ខ្ញុំអត់បានឡើងដល់មជ្ឈិម ខ្ញុំរបួសម៉ង ។

ដានី ៖ ភូមិភាគនៅភូមិភាគ?

ភីន ៖ ភូមិភាគនិរតីកាលនឹង អត់បានឡើងមជ្ឈិមទេ ។

ដានី ៖ ជាមួយពីណាគេ អ្នកណាគេប្រធានកងពល?

ភីន ៖ ហ៎! និរតី ភូមិភាគ កងពលនឹងដូចជាអត់ដឹងចាំឈ្មោះពីណាទេកាលនោះ ចាំតែឡើងទៅដំបូងដែលថាមនុស្សមកពីហាណូយនឹង ប៉ុនស្លាប់បាត់ហើយឈ្មោះ តា ណាត តានឹង ។ ប៉ុនស្លាប់ហើយគ្មាននៅ កើតស្រញ៉ុក ។

ដានី ៖ តា ណាតៗ ខ្ញុំឮឈ្មោះគាត់តើ ។

ភីន ៖ ចឹងហ៎! ប៉ុនមិនដឹងស្អីណាតទេ ខ្ញុំស្គាល់នៅចាំ ។

ដានី ៖ មិនមែនតាណាតកងពល១២?

ភីន ៖ ក្រោយមកទៅនៅដឹង ប៉ុនកងដំបូង១៨០នឹង គឺណាតហ្នឹងហើយ ។

ដានី ៖ តាណាត ១៨០ ។

ភីន ៖ តា ណាត គ្រាន់តែខ្ញុំដឹងថាគាត់មកពីហាណូយកាលនោះ ។

ដានី ៖ ចឹងបន្ទាប់ពីយើង នៅក្នុងកងមួយឆ្នាំ គេមានរៀបជាមន្ទីរ ដូចថាមានមន្ទីរពិការ?

ភីន ៖ អឺ! មានហើយកាលនឹង ក្រោយមកមួយឆ្នាំខ្ញុំថាហ្នឹង គេរៀបហើយរៀបមន្ទីរពិការ ។

ដានី ៖ ដល់ពេលគេរៀបមន្ទីរពិការនឹង ហើយគេយ៉ាងម៉េចទៀត?

ភីន ៖ គេដកចេញពីកងហើយ គេឲ្យមកនៅ ។

ដានី ៖ នៅមន្ទីរពិការ?

ភីន : ហ្នឹងហើយ នៅតាមកងគេពិបាកមើលថៃយ៉េងដែលនឹងកាលនោះ កងទ័ពគេដើរចល័តគ្រប់កន្លែងហើយយើង ។

ដានី : មន្ទីរពិការនៅណាទៅ?

ភីន : មន្ទីរពិការកាលនឹងខ្ញុំនៅដល់នេះ ស៊ឹងចំប៉ុជីឆ្នាំងមួយកន្លែង ។ ស្គាល់អត់?

ដានី : អត់ ។

ភីន : អត់ស្គាល់ ។ ស៊ឹងចំប៉ុនៅខេត្តកំពង់ស្ពឺជិតដោះកញ្ជរ ។ ស្គាល់ទាដោះកញ្ជរ ។

ដានី : ដោះកញ្ជរស្គាល់ផ្លូវជតទៅដល់កំពង់សោមហើយ អាផ្លូវជិតដល់វាលរិញ ។

ភីន : មិនទាន់ជិតទេ ពាក់កណ្ដាលទេ ។

ដានី : តាមខ្ញុំធ្លាប់ជួបពូមីងដែលគាត់និយាយប្រាប់ កន្លែងដោះកញ្ជរនឹងវាមានមុនពេលបែក៧៥ ទៅមានបន្ទាយរបស់លន់ នល់ មួយដែល ។

ភីន : បន្ទាយនឹងទទឹង១គីឡូ បណ្ដោយ៣គីឡូ ។

ដានី : បាទ! មានបន្ទីរផ្សំគាត់ធ្វើហ្នឹង ។

ភ់ន : អឺៗ! ធ្វើមេហ្នឹង ។ ប៉ុនគាត់ទៅស្រុកថៃ ស្លាប់តាមផ្លូវ តាហ្នឹងផ្ទុះមីន គាត់អត់ចុះចូលជាមួយយើងដែលវៃឈ្នះហើយទេ បន្ទាយនឹងរឹងជាងភ្នំពេញទាំងអស់ វៃបែកភ្នំពេញហើយ បន្ទាយនឹងអត់បែកទេ មិនឲ្យយើងកាន់របងលួសគាត់ទៀត ។ យ៉េងទៅចរចាទៅអឺអត់ឲ្យកាន់ទេ ។

ដានី : គាត់នេះដែរ រឹងម៉ង?

ភីន : ចុះទាហានគេ៣០០០-៤០០០ពាន់នោះនៅមួយបន្ទាយសុទ្ធតែទាហាន គ្មានអ្នកណាធ្វើអីបែក ទាល់តែគាត់ចេញខ្លួនគាត់ ទាហាននៅហ្នឹងចុះចូល គាត់ចេញផុត ប៉ុនទៅផ្ទុះមីននៅកំពង់សិលា ដើរទៅអត់ដល់ថៃ ។

ដានី : មីនខាងយើង?

ភីន : មីនគាត់ដាក់ខ្លួន ប៉ុនគាត់ដើរទៅវង្វេងវង្វាន់អស់ទៅ រកមិនឃើញផ្ទុះម់នខ្លួនឯង គាត់នឹងខ្មែរក្រហមមិនហ៊ានដាក់មីនទេកាលនោះ អត់មាន ។

ដានី : ចឹងកាលនៅមន្ទីរពិការនឹង លោកពូនៅក្នុងមន្ទីរពិការរបស់កងទ័ពទេ មិនមែន?

ភីន : កាលនោះមើលដូចគេរៀប នៅក្នុងកងទ័ពដដែល ប៉ុនគ្រាន់មានមន្ទីរពិការគេមួយ ។

ដានី : គេអត់ឲ្យលោកពូមានតួនាទីអីទេ?

ភីន : មិនមែនទេ យើងនៅទាហានធម្មតា នៅពិការ ។

ដានី : យើងធ្វើអីខ្លះទៅ ខាងពិការ?

ភីន ៈ ហ៊ឺ! ពិការកាលនឹងដូចគេឲ្យដាំបន្លែហូបខ្លួនឯង ចិញ្ចឹមសត្វពន្លាត់អ៊ីខ្លួនឯងប៉ុននឹងទេ ស្បៀងអាហារអីផ្សេងទៀត គេឧបត្ថម្ភទេ ស្រូវអង្ករអីគេឲ្យទេ តែគ្រាន់គ្មានប្រាក់ខែ ប្រាក់ថ្ងៃអីទេ ។

ដានី ៈ ប៉ុន្តែយើងហូបចុក យើងបានគ្រប់គ្រាន់បរិបូរ?

ភីន ៈ បាទ! អត់ៗទេ ។

ដានី ៈ យើងដាំខ្លួនឯង យើងចិញ្ចឹមខ្លួនឯង ហូបខ្លួនឯងទៅ?

ភីន ៈ បាទ! ហូបខ្លួនឯងទៅ ។

ដានី ៈ ចុះដូចថាស្រូវអង្ករ យើងធ្វើដែរ?

ភីន ៈ ស្រូវអង្ករ អត់ធ្វើទេ ពួកពិការគេអត់ឲ្យធ្វើទេ វាពិបាក បើចិញ្ចឹមសត្វចិញ្ចឹមអីចិញ្ចឹមចុះ វាចិញ្ចឹមកើត ។

ដានី ៈ ចឹងមន្ទីរពិការនៅខាងដោះកញ្ជរទេ?

ភីន ៈ នៅ ខ្ញុំហៅស៊ីងចំប៉ុជីឆ្នាំង នៅក្នុងព្រៃទេមន្ទីរនឹង បើទោះជាប្រាប់ប្អូនឯងរកមិនឃើញដែរ ។

ដានី ៈ ប៉ុន្តែនៅខាងម្តុំៗដោះកញ្ជរ?

ភីន ៈ នៅ បើយើងទៅពីភ្នំពេញទៅ យើងមិនទាន់ដោះកញ្ជរ គេហៅភូមិដន្លាប់កាប់កងចេញពីដន្លាប់កាប់កង់នឹងប្រហែលជា១០គីឡូ ដល់ស៊ីងចំប៉ុជីឆ្នាំងហ្នឹងហើយ ។ កន្លែងនឹងវាសំបូរទឹកវាមានចំការក្រូចចំការចេកអី គេឲ្យទៅនៅកន្លែងមានចំការស្រេចៗនឹង ព្រោះពួកពិការគេចិញ្ចឹមចឹង ។

ដានី ៈ នៅនឹងរហូតដល់បែក៧៩?

ភីន ៈ អាហ្នឹងយើងនៅពេលបែកហើយ ។

ដានី ៈ បាទ! ពេលបែករំដោះឆ្នា៧៥?

ភីន ៈ អឺ! យើងនៅក្នុងចន្លោះព៧៤ ៧៥នៅនឹងហើយ ។

ដានី ៈ ៧៦?

ភីន ៈ ៧៦ ខ្ញុំគេយកទៅឲ្យនៅកំពង់សោមហើយ លែងឲ្យនៅព្រៃហើយ ស្រុកគេស្រួលបួលមែនទែនហើយគេឲ្យទៅនៅជិតៗផ្សារម្តង ព្រោះពួកហ្នឹងវាដើរមិនដល់ផ្សារ ។ ចុះកាលនៅក្នុងព្រៃជិតដីរ៍ ចុះមានឡានណាដូចឥឡូវ ។

ដានី ៈ មានដីរ៍ដែលកាលនោះ?

ភីន ៈ មានតើ ។

ដានី ៖ យើងជិះដំរយើងទៅណាមកណា?

ភីន ៖ អឺ! ទៅណាឆ្ងាយ ចង់ដើរទៅណាទៅណែដំរី ។ មន្ទីរខ្ញុំនៅ មានដំរី២ ។

ដានី ៖ ចឹងយើងចេះប្រើដំរី ឬក៏មានហ្មរគេ?

ភីន ៖ មានហ្មរគេមួយ ប៉ុនដល់យូរទៅ យើងចេះប្រើវាបាន អ្នកណាហ៊ានប្រើវាបាន ។

ដានី ៖ ចឹងដល់ពេលយើងបែក យើងរំដោះបានឆ្នាំ៧៥ ហើយលោកពូផ្លាស់មកកំពង់សោម វិញ?

ភីន ៖ ៧៥មក៧៦ ខ្ញុំមកកំពង់សោម ។

ដានី ៖ នៅក្នុងអង្គភាពអីដែរ កំពង់សោម?

ភីន ៖ កំពង់សោមកាលនឹងនៅកងពល១៦៤ ។

ដានី ៖ នៅជាមួយតាមុត?

ភីន ៖ តាមុត ។

ដានី ៖ តែលោកពូមកកំពង់សោមនឹង នៅក្នុងកងពលហ្នឹង ប៉ុន្តែមាន?

ភីន ៖ នៅមន្ទីរពិការ ។

ដានី ៖ នៅមន្ទីរពិការ?

ភីន ៖ បាទ!

ដានី ៖ ព្រោះខាងកងពល១៦៤នឹង គេខាងជើងទឹក គេទៅការពារកោះ ការពារអីៗ លោកពូអត់បានទៅនឹងគេទេ?

ភីន ៖ ហ៊ឺ! អ្នកណាគេឲ្យទៅ ។

ដានី ៖ ហែលទឹកអីអត់កើត?

ភីន ៖ អឺ! នៅមន្ទីរពិការនឹង គេរៀបកន្លែងផ្សារនឹងម៉ង់កាលនោះ ។

ដានី ៖ គ្នាច្រើនទេ ខាងមន្ទីរពិការ?

ភីន ៖ នៅមន្ទីរពិការ មួយកងពលកាលហ្នឹងដូចមាន៤០នាក់ ៤០ជាងតិចតួចប៉ុននឹង ។

ដានី ៖ មាន៤០នាក់ទេ?

ភីន ៖ អឺ! គេរើសអាអ្នកអន់ៗមែនទែន បើពិការល្មមៗគេមិនឲ្យមកទេ ឲ្យនៅតាមកង ត្រូវដៃត្រូវអី ពិការតិចតួចអីមិនទេ ។ ធម្មតាអ្នកណាចង់មកនៅចឹង វានៅកន្លែងអផ្សុកដែរណាកន្លែងនឹង មិនស្រួលណាដូចគេនៅដើរហើរបាន ។

ដានី ៖ បាទ! កាលហ្នឹងយ៉េងយុវជន ចូលចិត្តការដើរហើរមានសេរីភាព ។

ភីន ៖ ហ្នឹងហើយចូលចិត្ត ។

ដានី ៖ ចឹងនៅក្នុងពិការហ្នឹង មកដល់កំពង់សោម យើងធ្វើអីទៅ?

ភីន ៖ កំពង់សោមនឹងគេអត់មានធ្វើអីច្រើនដែរ គេឲ្យចាប់ផ្ដើមឲ្យយើងពួកពិការនឹង មើលឃ្លាំង ហើយ ថែរក្សាឃ្លាំងរបស់របរគេហ្នឹងហើយ ។

ដានី ៖ កាលនឹងមានឃ្លាំង មានរបស់របរអីខ្លះ?

ភីន ៖ ហ៊ោ! អាឃ្លាំងកាលហ្នឹងឃ្លាំងស្បៀងអាហាររបស់ទ័ពហ្នឹងឯង ។

ដានី ៖ កាលនឹងនៅកំពង់សោម អត់មានប្រជាជននៅណា?

ភីន ៖ កំពង់សោម ដែលប្រជាជនគេឲ្យមកនៅព្រៃទប់អស់ហើយ កំពង់សោមសម្រាប់ទាហាន សម្រាប់ដែល អឺ!ធម្មតាកម្មករ ប៉ុនកម្មករកាលនឹងកម្មករកំពង់ផែសុទ្ធតែទាហានដែរ ។

ដាន់ ៖ អតីតទាហាន?

ភីន ៖ អត់អតីតទេ ទាហានម៉ង ។ ទាហានទៅពីនឹងទៅ ពីឧត្តរមានជ័យនឹងទៅ ភូមិភាគឧត្តរ ប៉ុន មិនមែនតែឧត្តរមានជ័យទេ ហ៊ោ!មានតាំងពីបូព៌ាអីមកខ្លះ ៣-៤កងវរៈនោះ ចុះលើកដាក់ មានម៉ាស៊ីនណា យើងកាលនោះ ។

ដានី ៖ ចឹងកាលនោះនៅកំពង់ផែកំពង់សោមទាហានដែរ ទាហានអ្នកមើលកាលខុសត្រូវលើកដាក់ ទំនិញដាក់កប៉ាល់លើកចុះឡើងៗក៏ទាហាន?

ភីន ៖ កម្មករលើកដាក់គឺទាហាន តែមេដឹកនាំកំពង់ផែនោះ មិនមែនទាហានទេ គេខាងស៊ីវិលដែរ ទេ គេអ្នកចេះដែលហ្នឹង ។

ដានី ៖ ពីណាគេកាលនឹង?

ភីន ៖ កាលហ្នឹងខ្ញុំទៅពីភ្នំពេញទៅ ខ្ញុំអត់ស្គាល់ទៀត មេគេ មានមេគេផ្សេងពីទាហាន ប្អូនឯងនឹក មើលមានស្គាល់ទេ សុទ្ធតែអ្នកគេចេះ ។

ដានី ៖ ខ្ញុំធ្លាប់ឮឈ្មោះ ។

ភីន ៖ តា គ្រិន ។

ដានី ៖ ខ្ញុំធ្លាប់ជួបពួអតីតគាត់ធ្លាប់នៅ១៦៤ដែរ តា គ្រិន, តា ឡូញ?

ភីន ៖ តា ឡូញ ខាងនេសាទរដ្ឋ ។

ដានី ៖ តា ឡូញ ខាងនេសាទ ។

ភីន ៖ តែគេនៅក្នុងកំពង់ផែនឹងជាមួយគ្នាគេ ។ តា គ្រិន ហ្នឹង គាត់ចាត់ចែងនៅកំពង់ផែទាំងអស់ កាបាល់ចេញចូលដឹកជញ្ជូន ។

ដានី ៖ បើតា មុត គាត់ខាងកងទ័ពទេ?

ភីន ៖ ទេ! តា មុត ខាងទាហាន អឺ!ហ្នឹងហើយ ។

ដានី ៖ ខាងចាហានសុទ្ធ?

ភីន ៖ បាទ! គេបែងចែកគ្នាដែលកាលហ្នឹង ។

ដានី ៖ ចឹងបើពួកពិការគឺនៅមន្ទីរពិការសុទ្ធ យើងមើលតែឃ្លាំងទេ?

ភីន ៖ មើលឃ្លាំង ថែរក្សាឃ្លាំង ។

ដានី ៖ ចុះឃ្លាំងយើងពិការចឹង ត្រូវទំនិញចេញចូលអី?

ភីន ៖ មានកម្លាំងគេមកធ្វើ យើងគ្រាន់យាមមើលថែឲ្យរបស់របរនឹងវាគង់វង្ស កម្លាំងគេលើកដាក់ដេរ្យង ។

ដានី ៖ ក្នុងឃ្លាំងនឹង មានទំនិញយើងផលិតបាន ឬក៏ទំនិញ?

ភីន ៖ ទំនិញកាលនឹងទិញមកពីខាងក្រៅ ហើយនឹងទំនិញរបស់យើងនៅសល់ពី ។

ដានី ៖ លន់ នល់មក?

ភីន ៖ អឺ! ហ្នឹងហើយ ផ្ទះទាំងអស់នៅផ្សារហ្នឹង គេធ្វេ តាមផ្ទះ និយាយរួមតាមផ្ទះគេមួយៗហ្នឹង គេអត់ឲ្យមានយកទៅណាទេ ផ្ទះគេណាបិទទុកនៅហ្នង ផ្ទះណាបិទទុកហ្នឹងឯង ។

ដានី ៖ បានន័យថាទំនិញហូបចុក គ្រឿងបរិភោគអីនឹងក្នុងឃ្លាំង?

ភីន ៖ បាទ! មានមួយចប់ ។

ដានី ៖ ហើយចុះទំនិញជាគ្រឿងសម្ភារៈសម្រាប់កងទ័ព?

ភីន ៖ សម្ភារៈកងទ័ពក៏គេនៅនឹង ។

ដានី ៖ នៅនឹងដែរ?

ភីន ៖ អឺ! ពេលនោះគេមិនទាន់ធ្វើដោយឡែកទេ គេដាក់នៅរួមគ្នានឹង ប៉ុនដល់បាន៧៦ ៧៧មកគេរៀបរយដាក់ដោយឡែកៗ ហើយសម្ភារៈចាហាន ។

ដានី ៖ ចាហានដូចជាសម្ភារៈខាងកងទ័ពដើងទឹកមានដូចជាអាវុធ កប៉ាល់ ដូចជាស្អីនឹង យើងយកមកដាក់ក្នុងឃ្លាំងនឹងដែរ?

ភីន ៖ សម្ភារៈនឹងដាក់ឃ្លាំងដូចគ្នា តែអត់ដាក់ក្នុងឃ្លាំងតែកប៉ាល់ទេ វានៅលើទឹក បើឧបករណ៍ ។

ដានី ៖ កាលនឹងអាវុធយើងទំនើបៗដែរ ដូចថាពេលយើងត្រូវការពារផ្ទៃទឹកអីដែរ?

ភីន ៖ ទេ! បើខ្ញុំនិយាយពីនោះហើយមកនេះ ខ្ញុំអាចថា ខ្ញុំមិនដែលទៅឃើញនោះទេ ឥឡូវនឹងមិនដែលឃើញទេ ។ ប៉ុន្តែឮថា យកមកពីចិនដដែលហ្នឹង ដូចគ្នា ។

ដានី ៖ បាទ! ឥឡូវនឹងយើងមានជំនួយមកពី ។

ភីន ៖ ពេលនោះមានចេះ មាននាវាប្រឆាំង នាវាមុជទឹក មាននាវាដោះមីន មាននាវាចម្បាំងធម្មតា ។

ដានី ៖ ភី.ជី.អេស(P.G.S) អី?

ភីន ៖ មិនមាននិយាយរាប់ចូលទេ P.G.S វត់ចាញ្ញរលកទេមិននិយាយទេ ។ កប៉ាល់ដោះមីន មីនដាក់ក្នុងទឹកគេមិនឲ្យមនុស្សដោះទេ ឲ្យកប៉ាល់នឹងទៅដោះខ្លួនវា ។ កប៉ាល់ទៅដោះគេមិនទៅមុជដោះទេ គេបរបំបុក ។

ដានី ៖ បុកទៅវាផ្ទុះ?

ភីន ៖ អឺ! ហើយលឿនប៉ុនណា បើផ្ទុះមិនត្រូវ ស្មើនឹងយន្តហោះ អាចលឿនជាង ។ មីនគេមួយប៉ុនពាង៥០០គីឡូទំងន់ មីនសម្រាប់គេផ្ដាច់ផ្ទុះកប៉ាល់ ប៉ុនមីននឹងគេយកទៅទម្លាក់ចោលទេ ។ តែបើកន្លែងនេះមាន មីនទម្លាក់ចោលនឹងហើយ អត់មានកប៉ាល់ណាហ៊ានទៅជិតទេ បើថាគេស៊ើបការណ៍ដឹង ឬគេរាវឃើញ គេហៅអានឹងឯងទៅបរបំបុកចោល ។

ដានី ៖ កប៉ាល់ទៅបាត់ទៅ បាន?

ភីន ៖ ទៅបាត់ទៅបានវាផ្ទុះក្រោយ វាលឿនណាស់ ។

ដានី ៖ លឿន?

ភីន ៖ បាទ! តែបើរបស់នឹងវាមាននៅដល់សព្វថ្ងៃ សង្គ្រាមជាមួយថៃក៏លែងខ្លាចហើយ ។ ប៉ុនឥឡូវសម្ដេចហ៊ុន សែនទិញបានហើយដឹង ។ ហ៎! ក្រែងលរគេឲ្យមកទៀត ។

ដានី ៖ ខ្ញុំដូចជាមិនដឹងច្បាស់ដែរ បញ្ហា ។

ភីន ៖ មានអានឹង ហើយគេហៅគ្រាប់កាំជ្រួចនោះ ឥឡូវមានអត់ ។

ដានី ៖ កាំជ្រួចអីគេ?

ភីន ៖ ប្អូនឯងចេះអង់គ្លេស គេហៅ silkworm អានឹងបកប្រែមកថាម៉េច ។

ដានី ៖ silkworm?

ភ់ន ៖ ថាដង្កូវនាងដឹង ។

ដានី ៖ បាទ! ដង្កូវនាងនឹងចឹងហើយ ភាសាអង់គ្លេស ។

ភីន ៖ គេមានអានឹង ហើយមានច្រើនទៀត ។

ដានី ៖ silkworm កាំជ្រួចប្រភេទម៉េច?

ភីន ៖ កាំជ្រួចប្រភេទបាញ់នាវា ។

ដានី ៖ បាញ់នាវា?

ភីន ៖ បាទ! នាវាធំៗ ទំហំបំផ្លាញវាបាន៣០០ម៉ែត្រ៤ជ្រុង នាវាប៉ុន្មានក៏ដោយ វាកំទេចបាន៣០០ម៉ែត្រ៤ជ្រុង ។

ដានី ៖ ៣០០ម៉ែត្រ៤ជ្រុង គឺបាញ់តែមួយនឹងខ្ទេច?

ភីន ៖ បានតែមួយនឹងឯង ខ្ទេចរលំបានប៉ុននឹង នាវាហ្នឹងធំប៉ុនណាក៏ដោយ ប៉ុនកំទេចបានប៉ុននឹង ។

ដានី ៖ កាលនឹងមានកំពង់ផែមានប៉ុន្មាន?

ភីន ៖ ផែ មានផែចាស់ ផែថ្មី ហើយនឹងផែរាមប៉ុននឹង ។

ដានី ៖ ផែរបស់កងទ័ព ចាំមើលផែចាស់នៅណា?

ភីន ៖ ផែចាស់ជាប់ផែថ្មីជាមួយគ្នា ផែចាស់អាផែចូលទៅក្នុងសមុទ្រអាវែង ។

ដានី ៖ ហើយនឹងរាម?

ភីន ៖ អាផែថ្មីនឹង ផែអត់មានធ្វើស្ពាន ផែជាប់ដីគោក ហើយនឹងរាម ។

ដានី ៖ ចុះស៊ីងហាវ?

ភីន ៖ ស៊ីងហាវអានឹងកន្លែងគេធ្វើថ្មី ផែយោធា តែធ្វើមិនទាន់ហើយទេ ដីករួងភ្នំដាក់នាវា ។ តែឥឡូវនេះ បើសម្តេចហ៊ុនសែនទៅធ្វើនៅនឹងល្អ ។

ដានី ៖ កន្លែងនឹង ខ្ញុំទៅមើលដែរ ឃើញវានៅសល់ស្លាក់ស្នាម ។

ភីន ៖ នៅសល់?

ដានី ៖ នៅសល់ស្លាកស្នាមដូចថាកាលនឹងយើងធ្វើអត់ទាន់ហើយ គ្រាន់មានដា ដូចថាគេចាក់ថ្មចាក់អី ។

ភីន ៖ នៅទេប្អូន គ្រាន់តែចាក់អាចង់ដីទៅក្នុងសមុទ្រអស់ភ្នំមួយ មួយថ្ងៃ ឡាន១០០ចាក់បានមយម៉ែត្រទេប្អូន ។

ដានី ៖ លោកពូធ្លាប់ទៅមើលនឹងដែរ?

ភីន ៖ ទៅ ចុះខ្ញុំនៅមន្ទីរពិការ យើងដើរហើរបាន ទៅមើលទៅអី ហើយយើងនៅឃ្លាំងយើងមាន សិទ្ធិទៅមើលយករបស់របរឲ្យគេ ប៉ុននឹងឯង ។

ដានី ៖ កាលនឹងយកថ្មពភ្នំណាមក?

ភីន ៖ ភ្នំនៅក្រោយនឹងឯង ចុចរលាយអស់ភ្នំមួយភ្នំពីរហើយ ចុចដាក់សមុទ្រ ។

ដានី ៖ កាលនឹងផែនការដែលធ្វើនឹង ខាងកងពលគេរៀបចំធ្វើខ្លួនយើង ឬក៏មានពីខាង?

ភីន ៖ កងពលគេរៀប ប៉ុន្តែមានមេពីលើគេអ្នកឲ្យធ្វើហើយ ។

ដានី ៖ ដូចយើងធ្វើព្រលានយន្តហោះកំពង់ឆ្នាំងនឹង?

ភីន ៖ ហ្នឹងហើយដូចគ្នា ។

ដានី ៖ កាលនឹងចិនអីមកជួយធ្វើដែរអត់?

ភីន ៖ មិនទេ អានោះ ។

ដានី ៖ ស៊ីងហាវ?

ភីន ៖ ស៊ីងហាវ បាទ! អានឹងកម្មករគេមក ។

ដានី ៖ គេមកដែរ?

ភីន ៖ បាទ! មកធ្វើ ។

ដានី ៖ អ្នកជំនាញបច្ចេកទេសគេ?

ភីន ៖ ជំនាញ គេប៉ុនយើងកម្មករយើងទាហាន ។

ដានី ៖ យើងកម្មករយើងដឹង ហើយគេប្រាប់យើងថា ដាក់ចេះៗ ខាងចិនទេ?

ភីន ៖ បាទ! ហ្នឹងហើយ ។

ដានី ៖ ច្រើនដែរ អ្នកធ្វើនៅហ្នឹង?

ភន ៖ ច្រើនណាស់ប្អូន រាប់ពាន់នាក់ ។

ដានី ៖ ចុះយើងអាឡែងតែមានកម្លាំងយ៉ាងម៉េចដូចថា កម្លាំងមួយការពារ កម្លាំងធ្វើដែផង?

ភីន ៖ គេមានកងពល មានកងវរសេនាធំគេ វរសេនាធំនៅប្រចាំការណ៍នៅកោះគេនៅ គេមានខែគេដូរ ៣ខែឬ៦ខែគេដូរគ្នាម្តង ។ អាដូរនឹងហើយ មកធ្វើកន្លែងនឹង អាអ្នកដែលទៅថ្មីមិនទៅនោះទៅ ។

ដានី ៖ ធ្វើមិនយ៉ាប់ងាប់ហើយ?

ភីន ៖ យី! ម៉ាស៊ីន អត់ប្រើមនុស្សវែកលីសែង អត់មានទេ ។

ដានី ៖ ប៉ុន្តែយើងដឹកពីកន្លែងដាក់ឡាន ហើយចុះពីឡានមក?

ភីន ៖ ប្រើម៉ាស៊ីនទាំងអស់ហើយ កងទ័ពនឹងគឺបញ្ជាម៉ាស៊ីននឹង ។

ដានី ៖ មិនជាហត់អី ប្រើកម្លាំងខ្លាំង?

ភីន ៖ មិនទេៗ ហើយកន្លែងនឹងគេមិនអត់បាយទេ ។

ដានី ៖ គេអត់ៗបាយ?

ភីន ៖ បាទ!

ដានី ៖ ហូបអីបរិបូរ?

ភីន ៖ ចុះបើធ្វើអត់បាយអ្នកណាធ្វើកើតកន្លែងនឹង ។

ដានី ៖ កាលនឹងលោកពូអីហូបចុកបរិបូរ?

ភីន ៖ ខ្ញុំហូបមិនខ្វះអីនៅមន្ទីរពិការយើង គេអត់ឲ្យអត់ទេ ហើយវាមាន ។

ដានី ៖ ៣ពេល ឬក៏២ពេល?

ភីន ៖ ហ៎! កាលនឹងរកពេលហូប៣ពេលមិនឃើញទេ ។

ដានី :	ម៉េចចឹង?

ភីន :	វាហូបឆ្អែតតែ២ពេលទៅ វាទម្លាប់ចឹង វាធម្មតាទៅពោះ គ្មានទឹកឃើញ៣ពេលទេ ។

ដានី :	ព្រលឹមឡើង?

ភីន :	បើព្រលឹមឡើងហូបស្អិតិចតួចអានឹងហូប តែបើឲ្យបាយហូបតែ២ពេល ។

ដានី :	ប៉ុន្តែយើងហូបមួយឆ្អែតៗ?

ភីន :	បាទ!

ដានី :	អត់មានរបបអីទេ?

ភីន :	បាទ! មិនទេ ។

ដានី :	ម្ហូបអីក៏បានមានសាច់ទៀត?

ភីន :	ខ្ញុំចៀសផុតដែលកាលសម័យនឹង ដែលចៀសផុតពីកន្លែងដែលថាពិបាកនឹង យើងនៅកន្លែងជាមួយកងទ័ពនឹងអត់មានខ្វះខាតអី ។

ដានី :	ខ្ញុំធ្លាប់ជួបប្អូនតាមុត តាអឹម ។

ភីន :	នៅរស់ទេ តាអឹម ។

ដានី :	នៅរស់ គាត់នៅស្រុកគាត់នៅជុំគិរី គាត់រីត្រែតហើយ គាត់កាលពីសមាហរណកម្ម គាត់ចូលទៅខាងភូមិភាគ៣នៅខាងកំពង់ស្ពឺ គាត់នៅខាងសេនាធិការ ។

ភីន :	គាត់នឹងប្រវត្តិគាត់ពីដើមមក គាត់មិនមែនទាហានទេ តាអឹមៗគាត់អ្នកកាត់ដេរជំនាញមួយរូបប៉ុននឹងទេ កាត់ដេរសំលៀកបំពាក់ឲ្យកងទ័ព ។ ប៉ុនពីមុននឹងកាត់ដេរឲ្យកងទ័ព គាត់អ្នកកាត់ដេរ រកស៊ីឈ្នួលគេពីសម័យដើមមក ។

ដានី :	បាទ!គាត់និយាយចឹងដែរ គាត់ថាកាលពេលមកនៅក្រាំងដីវ៉ាយ គាត់នៅជាងដេរ ពីរនាក់

ភីន :	រហូតមកនៅកំពង់សោមក៏ជាងដេរដែរ ។

ដានី :	បាទ! គាត់ជាងដេរខោអាវឲ្យកងទ័ពឲ្យអីនេះនឹង ។

ភីន :	បាទ! គាត់ជំនាញជាងខាងដេរ មើលគេដេរសម័យដើមនឹង អ្នកចេះដេរខោអាវហ្វាសេជំនាញហើយណា ខោអាវហ្វាសេដេរខុសសងគេ បើថាក្រណាត់គេតម្លៃ៣០០០ សងគេក៏៣០០០ដែរ ដេរខុះថ្នេរមួយក៏សងគេដែរ ។

ដានី :	ប៉ុន្តែគាត់កាលពេលគាត់ធ្វើដៃនៅស៊ីងហាវ គាត់ទៅដូចថាខាងគ្រប់គ្រងឡាន?

ភីន :	គាត់គេឲ្យខាងដឹកជញ្ជូន ។

ដានី :	ដឹកជញ្ជូន?

ភីន :	ដឹកជញ្ជូន ពួកដឹកដីនឹងហើយ ។

ដានី ៖ ជីកដីនឹង?

ភីន ៖ ហ្នឹងហើយ(សើច) ។

ដាន់ ៖ លោកពូស្គាល់គាត់ច្បាស់ដែរ?

ភីន ៖ ហ៊ើ! ចុះនៅជាមួយគ្នា កំពង់សោមនៅជាមួយគ្នាតើ ។

ដានី ៖ នៅជាមួយគ្នា?

ភីន ៖ បាទ! តែគ្រាន់គាត់អត់ពិការ ខ្ញុំពិការ គ្រាន់ថា ផ្ទះនៅជិតគ្នា នៅផ្សារ គាត់ហ្នឹងក៏នៅនឹងផ្សារនឹងដែរ ។

ដានី ៖ ពូខានជួបគាត់យូរហើយ?

ភីន ៖ ហ៊ើ! ខានជួបរហូតតាំងពីបែកគ្នា កាលយួនចូលមកលែងជួបគាត់ តែឥឡូវនេះមិនដែលបានទៅជួបគាត់ ។

ដានី ៖ ចុះដែលមានជួបតាមុតដែរ?

ភីន ៖ មិនទេ អត់ដែរទេ ។

ដានី ៖ ចុះកាលនៅធ្វើការជាមួយគ្នានៅកំពង់សោម?

ភីន ៖ ហ៊ើ! កាលនៅនឹងជួប ។

ដានី ៖ ដូចថាយើងរាក់ទាក់អី ស្និតស្នាលជាមួយគ្នាដែរ?

ភីន ៖ ចុះគ្នាស្និ គាត់ ។

ដានី ៖ គាតមនុស្សស្រួលដែរ?

ភីន ៖ ស្រួលប្អូនអើយ មិនដូចគេថាមនុស្សកាចសាហាវណា គ្មានទេ មនុស្សមាត់ចឹង ។

ដានី ៖ បើតាអ៊ឹម ខ្ញុំធ្លាប់ជួបគាត់សួរនាំគាត់ដូចពូចឹងដែរ គាត់ធម្មតា ហើយ ។ ចុះកាលនឹងនៅពេលដែលធ្វើអីនៅក្នុងពិការនឹង ពូអត់មានតួនាទីអី?

ភីន ៖ តួនាទីអីយើងអត់មាន ។

ដានី ៖ អត់ទេនោះ?

ភីន ៖ អឺ!

ដានី ៖ នៅហ្នឹងរហូតដល់យើងបែករត់យួននឹងម៉ង ឬក៏លោកពូមានផ្លាស់ប្តូរទៅណាទៀត?

ភីន ៖ រត់យួន ទាល់តែរត់មក យើងមកនេះ ។

ដានី ៖ ប៉ុន្តែរត់ពីកំពង់សោមនឹងដែរ?

ភីន ៖ បាទ!

ដានី ៖ កាលនឹងលោកពូរៀបការហើយនៅ?

ភីន : ការហើយ ។ អឺ! ការហើយៗយួនចូលបណ្តោយ ។

ដានី : ឆ្នាំណា ការ?

ភីន : ការ៧៧ ។

ដានី : ការ៧៧?

ភីន : អឺ! ចុងៗឆ្នាំទៀត ។

ដានី : ចុងឆ្នាំ៧៧?

ភីន : អឺ! (សើច) ។

ដានី : កាលនឹងយ៉ាងម៉េចដែរ លោកពូអាចរៀបរាប់ពេលដែលការនឹងយើងយ៉ាងម៉េច យើងលោកពូដូចថាពេញចិត្តគ្នាការ ឬក៏ខាងអគ្គភាព អង្គការអីគេដូចថា?

ភីន : អ! មុនយើងការ គេឲ្យយើងមើលដែរនឹង បនណាមិនចេះគេបង្ខំបានទេ ស្តាប់ក្នុងវិទ្យុដូចពិបាកស្តាប់ណាស់ខ្ញុំ ។ មនុស្សនិយាយដូចថាមនុស្ស១០និយាយ១០ ខុសគ្នាទាំង១០ ។

ដានី : បាទ! ឥឡូវនិយាយពីបទពិសោធន៍របស់លោកពូ?

ភីន : អឺ! អាណាទៅបង្ខំយើងណា ឥឡូវប្អូនឯងទៅសួរ ម៉ុង ឫទ្ធី ការសម័យនឹងដែរ ហើយសួរសម្តេច ហ៊ុន សែន ការដូចគ្នា ។ ការខ្ញុំការតែមួយគូទេ តែខ្លួនខ្ញុំមួយនឹង តែក្នុងនឹងមានតែមេ៦នាក់ទេ ការមានមនុស្ស៦នាក់ ។

ដានី : ពីណាគេ?

ភីន : មេៗយើងចាស់ៗដែលនៅជាមួយគ្នានឹងគេយកធ្វើចាស់ទុំហើយ ដូចយើងឥឡូវហៅចាស់ទុំ ។ ប៉ុនពីមុនមានចាស់ទុំណានៅជិត មានអាចារ្យណា ។

ដានី : មេដូច តា មុត ចឹង?

ភីន : មិនមែនទេ យើងការត្រឹមថ្នាក់ទាបៗនឹង គេអត់ចូលរួមទេ ប្រកាន់សក្តិដូចឥឡូវចឹង ។ ឥឡូវនេះដល់សក្តិធំអាណាគេមកស្គាល់យើង ។ ប៉ុន្តែពីមនុសវាគ្រាន់បើជាងឥឡូវ គ្រាន់បើត្រង់ថា គេដើរទៅណាក៏បាន គេសួរនាំអីកូនទាហានបាន ។ ឥឡូវនេះគេប្រកាន់ដែរ ។

ដានី : ឥឡូវតែធំមានលុយ រិតតែ ។

ភីន : បាទ!ដូចខ្ញុំនិយាយមិញចឹង ទូរស័ព្ទទៅរកគេៗនិយាយលេងធម្មតាចឹងទៅ អត់មាននិយាយសាច់ការណ៍អីទេ យើងចង់ជួបគេនិយាយសាច់ការណ៍ ប៉ុន្តែគេមិនសូវទេ ។

ដានី : មកពីលោកពូអត់សួរសាច់ការណ៍?

ភីន : សួរ ប៉ុន្តែតែចាប់ផ្តើមនិយាយលេងហើយ មិនដឹងសួរម៉េចទៀតទេ ឈប់ហើយ ។ គាត់សើចឈប់បិទទូរស័ព្ទទៅ បើជួបមាត់ផ្ទាល់មានអី ធម្មតានិយាយ ។

ដានី ៖ ចឹងកាលនោះប្រពន្ធលោកពូគាត់ធ្វើអីដែរ?

ភីន ៖ កាលនឹងគេនៅមិត្តនារីគេហៅមិត្តនារីៗ ។

ដានី ៖ មិត្តនារីៗ នៅក្នុងកងពល?

ភីន ៖ ក្នុងជួរបដិវត្តន៍នឹង ក្នុងកងពលហ្នឹង ប៉ុន្តែនៅចំការដូង ។

ដានី ៖ ចំការដូងចេង ហេងនឹង?

ភីន ៖ ចំការដូងចេង ហេងនឹង ទុកឲ្យខ្ញុំហូបដង កុំកាប់រំលំអស់ ។

ដានី ៖ ដូងចាស់ៗហើយ វាលែងសូវផ្លែ ។

ភីន ៖ អត់មានគេដាំថែម ។

ដានី ៖ ខ្ញុំដូចអត់ដឹងដែរ ។

ភីន ៖ កាលសម័យនឹងគេដាំថែមតើ ដាំថែមកជិតដល់ព្រលាន (យន្តហោះ) កងកេង ។

ដានី ៖ ចឹងកាលនឹងគាត់នៅក្នុងកងពលដែរ លោកពូធ្លាប់ខស្សាហ៍ឃើញគាត់ដែរ បានពេញចិត្តគាត់?

ភីន ៖ ឃើញៗគេទៅមកក្នុងកងពលអាចស្គាល់ ។

ដានី ៖ ស្រុកកំណើតគាត់នៅណាដែរ?

ភីន ៖ ទៅជិតតែគ្នា ។

ដានី ៖ នៅជិតគ្នា?

ភីន ៖ អឺ! ហ្នឹងហើយ ។

ដានី ៖ ស្គាល់ពីមុនមក?

ភីន ៖ មិនទេ ពីកំណើតមកយើងមិនស្គាល់ទេ គេឲ្យយើងទៅមើលទៅអី សួរនាំអីត្រឹមត្រូវណាស់ បានគេការឲ្យយើង បើយើងមិនត្រូវ យើងមិនសួរក៏គេអត់ការឲ្យដែរ ។

ដានី ៖ ចឹងដល់ពេលចុង៧៧នឹង លោកពូរៀបការតែមួយគូនឹង?

ភីន ៖ មួយគូខ្ញុំ ។

ដានី ៖ អត់មានច្រើនគូ?

ភីន ៖ អត់ទេ តែពេលខ្លះគេការច្រើនដែរ ដល់១០ ដល់១៥អីចឹង ការឲ្យកងទ័ពមានការច្រើន ។

ដានី ៖ ខ្ញុំចង់ដឹងពីពិធីរៀបការ លោកពូអាចរៀបរាប់តាំងពីដំបូងគេចាប់ផ្ដើមយ៉ាងម៉េច បន្ទាប់មកយ៉ាងម៉េចៗ រហូតដល់ចប់?

ភីន ៖ ការនឹងដូចអាចារ្យប្រដៅយើងសព្វថ្ងៃចឹង ប៉ុនអាចារ្យប្រដៅឥឡូវអត់មានលើកពីប្រវត្តិពីអីទេណា ។ ពីមុនគេលើកពីប្រវត្តិរូបរបស់យើង ប្រវត្តិរូបយើងម៉េចៗគេសរសេរតាមនឹង

មកទាំងសងខាងនឹង ។ ដល់ហើយគេអានប្រវត្តិរូបនឹងចប់ទៅ មេគេផ្ដាំផ្ញើអីថាដូចអាចារ្យ យើងឥឡូវចឹង ហើយឲ្យយើងប្ដេជ្ញារៀងខ្លួនចប់ប៉ុននឹងឯង ការតែ៣ម៉ោងយូរបំផុត ហើយ ។

ដានី : ចុះមានជប់លៀងអីដែរ?

ភីន : ហ៎! ជប់លៀង កុំនិយាយលេង ។

ដានី : មានអីខ្លះជប់លៀង?

ភីន : អឺ! ជប់លៀងមានរបស់របរហូបចុកដូចឥឡូវដែរតើ កាលយើងរំដោះហើយមិនមានរបស់របរសព្វគ្រប់ហើយ មានមិនអត់ទេ ។

ដានី : គេឲ្យសម្រាកប៉ុន្មានថ្ងៃដែរ ដែលយើងការ?

ភីន : ហ៎! កាលហ្នឹងខ្ញុំពួកនៅក្រោយ ខ្ញុំការហើយយកមកនៅជាមួយគ្នារហូតមក ។

ដានី : មកនៅជាមួយគ្នារហូត?

ភីន : បាទ! តែលងទ័ពគេមានពេលគេ អ្នកណាឲ្យទៅនៅជាមួយទ័ពដូចឥឡូវនេះមិនទេ ។ នៅមិនដឹងច្បាំងថ្ងៃណាអីថ្ងៃណានោះ ប្រពន្ធគេទុកភូមិផ្សេង ហើយប្ដីនៅកោះនៅណាណោះ អ្នកណាឲ្យទៅនៅជាមួយ គ្រុនចាញ់ងាប់ មានចឹងខាងទ័ព ។

ដានី : ចឹងដល់ពេលលោកពូ ពេលការហើយ យើងនៅជាមួយគ្នាម៉េង?

ភីន : នៅជាមួយគ្នាបាន ពួកពិការ ។

ដានី : នៅជាមួយគ្នា តែការងារគាត់នៅធ្វើដដែល ហើយក៏?

ភីន : គាត់ទៅធ្វើកន្លែងគាត់ទៅ យើងមកដេកនៅឯផ្ទះយើង ។

ដានី : ចុះដល់ពេលយួនចូលឆ្នាំ៧៩ យើងម៉េច លោកពូអាចរៀបរាប់ពេលនឹង លោកពូមានកូននៅ?

ភីន : នៅទេ! អត់មានទេ ខ្លួនមួយៗទេ ។

ដានី : យើងចាប់ផ្ដើមយ៉ាងម៉េច ព្រោះពេលខែយួនចូល៧៩ដើមឆ្នាំ៧៩ យួនចូលមកហើយ ។ ហើយការយើងដំណើរយើងរត់យើងអីធ្វើម៉េចទៅ ពូអាចរៀបរាប់កន្លែងនឹងបានទេ?

ភីន : ខ្ញុំនឹកចេះមករួច ពិបាកខ្លាំងបួន ប៉ុនចេះរស់ដល់សព្វថ្ងៃ អ្នកពិការនៅជាមួយខ្ញុំងាប់ទាំងអស់អត់មានរស់មួយទេ ។

ដានី : ងាប់យ៉ាងម៉េច ដោយសារម៉េច គាត់ស្លាប់?

ភីន : ដែលវាងាប់ យួនបាញ់ចោល ។

ដានី : គេចាប់បាន?

ភីន ៖ ចុះគ្នារត់រួច អ្នកដែលធ្ងន់ៗដាងខ្ញុំទៅទៀតមកអីបាន ហើយមានអ្នកណាដឹកអៀវអីគ្នាបាន ដើរមកត្រឹមប៉ុន្មាន គេទាន់ត្រឹមប៉ុន្មានគេវ៉ៃចោលត្រឹមនឹងអស់ ។

ដានី ៖ ចុះលោកពូយ៉ាងម៉េចទៅយើងរត់?

ភីន ៖ ខ្ញុំគេចរួច ចូលព្រៃចូលអី ។ នេះខ្ញុំមកនេះ ខ្ញុំបានតែមកនៅប្រកនេះ វារត់ពីកំពង់សោម មក បើធម្មតាគេនៅកោះកុងទេ ប៉ុនខ្ញុំគោលដៅកាលនោះ យើងបម្រុងទៅផ្ទះទៅសម្បែង យើងមិនបកពីកំពង់សោមទៅតាមផ្លូវលេខ៣ ទៅស្រុក ។ មិនបានទៅផ្លូវលេខ៣មកផ្លូវ លេខ៤ទៀត មកផ្លូវលេខ៤កាលហ្នឹងយួនអីចូលដល់ភ្នំពេញហើយ យើងទៅស្រុកណាបាន ទាល់ងាកចេញពីនឹងមកវិញ មិនចូលមកអមលាំង មកកំពង់ឆ្នាំងនេះ បានខ្ញុំវិលកាច់ត្រឡប់ មកនេះវិញ ។

ដានី ៖ កាលនឹងទៅតែពីរនាក់?

ភីន ៖ បាទ! មកជាប់គ្នាជាមួយប្រពន្ធ អត់ដាច់ទេ ។

ដានី ៖ នៅជាមួយគ្នាអត់ដាច?

ភីន ៖ បាទ!

ដានី ៖ ដល់ពេលយើងបកមកផ្លូវជាតិលេខ៣ហើយ ដល់ពេលសភាពការណ៍ថាយួនចូលពេញ ក៏យើងបកទៅខាង?

ភីន ៖ អត់ល្អ ផ្លូវលេខ៤ៗហើយក៏មិនល្អទៀតចេញហើយអានឹង បែកពីផ្លូវហើយចូលមកតាម ផ្លូវលំតាមក្នុងព្រៃ ។ ប៉ុនកាលនឹងអានឹងមានឡានជិះបានឡានមិនខុះទេ ខ្ញុំដើរមកសុទ្ធសាធ មកយើងដល់ព្រំដែននេះ ដែលយើងដើរសុទ្ធហើយ ។

ដានី ៖ ចឹងកាលពីអមលាំងអី លោកពូដើរជាមួយខាងកងទ័ព ឬក៏នៅជាមួយ?

ភីន ៖ មិនទេ យើងជិះឡានហើយទ័ពគេនៅផ្សេង គេលែងមកអីជាមួយយើងហើយ យើងបែក ហើយបែកចេញពីអង្គភាពហើយ ចេះតែមកឲ្យរួចខ្លួនទេ ។

ដានី ៖ យ៉ាងម៉េចទៅមកដល់អមលាំង?

ភីន ៖ មកដល់អមលាំង យួនគេមកដល់នឹងទៀត យើងមកទៀតៗយើងមកចូលកំពង់ឆ្នាំងចូលអី ប៉ុនចូលកំពង់ឆ្នាំងអត់បានដេកទេ មកដេកនៅបាត់ដំបង ។

ដានី ៖ ជិះឡាន?

ភីន ៖ ជិះឡានៗរហូតមកដល់បាត់ដំបង មកចប់ជិះឡានថ្មគោល ចប់ហើយ ។

ដានី ៖ ឡាននឹងរបៀបឡានយ៉ាងម៉េច?

ភីន ៖ ឡានរដ្ឋគេ ។

ដានី ៖ ឡានរបស់ខាង?

ភីន ៖ ខាងទាហានខាងអី យើងឃើញគេបើក គេបរមកសុំគេជិះបាន ។

ដានី ៖ កាលនឹងខាងកងទ័ពខ្មែរក្រហម?

ភីន ៖ បាទ!

ដានី ៖ ខាងកងទ័ពៗ អីចឹងទៅយើងសុំគេជិះទៅជាមួយកងទ័ពទៅ?

ភីន ៖ សុំជិះមិនមានអស់លុយអស់កាកអីទេ ។

ដានី ៖ ៧៩ ហ្នឹង?

ភីន ៖ ៧៩ ហ្នឹង ។

ដានី ៖ កាលពេលខែប៉ុន្មាន?

ភីន ៖ យួនចូលថ្ងៃប៉ុន្មាន?

ដានី ៖ យួនចូលដលភ្នំពេញថ្ងៃ៧មករា ។

ភីន ៖ ៧ អឺ!ចាប់ពីថ្ងៃ៧មក យើងជិះឡានបណ្តើរៗមករហូត ។ បើតាមមកៗនេះម៉ង ដល់ព្រំដែនមិនបាច់ពិបាកទេ ប៉ុន្តគេមិនឲ្យមកដែរនឹង ចាំមើលខ្លាចយួនទៅស្រុកវិញដែរ ប៉ុន្តយួនវាមិនទៅ ។

ដានី ៖ បើយួនទៅស្រុកវិញ យើងនៅដដែល?

ភីន ៖ យើងមកវិញ ប៉ុន្តគេមិនទៅដែរ យើងចេះតែមកៗ ។

ដានី ៖ ដល់ពេលឡានគេមកដល់ថ្មគោល ចាប់ពីយ៉ាងម៉េចទៀតទៅ?

ភីន ៖ ថ្មគោលនឹងចប់ត្រឹមហ្នឹងហើយ ថ្មគោលនឹងយួនសម្រាប់មនុស្សអស់៣០០ត្រង់នឹងខ្ញុំប្រាប់ទាំងពួកពិការ ទាំងពួកដេកពេទ្យ ចុះឡានដឹកមកពីភ្នំពេញមកៗគរកំបុតត្រឹមនឹងឯង លែងទៅមុខបានទៀតហើយ ។

ដានី ៖ បានន័យថាពេលដែលមកដល់ថ្មគោល អ្នកដែលរបួសខ្លាំង អ្នកដែលពិការគាត់ដើរអីអត់បាន បានន័យថានៅនឹង?

ភីន ៖ បាទ! អស់មានអ្នកយករួចហើយ ។

ដានី ៖ ដល់ពេលចឹង យួនចូលមកដល់ឃើញនឹងសម្លាប់មនុស្ស?

ភីន ៖ រោងម៉ាស៊ីនកិនស្រូវថ្មគោល ប្អូនឯងទៅមើលនៅទេរោងម៉ាស៊ីនហ្នឹង ប៉ុន្តខ្មោចវាអស់ហើយ ។

ដានី ៖ ដល់ពេលនឹងគេ?

ភីន ៖ ខ្ញុំរត់រួច ខ្ញុំចូលក្នុងស្រែមានដញ្ញាំងខ្ពស់ៗ ដញ្ញាំងស្រុកនឹងត្រឹមៗនេះ ពេលរថក្រោះមកខ្ញុំអន្ទុយក្នុងដញ្ញាំងរួចបាន៤០០-៥០០នាក់ដែរតើ ។

ដានី ៖ រួចបានច្រើនដែរ?

ភីន ៖ បាទ! រួចច្រើន មនុស្សវាច្រើនរាប់ពាន់នោះ ។ តែយើងអន្ទុយ ខ្ញុំនៅសាលាកាលេះចេញពីសាលាកាលេះទៅ ខ្ញុំទៅនៅក្នុងដញ្ញាំងស្រូវ ។

ដានី ៖ លោកពូអាចរៀបរាប់កន្លែងសកម្មភាពនឹងតិចមើល ដូចថាពេលដែលយួនចូលមកចឹង ដូចថា យើងនៅកាលនឹងរាប់ពាន់នាក់?

ភីន ៖ បាទ!

ដានី ៖ ហើយអកដែលរត់រួចនឹងយើងចូលក្នុងស្រែទៅ?

ភីន ៖ អឺ!

ដានី ៖ ទៅពួកក្នុង?

ភីន ៖ ដញ្ញាំងស្រូវយើងនឹង មិនមានព្រៃណាអត់ទេ ។

ដានី ៖ ហើយចុះអ្នកដែលអត់ពួកនឹងយ៉ាងម៉េច យួនធ្វើម៉េច ?

ភីន ៖ គ្នាចេញវាមិនរួច ចុះពិការកំបុតដៃកំបុតជើងដើរមិនរួចនោះ នៅព្យាបាលនៅពេទ្យនៅឡើយ រត់រួចតែពួកពេទ្យដែលវាជើងដៃជាល្អ បើអ្នកដែលនេះ គ្នាសែងយកអីកើត ។ បើយើងយករថក្រោះមក ស្មើតែរថក្រោះឡានគ្នាឯង ។ ដល់មកដល់ឆឹប បានគេចេញមកសុទ្ធតែមួកគោបវៀតណាម ហើយរត់ទៅណា ។

ដានី ៖ គេបាញ់មកម៉ង ឬក៏គេប្រើយ៉ាងម៉េច?

ភីន ៖ បាញ់ម៉ង គ្មានសួរទេ ។

ដានី ៖ ពូឃើញផ្ទាល់ភ្នែក?

ភីន ៖ អឺ! ចុះបើខ្ញុំនៅនឹង ម៉េចមិនឃើញ ។

ដានី ៖ គេបាញ់ហើយគេទៅទៀត?

ភីន ៖ បាញ់ហើយគេទៅគេទៅបាត់ដំបង គេប្រញាប់ទៅបាត់ដំបង ហើយខ្ញុំអន្ទុយមើលរថក្រោះមើលឡានគេទៅៗ ។

ដានី ៖ ចុះកាលនឹងប្រពន្ធលោកពូ គាត់?

ភីន ៖ នៅពួកជាមួយនឹងគ្នាឯង ។

ដានី ៖ ប្រហែលជាស្លាប់ប៉ុន្មាន?

ភីន ៖ ហ៊ឺ! ខ្ញុំថា៣០០នឹងហើយ ។

ដានី ៖ បានពេលដែលកងទ័ពយួនទៅផុត យើងមានបានមកមើលសាកសព?

ភីន ៖ មិនទេ លែងមកហើយ ។

ដានី ៖ ទៅទៀតបណ្តោយ?

ភីន ៖ មិនទេ លែងមកហើយ សពហ្នឹង អីហ្នឹង គឺប្រជាជនគាត់គិតគូគេផុតគេយកទៅធ្វើអីៗ យើងមិនដឹងទេ យើងចេញមកហើយ ។ នៅអើតអីទៀតអើតឆាប់ទៀត មិនបានទេ រឿងចឹងទេ ។

ដានី ៖ នៅកន្លែងណា រោងម៉ាស៊ីនថ្មគោល?

ភីន ៖ រោងម៉ាស៊ីនថ្មគោល ផ្លូវបំបែកទៅបវេលទៅ ប្អូនឯងទៅមើលទៅ រោងម៉ាស៊ីននឹងនៅទេ គ្មានអ្នកណារើរុះអីទេ ។

ដានី ៖ កាលនឹងបើតាមលោកពូចាំអាចថាថ្ងៃខែដឹងទេ ដែលយួនបាញ់?

ភីន ៖ មិនចាំទេ ព្រោះយើងភ័យខ្លាំងណាស មិនមានអ្នកមានកាំភ្លើងអីនឹងគេ ដៃទទេរអស់ទៅហើយ ។

ដានី ៖ ខែប្រាំង ហើយខែវស្សា?

ភីន ៖ ខែប្រូតៗមិនទាន់ហើយផង ។

ដានី ៖ ប្រូតមិនទាន់ហើយ?

ភីន ៖ បាទ! ប៉ុនកន្លែងខ្ញុំពួកក្នុងជញ្ជាំងគេប្រូតហើយ ។

ដានី ៖ បើតាមលោកពូប៉ាន់ស្មានមើល ពេលដែលយួនចូលភ្នំពេញដែលយើងចាប់ផ្តើមរត់ថ្ងៃ៧មករា ប្រហែលចន្លោះប្រហែលប៉ុន្មានថ្ងៃ?

ភីន ៖ ខ្ញុំចាំបានគ្រាន់បើ៧មករា ៧ខ្ញុំមកដេកនៅអមលាំងមួយយប់វា៨ ។ ចេញមកដេកនៅកំពង់ឆ្នាំងមួយយប់៩ អានឹងខ្ញុំជិះរទេះភ្លើងទៅភ្នំតូចហើយ១០ ដេកភ្នំតូចបាន៣ថ្ងៃវា១៣ៗ យើងមកវិលថ្មគោលវិញ អានឹងមកដល់ថ្មគោលថ្ងៃ១៣-១៤ហ្នឹងអំឡុងនឹង ។ ហើយមកនៅនឹងបាន៣-៤ថ្ងៃដែលយួនមកដល់ហើយ គេមកតាមសៀមរាបកាលនឹងមកផ្លូវលេខ៦

ដានី ៖ មកពីកាត់ពីសៀមរាបមកពីបន្ទាយមានជ័យចូលមកបាត់ដំបង?

ភីន ៖ បាទ! ហ្នឹងហើយទៅពីផ្លូវលេខ៦ មិនមែនមកពីបាត់ដំបងផ្លូវលេខ៥ទេ អត់ទេ មានមកពីនេះ យើងទៅពីនឹងទៅ ។

ដានី ៖ ចឹងខ្ទង់ថ្ងៃ១៧-១៨?

ភីន ៖ ហ្នឹងឯងខ្ទង់ប៉ុននឹង ។

ដានី ៖ ដល់ពេលយើងៗជិះរទេះភ្លើង ចេញពីនេះតាមផ្លូវជាតិលេខ៥ យើងទៅដល់ថ្មគោលវគ្គជាមួយយួនវាមកពីសៀមរាប?

ភីន ៖ ផ្លូវនេះគេសម្រាប់ដឹកអ្នករបួស ដឹកមនុស្សនឹងទៅដាក់ទុកដាក់តាមវ៉ាៗនឹងរហូត សម្រាប់គាត់មកតាមព្រំដែន ប៉ុនយើងរៀបរយអត់ទាន់ទេ យួនគេតាមទាន់ត្រឹមហ្នឹងក៏អស់មួយចំនួននឹងទៅ ។

ដានី ៖ អស់មួយចំនួន?

ភីន ៖ បាទ!

ដានី ៖ តែលោកពូពេលដែលគេបាញ់ គេអីហើយ យើងអត់បានមកមើលសាកសព យើងដឹង?

ភីន ៖ មិនទេ ពើតយកតែរួចខ្លួន ។

ដានី ៖ កាលនឹងភ័យខ្លាំង?

ភីន ៖ អឺ! ដើរអានឹងចាប់ផ្ដើមដើរហើយ អត់មាននេះទេ ដើរហើយចោលឡានចោលម៉ូតូអស់ហើយ គ្មានអ្នកណាយកអីកើត ។

ដានី ៖ ប៉ុន្តែកាលនឹងដើងពូដូចថាយើងជាលែងឈឺលែងអីហើយ?

ភីន ៖ ហ៉ើ! ប្អូនដើរបានតែប៉ុន្មានថ្ងៃឈឺទៀត ខ្ញុំ ស្ពាយតែថ្នាំចាក់ទេណាខ្ញុំ ។

ដានី ៖ ដើរយ៉ាងម៉េចទៅលោកពូអាចរៀបរាប់ពេលដែលយើងដើចេញពីថ្មគោលមក?

ភីន ៖ ដើរពីថ្មគោលមក ដើរតាមប្រឡាយគេៗហៅភូមិគោកឃ្មុំ ។

ដានី ៖ ភូមិគោកឃ្មុំ ខ្ញុំឮបទចំរៀង ឱ!ភូមិថ្មគោល?

ភីន ៖ មាន ចេញពីដើមដំបូងមកគេហៅភូមិប្រាសាទៗនៅកណ្ដាលបឹងកណ្ដាលវាល ដើរពីភូមិប្រាសាទនឹងមកដល់ភូមិគោកឃ្មុំ ចេញពីភូមិគោកឃ្មុំមកដល់ភូមិរូងជ្រៃ រហាត់ទឹក ដល់បវេលហើយ ។ ដើរដល់ចំងាយនឹងអស់ស្បៀងហើយ ស្ពាយមិនបាន ។

ដានី ៖ យើង?

ភីន ៖ យើងអ្នកពិការស្ពាយមិនបាន ទៅសុំស្បៀងគេនៅបវេលនឹង គេឲ្យ ពេលនោះអង្ករអស់ទៀត ម៉ាស៊ីនកិនមិនទាន់គេឲ្យគ្រាប់សណ្ដែក ស្ពាយគ្រាប់សណ្ដែកទៀត សណ្ដែកខៀវ យើងហូបឆ្ងាញ់ណាស់សណ្ដែកខៀវ ។

ដានី ៖ ពេលយើងអត់មានបាយទៅ ហូបអានឹងបាន?

ភីន ៖ ហ្នឹងហើយឆ្ងាញម៉េង ដាក់ដាំធ្វើបាយ ។

ដានី ៖ កាលនឹងពេលយើងដើរនឹង ដើរមួយកងទ័ព ឬជាមួយប្រជាជន?

ភីន :	ហ៊ើ!អត់មានកងទ័ពដើរជាមួយយើងហើយ កងទ័ពគេនៅដោយឡែកៗតែគ្នាគេ យើងដើរជាមួយអ្នកស្រុកអ្នកស្រែយើងនឹង ។ ស្គាល់គ្នាណា តាមរកគ្នានឹង ។

ដានី :	ដាច់បាយដាច់ទឹក អានឹងមានគ្រាប់សណ្ដែក ដល់បវេលទៅ?

ភីន :	ដែលគ្រាប់សណ្ដែកយើងហូបមួយរយៈ ក្រោយមកយើងហូបអង្ករវិញហើយ អត់ខ្វះទេ ។

ដានី :	មកស្នាក់នៅត្រឹមបវេល ហើយក៏យើងបន្តដំណើរ?

ភីន :	មិនទេ អូ! មកបវេលតាមទាន់នឹងទៀត ។

ដានី :	យួនមកតាមទាន់នឹងទៀត?

ភីន :	ទាន់ទៀត អ្នករបួសមួយចំនួនស្លាប់នៅសាលាបវេលនឹងទៀត ប៉ុនខ្ញុំបេញ្ចេញផុតទៀត ហើយទៅមកគេហៅតាមភូមិ ហ៊ើ!ឥឡូវនេះភ្លេចអស់ភូមិនឹង គេហៅភូមិស្ដោស្ទឹង ប៉ុនមុនមកដល់ស្ដោស្ទឹងគេហៅភូមិព្រៃធំមួយទៀតនៅកណ្ដាលព្រៃ ។

ដានី :	ស្ដោស្ទឹង មកខាងរតនមណ្ឌល មកខាងផ្លូវ?

ភីន :	បាទ! មកនឹងវិញ គេអត់ឲ្យទៅព្រំដែនទេ ។

ដានី :	ចាក់តាមណាទៅ ចាក់ពីបវេលទៅតាមផ្លូវណា បានទៅខាងស្ដោស្ទឹង?

ភីន :	ផ្លូវបវេលនឹងចេញពីសាលាមួយ សាលាកាលេះដឹង សាលាអីទេប្អូន មកគេហៅមកភូមិព្រៃធំៗភូមិហ្នឹងនៅកណ្ដាលព្រៃ ផ្លូវព្រៃធំផ្លូវទៅចក្រី កំពង់ឡៃ ទៅភ្នំកុយ ព្រំដែនកំរៀងផ្លូវនឹង ។ ប៉ុនខ្ញុំមិនទៅនឹងទេ គេមិនទាន់ឲ្យទៅព្រំដែនទេ ពេលនោះគេឲ្យបកមកស្ដោមកស្ទឹងវិញ មករូងចាំងចោទ ជិតរោងចក្រសរសនេះ ។

ដានី :	មកខាងស្ដោ ខាងស្ទឹងវិញ ទៅជួបពីណាវិញកាលនោះ?

ភីន :	កាលនឹងគេរៀបចំមន្ទីរ រៀបចំអីឲ្យយើងកន្លែងយើងរស់នៅពួកពិបាកៗនឹង ឲ្យមកដាច់ស្បៀងខ្លាចស្លាប់អស់ ឲ្យនៅជិតៗប្រជាជន ។

ដានី :	កន្លែងត្រែង កន្លែងជ្រាវអីនឹង?

ភីន :	ចំកន្លែងផ្លូវជាតិនឹងមិនសូវឲ្យនៅទេ គេឲ្យនៅខាងៗ នៅតាមដងស្ទឹង ។

ដានី :	នៅខាងដងស្ទឹង?

ភីន :	បាទ! ដងស្ទឹងគេហៅរូងប្រាំងចោទហ្នឹងដងស្ទឹងហើយ មានចំការក្រូច ចំការអីច្រើនណាស់ គេឲ្យយើងទៅនៅនឹង ស្រណុកគេឲ្យស្បៀងឲ្យអីហូប នៅហ្នឹង ។

ដានី :	ហ្នឹងកងទ័ពគេនៅក្បែរៗនឹង?

ភីន :	កងទ័ពគេនៅមុខនេះ គេនៅព្រំដែននេះ ហើយអ្នកនៅច្បាំងគ្នាជាមួយយួនគេនៅជិតបាត់ដំបងនេះទៅទ័ពគេ ។

ដានី ៖ កាលហ្នឹងខ្ញុំធ្លាប់ដឹងដែរ កាលខ្ញុំធ្លាប់សួរគេថា ដូចថានៅបាត់ដំបង ចេញពីបាត់ដំបងមក យើងវើហូរហែលមកៗកន្លែងស្ទឹងនឹង យើងមានចាប់ផ្ដើមមានកងទ័ពមានអី ។

ភីន ៖ បាទ! ហើយខ្ញុំនៅនឹងបានប៉ុន្មានដូចថាមួយខែជាងទេប្អូន យួនតាមទាន់ទៀតៗទៅទៀត ។ អ្នកពិការមករួចជាមួយខ្ញុំប៉ុន្មាន៥០-៦០នាក់មកបង្ហើយត្រឹមនឹងហើយ ។

ដានី ៖ ម៉េចយួនតាមទាន់ត្រង់នឹង?

ភីន ៖ ទាន់ត្រង់នឹងទៀត គេហៅភូមិមួយ ប្អូនឯងដែលទៅផ្លូវនឹងស្គាល់គេហៅភូមិទាក់ធំម ជិតត្រដក់ពរ ភូមិនឹងជាប់ភ្នំវាយចាប ។

ដានី ៖ បាទ! ខ្ញុំឮត្រដកពរ វាយចាប ប៉ុន្តែភូមិមិន ។

ភីន ៖ អត់ដែលទៅដល់ទេ?

ដានី ៖ អត់ដែលទៅដល់ ។

ភីន ៖ ត្រដក់ពរ វាតាមៗមិនទាន់ទេ ទៅទាន់ភូមិទាក់ផ្អឹមនឹង តាមទាន់ ។

ដានី ៖ ជិតដល់ភ្នំវាយចាប?

ភីន ៖ បាទ!មនុស្ស៦០០០នាក់ទៅនៅក្នុងភូមិនឹង ។ មួយភូមិទេ នៅនឹងនៅរបៀបសម្រាកយកកម្លាំងយកអីទៅទៀតទេ ប៉ុននៅ៣ថ្ងៃៗ យួនទាន់ បង្ហើយពួកពិការនៅនឹង ។ ខ្ញុំអនោចអធម្មណាស់ ខ្ញុំរត់ចូលព្រៃរួច ។

ដានី ៖ ឃើញទៀត ពូកាលនឹងឃើញ?

ភីន ៖ ជាក់ស្ដែងនឹងភ្នែកមានកងទ័ពគេមួយក្រុមនៅយាមពីមុខភូមិ យាមប្រជាជនដែរ ។

ដានី ៖ កងទ័ពអីគេ?

ភីន ៖ កងទ័ពយើងខ្មែរក្រហមនឹងកាលនោះ យាមសម្រាប់មើលខ្លាចថាយួនអីវាមកទាន់ ។ ប៉ុនគេមក យួនវាចេះដែរ វាដើរក្នុងព្រៃ អ្នកយាមមើលមិនឃើញឯណា ស្រាប់តែយនចេញក្រោយអ្នកយាមនេះ ។ ចេញក្រោយអ្នកយាមវាមើលឃើញវាបាញ់ៗទៅគៀកភូមិបាត់ទៅហើយ អ្នកស្រុករត់ណាទាន់នោះ ប្រហែលនោះផ្លូវបំបែកក្រហមនេះ ។ ប៉ុននឹងបាត់ហើយបាញ់គ្នាកិល ។ យួនវាដឹងថាដល់ភូមិប្រជាជននៅហើយមានអីទៀត ។ អ! ប្អូនអើយវាបាញ់គ្រាប់បេវា មិនបាញ់ផ្ទុះដីទេ បាញ់ផ្ទុះលើមេឃទាំងអស់ គាត់សូវៀតកាលនោះអាក្រម៉ោងៗបេះគ្រាប់គេ ។

ដានី ៖ បាញ់ផ្ទុះលើ អំបែងបាច់?

ភីន ៖ បាញ់ផ្ទុះលើទាំងអស់ ។

ដានី ៖ ចុះអំបែង?

ភីន ៖ តែគាប់ជួនមួយភូមិអត់មានត្រូវអ្នកណាមួយដែរមនុស្ស ទាល់តែចេញផុតពីភូមិបានត្រូវ ។ ចេញផុតពីភូមិទៅបានប្រហែលជាកន្លះគីឡូជាង មនុស្សអ្នកពិការគ្មានអន់ហើយ ដើរលែងរួចហើយ ។ ហើយយួកក៏គេតាមទាន់ ព្រោះគេមានរថក្រោះអីផង ដេញកិន ។

ដានី ៖ ដេញកិនម៉ង?

ភីន ៖ បាទ! ចុះកណ្ដាលវាលចេះគ្មានស្អី ផ្លូវអាណានៅនឹងផ្លូវកិនផ្លូវ អ្នកណាចូលព្រៃកិនព្រៃទៅ ហើយខ្ញុំនឹកឃើញថារត់ផ្លូវវាមិនរួច ខ្ញុំវាកមកព្រៃៗរបោះៗរថក្រោះបរបានទៀត ។ យី! អញទៅណាចេះ ចូលអាព្រៃស្តុកមែនទែន អាព្រៃផៀតមែនទែន ចូលអានឹងរួចៗវាអត់តាម ។

ដានី ៖ ចូលតែម្នាក់លោកពូ?

ភីន ៖ ហ៊ា! ចូលគ្នាច្រើន ។ ដែលស្លាប់ៗនឹងពួកពិការទេ ។

ដានី ៖ ដែលធ្ងន់ធ្ងរ?

ភីន ៖ បាទ! ដែលគ្នាទៅណាមិនរួចសោះ ស្លាប់នឹងឯង អស់ៗផុតពូជហ្នឹងហើយ ។

ដានី ៖ យួនបើកកិនម៉ង?

ភីន ៖ បាទ! សល់ខ្ញុំប៉ុន្មាននាក់ដែលអាចដើររួចបានខ្លះនឹងសល់ ខ្ញុំហៅចូលព្រៃមករួចខ្លួនរហូតមកដល់ព្រំដែនមក អស់ហើយអស់អ្នកពិការចប់ប៉ុននឹងឯង ។

ដានី ៖ កាលជិតនាន់នឹងខ្ញុំធ្លាប់ជួប គាត់នៅខាងសំឡូត ឈ្មោះ ពូ កប ឥឡូវគាត់នៅវាលវែងដែលពូឈ្មោះគាត់ គាត់រត់ខាងនឹងដែរ រត់គាត់ពិការ ។

ភីន ៖ ទាបហើយខ្ពស់ កប?

ដានី ៖ ប្រពន្ធគាត់ឈ្មោះ នឹម ។

ភីន ៖ អ! ស្គាល់មិនអស់ទេ ប្អូន ។ ខ្ញុំមកផ្លូវនឹង ចេញពីទាក់ធ្នឹមនឹងទៅ គេហៅអូរក្រញ៉ូងៗទៅ ប៉ុនកន្លែងចេញពីទាក់ធ្នឹមនឹងទៅ កន្លែងវេទនាហើយណា ទឹកអត់មានផឹកទេ មួយយប់មួយថ្ងៃ រកទឹកផឹកមិនបានទេ ផឹកទឹកនោមប្រើសទេ ។

ដានី ៖ ផឹកទឹកនោមប្រើសម៉េច?

ភីន ៖ ប្រើសមាន ទឹកនោម កន្លែងវាដេកភក់ ដូចជ្រូក មានតែភក់អត់មានទឹក មាននោមវានឹងឯងទឹក ។ ផឹកដើម្បីរស់ទៅទៀតទៅ ។

ដានី ៖ ដល់ពេលរយៈពេលប៉ុន្មានទៅមកដល់ព្រំដែន?

ភីន ៖ ដើរបើគិតពីកន្លែងទាក់ធ្នឹម ចេញមកដេកផ្លូវ៣យប់ដល់តាសាញ ដល់នេះគេហៅភូមិកណ្ដាលៗនឹងវាជាប់ភូមិខ្មែរយើងហើយ ចប់ហើយ ។

ដានី :	ភូមិកណ្ដាលជួប?

ភីន :	អស់មានភូមិតទៅទៀតហើយ ។

ដានី :	ហ្នឹងនៅក្នុងណាទៅ?

ភីន :	ស្រុកសំឡូត ។

ដានី :	នៅស្រុកសំឡូត?

ភីន :	បាទ! ភូមិកណ្ដាលគេហៅអូររថក្រោះៗ ពួករថក្រោះបរដល់ត្រឹមហ្នឹងឯង ចប់នឹងអូរនឹងហើយ ។

ដានី :	មកដល់អូររថក្រោះ?

ភីន :	បាទ! ដល់អូររថក្រោះនឹងចប់ជាស្ថាពរ គ្រឿងចក្រគ្រឿងម៉ាស៊ីនអី ។

ដានី :	កាលនឹងមកជួបគ្នាច្រើនទេមកដល់ អូររថក្រោះ?

ភីន :	ជួបគ្នាច្រើនហើយអានឹងមូលគាំងពីណាពីណែមកជុំគ្នានៅនឹង ។

ដានី :	ប៉ុន្មានខែ បានមកដល់អូររថក្រោះ?

ភីន :	ហ៎! មិនដល់ខែទេ ដើរប៉ុន្មានថ្ងៃទេ ពីទាក់ធ្នឹមនឹងទៅដល់ហើយអូររថក្រោះនឹងពី៣-៤ថ្ងៃ

ដានី :	បាទ! យាងម៉េចទៀតទៅមកដល់អូររថក្រោះ?

ភីន :	ដល់អូររថក្រោះទៅយើងគិតគ្នាមក គ្មានស្អីទៀតបើដាច់អស់ហើយបើស្បៀងដាច់ស្អីក៏ដាច់អស់ រូតមកដល់ព្រំដែន ។ ប៉ុនដើមពីនឹងមក ពីភូមិកណ្ដាលមកដល់ព្រំដែន៨យប់៨ថ្ងៃ ។

ដានី :	ព្រំដែនណាទៅ?

ភីន :	ព្រំដែននៅម៉ាឡៃ-ប៉ៃលិនវិញ ។ គេឲ្យដើរមកនឹងវិញ គេអត់ឲ្យចលនៅព្រំដែនជិតនឹងទៀត ត្រង់នឹងជិតព្រំដែនហើយ មិនឆ្ងាយទេ ប៉ុនខ្ញុំនិយាយនេះហាក់ដូចមិនជឿ ប៉ុនគេឲ្យដើរបណ្ដោយស្ទឹងនឹងមកលើរហូត ។

ដានី :	ដើរមកលើមក?

ភីន :	មកភ្នំខៀវ ។ ប្អូនឯងដែលឮភ្នំខៀវ?

ដានី :	ភ្នំខៀវ ប៉ៃលិន ។

ភីន :	អឺ! ឡើងភ្នំ គ្រាន់ឡើងពីព្រឹកថ្ងៃត្រង់ដល់កំពូល ចុះពីកំពូលមក ពីម៉ោង១២ដល់ដីនេះម៉ោង៦ល្ងាច ។

ដានី :	ម៉េចបានគេឲ្យយើងដើរ ចាំបាច់ដើរឆ្លងកាត់តាមនឹង មិនឲ្យយើងចូលទៅព្រំដែន?

ភីន :	កន្លែងនឹង កន្លែងទាហានគេមានលាក់ការណ៍រឿងអីគេ យើងមិនដឹងទេ កាលនោះ ។

ដានី :	កាលនឹងដើរគ្នាច្រើន?

ភីន ៖ អឺ! រាប់ពាន់នាក់ ។

ដានី ៖ ពីព្រោះតាមខ្ញុំធ្លាប់ជួបពូម៉ង ពេលដែលយើងដើរឡើងភ្នំខៀវអីនឹងស្លាប់ច្រើនមែនទែន?

ភីន ៖ ស្លាប់ច្រើន អត់មានទឹកផឹក រស់ដំរី ។ ខ្ញុំសរសើរដំរីទល់សព្វថ្ងៃ មនុស្សរាប់ពាន់រស់ដោយសារដំរីទេ ។ ឡើងភ្នំខៀវ ឡើងរួចដំរីនាំផ្លូវឡើងរួច ដល់ពេលចុះវិញរកផ្លូវចុះមិនឃើញ វាចោទដាច់ទាំងអស់ ភ្នំខៀវនឹង រកផ្លូវចុះមិនឃើញដល់ម៉ោង១២អស់ទឹកផឹកមែនទែន ដំរីក៏វាស្រេចទឹកដែរ ដំរី៥ក្បាល ដែលនាំយើងរួចមនុស្សនឹង ។ ទាល់តែហ្មរដំរីក៏គាត់មិនដឹងធ្វើម៉េច ដំរីវាចង់ផ្លូវហើយ ក៏គាត់នឹកឃើញរឿងមួយ ដំរីវាចេះដើររកទឹកខ្លួនវា អត់បញ្ឆោវាទេ បណ្តោយឲ្យវាដើររកផ្លូវចុះខ្លួនវា ហើយខ្ញុំដើរក្រោយដំរីដើរមើល ៗ វាចុះផ្លូវណារួច ហើយបើសិនសុទ្ធតែថ្ម ហើយវាមានប្រឡោះមួយ ៗ ។ ចេះណាប្អូន វាទៅដល់ឈូសថ្មៗ ណាមិនទំនងវាឈូសមើល បើរឹងអាចចុះ បើមិនរឹងទេ វាឈូសទៅធ្លាក់ទៅវាអត់ចុះទេ ។ ទាល់តែទៅដល់កន្លែងមួយ ដែលវាត្រូវចុះបាន មានដើមអង្កត់ខ្មៅប៉ុននឹងមួយ វារសនៅអែបថ្មដុះអែបថ្មចេះដុំធំចឹងមក វាយកដៃវាទៅចាបអង្រួនដើមឈើ ។ អង្រួនទៅដើមឈើនឹងវារឹងអង្កត់ខ្មៅឫសវាវែង អង្រួនទៅវាអត់រង្គើរៗ វាយកក្បាលវាទល់ទៀត អានឹងចំរាក់ហើយនឹង ក្បាលទល់ក៏វាអត់រង្គើរ វាចុះសំរូតជើងចុះៗទៅរអិលរូសៗដៃវាបួងដាប់ដើមឈើ ហើយគូថវាទៅក្រោមបាត់វារអិលនោះទៅក្រោមបាត់ក្បាលមកលើវិញហើយ ទៅបួងដាប់ចឹង វាដឹងថាខ្លួនវារួចហើយ វាចុះសំរូតវាលែងដៃវានឹងពីដើមឈើរអិលម៉ង ហើយយើងមនុស្សម្នានឹង ដំរី៥វាទៅបណ្តោយគ្នាវាទៅយើងទៅពីក្រោម ។

ដានី ៖ គិតទៅចេះ ដំរី?

ភីន ៖ ចេះណ៎ាប្អូនដំរីធ្វើសង្គ្រាមមិនឆាយឆាប់ទេ ដំរីហើយសេះចេះ គោក្របីឆាប់ឆាប់ៗអស់ អត់មានអ្នកណាយកមកបានទេ បានដំរីហើយសេះបានដល់ព្រំដែន ។ វាចុះទៅផុតភ្នំនឹង បានដល់ទឹកដេកនៅនឹងម៉ង ដេញឲ្យវាទៅទៀត លែងទៅដែរ ហើយយើងក៏ដេកជាមួយវាមួយយប់នៅនឹងទៅ ។

ដានី ៖ វាអស់កម្លាំងវា?

ភីន ៖ អឺ! វាអស់កម្លាំងវាអត់ទឹក ទៅផុតពីនឹងទៅបានទៅដល់ព្រំដែនហើយ ។

ដានី ៖ មកដល់ខាង?

ភីន ៖ ដល់ដេកផ្លូវមួយយប់២យប់ មកដល់ប៉ៃលិនហើយ ។

ដានី ៖ មកដល់ប៉ៃលិន?

ភីន ៖ បានមកដល់ប៉ៃលិនយួនទាន់មិនយើង យួនមកដល់ប៉ៃលិនមុនយើង ។

ដានី ៖ ធ្វើម៉េចទៅចឹង?

ភីន ៖ បាញ់ផាប់មួយចំនួនទៅ បានយើងគេចចូលព្រំដែន ចូលទៅតាមភ្នំ ។

ដានី ៖ ទៅតាមភ្នំ?

ភីន ៖ បាទ! មិនមានមកតាមផ្លូវបានទេ យួនគេដល់នឹង ។

ដានី ៖ ចឹងយើងគេចមកខាងព្រំដែនវិញ?

ភីន ៖ បាទ!

ដានី ៖ មកព្រំដែនម្តុំណាទៅ?

ភីន ៖ ព្រំដែនយើងចូលដំបូងគេហៅបឹង បើដូចឥឡូវនៅប៉ៃលិនគេហៅបឹងព្រលិត មានបឹងព្រលិតទេ?

ដានី ៖ បាទ!មាន ។

ភីន ៖ អឺ! នឹងព្រលិតជិតព្រំដែន ខ្ញុំចូលម្តុំនឹង ចូលមកជួបទាហានជួបអីគេនៅនឹង គេឲ្យបាយឲ្យអីហូប យើងមកដាច់បាយហើយគេឲ្យគ្រង់ទង់ ឲ្យអង្ករឲ្យត្រីអីហូបរាប់ពាន់នាក់ហ្នឹងទៅរួចខ្លួនដល់ហើយចេញពីនឹងមកគេអត់ឲ្យនៅនឹងទេ ព្រោះកន្លែងនឹងថៃសម្លាប់មនុស្សយើងច្រើនដែរ ។

ដានី ៖ ថៃសម្លាប់ដែរ ម៉េចចឹង?

ភីន ៖ ខ្មែរយើងគៀសខ្លួនចូលទៅភ្នំ មានភ្នំមួយ ផ្លូវចូលទៅប៉ៃលិន ភ្នំស្រុកថៃ មិនមែនស្រុកយើង វាយកទៅចងដៃសម្លាប់ចោលអស់ អត់មានបាញ់ទេ ថៃ វាចងចឹង ។

ដានី ៖ ហេតុ ចងម្រាមដៃ?

ភីន ៖ មេដៃចងសរសៃរអំបោះឯងរើស្រែកទឹក រើដាច់បាញ់ចោល វ៉ៃចោល ។

ដានី ៖ ពូឃើញ?

ភីន ៖ ធម្មតា ទ័ពទេគេនិយាយប្រាប់យើង អត់ឲ្យយើងចូលកន្លែងនឹង ហើយយើងអត់ចូលកន្លែងនឹងរស់ទៅ ។

ដានី ៖ ម៉េចបានទៅចូលកន្លែងនឹង?

ភីន ៖ ចុះថៃកាលនឹងនៅទំនាស់គ្នាជាមួយខ្មែរយើង មិនយើងបាញ់យន្តហោះវាធ្លាក់មួយ វាមកលួចកាច់ត្បូងយើងនៅភ្នំយ៉ាត ហើយយើងមិនបាញ់ ត្បូងតាំងពីជំនាន់សម្តេច សីហនុនោះ អាណាដែលលក់ទៅណា ត្បូងប៉ុនកំភួនដៃនោះនឹង ។ ហើយថៃវាដឹងយក យន្តហោះមកកាច់យកនឹង ។

ដានី ៖ កន្លែងនៅលើភ្នំយ៉ាត?

ភីន ៖ ភ្នំយ៉ាត ហើយទ័ពនៅយាមនៅនឹងវាមិនទឹងវាបាញ់ធ្លាក់ជើងស្ទុបយន្តហោះវែៗ ។ ហើយគ្រាន់តែបាញ់ធ្លាក់ហើយប៉ុន្មានថ្ងៃ យើងបែកយួនចូលភ្នំពេញ ។

ដានី ៖ បាញ់បានយើងយកត្បូងវិញបានអត់?

ភីន ៖ អត់បានទេ អាត្បូងនឹងយកកន្ទុំយេទេ វាមកយកនោះ ។ ដល់ក្រោយឡើងនោះបានបាញ់ទេ ២ថ្ងៃក្រោយមក ។

ដានី ៖ ចឹងវាទឹងយើង ពេលយើងចូលទៅវាសម្លាប់?

ភីន ៖ ចូលទៅវាមានគំនុំ ថៃ ។

ដានី ៖ សម្លាប់អស់ច្រើន?

ភីន ៖ ហេ! អស់ច្រើន ទ័ពទាហានចូលទៅមើលទេ ប៉ុនយើងមិនឃើញភ្នែកយើងថាតែតាមគេដូច្នេះយើងមកតាមព្រំដែន ខ្ញុំមកដល់កំរៀងមករួចអស់មនុស្ស ។

ដានី ៖ ចឹងលោកពូអត់ចូលទៅក្នុងដីថៃ?

ភីន ៖ មិនទេ មិនចូលទេ ។

ដានី ៖ ដើរមកកំរៀងវិញ?

ភីន ៖ ទៅដល់ព្រំដែន បាទ! មកនៅកំរៀងមកនៅអូរដានឹងបានរាប់ហើយ មកអត់បាយអត់ទឹកហើយ ហូបតែត្រពាំង ហូបតែអីចឹងទៅ ។

ដានី ៖ អត់មានអង្ករ?

ភីន ៖ អត់ទេ! អង្ករគេដឹកឲ្យអត់ទាន់ទេ ។

ដានី ៖ ចឹងហើយហូបតែត្រពាំង ហើយអត់អីដែរ?

ភីន ៖ ងាប់មនុស្សឈឺងាប់ចង់ផុតពូជ ហូបត្រពាំងមិនដូចអីទេ ត្រពាំងហើម ។

ដានី ៖ យើងមានជាតិហើរ?

ភីន ៖ បាទ! ប៉ុន្តែចេះតែរស់ៗបានមកទៅ ទម្រាំដល់កាកបាទក្រហមជួយទាន់ ។

ដានី ៖ ជួយចាប់ផ្ដើមពីឆ្នាំណា?

ភីន ៖ ជួយមើលពី៧៩ខែប៉ុន្មានទេ ដូចខែភ្លៀងជោគជាំ ខែ៨ខែ៩គេជួយ ។

ដានី ៖ បានគេជួយទាន់?

ភីន ៖ បាទ! គេជួយទាន់ ។

ដានី ៖ ពេលនឹងលោកពូមកនៅខាងកំរៀងអូរដា?

ភីន ៖ នៅអូរដាហើយ នៅទល់មុខបន្ទាយឡែម គេនឹង ។

ដានី ៖ ដល់ពេលយ៉ាងម៉េចទៀតទៅ បន្ទាប់ពីពេលនឹងទៀត?

ភីន ៖ អានឹងយើងនៅបានមួយវស្សានឹង បានគេផ្លាស់កន្លែងពីនឹងមកនៅចំការដូង ម៉ាឡៃ ។

ដានី ៖ ចេញមកខាងម៉ាឡៃវិញ?

ភីន ៖ បាទ! ដើរតាមព្រំដែននឹងរហូត ។

ដានី ៖ ដើរតាមចំការដូង ដើរតាមដីថៃនឹង?

ភីន ៖ បាទ!

ដានី ៖ ដីថៃបានចូលមក?

ភីន ៖ អត់ទេ! អត់មានដើរដីគេទេ ដើរដីយើងរហូត ។

ដានី ៖ ប៉ុនក្រែងចំការដូងនៅខាងដីថៃតើ?

ភីន ៖ ចំការដូងដីថៃ គ្រាន់មានឈ្មោះ ។

ដានី ៖ យើងហៅដោយសារម៉ាឡៃ ទល់មុខចំការដូងថៃ?

ភីន ៖ បាទ! ហ្នឹងហើយទល់មុខចំការដូង ចំការចេក ។

ដានី ៖ មកដល់ម៉ាឡៃ?

ភីន ៖ មកដល់ម៉ាឡៃ ឈប់ត្រឹមនឹងហើយ គេធ្វើភូមិធ្វើដ្ឋានអីនៅនឹង ។ មកដល់មនុស្សនៅសល់ប៉ុន្មានរាប់ចង់ផុតពូជត្រង់នឹង វាហូបត្រពាំងហូបអី ហើយវាហេវហត់ ពីមុនមកមនុស្សបាក់កម្លាំង ។

ដានី ៖ បាទ! ឈឺផង មានគ្រុនចាញ់?

ភីន ៖ បាទ! គ្រុន សុទ្ធតែគ្រុន ស្លាបរកមនុស្សកប់មនុស្សមិនបានទេម្ដុំនឹង ។

ដានី ៖ កាលនឹងពិបាកមែនទែន?

ភីន ៖ ពិបាកមែនទែន ។

ដានី ៖ លោកពូអត់អីទេ អត់មានឈឺ មានអី?

ភីន ៖ ឈឺដូចគ្នា ប៉ុន្តែខ្ញុំចេះដោះស្រាយខ្លួនរួចចឹងម៉ង គេហូបត្រពាំងច្រើនខ្ញុំអត់ហូប ។

ដានី ៖ ពូហូបអីវិញ?

ភីន ៖ ខ្ញុំដើរជីកក្តួច ជីកដំឡូងហូបវិញ ។

ដានី ៖ ពូគិតថាហូបត្រពាំងច្រើនអត់កើត?

ភីន ៖ ស្លាប់អត់បានទេ ហើមម៉ង ឲ្យតែហូបហើមត្រពាំង ។ យើងហូបល្មមៗម្ដងម្កាល់អត់អី ប៉ុនដល់ហូបប្រចាំថ្ងៃអត់ទេ អត់បាន ។

ដានី ៖ ដល់ចឹង ដល់ពេលយើងមកនៅខាងម៉ាឡៃ៧៩?

ភីន ៖ ៧៩ ។ នៅ៧៩ចុងឆ្នាំហើយ ។

ដានី :	នៅធ្វើអីទៅនៅម៉ាឡៃ?

ភីន :	មិនធ្វើអីទេ ធ្វើតែផ្ទះខ្ទមៗនៅខ្លួនឯង ដើររកចិញ្ចឹមជីវិតខ្លួនឯងតែប៉ុននឹង គេមិនឲ្យធ្វើអីទៀត លែងប្រើធ្វើអីទាំងអស់ ម្នាក់ៗដោះស្រាយជីវិតខ្លួនឯងចឹងណា ។

ដានី :	ប៉ុន្តែគេកងទ័ពគេ?

ភីន :	កងទ័ពគេនៅមុខ កងទ័ពគេមានអង្គភាពគេដោះស្រាយគ្នាគេ ។

ដានី :	ដល់ពេលប្រជាជននៅខាងក្រោយនៅខ្ទមទៅ?

ភីន :	បាទ! ហ្នឹងហើយ នៅតាមអូរនឹងរហូតចឹងទៅ ។

ដានី :	នៅតាមអូរ?

ភីន :	បាទ!

ដានី :	ខាងដឹកជញ្ជូនអីអត់ទេ?

ភីន :	ដឹកជញ្ជូនគេនៅផ្សេងទេ យើងមិនមែនដឹកជញ្ជូនយើង ។

ដានី :	យើងប្រជាជនសុទ្ធ?

ភីន :	អឺ! ប្រជាជនយើងនៅផ្សេង ។

ដានី :	ស្គាល់តាចៀមដែរ?

ភីន :	អូ! ស្គាល់អាតានឹង ។ នៅឥឡូវ?

ដានី :	គាត់នៅម៉ាឡៃ ។

ភីន :	ហ៎! ធ្វើមេធំមិនស្រួល?

ដានី :	គាត់ឥឡូវគាត់រីត្រៃតហើយ កាលពីមុនគាត់ ។

ភីន :	ចាស់ហើយ គាត់បងខ្ញុំ ។

ដានី :	បាទ! គាត់អាយុ៦០ជាង ឥឡូវគាត់នៅធ្វើការងាររខាងបក្ស កាលមុនគាត់អភិបាលរងស្រុកម៉ាឡៃ ។

ភីន :	គាត់ជនជាតិ ប្រពន្ធគាត់ឈ្មោះ សឿន ។

ដានី :	ឈ្មោះ លី?

ភីន :	លីមួយទៀត អឺ!ប្រពន្ធតាចៀមឈ្មោះលី តែប្រពន្ធតាហុងបានឈ្មោះនេះ ។ តាហុងនៅនឹងដែរ?

ដានី :	បាទ! នៅនឹងដូចគ្នា ។

ភីន :	គ្នាគាត់ហើយ ពួកក្រសួងការបរទេស ។

ដានី :	ចឹងកាលនឹងលោកពូស្គាល់គាត់ច្បាស់ដែរ?

ភីន ៖ ស្គាល់ មកជួបគ្នានឹងឯង ពួកក្រសួងការបរទេសគេចេញតាមប៉ោយប៉ែត គេដើរតាមខ្សែនឹងមកវិញ ហើយខ្ញុំលេងកាត់ឯណាឯណានោះ ។

ដានី ៖ ទៅនៅនឹងបានរយៈពេលប៉ុន្មានដែរ?

ភីន ៖ នៅហ៎!ប្អូនដូចមួយវស្សានៅនឹង ខ្ញុំចាំបានត្រង់ថាដល់ពេលយើងបែកមកនេះទៀតមក វាខែវស្សា ខែយើង បើគិតពីគេដកស្ទូង១ហើយ១ ថៃឃើញសន្ទូងថៃបែកគុម្ពឡើងធំ១ហើយ គេស្ទូងហើយអស់ហើយ ប៉ុន្តែខ្មែរយើងគ្មានធ្វើអីទេ ។

ដានី ៖ ចឹងក្នុង៧៩ដដែល?

ភីន ៖ ៧៩ ក្នុងឆ្នាំ៨០ខែ ដូចខែ១១ខ្ញុំមកនេះ ។

ដានី ៖ ម៉េចបានលោកពូចេញពីម៉ាឡៃមកនៅនេះវិញ?

ភីន ៖ កាលនឹងគេត្រូវដែល កាលនឹងយួនមកនៅម៉ាឡៃហើយ មកនៅលើភ្នំនឹង យើងនៅលែងបាន យួនយកហើយ ម៉ាឡៃ ។

ដានី ៖ ដល់ពេលយួនចូលម៉ាឡៃ ប្រជាជនអីទៅណាវិញ?

ភីន ៖ ប្រជាជនចូលជំរំហើយពេលនោះ អ្នកដែលចូលជំរ គឺចូលជំរ ហើយខ្ញុំអត់ចូលជំរនឹងគេទេ ។

ដានី ៖ ជំរ៨៥មែនទេ?

ភីន ៖ ជំរនឹងគេហៅជំរំស្ទីទេគេហៅ អាប្អូនកាលនោះ ។

ដានី ៖ តា ង៉ុក?

ភីន ៖ មិនមែនទេ តា ង៉ុក ហួសមកហើយ គេហៅជំរអីមួយទៀត គេធ្វើក្រោយតា ង៉ុក នឹង ។

ដានី ៖ ដល់ពេលយួនចូល គេចូលជំរំ លោកពូអត់ចូលជំរំ?

ភីន ៖ អត់ចូលទេ មានមួយភាគអត់ចូល មួយភាគច្រើនគេអត់ចូល ។ អាមួយភាគអត់ចូលនឹងមួយចង់ទៅកោះកុង ព្រោះកោះកុងគេមិនទាន់ចូលជំរទេ ប៉ុន្តែបើទៅកោះកុងថៃដឹកវាគ្មានលុយពិបាក ។ ប៉ុន្តែមកនេះថៃដឹកដូចតែគ្នា ។

ដានី ៖ ថៃដឹកពី?

ភីន ៖ ពីភូមិដូងចុះមកនេះ មកចុះយើងប្រាប់យើងនេះ ខាងលិចជា ។

ដានី ៖ ខាងលិចជា?

ភីន ៖ បាទ! កាលនឹងមានកងទ័ពនៅនឹង គេដឹកយកមកដាក់នៅនឹង ។ យកមកប៉ុន្មានរយ៣០០-៤០០គ្រួសារកាលនឹង ។

ដានី ៖ ចុះលោកពូម៉េចបានអត់សម្រេចចិត្តនៅជំរំ?

ភីន : នឹកឃើញថានៅជំរំវាពិបាកកាលនោះ យើងមិនដែលដឹង មិនដឹងម៉េច គេនៅគេធ្វើអីយ៉ាង ម៉េច យើងមិនដឹងរឿង ប៉ុនអ្នកខ្លះចង់ទៅនៅ អ្នកខ្លះមិនចង់ទេ ។ ប៉ុនដល់ទៅនៅជំរំវា ស្រួលទៅវិញទៅ មានអង្គការអីគេចិញ្ចឹម ។ ប៉ុនគេមកនេះហើយ ក៏គេតាមចិញ្ចឹមដែរ ។

ដានី : ប៉ុន្តែមូលហេតុ គេនិយាយប្រាប់ថាម៉េចបានលោកពូគិតថា អត់ចង់នៅជំរំ ហើយចង់មក នៅប្រាច់?

ភីន : ទេ! ដំបូងចឹង យើងវិភាគខ្លួនយើង ជួនខុសជួនត្រូវដែរនឹង មិនដឹងថាទៅនៅជំរំបែបណា ហើយទៅនៅស្រុកគេវាជ្រៅ វានឹកឃើញអាស្រុកខ្លួនឯងនេះទៀត ទោះបីជាស្រុកកើត សង្គ្រាមម៉េចក៏នៅតែនឹកឃើញដែរ ។

ដានី : អត់ចង់បែកស្រុក?

ភីន : ពួកហ្នឹងយកខ្ញុំទៅអាមេរិច បើទៅអាមេរិច អត់ស្គាល់ប្អូនឯង ឡាន២-៣មកចំហរគូថចាំ យក ។

ដានី : មកចាំយកដែរ តែអត់ទៅ?

ភីន : អឺ! យើងមិនទៅ គេសួរយើងមិនបាច់ធ្វើទៃស្តធ្វើអីដូចឥឡូវនេះរាប់ខែរាប់ឆ្នាំអត់បានទៅ អត់អស់លុយទៀត ។

ដានី : ឆ្នាំណាហ្នឹង?

ភីន : អានឹង៧៩ ។

ដានី : ៧៩?

ភីន : អឺ! ចុងឆ្នាំ ។

ដានី : គេមិនបាច់ធ្វើទៃស្តគេឲ្យទៅ?

ភីន : មិនទេ ។

ដានី : ប៉ុន្តែកាលនឹងដោយសារទឹកចិត្តស្នេហាជាតិ ស្រឡាញ់ស្រុកទេសពេក?

ភីន : អ! អាប្អូនថា នឹកឃើញថា នឹកឃើញម៉ែ នឹកឃើញឪនឹកឃើញបងប្អូន ឯងទៅស្រុកគេ មិនដឹងយ៉ាងណាទេ ។

ដានី : អត់ទៅ?

ភីន : បើអ្នកនៅជាមួយខ្ញុំមួយចំនួនធំទៅអស់ ។ សួរទៀត ខ្ញុំទៅហើយណា អើ!ទៅៗ ស្រុក យើងពិបាកណាស់ ។ ធ្វើម៉េចដោះឲ្យរួចខ្លួន ឯងរួចបែបម៉េច អញរួចបែបម៉េចធ្វើតាមនឹង ចុះទៅឥឡូវនឹង វានៅអាមេរិចអស់ បារាំងអស់ ។

ដានី : កាលនឹងទាំងលោកពូ ទាំងប្រពន្ធអត់ចង់ទៅអាមេរិច?

ភីន ៖ អត់ៗ វាលើកសាកាដូយើងដាក់លើឡាន សុខចិត្តឲ្យលើកចុះវិញ មិនទៅទេៗ ហើយគេមិនបង្ខំយើងដែរ គេលើកដាក់ឲ្យយើងវិញមក យើងក៏មិនទៅៗ

ដានី ៖ ដល់ពេលចឹង លោកពូមកប្រាប់នឹងមក?

ភីន ៖ ដល់ចឹងយើងនៅភូមិដូងបាន២-៣ថ្ងៃទៀត មុននឹងវាយកនឹង នៅ២-៣ថ្ងៃទៅបានគេនឹកឃើញថា នៅនឹងវាលែងសុខហើយ យួនវានៅដល់ចំការចេកចំការអីនឹងៗ ស្គាល់ចំការចេកៗមុខម៉ាឡៃជិតដល់ព្រំដែនជិតព្រំដែន គេហៅ ភូមិចំការចេក បឹងត្រកួន ភូមិចំការចេក បឹងត្រកួនៗ បឹងត្រកួនជាប់ព្រំដែនម៉ង់ៗ

ដានី ៖ ខ្ញុំទៅដល់ ប្រហែលជាមិនចាំឈ្មោះអីលិតពេក ព្រោះខ្ញុំទៅៗ

ភីន ៖ ទៅតាមភូមិឥឡូវនេះៗ

ដានី ៖ ខ្ញុំអត់ដែលឃើញពីមុនមក ឃើញតែឥឡូវ តែប៉ុន្មានឆ្នាំៗ

ភីន ៖ ពីមុនព្រៃសុទ្ធ តែមានភូមិចាស់គេមួយៗ ៗ

ដានី ៖ ឥឡូវវាលស្រឡះសល់តែចំការ ៗ

ភីន ៖ ចឹង ពីមុនវាលតែស្រុកថៃ ដីយើងវាលព្រៃទាំងអស់ៗ

ដានី ៖ ឥឡូវផ្លូវតាមក្រវាត់ព្រំដែនធំចិនៗ

ភីន ៖ ចាក់កៅស៊ូនៅ?

ដានី ៖ អត់ទាន់ទេ ទើបបង្រាបៗ

ភីន ៖ ផ្លូវក្រហមនោះៗ

ដានី ៖ ប៉ុន្តែផ្លូវនឹងគេចាក់កៅស៊ូហើយ ប៉ុន្តែគេអត់ទាន់ចាក់ គេទើបធ្វើពង្រាបស្មើ តរហូតពីម៉ាឡៃតរហូតដល់ៗ

ភីន ៖ នៅស្រុកនឹងប៉ុន្មានខែពិបាកណាស់ប្អូន ពិបាកត្រង់បេះ ស្អីៗមានទាំងអស់ ប៉ុនពិបាកយើងដើរហើរពេលភ្លៀង យើងមិនសូវមានរបស់របរដើរហើយដូចឥឡូវ ពីមុនយើងដើរនឹងជើងមែនៗៗ ដើរបានលុះត្រាតែដើរពេលភ្លៀង តែពេលភ្លៀងហើយដើរលែងបានហើយជាប់ៗ

ដានី ៖ ស្អិតម៉ង?

ភីន ៖ ជាប់ដីប៉ុននេះដើរលែងរួចតែម្តងមនុស្ស លើកជើងលែងរួច អន្លុយបេះក៏អន្លុយអត់កើតៗ

ដានី ៖ ខ្ញុំបើកឡានម្តងហើយ ឥឡូវក៏ដោយៗ ឥឡូវនឹងបើកឡានឲ្យតែខែភ្លៀង បើកឡានជាប់ ដីស្អិតតែម៉ងៗ

ភីន ៖ បើកំពុងភ្លៀងប្អូនឯងធ្វើអីក៏បានដែរ ដើរទៅអត់ចេះដាប់ទេ យើងទប់អិលតិចតួច តែរាំងភ្លៀងហើយដីងឈបងក់ដែរ ឈប់រាំងភ្លៀងឈប់ដើរទៅលែងរួច ។ តែបើរាំងរហូតដល់ក្រៀមដីអានឹងទៅបានទៀត តែរាំងហើយនៅសើមមិនបាច់ទៅទេ ។

ដានី ៖ ហើយលោកពូបន្ទាប់ពីចេញពីភូមិដូងនឹងមក ថៃគេដឹកមក?

ភីន ៖ ថៃគេដឹក កាលនោះ ។

ដានី ៖ មកប៉ុន្មានគ្រួសារ?

ភីន ៖ មកកាលនឹងគេឲ្យមក៣០០គ្រួ(សារ) ។ ។

ដានី ៖ មកនៅដំបូងគេ?

ភីន ៖ មកនៅដំបូងគេនេះហើយ ស្រុកនេះគេអត់មានប្រជាជនរត់ឡើងមកទេ ។

ដានី ៖ កាលនឹងអត់មានមនុស្សទេ ដែលពូមកដំបូង?

ភីន ៖ បាទ! អត់មានទេ មានតែទាហានៗខ្មែរយើង យួនមិនទាន់មកដល់ទេ ។

ដានី ៖ កាលនឹងទាហានខាងណាគេ ដូចថាខាង?

ភីន ៖ ទាហានខាងខ្មែរយើងដែរ ។

ដានី ៖ ខាងខ្មែរ ប៉ុន្តែយើងខាងនោះ ដូចខាងតាគាត់នៅ?

ភីន ៖ អ! យើងនិយាយឲ្យខ្លីទៅទាហានខ្មែរក្រហម មិនមែនទេ យួននៅត្រឹមសៀមរាបនៅឡើយ យួនមិនទាន់ចេញមកព្រៃទេ មួយដូរនេះ ដែលយើងមកនៅនឹង ខ្ញុំមកនៅនឹងបានប៉ុន្មានឆ្នាំ ។

ដានី ៖ នៅប្រាបហ្នឹង?

ភីន ៖ ប្រាច់ គេហៅប្រាច់ ។ ប៉ុនដីយើង ប៉ុនប្រាច់នឹងហៅចំពោះភូមិថៃចំមុខប្រាច់អានឹង តែភូមិយើងនេះគេហៅស្អីទេ ក្នុងព្រៃ យើងមិនដឹងហៅស្អី ។

ដានី ៖ មកនៅនឹងបានរយៈពេលប៉ុន្មានទៅ?

ភីន ៖ ទៅនៅនឹងប៉ុនដល់ដូច២ឆ្នាំ ។

ដានី ៖ ២ឆ្នាំធ្វើអីខ្លះទៅ?

ភីន ៖ ហ៎! អត់ធ្វើអីទេ យើងធ្វើមួយហូបខ្លួនយើង ។

ដានី ៖ កាលនឹងលោកពូអត់មានទាក់ទងជាមួយខាងកងទ័ព?

ភីន ៖ គ្មានទេ យើងនៅភូមិ ប៉ុនយើងនៅជិតៗកងទ័ពនឹងឯង ប៉ុនកាលនោះគេមិនទាន់ប្រើយើងឲ្យធ្វើអីទេ គេនៅតែច្បាំងគ្នាគេ ។

ដានី ៖ លោកពូមានកូននៅកាលនោះ?

ភីន ៖ ដែលមកដល់នឹងមានហើយ មានមីបង ។

ដានី ៖ កាលនឹង គាត់នៅតូចមើលទៅ?

ភីន ៖ តូច មកដើរតាមភ្នំ ។

ដានី ៖ ពេលធ្វើដំណើរចឹងពិបាក?

ភីន ៖ ពិបាក ស្តាយតាមហើយអានឹង ។

ដានី ៖ ទៅណាមកណាស្តាយតាម?

ភីន ៖ បាទ! ពិបាកមែនទែនដល់ពេលឃួនគេមកនៅតាមព្រំដែន នៅតាមផ្លូវនេះ នៅផ្លូវអន្លង់វែងនៅ ប៉ុនគេមកនៅអាផ្លូវលំក្នុងព្រៃ ប៉ុនឥឡូវវាបាត់អស់ហើយផ្លូវ ។ នៅហ្នឹង យើងនៅលើភ្នំជួរភ្នំនឹងរហូតទៅ ។

ដានី ៖ យើងឡើងលើភ្នំនឹងចឹង?

ភីន ៖ បាទ! នៅដីយើងនេះ ។

ដានី ៖ ដីយើងលើភ្នំ?

ភីន ៖ ដីយើងត្រឹមណានៅនឹង នៅថៃគេមិនឲ្យនៅទេ ។

ដានី ៖ យើងធ្វើជាខ្ទមធ្វើជាអីនៅទៅ?

ភីន ៖ ធ្វើផ្ទះតូចៗចឹង ផ្ទះប៉ុនៗនឹង ធំជាងហ្នឹង តាមគេមានលទ្ធភាពធ្វើ ប៉ុនគេធ្វើឈើមូលសម្រាប់ធ្វើចោល ។

ដានី ៖ ចុះដល់ពេលអង្គរស្មីគេបើកឲ្យ?

ភីន ៖ គេខបត្តម្ពហើយកាលនោះ កាកបាទក្រហម ។

ដានី ៖ កាកបាទក្រហម?

ភីន ៖ បាទ! គេតាមជួយយើងហើយ ។

ដានី ៖ ឆ្នាំណាដែលលោកពូនៅលើភ្នំ?

ភីន ៖ ឆ្នាំ៧៩ ៨០ ៗខែ១ខ្ញុំនៅប្រាច់ទេ ហើយនៅប្រាច់បានប៉ុន្មានខែ បានយើងមកនៅតាមភ្នំចេះទៀត ។ កន្លែងដែលនៅមិនបានកន្លែងដែលឃួនវ៉ៃ គេឡើងមកវ៉ៃហើយនឹង ដឹងថាយើងមកនៅនឹង គេវ៉ៃតាមកន្លែងមួយៗរហូត ។

ដានី ៖ តែដល់ពេលយើងធ្វើផ្ទះនៅចឹង កងទ័ពនៅខាង?

ភីន ៖ កងទ័ពគេនៅមុខ យើងធ្វើនៅក្រោយ ។

ដានី ៖ កាលនឹងពេលមកដល់នៅនឹង ប្រហែលជាប៉ុន្មានគ្រួសារ?

ភីន ៖ ហ៎! យើងរាប់មិនអស់ទេ ច្រើនហើយ ។

ដានី ៖ ច្រើនហើយ?

ភីន ៖ បាទ! គេមកពីខាងភូមិភាគត្បូងសានមកដង មករួមគ្នាលើភ្នំដងរែកនឹងឯង ។ ភូមិភាគត្បូងសាន ឡើងមកនឹងទាំងអស់ អ្នកដែលគេមក អ្នកមិនមកគេមិនមកទេ ។

ដានី ៖ មកពីខាងត្បូងសាន?

ភីន ៖ ចឹងហើយបានកើតមានជនជាតិនៅតាមនេះ ពីមុនមិនមានទេនេះ ជនជាតិនោះ ដោយសារគាត់មកពីស្រុកចាស់គាត់ដែរ ។

ដានី ៖ ចឹងពេលនៅចេះ កាលនឹងកងទ័ពច្រើនកាលនឹង?

ភីន ៖ ច្រើន កងទ័ពយើងនៅទាំងអស់តើ មានទាន់វៃបាក់បែកគ្នាស្លាប់អីណាទេ នៅក្នុងនឹងទាំងអស់ ។

ដានី ៖ តា ម៉ុក គាត់ទទួលគ្រប់គ្រងខាងនឹង?

ភីន ៖ បាទ! មួយជួរនេះ គេបែកគ្នាផ្នែកៗរបស់គេ ។

ដានី ៖ គេបែកផ្នែក កាលនឹងដូចតា ម៉ុក ចាប់ពីត្រឹមណាទៅត្រឹមណា?

ភីន ៖ តា ម៉ុក ដូចតាំងពីព្រំដែនលាវមក កាលនោះ ។

ដានី ៖ ពីព្រំដែនលាវ គេហៅ១០០១?

ភីន ៖ ១០០១គេហៅ១០០១ ។

ដានី ៖ ពី១០០១មកដល់ខាងណាទៅ?

ឥភីន ៖ មកដល់ ទៅដបជិតទៅដល់ជិតប៉ោយប៉ែតនោះ មួយជួរខាងនេះប៉ោយប៉ែត ខ្ញុំអត់ស្គាល់អស់ទេខាងនឹង យើងចន្លោះ យើងអត់បានដើរ ។

ដានី ៖ បើ១០០១?

ភីន ៖ ១០០១មកនេះ ១០០១ដំបូងឡើងនៅលើនេះទេ នៅលើ តា ពក ទេ ។

ដានី ៖ កែ ពក?

ភីន ៖ បាទ! កែ ពក ប៉ុនគាត់ស្លាប់បាត់ ។ តែក្រោយមករួមគ្នាទាំងអស់ ។

ដានី ៖ ចុះបើខាងជួរម៉ាឡៃ ខាងកំរៀង ភ្នំព្រឹកអីនោះ?

ភីន ៖ ជួរម៉ាឡៃ កំរៀងខាងណាទេ ប៉ុនកាលនឹង អ៊ី ឈាន នៅនឹងដែរ ប៉ុន អ៊ី ឈាន មិនទាន់ទទួលរួមទេ កាលនោះ នៅតូចជាងគេទេ ប៉ុនមិនដឹងពីណាទេ តែខ្ញុំស្គាល់អត់អស់ទេខាងនឹង ។

ដានី ៖ ពូចេញពីនឹងយូរហើយ?

ភីន ៖ អឺ! ចេញមកយូរហើយ ដល់ពេលគេរៀបចំក្រោយមិនដឹងពីណា ។

ដានី ៖ ចឹងកាលនឹងនិយាយទៅកងទ័ពកាលនឹងច្រើន?

ភីន ៖ ចុះកងទ័ពយើង កងទ័ពប៉ុន្មានសែននៅទាំងអស់ យើងមិនទាន់ស្លាប់ទេ យួនវាវៃអីរបួសប៉ុន្មានអត់ទេ ។

ដានី ៖ ប៉ុន្តែនិយាយទៅកងទ័ពនៅនឹងច្រើនជាងកន្លែងផ្សេងៗទៀត?

ភីន ៖ បាទ! ចុះមក មានកន្លែងផ្សេងៗណា មករួមព្រំដែនអស់ហើយ ។

ដានី ៖ ខ្ញុំចង់និយាយថា បើខាងប៉ៃលិន ខាងម៉ាឡៃអី បើប្រៀបធៀបទៅកងទ័ពនេះច្រើនជាង?

ភីន ៖ អូ! យើងប្រៀបធៀបមិនជាងគ្នាទេ ប្អូន កាលនឹងគេបែងចែកប្រហាក់ប្រហែលគ្នាគេទេ ។

ដានី ៖ ប្រហាក់ប្រហែលគ្នាទេ?

ភីន ៖ បាទ! ការពារកន្លែងគេមួយៗនោះ គេមិនឲ្យលើសលួសគ្នាច្រើនទេ បើតំបន់ណាកន្លែងណាច្រើនជាងគេៗអាចដកហូតទៅបន្ថែមកន្លែងនេះ កន្លែងនោះដែរតើ ។

ដានី ៖ ចុះលោកពូ ពេលចាប់ផ្ដើមយើងមកនៅចឹង យើងចាប់ផ្ដើមរៀបចំជាធ្វើខបត្តម្ភកងទ័ពយើងជួយសហការណ៍ជាមួយកងទ័ពអីនៅ?

ភីន ៖ ពេលនោះ កងទ័ពគេស្បៀងដោយឡែង យើងខបត្ថម្ភតែខ្លួនយើងទៅ ប្រជាជន ខាងកាកបាទក្រហមគាត់ជួយខ្វះ យើងនៅតាមផ្ទះនឹងយើងក៏មិននៅទំនេរដែរ យើងនៅដាំស្រូវដាំអីហូបបន្ថែមអីនឹង តែគ្រាន់យើងមិនលក់ដូរអីទេ ចិញ្ចឹមសត្វពន្ធាត់ចែកគ្នាហូប ។

ដានី ៖ តែយើងចាប់ផ្ដើមជួយ ខ្ញុំចង់និយាយជួយនេះ ដូចជួយធ្វើការងារដូចជា ដូចក្នុងវិទ្យុខ្ញុំស្ដាប់យើងចាប់ផ្ដើមធ្វើចំរូង ដូចជាធ្វើរបស់របរធ្វើជា?

ភីន ៖ អានឹងដល់ក្រោយមក ឆ្នាំ៨២ ៨៣ ដែលកាលនឹងវៀតណាមគេវៃខ្លាំង យួនគេវៃតាមព្រំដែននឹង វៃៗឲ្យអស់អត់ឲ្យមានទេ វៃហើយដែនការធ្វើរបងស៊ីម៉ង់ទៀត អត់ឲ្យចុះរួចមនុស្ស ។ តែគាត់ក្រ គាត់ធ្វើទៅមិនរួច សុខចិត្តក-៥វិញ ប្រមូលមនុស្សខ្មែរយើងឲ្យមកស្លាប់នៅនេះ រឿងចឹង ។ ហើយកាលនឹងគេចាប់ផ្ដើមប្រើយើងហើយ ប្រើមិនធ្វើអីទេ ធ្វើចំរូងនឹង ។

ដានី ៖ ចាប់ផ្ដើមពីឆ្នាំណា?

ភីន ៖ ៨២ ៨៣មក ប្រើតិចៗមកហើយ ។

ដានី ៖ កាលនឹងយើងធ្វើចំរូង គេមានបង្រៀន គេបង្ហាត់អីឲ្យយើងធ្វើដែរអត់?

ភីន ៖ អឺ! ចំរូងល្ងង់អីចេះខ្លួនយើង គេបង្ហាញតិចមិនចេះខ្លួនឯង គេបង្ហាញដែរ មិនអត់ទេ បិទធ្វើអី យើងអ្នកនៅក្រោយយុទ្ធជននឹង គេឲ្យបិទចំរូងនឹង គេអ្នកយកចាក់ខ្លួនគេ ទាហាន ។

ដានី ៖ ចំរូងគេបិទពីឫស្សី?

ភីន ៖ បុស្សី ភ្នំយើងនឹង ។

ដានី ៖ ប៉ុន្តែកាលនឹងជនជាតិ បង្រៀនធ្វើ ឬក៏យ៉ាងម៉េច?

ភីន ៖ មិនទេ ខ្មែរគ្នាយើង ពេលនោះ ជនជាតិមិនទាន់មកដល់ទេ គេនៅ១០០១នោះ យើងនៅនោះដោយឡែកតែខ្មែរយើង ។

ដានី ៖ បើតាមខ្ញុំស្ដាប់តាមវិទ្យុ តាមឯកសារ ឮគេថាមានចំរូង មានដំរឆក់មានអី?

ភីន ៖ ដំរឆក់ អានឹងពិបាកប្រាប់ណាស់ អានឹងគេផ្សំគ្រឿងផ្សំទេ បានទៅជាដំរឆក់បាន ។ ប៉ុនដំរឆក់នេះ មិនមែនតែខ្មែរយើងទេឆ្ងល់ អាមេរិចកាំងឆ្ងល់ដែរ មកសួរ ប៉ុនសួរយើងប្រាប់ម៉េចកើត តែវាសួរវាធ្វើយកមកសម្លាប់មនុស្សដដែលកុំប្រាប់វា ។

ដានី ៖ តែប្រាប់ខ្ញុំៗទៅធ្វើអីកើត ។

ភីន ៖ ខ្មែរយើងគ្មានស្អី ខ្មែរយើងចេះហើយ មិនអត់ទេ មិនល្ងង់ទេ ហើយយើងសួរតែខ្មែរគ្នាយើងក៏ដឹងដែរ គេផ្សំពីពិសអាប្អូនអានឹង ។

ដានី ៖ ពិសពស់ ពិសអី?

ភីន ៖ បាទ! ឲ្យតែពិស ។

ដានី ៖ គេម៉េច គេដាក់?

ភីន ៖ គេស្ងួវា ស្ងោរដូចថ្នាំពេទ្យចិន អ! អ្នកស្ងោរហើមមុខហើមមាត់អស់ហើយ ។

ដានី ៖ អាចំហាយពិសវាមកប៉ះ?

ភីន ៖ អ្នកស្ងោរនឹងមានស្កុរ មានទឹកដោះគោឲ្យគាត់ហូបបានធ្វើបាន បើមិនចឹងទេ ងាប់ ផ្សែងវាហ៊ុយៗផ្សែង មុខហើមពុល ខ្លាំង ។

ដានី ៖ អានឹងគេយកពីពិសពស់មក មានពិសអីទៀត?

ភីន ៖ សត្វអីក៏ឲ្យដោយ ឲ្យតែពិសដាក់ទៅ ចឹងបានថាគេផ្សំគ្នា យកមកត្រាំទឹកមក ត្រាំហើយគេយកមកចំរាញ់ទេ ចំរាញយកជាតិការ ។ ប៉ុនអាគ្រឿងផ្សំវាវត្ថុធាតុវាសំខាន់ គេហៅមេដំរ ប្អូនឯងមិនស្គាល់ទេ ដើរមេដំរដុះតាមភ្នំ ដើមនឹងធំ ស្រាល ដូចដើមគរនឹងមិនខុសគ្នាសាច់វា ប៉ុន្តែវាមានសំបកក្រាសដូចកៅស៊ូចឹង កាប់ប៉ុសៗឈាមវាហូររូស ដំរវាសរដូចដំរកៅស៊ូចឹង អានឹងគេហៅមេដំរៗ គេសម្រាប់យកទៅផ្សំអានឹងហើយ ។

ដានី ៖ ហើយគេយកទៅដាក់នឹង?

ភីន ៖ ផ្សំហើយ យកទៅត្រាំជាមួយជាតិពិសជាតិអីនឹង យើងយកទៅចំរាញ់ យកទៅចំហ៊ុយដូចខ្ញុំថាចឹង រំងាស់វារហូតទៅដល់ការធ្វើថ្នាំពេទ្យចិនៗបានខ្ញុំថាហើមមុខ ហើមមាត់គ្នាអ្នកធ្វើជនជាតិទេ គេស្ទាត់ជំនាញខាងនឹង ។ ធ្វើហើយមួយឆ្នាំងខ្វះអី អីចំរាញ់ខាងនោះបាន

ប៉ុន្មាន មួយកែវនោះផង វាខះទៅណា ទៅជាកាក ។ ទៅជាកាកអានឹងហើយគេចែកកង ទ័ពគេដាក់ ក្នុងបំពង់ជ្រលក់ចុងព្រួញតិចៗទេ មើលមិនឃើញផង ចុងតិចៗចឹងឯង ឲ្យតែជាប់ខ្មៅតិច បានហើយ គេយកចាក់ៗ ហើយព្រួញនឹងទៀត គេមិនមែនចេះតែឲ្យយើងកាន់ចំរូងដាក់ ជ័រឆក់ទាំងអស់ទេ ផាប់ខ្លួនឯងៗ ប្អូនឯងកាន់១០០ទៅ ខ្ញុំកាន់១០០ទៅ រាប់ពេលដាក់ នឹងក៏រាប់ ពេលដោះមកវិញក៏រាប់ដែរ ។

ដានី : ដើម្បីចល័ត?

ភីន : កុំឲ្យបាត់ អានេះខ្លាំងជាងមីនទៅទៀត តែបាត់ណាមុតខ្លួនឯងមើលមិនជាដែលនឹង ។

ដានី : ចុះអានឹងបើមុត មើលអត់ជាគេ?

ភីន : មើលអត់ជាទេ តែបើនៅជិតគ្រូនឹង មើលបាន បើឆ្ងាយពីគ្រូហើយទៅហើយ ។

ដានី : អានឹងប៉ះតែតិច?

ភីន : ចូលតែតិច ជាប់ឈាម ប្រឡាក់ឈាមយើងនឹងអាចុងនឹង ចាប់ផ្ដើមស្ពួតកហើយ អត់មានទឹកមាត់លេបទេ ស្ពួតតែ៥-៣-៨នាទី ៥នាទីក្រោយមក ទៅហើយ ។

ដានី : ស្លាប់ហើយ?

ភីន : លេបទឹកមាត់ទៅអត់រួចគាំងបេះដូងមនុស្ស ។

ដានី : អានេះខ្លាំងជាងពិសពស់ទៀត?

ភីន : បាទ! មិនមែនដូចពិលពស់ទេ ពិសពស់រហូតដល់យើងស្លាប់នៅយើងលេបទឹកមាត់ អានេះអត់លេបកើតទេ ។

ដានី : រឹងកករម៊ង?

ភីន : បាទ! រឹងកករស្ដូបទៅហើយ ។

ដានី : ខ្លាំងណាស ពិសនឹង?

ភីន : បាទ!

ដានី : វាត្រូវអំបែងត្រូវអីវាអាច?

ភីន : អឺ! យើងស្លាប់នៅផឹកទឹកកើត អានេះផឹកទឹកមិនកើតទេ ស្លាប់ហាមាត់ជ្រុងហើយស្លាប់អានឹង ។

ដានី : ចឹងយើងយើងចាប់ផ្ដើមធ្វើនឹងតាំងពី៨២ ៨៣ មកយើងចាប់ផ្ដើមធ្វើ?

ភីន : ៨២ ៨៣យើងធ្វើតិចៗហើយ ព្រោះដែនការយួនគាត់វៃខ្លាំង វៃផ្ដាច់លែងឲ្យមានដែរខ្មែរយើង ប៉ុនចេះត្រដរនៅទៅ ។

ដានី : ចឹងនៅភូមិ លោកពូនៅខាងលើនឹងនៅរយៈពេលប៉ុន្មានទៅ បានយើង?

ភីន ៖ ភូមិ ហើយម៉េច?

ដានី ៖ បាទ! យើងនៅធ្វើនៅតាមផ្ទះតាមអី?

ភីន ៖ ឲ្យនៅរាប់ឆ្នាំ ប្អូនឯងមើល គិតទៅតាំងពី៨១មកៗយើងនៅនេះ ៨២ ៨៣យើងចេះតែទៅហ៎យ យួនវ៉ៃត្រង់ណាដកពីនឹងទៅនោះ វ៉ៃត្រង់នោះដកពីនោះទៅនោះ ។

ដានី ៖ យួនវាវ៉ៃពីក្រោមឡើងទៅលើវិញចេះ?

ភីន ៖ អឺ! យួនគេឡើងវ៉ៃលើ គេស៊ើបដឹងតែយើងនៅណាគេវ៉ៃទៅ ស៊ើបដឹងថាយើងនៅត្រង់គេវ៉ៃទៅ យើងទៅទៀត ។ អ្នកណាងាប់នៅនឹងទៅ អ្នកណារស់ទៅទៀតទៅ ។

ដានី ៖ យើងចេះចល័តនៅលើភ្នំនឹង?

ភីន ៖ ចល័ត នែក!ដាំបាយហូបហើយ សាក់កាដូចេះចងឆ្នាំងចងចានហើយ អត់មានទុកប្រហែលទេ កូនចៅអត់មានឲ្យដើរលេងទៅណាឆ្ងាយទេ ខ្លាចគេវ៉ៃគ្រិលទៅ ដឹងទៅណារកម៉ែរកឪលែងឃើញហើយ ប្រយ័ត្ន ។ ដល់ចឹងទៅវាទៅជាទម្លាប់ បាយតែហូបហើយចឹង ចងឆ្នាំងចងចានដាក់សាក់កាដូហើយទុកម៉ុំនៅស្ងៀម ។

ដានី ៖ គេវ៉ៃតែពេលថ្ងៃ ពេលយប់អត់អី?

ភីន ៖ យប់ក៏វ៉ៃ តាមលទ្ធភាពគេធ្វើទៅកើត ហើយយើងប្រយ័ត្នគ្រប់ពេលចឹងដែរ ដូចគ្នាប្រជាជនចេះតែគេចរួចចឹងទៅណា បើថាប្រហែលដូចយើងឥឡូវនេះងាប់ហើយ គេវ៉ៃងាប់ហើយ ។ អឺ! យួនវ៉ៃរកតែផ្ទះបាយ ក្រៅពីផ្ទះបាយមិនវ៉ៃទេ គេដឹងកន្លែងងាប់លឿនដែរនឹង ។

ដានី ៖ ម៉េចចឹង គេវ៉ៃផ្តាច់ស្បៀងយើង?

ភីន ៖ អឺ! ហើយយើងក៏ដឹង វ៉ៃគេដោយសារចឹងដូចគ្នា ផ្តាច់ស្បៀងដូចគ្នា ។

ដានី ៖ តែយួនវានៅអន្លង់វែងនឹង?

ភីន ៖ ដួរអន្លង់វែងនឹងរហូតតាមផ្លូវបារាំងចាស់ ។

ដានី ៖ ចុះមានទ័ពខ្មែរនៅជាមួយដែរ?

ភីន ៖ ហ៎! ខ្មែរមានហើយ ចុះខ្មែរកង០៩ កងអីនឹង កងសម្តេច ហន សែន ដឹងតាមមើល ០៩ខ្ញុំមិនស្គាល់ទេ ថាចាប់បានចាប់អីសួរថានៅ០៩ ។ ប៉ុន្មមួយដួរភ្នំដងរែកនេះ ដែលស្លាប់អនោចកងម្ទជាងគេនៅព្រះប្រឡាយ ។

ដានី ៖ នៅណាព្រះប្រឡាយ?

ភីន ៖ ព្រះប្រឡាយជាប់មុខត្រពាំងប្រាសាទ វ៉ៃឆ្នាំ៨៤ គាត់ត្រូវផ្តាច់ទាំងអស់ហើយ ។ ហើយវានៅរឹងខ្លាំងជាងគេនឹង មួយដួរនឹងអត់សូវរឹងទេទ័ពល្មមៗ នៅនោះប្រកដឹកជញ្ជូនចុះឡើង

កន្លែងនោះទ័ពច្រើន ហើយទីតាំងក៏រឹងមាំដែរ ។ ដូច្នេះ យួនគេវៃផ្តាច់នៅនឹង ៣០០០០ យួនមកវៃប្រកព្រះប្រឡាយ ។

ដានី : យួន៣០០០០នាក់?

ភីន : បាទ! ៣០០០០ ហើយខ្មែរក្រហមតិចមួយ រកមនុស្សមិនឃើញ ហើយដឹងថាវៃទប់គាត់បាន មិនមានបន្ទុំចិត្តទ័ពមានប៉ុន្មានចុះមកក្រោមហើយ ប្រជាជននៅលើភ្នំ ។

ដានី : ប្រជាជនស្លាប់ច្រើនដែរ?

ភីន : ប្រជាជនអត់ទេ ប្រជាជនគេរួច កាកបាទក្រហមគេយកទៅចិញ្ចឹមនៅដីថៃ នៅតទល់តែទាហានទេ ។

ដានី : ចុះពេលនឹង ឧបមាថាយើងចាប់បានទាហានយួនយើងយ៉ាងម៉េច?

ភីន : ហ៊ើ!ចាប់បានទាហានយួនឲ្យទៅទាំងអស់តើ នេះអាខ្លះឲ្យទៅអត់ទៅទេ ដឹងថានៅនេះស្រួលវាអត់ទៅទេ ។

ដានី : ឲ្យទៅណាវិញ?

ភីន : ឲ្យទៅស្រុកវិញអត់ទៅទេ ។

ដានី : យើង?

ភីន : បាទ! ចុងបញ្ចប់វៃឆ្នាំ៨៤ដែលវៃខ្លាំងដូចខ្ញុំថា យួនងាប់ពិបាកមើល អត់ទឹកផឹក ចុះវៃខែប្រាំង ហើយខ្មែរក្រហមវាតិច មានទៅវៃអីកើត មានតែវៃឡានដឹកទឹកនឹង វៃតែឡានដឹកទឹកគាត់ទេកាលនោះ ។ អត់មានវៃអីទេ ស្លាប់នឹងអត់ទឹកផឹក នៅតាមគល់ឬស្សី គល់ផ្គង់នឹងពូអើយល្អមើល ទាល់តែច្រើនពេល ហើយវាវង្វេងព្រៃ ។

ដានី : វាអត់ស្គាល់ភូមិសាស្ត្រ?

ភីន : បាទ! អត់ស្គាល់ ហើយដល់អត់ទឹកវាអត់ហ៊ានរត់ទេ សុខចិត្តដេកឈរងាប់អង្គុយងាប់ មិនត្រូវគ្រាប់ទេ ។

ដានី : ប៉ុន្តែបើយើងចាប់បាន យើង?

ភីន : ចាប់បានអត់មានសម្លាប់ទេ ថៃ ដែលក្រោយយើងចិញ្ចឹម ចាប់បានចិញ្ចឹមប្អូន ។

ដានី : ចិញ្ចឹមហើយយើងឲ្យទៅថៃ?

ភីន : ចិញ្ចឹមហើយយើងឲ្យទៅស្រុកៗមិនទៅទេ កម្ពុជាក្រោមអីនេះ អត់ទៅសោះ ។

ដានី : សុខចិត្តនៅជាមួយវិញ?

ភីន : បាទ!

ដានី : មានៗអ្នកដែលនៅរហូត?

ភីន ៖ មិនទេ មិននៅរហូតៗ ដល់ក្រោយមកដែលយើងពេលនឹងវាយ៉ាងម៉េចទេ ខ្ញុំមិនដឹង ហើយថៃគេទទួលយកទៅប្រទេសទីពា គេយកទៅប្រទេសទីពាទាំងអស់ៗ ប្រទេសទីពាអាច ទៅដល់អាមេរិចដល់អីៗ

ដានី ៖ យើងកាលនឹងខាងខ្មែរក្រហម យើងចាប់បានយើងប្រគល់ឲ្យថៃ?

ភីន ៖ អត់ប្រគល់ទេ យើងនៅចិញ្ចឹមខ្លួនយើងនឹងឯង ប៉ុនពេលដែលប្រគល់ចុងក្រោយនេះ ពួក នឹងសំណូមពរគាត់ៗចង់ទៅប្រទេសទីពា អត់ចង់ទៅប្រទេសដើមវិញហេ៎ៗ ហើយដូច្នេះ ធ្វើតាមសំណូមពររបស់គាត់ដែរនឹង ឲ្យទៅប្រទេសទីពាមានតែឲ្យទៅតាមថៃៗគេយកទៅ ហើយថៃគេមកយកទៅ ប៉ុនមិនដឹងគេយកទៅអាមេរិច នៅបារាំងយើងមិនដឹងៗ

ដានី ៖ ចឹងនៅដល់ប៉ុន្មានទៅ បានយើងចុះមកខាងក្រោម?

ភីន ៖ នៅដល់ចុះមកនេះៗ ដល់សមាហរណកម្មៗ

ដានី ៖ ចឹង?

ភីន ៖ អឺ! ចុះមក មុនសមាហរណកម្មនៅលើទាំងអស់ៗ

ដានី ៖ នៅលើទេចឹង?

ភីន ៖ បាទ! នៅលើទេៗ

ដានី ៖ ចុះតាៗគាត់នៅណាទៅ?

ភីន ៖ នៅលើជួរភ្នំនឹងដូចគ្នា ជាមួយគ្នាៗ

ដានី ៖ ចឹងកាលពីដំបូង ពីឆ្នាំ៨០ៗមានតែតាម៉ុកមួយនៅនឹង?

ភីន ៖ គេមិននៅមលគ្នាទេ គេបែកគា នៅតាមជួរព្រំដែនគេនៅ តាមមើលគេនៅគ្រប់គ្រងកន្លែង មួយ ប៉ុនខ្ញុំយល់មិនអស់ដែរទេៗ

ដានី ៖ ប៉ុន្តែលោកពូមកដំបូង ឃើញតែ តា ម៉ុក មួយ?

ភីន ៖ បាទ! នៅនេះគេឲ្យតា ម៉ុក មក ព្រោះតា ម៉ុក ដើរលឿនជាងគេ ប៉ុនរុកព្រៃអាតានឹង អ្នកស្រែៗ

ដានី ៖ គាត់ពូកែរុនព្រៃ?

ភីន ៖ អឺ! គេប្រើឲ្យមកនៅព្រៃហើយ គេអ្នកនៅក្រុងគេនៅកន្លែងល្អៗ

ដានី ៖ ប៉ុន្តែជើងគាត់ពិការ ជើងមួយចំហៀង?

ភីន ៖ ហេ៎! ពិការទើបមកពិការនៅកន្លែងព្រះប្រឡាយនេះទេ ពីមុនមកអត់ពិការទេៗ

ដានី ៖ ពីមុនមកអត់ទេ?

ភីន ៖ អត់ទេ គាត់ជើងជាល្អ ដើរលឿនណាស់តានេះៗ

ដានី :	គាត់ពូកែរុកព្រៃ?

ភីន :	គាត់ដំណើរគាត់ដំណើរក្អែកលោត ដើរលោតតើតៗ ហើយមនុស្សធំ ស ។

ដានី :	ហើយលោកពូស្គាល់គាត់ច្បាស់ដែរ?

ភីន :	ទេ! ខ្ញុំនៅនេះស្គាល់ ។

ដានី :	ស្គាល់ដោយសារទាក់ទងនិយាយលេងសើចហើយ?

ភីន :	ចុះយើងមកនៅនេះ ពីមុនយើងអត់ដែលស្គាល់ច្បាស់ ដល់មកនៅនេះ គាត់គ្រប់គ្រង នៅនេះ យើងស្គាល់ប្រជាជន យើងស្គាល់ បើគាត់ដើររុកតាមភូមិរាល់តែថ្ងៃ ។

ដានី :	គាត់ដូចថាមនុស្សរុះរាយ?

ភីន :	មនុស្សនឹងអត់ចេះខ្វាចទេ មិនគាត់មិនខ្វាចទេ មិនដឹងថាគាត់អាងអីដែរ ព្រោះធម្មតាអ្នកធំ គេលាក់គេពួក តានេះមិនលាក់ទេ ។

ដានី :	ចឹងដូចជាតាៗផ្សេងទៀត គាត់មកនៅនឹងឆ្នាំណា?

ភីន :	មិនទេ តាៗផ្សេងៗ គាត់ទើបមកឆ្នាំប៉ុនានក្រោយ មុនសមាហរណកម្ម ដូចមួយឆ្នាំ២ឆ្នាំ ។

ដានី :	ចុះពីមុនគាត់នៅណា?

ភីន :	នៅលិច ខ្ញុំអត់ដឹងដែរ នៅកោះកុងនៅប៉ៃលិនដែរមិនដឹងទេ ប៉ុនតាមមើលនៅ២កន្លែងនឹង ឯងនៅលិច ។

ដានី :	ចុះនៅខាងស្ទឹងគេ មានមន្ទីរមួយនៅខាងជប់គគីរមានដែរដឹង?

ភីន :	អឺ! អានឹងមកនៅមួយភ្លែតទេប្អូន គ្មាននៅយូរទេ នៅយូរនៅលិចទេ ។

ដានី :	នៅលិចនៅណាទៅ?

ភីន :	បើមិនកោះកុងដូចជាប៉ៃលិន បើថាយូរ ព្រោះតាៗ ខ្ញុំមិនដែលឃើញគាត់ទេ ទើបមក ឃើញគេមកនៅនេះទេ គាត់មកនៅនេះ ។

ដានី :	ចុះលោកដូចថាគេចាប់ផ្តើមមានជាឃ្លាំង មានជាផ្ទះអីនៅខាងក្រោម មានស្ពាន មានមន្ទីរ ពេទ្យអីចាប់ផ្តើមពីឆ្នាំណាទៅ?

ភន :	ស្ពានមន្ទីរពេទ្យនឹង ផ្ដើ៨០ប៉ុន្មានទេ មើលជិនាន់អ៊ុនតាក់ ហ៉ើ! ៩៣ៗផ្ដើពី៩២អីមក ព្រោះកាលនឹងយើងវ៉ៃបែកនេះវ៉ៃបែកអន្លង់វែង ។

ដានី :	បែកអន្លង់វែង វ៉ៃបែកពេលណា?

ភីន :	វ៉ៃបែកពេលឆ្នាំ ឃើ!មើលភ្លេចហើយ ៨៣ ៨៤ទេដឹង ។

ដានី :	៩០ៗ?

ភីន :	៩០អឺ! ខ្សែ អាច៨៨ ៨៩ ។

ដានី ៖ ៨៩ ពេលយួនដកចេញ?

ភីន ៖ ក្រោយពីវ៉ៃព្រះប្រឡាយធំមក យួនចាប់ផ្ដើមចេះរបៀបថាអន់ៗទៅហើយ ប៉ុន្តែមិនដឹងគេដកពេលណាៗខ្ញុំមិនដឹងទេ ទាល់តែនៅតែទាហានខ្មែរ ហើយយួនខ្លះ បានខ្មែរក្រហមវ៉ៃបែកៗចាប់ផ្ដើមវ៉ៃបែកពីបនាយនេះទៅមុន ពីប្រាច់ គេហៅថ្កាមរមាស ចាប់ផ្ដើមបែកដំបូងពីនឹងទៅៗ បែកថ្កាមរមាស នឹកឃើញថានៅមានបានហើយនឹងៗ

ដានី ៖ កាលពេលយើងវ៉ៃបែកពី៨៩អីនឹង យើងវ៉ៃបែកយើងចាប់ផ្ដើម?

ភីន ៖ ចាប់ផ្ដើមមនុស្សដែលចុះមកហើយ ដែលនៅលើភ្នំៗ

ដានី ៖ យើងចុះមក?

ភីន ៖ អឺ! ចុះមកនៅតាមកន្លែងមួយៗ ។

ដានី ៖ ចុះមកនៅតាមកន្លែងមួយៗ?

ភីន ៖ អឺ!យើងធ្វើកន្លែងនៅត្រង់ណាៗ ប៉ុន្តែមិននៅចំហផងទៀត កន្លែងវាលៗមិននៅទេ នៅក្នុងព្រៃៗ នៅពួនកន្ទុកកន្ទាក់ៗ

ដានី ៖ ចុះផ្លូវនេះមានតាំងពីពេលវ៉ៃបែក ហើយទើបពេលវ៉ៃបែកបានធ្វើ?

ភីន ៖ ប្អូនអើយ តា ម៉ុក ធ្វើទេ ផ្លូវនេះៗ

ដានី ៖ ផ្លូវចុះមក តា ម៉ុក ធ្វើទេ?

ភីន ៖ អឺ! គ្មានអ្នកណាធ្វើអត់ទេៗ

ដានី ៖ តា ម៉ុក ធ្វើឆ្នាំណា?

ភីន ៖ ធ្វើផ្លូវឆ្នាំវ៉ៃបែក មើលនិយាយឆ្នាំវ៉ៃបែកមិញ៨៨ ៨៩នឹងឯងៗ ឥឡូវផ្លូវនេះខ្ញុំកំណត់ថាវ៉ៃបែកអន្លង់វែងនេះឯងធ្វើផ្លូវនេះៗ បែកថ្ងៃនឹងធ្វើថ្ងៃនឹងៗ

ដានី ៖ បែកថ្ងៃនឹងធ្វើថ្ងៃនឹងបណ្ដោយ?

ភីន ៖ ឥឡូវខ្ញុំប្រាប់ ចាប់ផ្ដើមវ៉ៃបែក វ៉ៃលើដាំនេះ ដាំបន្ទាយយួន វ៉ៃរាប់ឆ្នាំអត់បែកទេ អស់គ្រាប់មិនដឹងប៉ុន្មានសិបតោនទេបនៗ ទាល់តែបែកចុចអាវំសេវធុងសាំងមួយប៉ុននេះ ដាក់មកធុងសាំងនឹងមួយវំសេវធុងអត់មានគ្រាប់អីទេ ចុះវ៉ៃគ្រាប់១២០វ៉ៃអត់បែកទេ ដី១គីឡូ៤ជ្រុងរលាយអស់ ព្រៃខ្ទេចអស់ ត្រង់សេរគេធ្វើមាំដែរយួនធ្វើគេសុទ្ធតែធ្វើចេះ ហើយលុបដីទៀត បើបាញ់ត្រូវចំម៉ឺងបានស្លាប់ បើមិនត្រូវទេ អត់ទៀតៗ វ៉ៃមិនបែកទាល់តែគេរកវិធីច្នៃធ្វើអានឹងគ្រាប់ៗ

ដានី ៖ យកមកដាក់នឹងម៉ឺង?

ភីន ៖ លួនអូសធុងសាំងយកមកដាក់នៅមុខបន្ទាយ លួនយប់ៗ

ដានី ៖ រំសេវនៅពេកយើងអូសរួច?

ភីន ៖ មិនទេ យកទៅធុងសាំងទទេរទេ ចុះរុន្ធវ៉ាប៉ុនល្មមលូកដៃរៀបកើត អត់ចុះចំហរទាំងអស់ទេ រៀប៣-៤យប់ ទម្រាំតែពេញ ធម្មតាលូនទៅដាក់ក្បែរបន្ទាយមិនទៅស្រួលណាទាហាន យាប់ដែរ ។ រំសេវបុប្ផាមិនដឹងប៉ុន្មានរយគ្រាប់ទេ ពេញអានឹងបានចុច នេះរណ្ដៅនឹងទើបលុបឥឡូវនេះ ពួកប៉ូលីសពួកអីវ៉ាធ្វើផ្ទះលើ កុំអីអត់លុបទេ ។

ដានី ៖ បើយើងចុចទៅ?

ភីន ៖ ចុចទៅកប់ស្លាប់ម៉ង ជិតពេល វ៉ារយាស់ទ្រូង រយាស់អីទៅស្លាប់ឯងម៉ង ។

ដានី ៖ វ៉ាពូខ្លាំង?

ភីន ៖ វ៉ាខ្ទរ រយាស់យកម៉ងនៅលែងបាន ។ ហើយកងទ័ពនៅនឹងដែលខ្ញុំដឹងឈ្មោះៗដូចពូក្រឹងៗនៅនឹងមេទាហាន មេវរៈគាត់នៅនឹង ឥឡូវនេះគាត់អាចនៅសៀមរាបនៅអី គាត់មិនស្លាប់ទេ មេស្លាប់ៗកូនទាហានរត់ៗនឹងបណ្ដោយ ។

ដានី ៖ គាត់មិនមាននៅក្នុងនឹងណា?

ភីន ៖ បាទ! វៃបែកពីនឹងមកដេញមកពីថ្កាមរមាសទៅអន្លង់វែង អន្លង់វែង បាញ់ចូលកាណុងមួយគ្រាប់ទៅៗបណ្ដោយចោលកាំភ្លើងទាំងអស់ បាញ់១០៥ចូលកាណុងភ្លក់ ។

ដានី ៖ ចូលភ្លក់ម៉ង?

ភីន ៖ អឺ! ចូលម៉ង គាត់ជំនាញណាស់អាមនុស្សនឹង ប៉ុនស្លាប់បាត់ទៅ ។

ដានី ៖ ដល់ចឹងពេលវៃបែកភ្លាមធ្វើផ្លូវភ្លាម?

ភីន ៖ ធ្វើភ្លាម បែកយប់នឹង ព្រលឹមឡើងមានអាត្រាក់ទ័រមកភ្លាម អាត្រាក់ទ័រនឹងធ្វើផ្លូវកើតណា ចុះពីលើភ្នំមកធ្វើមកដល់ក្រោមនឹង អាត្រាក់នឹងបាក់ដៃៗប៉ែលមួយតិចទេ ប៉ុនគ្រឿងបន្លាស់វ៉ាអត់មាន ចោលនឹងចោលទាំងថ្មី រហូតដល់ទាហានរដ្ឋាភិបាលយកលក់អេតចាយអស់ ។

ដានី ៖ ចឹងដូចថាយើងបានគ្រឿងចក្រមកពីពីណា?

ភីន ៖ ចិនឲ្យ ប៉ុនឲ្យយើងនៅលើភ្នំ យើងប្រើមិនកើត មិនមានកន្លែងប្រើ ។

ដានី ៖ ចឹងយើងមានគ្រឿងចក្រគ្រឿងអីសម្រាប់ធ្វើផ្លូវនឹង តាំងពីមុនវៃបែកនឹងទៅទៀត?

ភីន ៖ មាន ។

ដានី ៖ ដល់ពេលធ្វើនឹង កងទ័ពយើងធ្វើ ឬក៏មានអ្នកជំនាញអីពីខាងណាមកធ្វើ?

ភីន ៖ មិនមានទេ ពួកវិស្វកម្មកងទ័ពនឹងម៉ង ធ្វើអត់មានគេអ្នកជំនាញគេពីក្រៅមកទេ ខ្មែរគ្នាយើងសុទ្ធសាធ ។

ដានី ៖ ហើយចុះយើងចាប់ផ្ដើមធ្វើពីឆ្នាំ មិនដឹង៨៩ ឬក៏៩០អី?

ភីន ៖ អើ! យើងមិនកំណត់ច្បាស់បានៗ

ដានី ៖ ដល់ពេលយើងធ្វើផ្លូវ យើងចាក់ជាផ្លូវលំ ផ្លូវដីធម្មតាទេ?

ភីន ៖ ធ្វើឲ្យផ្លូវដី មានឡានចាក់ដីគ្រោះ អ!ដីក្រហម ដីសចាក់ដំបូង ចាក់បានមួយឆ្នាំ២ឆ្នាំ បាន ដាក់គ្រោះដែរៗ

ដានី ៖ ចឹងធ្វើបានរយៈពេលប៉ុន្មាន ពីលើភ្នំរហូតមកដល់អន្លង់វែង?

ភីន ៖ ពីខ្ញុំនិយាយពីដើមដំបូងចុះ បែកភ្លាមភ្លឺឡើងធ្វើពីលើភ្នំចុះដល់ជើងភ្នំ ហើយធ្វើពីជើងភ្នំដល់ អន្លង់វែងប៉ុន្មានថ្ងៃទៀត ធ្វើដល់គ្រាន់តែឈូសឲ្យឡានបរបានៗ

ដានី ៖ ឈូសឲ្យឡានបរបាន?

ភីន ៖ បាទ! ២ថ្ងៃទៅ៣ថ្ងៃប៉ុននឹងទេ ទៅដល់អន្លង់វែង តែមានកងគេធ្វើពីក្រោយទៀតៗ

ដានី ៖ ធ្វើកាលនឹងអត់ខ្វល់ចឹងទេ គ្រាន់មានផ្លូវ?

ភីន ៖ ទាបទេ ធ្វើទាប ស្មើយើងធ្វើបរបណ្ដោះអាសន្ន អត់មានផ្លូវទេ នោះផ្លូវយួនគាត់បរមាន នៅផ្លូវចាស់គាត់ក្រោយ បរកាត់ព្រៃឡានគាត់មកដល់ជើងភ្នំដូចគ្នា ប៉ុន្តែគាត់បររុកព្រៃទេ ដីទឹកអត់មានផ្លូវទេៗ

ដានី ៖ ចឹងធ្វើផ្លូវនេះពេលឆ្នាំ៩០ទេ ៨៩ ៩០?

ភីន ៖ បាទ!

ដានី ៖ ធ្វើទៅដល់អន្លង់វែង ទៅដល់កន្លែងស្ពានធ្វើពេលនឹងដែរ?

ភីន ៖ ទេ! ស្ពាននឹងធ្វើក្រោយមកទៀត មួយឆ្នាំ២ឆ្នាំក្រោយមកទៀតបានធ្វើៗ

ដានី ៖ កាលនឹងធ្វើទៅដល់កន្លែងនឹងធ្វើម៉េច?

ភីន ៖ ហ៊ឹ! ស្ពាននឹងធ្វើជំនាន់អ៊ុនតាក់ៗ អ!ធ្វើជំនាន់អ៊ុនតាក់ៗ

ដានី ៖ ចុះដំបូងយើងធ្វើម៉េចបានឆ្លង?

ភីន ៖ ដែលឈើ ស្ពានឈើៗ

ដានី ៖ ធ្វើស្ពានឈើ?

ភីន ៖ បាទ! យកឈើៗ

ដានី ៖ យកឈើមូលៗទៅដាក់?

ភីន ៖ បាទ! ធ្វើសសរធ្វើនេះឈើៗ

ដានី ៖ ដាក់ឆ្លងទៅៗ ចុះពេលនឹង ចាប់ផ្ដើមមកប្រជាជនអីចុះមកនៅខាងក្រោម?

ភីន ៖ ចុះមកនៅធ្វើតាមភូមិ គេរៀបចំតាមអង្គភាពៗភូមិមួយទៅៗ

ដានី : ចឹងចាប់ផ្ដើមកកើតភូមិ ពីឆ្នាំពេលចុះពេលបែកនឹង?

ភីន : ពេលចុះមក បាទ!កកើតយើងនៅនេះមួយភូមិចឹង ឧទាហរណ៍ថាដូចភូមិឈើភ្លុំចឹង ។

ដានី : ភូមិជើងភ្នំនេះមានឈ្មោះនេះតាំងពីអង្កាល់?

ភីន : ភូមិជើងភ្នំនេះ ដំបូងឡើយដែល តា ម៉ុក គាត់រៀបចំភូមិពិការទេសុទ្ធតែអ្នកពិការ គាត់ចិញ្ចឹមមួយកន្លែងនឹង ហើយវាជិតផ្លូវផង គេនៅជីកស្បៀង ជីកអាហារអីឲ្យ ។

ដានី : ចឹងភូមិជើងភ្នំកើតមុនគេ ហើយយ៉ាងម៉េច?

ភីន : បើតាមគិតទៅអានេះយើងមិនថាមុនទេ គិតទៅមិនអន្ទង់វែងទេ គេមុននោះ ភូមិចាស់ភូមិអីនោះ ប៉ុនភូមិនេះវាកើតបន្ទាប់មកហើយ ។

ដានី : ចឹងឈ្មោះភូមិជើងភ្នំ កើតពីឆ្នាំ?

ភីន : ៩០មកហ្នឹងឯង ពេលយើងចុះមក ។

ដានី : ចឹងភូមិជើងភ្នំកើតឆ្នាំ៩០មកនឹង ពេលយើងចុះមក?

ភីន : បាទ! យើងចុះមក ។

ដានី : ប៉ុន្ដែដំបូងគេហៅភូមិនឹងភូមិពិការទេ?

ភីន : ពិការទេ គាត់យកមនុស្សមកចិញ្ចឹមកន្លែងនេះ ។

ដានី : កាលនឹងពូមកនៅនឹងដំបូងគេដែរអត់?

ភីន : ហ៉េ! ខ្ញុំនៅហើយ ។

ដានី : នៅពីឆ្នាំ៩០មក?

ភីន : ហ្នឹងហើយ ។

ដានី : ហើយក៏មុននឹងទៀត?

ភីន : ហ៉េ! មិនទេ មុននឹងយើងនៅនោះ ។

ដានី : ចឹងឆ្នាំ៩០ចុះមក មានបង្កើតភូមិនឹងមួយឈ្មោះថាភូមិជេងភ្នំ តា ម៉ុក អ្នកបង្កើត?

ភីន : គាត់អ្នកដាក់ឈ្មោះ ចុះបើយើងមកនៅជើងភ្នំដាក់ចឹងទៅ មានឈ្មោះ ។ ខ្លះហៅភូមិពិការ ប៉ុនដល់យូរទៅវាបាត់អាឈ្មោះភូមិពិការនឹងទៅ ។

ដានី : ភូមិពិការ ឬភូមិជើងភ្នំ?

ភីន : ហ្នឹងហើយ ។

ដានី : ប៉ុន្ដែអ្នកនៅនឹងភាគច្រើនអ្នកពិការ?

ភីន : ចុះគាត់រៀបឲ្យពួកពិការនៅនឹង ប៉ុនដល់យូរទៅ អាអ្នកមិនពិការក៏វាស្រឡាញ់ដែរក៏នៅជាមួយគ្នាទៅ ។

ដានី ៖ ចុះកាលពីជំបូង ពីណាគេធ្វើប្រធានភូមិ លោកពូ ហើយមិនមែន?

ភីន ៖ ហ៎!ប្រធានភូមិគេទៅបាត់អស់ហើយ គេមានកង់ទ័ពមេៗដែលពិការចឹង ឥឡូវគេទៅស្រុកទៅស្រែ ។

ដានី ៖ ពីណាគេជំបូងដែលលោកពូស្គាល់ឈ្មោះគាត់?

ភីន ៖ ភ្លេចឈ្មោះគាត់ហើយ គេទៅស្រុកបាត់យូរទៅ យើងភ្លេចឈ្មោះគេទៅ ។

ដានី ៖ គាត់ទៅស្រុកវិញទៅ?

ភីន ៖ អឺ! ទៅស្រុកកាលនេះនឹង កាលសមាហរណកម្មនឹង ។

ដានី ៖ ចុះប្រធានភូមិបន្ទាប់មកទៀត?

ភីន ៖ ប្រធានភូមិបន្ទាប់មកទៀតស្លាប់ហើយ បន្ទាប់ពីពិការនឹង មកគាត់ស្លាប់ពស់ចឹក ។

ដានី ៖ ពីណាគេ?

ភីន ៖ ឈ្មោះ មុយ កាលនឹង ប៉ុនស្លាប់ហើយគ្នា ។

ដានី ៖ គាត់ស្លាប់?

ភីន ៖ បាទ! ពស់វាំ ។

ដានី ៖ ហើយបន្ទាប់មកទៀត?

ភីន ៖ បន្ទាប់មកទៀត លោក បរ៉ានេះ ឥឡូវនៅសព្វថ្ងៃហ្នឹងឯង ។

ដានី ៖ ពី៩៨មក?

ភីន ៖ បាទ! ហ្នឹងហើយ ។

ដានី ៖ ឈ្មោះ បូរ៉ា ចុះពូ អនុ?

ភីន ៖ ខ្ញុំធ្វើការនៅលើនេះទេ ប៉ុនខ្ញុំរស់នៅក្នុងភូមិនេះ ។

ដានី ៖ ឥឡូវនេះពូធ្វើការនៅលើ?

ភីន ៖ បាទ! លើភ្នំទេ ចឹងបានខ្ញុំនិយាយថា បើយកប្រជាជនយកមកសម្ភាសន៍ក៏មិនមានដែរ ភូមិលើនោះភូមិប្រជាជនចំរុះមកពីនេះពីនោះគាត់មិនដឹងពីប្រវត្តិនៅស្រុកនេះទេ ។

ដានី ៖ ចឹងពូប្រធានភូមិខាងលើទេ?

ភីន ៖ ខាងលើ ។

ដានី ៖ ប៉ុន្តែពូនៅភូមិនេះ ធ្វើប្រធាននៅខាងលើវិញ?

ភីន ៖ បាទ!

ដានី ៖ ម៉េចចឹង?

ភីន ៖ ហើយចុះមិនទាន់បានទៅនៅនោះ យើងធ្វើការទៅហើយមកផ្ទះវិញ ។

ដានី : ប្រធានភូមិខាងលើ ប្រធានភូមិអីគេ?

ភីន : ឥឡូវនេះភូមិមិនទាន់មានក្រឹត្យទេ ។

ដានី : ភូមិអត់ទាន់មាន?

ភីន : ហ៊េ! បង្កើតយូរហើយ៦ឆ្នាំ ។

ដានី : តែក្រសួងមហាផ្ទៃគេអត់ទាន់ទទួលស្គាល់?

ភីន : អឺ! ហ្នឹងហើយក្រសួងមហាផ្ទៃនឹងក៏យឺតណាស់ ល្មមឈប់ធ្វើ ។

ដានី : ភូមិលើនឹង ភូមិអីគេ ឈ្មោះអី?

ភីន : គេហៅ ឥឡូវខាងខេត្តខាងអីគេហៅភូមិដាំខាងលិច ដាំខាងកើតវិញទេ ។

ដានី : នៅខាងកាស៊ីណូនឹងម៉ង?

ភីន : អឺ! អាកាស៊ីណូនឹងដាំខាងលិច តែបើគេដាក់ពីមុនមកដែលយើងហៅគេហៅភូមិអូរថ្ម ។

ដានី : ពីណាមក?

ភីន : ពីត្រឹមកាស់ណូទៅលិច ហើយអូរក្រញ៉ូងនឹង ពីត្រឹមផ្លូវចាស់នឹងទៅកើតហៅភូមិអូរក្រញ៉ូង ប៉ុនមានតែឈ្មោះទេ តែក្រញ៉ូងអស់ហើយឥឡូវនេះ ។

ដានី : អស់ក្រញ៉ូងហើយឥឡូវ?

ភីន : អស់ហើយ ។

ដានី : ពូមានបានក្រញ៉ូងអីនឹងគេ?

ភីន : មិនទេ ខ្ញុំមិនអ្នករកក្រញ៉ូងនឹងគេ ។

ដានី : ប៉ុន្តែចឹងភូមិខាងលើនឹងទើបបង្កើតថ្មី?

ភីន : បង្កើត៦ឆ្នាំហើយ ។

ដានី : ៦ឆ្នាំហើយ?

ភីន : បាទ!

ដានី : ចុះពីមុនមក?

ភីន : ពីមុនដែលមិនមានដាក់ឈ្មោះភូមិទេ តែយើងនៅនឹងហើយ ។

ដានី : យើងនៅនឹងហើយ?

ភីន : បាទ! តែមិនមានដាក់ឈ្មោះទេ ដែលក្រោយសមាហរណកម្មមក ខាងរដ្ឋាភិបាលឲ្យបង្កើត ឈ្មោះភូមិឈ្មោះអីចឹងទៅ ព្រោះប្រជាជនច្រើន គាត់មកពីក្នុងៗមកនៅច្រើន ។

ដានី : ពូប្រធានភូមិអី?

ភីន : នៅអូរថ្ម ។

ដានី ៖ អូរថ្ម?

ភីន ៖ បាទ! ប៉ុនផ្លូវខាងខេត្តគេហៅជាំខាងលិចទៅវិញ ប៉ុនយើងមិនទាន់ហៅណាមួយច្បាស់ ព្រោះគេមិនទាន់ឲ្យក្រិត្យ ។

ដានី ៖ ប៉ុន្តែលោកពូមានផ្ទះមានអីនៅនោះ?

ភីន ៖ មិនមានទេ ខ្ញុំធ្វើនៅនេះ ។

ដានី ៖ មានដីមានអីហើយ?

ភីន ៖ ដីមានហើយត្រៀមធ្វើផ្ទះ ប៉ុនខាងក្រសួងគាត់មិនទាន់ឲ្យច្បាប់ចឹង ខ្ញុំក៏មិនទាន់ហ៊ានទៅដែរ ។

ដានី ៖ ប្រុងទៅនៅនោះវិញ ផ្ទះនៅនេះធ្វើម៉េចចឹង?

ភីន ៖ ផ្ទះនៅនេះទុកឲ្យកូនទៅ ។

ដានី ៖ ទៅនៅនោះវិញ ទៅនៅជិតកាស៊ីណូ?

ភីន ៖ អត់ចេះលេងទេ នៅជិត ។

ដានី ៖ ធ្វើម៉េចចឹង នៅជិតកាស៊ីណូអត់ចេះលេង រកស៊ីវិញ?

ភីន ៖ បានមើលគេ ទៅបន្ទំៗជាមួយប្អូនឯងគ្រាន់ហូបបាយ ។

ដានី ៖ ចឹងពេលចុះមកក្រោមទៀត ភូមិនេះ គេហៅភូមិពិការចាប់ពីឆ្នាំ៩០មក?

ភីន ៖ បាទ! ដំបូងឡើយពិការហើយ ។

ដានី ៖ តា ម៉ុក គាត់អ្នកបង្កើតឈ្មោះភូមិនឹងបណ្តោយដំបូងនឹងភូមិពិការ?

ភីន ៖ បាទ!

ដានី ៖ កាលនឹងមានអ្នកពិការប៉ុន្មានទៅ?

ភីន ៖ ហ៎! ជាប់៣០-៤០គ្រួ(សារ) ហើយប្រមូលពីកងទ័ព មកអត់ទាន់អស់ទៀត តែគ្រាន់ថារៀបភូមិឲ្យហើយគាត់ប្រមូលមកបណ្តើរៗ ។ អ្នកណាគេចង់មកនៅក៏មកៗ អ្នកណាមិនទាន់ចង់ទេ គេនៅតាមអង្គភាពគេ ។

ដានី ៖ កាលនឹងពូនៅភូមិនឹងម៉ង?

ភីន ៖ ខ្ញុំនៅភូមិនឹង ។

ដានី ៖ ហើយបន្ទាប់ពីបង្កើតភូមិហ្នឹង ភូមិណាគទៅទៀតទៅ?

ភីន ៖ ហ៎!ហ៎ ភូមិនឹងគេបង្កើត ដូចថាភូមិនេះមិនមុនគេទេ បន្ទាប់មកទៀត នោះគេបង្កើតអន្លង់វែង ភូមិថ្មាត ភូមិជប់ ភូមិស្រះឈូកនេះ មានត្រពាំងស្រះឈូកពីដើមមក គេដាក់ឈ្មោះភូមិស្រះឈូកចឹងទៅ ។

ដានី ៖ ប៉ុន្តែពីមុនមកអត់មានឈ្មោះទេ?

ភ់ន ៖ មិនមានទេ ។

ដានី ៖ ទើបឆ្នាំ៩០នឹងទេ?

ភីន ៖ បាទ! ទើបបង្កើតហៅភូមិស្រះឈូកចឹង ។

ដានី ៖ ដោយសារមានស្រះឈូកនៅនឹង?

ភីន ៖ បាទ! ស្រះឈូកនៅនឹង ស្រះឈូកយើងពីបរម្យបូរាណ ។

ដានី ៖ ប៉ុន្តែស្រះពីបរម្យបូរាណមក គ្មានមនុស្សរស់នៅទេ?

ភីន ៖ គ្មានទេ ។

ដានី ៖ ដោយសារមានដើមឈូកដុះអីក្នុងនឹងគេដាក់?

ភីន ៖ បាទ!

ដានី ៖ តាម៉ុកអ្នកបង្កើត ឬក៏ប្រជាជនយើង?

ភីន ៖ ហ៉េ! យើងអត់ហៅទេ គាត់គ្រាន់តែអ្នករៀបភូមិរៀបអីឲ្យ យើងដាក់ឈ្មោះខ្លួនយើងចឹងទៅ ។

ដានី ៖ យើងដាក់ឈ្មោះខ្លួនយើង ប៉ុន្តែភូមិនេះ តា ម៉ុក គាត់អ្នកហៅភូមិជើងភ្នំ?

ភីន ៖ ជើងភ្នំ ។

ដានី ៖ ហើយស្រះឈូកនេះ ប្រជាជនយើងអ្នកហៅនាំគ្នាហៅស្រះឈូកចឹងទៅ?

ភីន ៖ ហ្នឹងហើយ ភូមិអស់នេះ ដល់ពេលគេមានក្រិត្យ រដ្ឋាភិបាលគាត់ដាក់ឈ្មោះតាមនឹងទៅ ។ យើងហៅភូមិអីដាក់ភូមិនឹងទៅ ។

ដានី ៖ ចឹងភូមិទំនប់លើ ទួលត្បែងអីនឹង?

ភីន ៖ ទំនប់លើ កាលនោះវាមានទំនប់មួយនៅក្នុងព្រៃ ទប់យកទឹកដីកក៏ហៅទំនប់ចឹងទៅ ។

ដានី ៖ ទំនប់នឹងទប់តាំងពីអង្កាល់ ទំនប់?

ភីន ៖ ទំនប់នឹងវាមានដល់សព្វថ្ងៃហ្នឹង ប្អូនឯងទៅមើលទឹកឡើងគគ្រាំ ។

ដានី ៖ ប៉ុន្តែទំនប់នឹង មានតាំងពីអង្កាល់មក?

ភីន ៖ សម័យតាគាត់ធ្វើ តាម៉ុកគាត់ធ្វើ ទប់យកទឹកដីក ។

ដានី ៖ ទប់យកទឹកដីក?

ភីន ៖ ព្រោះក្រណាស់ក្រទឹក ។

ដានី ៖ ចឹងគេហៅភូមិទំនប់?

ភីន ៖ ភូមិទំនប់ចឹងទៅ ទំនប់លើមិនមែនទំនប់ដាច់បាត់ចឹងទេ ។

ដានី ៖ ទំនប់លើ ។ ចុះទួលត្បែង?

ភីន ៖ ទួលត្បែង វាគេហៅតាមឈ្មោះព្រៃទេ ។

ដានី ៖ ព្រៃមានទួលដើមត្បែង?

ភីន ៖ មានត្បែង ប្អូនឯងទៅមើលមិនទាន់ផុតពូជទេនៅ ទួលនឹងខ្ពស់ជាងគេ ត្រង់នឹង ហើយមានត្បែងដុះទៅគេហៅភូមិទួលត្បែងនឹងទៅ ។

ដានី ៖ ពីឆ្នាំ៩០នឹងដែរ?

ភីន ៖ អឺ! ដូចគ្នា ហើយអាភូមិជប់ខាងលិចនេះ ខាងលិចទួលត្បែងមានភូមិជប់មួយទៀត នៅឆ្ងាយពីផ្លូវ អានឹងវាមានទឹកចេញកន្លែងនឹង ហើយកើតឲ្យភូមិមួយទៅនៅនឹងទៅ ជប់ចេញត្រង់នឹង គេហៅភូមិជប់ទៅ ។

ដានី ៖ គេហៅទៅមិនមែន តា ម៉ុក គាត់អ្នកដាក់ឲ្យហៅ?

ភីន ៖ ទេ! យេ់ងអ្នកស្រុកអ្នកស្រែនឹងយើងអ្នកពិនិត្យខ្លួនយើង ។

ដានី ៖ ចុះដល់ពេលឃុំត្រពាំងប្រិយ៍ម៉េចទៅបានគេដាក់?

ភីន ៖ ត្រពាំងប្រិយ៍ មិនមានត្រពាំងប្រិយមួយប្អូនឯងបានទៅឃើញហើយនៅ ។ តែគ្រាន់ឃុំនេះមិននៅចំត្រពាំងនឹងទេ មកធ្វើទីតាំងនៅនឹងផ្លូវ ។ តាមពិតគេដាក់ឈ្មោះត្រពាំងប្រិយ៍នឹងនៅក្នុងត្រពាំងធំណាស់ ឥឡូវទៅមើលគេជីកឡើង ត្រពាំងបរម្បបូរាណដែរដូចគ្នា ។

ដានី ៖ ម៉េចបានឈ្មោះត្រពាំងនឹងចឹង?

ភីន ៖ ត្រពាំងដុះប្រិយ៍ ។

ដានី ៖ ត្រពាំងមានដើមឈើ?

ភីន ៖ ព្រៃដុះក្នុងនឹង ដូចកក់ប៉ុនវាធំៗ ។

ដានី ៖ អានឹងហៅដើមប្រិយ៍?

ភីន ៖ ប្រិយ៍ ។

ដានី ៖ ហៅត្រពាំងប្រិយ៍ទៅ?

ភីន ៖ ប្រិយ៍ ។

ដានី ៖ ទឹកជុំ?

ភីន ៖ ទឹកជុំហ្នឹង ទឹកព័ទ្ធជុំវិញ មានកោះប្រឡោះកណ្តាល គេហៅទឹកជុំ ។

ដានី ៖ ភូមិទឹកជុំនឹងម៉េចដែរ សុទ្ធតែប្រជាជនធម្មតា?

ភីន ៖ ប្រជាជនយើងធម្មតានឹង ។

ដានី ៖ ហ្នឹងភូមិទឹកជុំ ចុះភូមិផ្សេងៗទៀត គេបង្កើត គេដាក់ទៅតាម?

ភីន : បាទ! បង្កើតហៅទៅតាមផ្សារចឹងទៅ ។

ដានី : ប៉ុន្តែភូមិនឹងច្រើនបង្កើតឆ្នាំ៩០?

ភីន : ជាមួយគ្នាដែលយើងចុះមករួមគ្នា ដូចខ្ញុំថាគេនៅតាមអង្គភាពគេមួយៗចឹង គេបង្កើតតាម គេហៅម៉េចទៅហៅចឹង ។ ដល់រដ្ឋាភិបាលយើង គាត់ឲ្យក្រិត្យនឹងឈ្មោះភូមិចឹងបណ្ដោយ ។

ដានី : ចុះភូមិទួលកណ្ដាលអី?

ភីន : បាទ! ទួលកណ្ដាលនៅនេះ អាចេញពីអន្លង់វែងមកនេះ នៅនឹងផ្លូវឯងទួលកណ្ដាល ។

ដានី : ម៉េចបានដាក់ឈ្មោះទួលកណ្ដាល?

ភីន : ហេ៎! ទួលកណ្ដាលនឹងប្រវត្តិនឹង ដែលពីមុនភូមិទឹកជុំមួយ អាទួលកណាលនេះទើបបង្កើតនឹង មានក្រិត្យហើយ អានឹងខ្ញុំចាំមិនអស់ទេ ។ តែពីមុនតែភូមិទឹកជុំមួយទេ តែពីមុនមកតែភូមិ ទឹកជុំតែមួយទេ ។

ដានី : ចុះឃុំកណ្ដាល?

ភីន : ឃុំកណ្ដាលនឹង មានឃុំមែនត្រង់នឹង ។

ដានី : ឃុំអន្លង់មកហ្នឹង?

ភីន : ឃុំពីសម័យតាហ្នឹង គាត់ធ្វើដាក់ស្បៀងអាហារអីត្រង់នឹង ។

ដានី : ពីសម័យតាម៉ុក ប៉ុន្តែដូចថាឆ្នាំ៩០គេហៅឃុំកណ្ដាល?

ភីន : បាទ! ដាក់មកតែនឹងវាមានគេឃើញឃុំធ្វើអីត្រង់នឹងទៅ ។

ដានី : ឃុំពីអន្លង់មកតាំងពីឆ្នាំណា?

ភីន : ឃុំហ្នឹងពីយើងចុះមកជាមួយគ្នានឹងឯង ។

ដានី : ដល់ពេលគេដាក់ឃុំត្រង់នឹង ក៏ហៅភូមិឃុំកណ្ដាលនឹងទៅ?

ភីន : អឺ! ហៅឃុំកណ្ដាលចឹងទៅ ។

ដានី : ចឹងឃុំនឹងកើតពេលចុះមក ហើយភូមិនឹងក៏កើតពេលនឹងដែរ?

ភីន : អឺ! មានកើតមុនចុះណាកើត អត់ទេ ។

ដានី : ចុះភូមិបឹង?

ភីន : ភូមិបឹង វាបឹងនៅពីមុខ វាមិនដូចកោះ មិនដូចភូមិទឹកជុំ ភូមិបង់វាមានដីពយទៅក្នុងបឹង ហើយនៅមួយភូមិត្រង់នឹងគេហៅភូមិបឹង ។ ពីមុន៨០២នៅខាងលើនេះទេ ភូមិបឹងដាក់ យូរណាស់ហើយ ។

ដានី : ចុះភូមិសន្តិភាព?

ភីន : សន្តិភាពក៏គេដាក់ក្រោយដែរ ។

ដានី : ដាក់ក្រោយទេ?

ភីន : បាទ! ក្រោយទៀត ក្រោយដែលពេលសមាហរណកម្ម ដែលមានក្រិត្យនឹងៗគេដាក់ភូមិនឹង ។

ដានី : ពីមុនមកភូមិអី?

ភីន : ពីមុនមកគេហៅភូមិស្អីៗផ្សេងទៀតទេប្អូន មិនមែនគេហៅភូមិនឹងទេ ភូមិគេហៅតាមអន្តភាពគេនៅវិញកាលនោះពីមុន ។

ដានី : ភូមិទឹកជុំ ដូចថាមានទឹកចេញ?

ភីន : បាទ! មានទឹកជុំ ។

ដានី : ភូមិដើមភ្នំតាម៉ុកអ្នកបង្កើត?

ភីន : គាត់អ្នកហៅចឹងទៅ វានៅជិតភ្នំ ។

ដានី : ទំនប់លើដោយសារមានទំនប់ទប់ទឹក?

ភីន : មានទំនប់មួយ ។

ដានី : ទំនប់នឹងទប់មុនៗបង្កើតភូមិនឹងទៀត?

ភីន : មុនតិចទេ ពេលយើងចុះមកនឹង ទប់យកទឹកឲ្យប្រជាជនដឹក តែដល់ពេលរៀបចំភូមិនឹងដាក់ឈ្មោះភូមិនឹងចឹងទៅ ។

ដានី : ចុះភូមិទួលសាលា?

ភីន : ទួលសាលា មានសាលា ។

ដានី : សាលាមានពីអង្កាល់?

ភីន : សាលាមានសម័យយើងចុះមក ប៉ុនធ្វើសាលារៀនមុនគេ ត្រង់នឹង សាលារៀនក្មេងធ្វើថ្មប៉ុនសាលាសមគេរើចោលអស់ទេដឹង មានសាលារៀន ។

ដានី : ចាប់ផ្ដើមធ្វើសាលារៀនហ្នឹង ក៏ដាក់ឈ្មោះ ភូមិទួលសាលា?

ភីន : បាទ! ដាក់ទួលសាលាទៅ ។

ដានី : ហើយភូមិឯកភាព?

ភីន : ឯកភាពក៏ដាក់ក្រោយដែរ ដាក់សមាហរណកម្ម ។

ដានី : ដាក់សមាហរណកម្ម ក្រោយ៩៨ហើយទេ?

ភីន : បាទ!

ដានី : ពីមុនមកអត់មានទេ?

ភីន ៖ ពីមុនមកមានតាមឈ្មោះអង្គភាពគេនៅមួយៗទេ ហើយឈ្មោះអង្គភាពគេនឹងខ្ញុំក៏ភ្លេចអស់ យើងមិនដឹងអស់ ។

ដានី ៖ អូរក្រញូង អូរថ្ម?

ភីន ៖ អូរក្រញូង អាអូរថ្មនឹងថ្មសុទ្ធម៉ង អូរមិនមានដីទេ ។

ដានី ៖ ភូមិរបស់លោកពូ?

ភីន ៖ បាទ!ហើយអាភូមិអូរក្រញូង វាក្រញូងច្រើន មានទំនប់មួយសុទ្ធតែក្រញូង ប៉ុនឥឡូវនេះ មានតែឈ្មោះទេ ។

ដានី ៖ គល់អីអស់ហើយ?

ភីន ៖ អឺ! មិនសល់ទេ ។

ដានី ៖ ឫសអីក៏គ្មានដែរ?

ភីន ៖ បាទ! ឫសក៏គាស់ដែរ ។

ដានី ៖ គាស់អស់ម៉ង?

ភីន ៖ បាទ! ដូចគេស្រឡាញ់អាក្រញូងនឹងម៉ង ។

ដានី ៖ ចឹងលោកពូទាល់តែថៃឈ្មោះនឹង តែចឹងគេលែង គេអត់ឃើញក្រញូង?

ភីន ៖ ទេ! ថៃមិនថៃស្រេចរដ្ឋាភិបាលទេ ខ្ញុំចេះហៅចឹង តែរដ្ឋាភិបាលមានក្រិត្យមកហៅភូមិខុស នឹងវាបាត់ហើយ ។

ដានី ៖ ចុះឃុំផ្សេងៗទៀត ដូចខាងឃុំត្រពាំងតាវ ឃុំអន្លង់វែង?

ភីន ៖ ត្រពាំងតាវគេហៅចាស់ តាមចាស់ ពីជំនាន់សម្តេចសីហនុមកហើយ ។

ដានី ៖ មានត្រពាំងតាវ?

ភីន ៖ ភូមិត្រពាំងតាវមក មិនមែនឃុំទេពីមុន ឃុំត្រពាំងតាវចាស់នៅជិតភ្នំនេះតាមផ្លូវក្រហម គេដាក់ឈ្មោះឃុំ យកភូមិតែម៉ង ។ តែភូមិហ្នឹងនៅឈ្មោះភូមិត្រពាំងតាវដដែល ។

ដានី ៖ ចុះមានភូមិត្រពាំងតាវ ឃុំត្រពាំងតាវ ឃុំអរអង្ក្រែ អានឹងភូមិគេបង្កើតក្រោយ?

ភីន ៖ អូរអង្ក្រែគេហៅតាមអូរ អូរនឹងមានឈ្មោះអូរអង្ក្រែមួយ ហៅតាមឈ្មោះអូរនេះទៀត មានដល់អូរត្បាល់ទៀត ប៉ុនគេអត់ហៅអូរត្បាល់នឹង គេហៅតែអូរអង្ក្រែ ។

ដានី ៖ ចុះអូរស្វាយអី?

ភីន ៖ អូរស្វាយមានដើមស្វាយចាស់បរមបូរាណ គេហៅអូរស្វាយ ។

ដានី ៖ អានឹងភូមិគេពីដើមមកហើយក៏?

ភីន ៖ អាអូរស្វាយហ្នឹង ក្បាលអូរស្វាយៗ វាមានដើមស្វាយ ដូចអន្លង់វែងចឹង ហើយស្វាយមិនមែនស្វាយល្អទេ ស្វាយចេកនោះ ។

ដានី ៖ ស្វាយចេកម៉េច?

ភីន ៖ ស្វាយចេកស្វាយផ្លែតូចៗដូចស្វាយព្រៃចឹង មានតែគ្រាប់អត់មានសាច់ទេ សាច់តិចៗ ។

ដានី ៖ ចុះបើនៅអន្លង់វែង?

ភីន ៖ អន្លង់វែង អន្លង់កន្លែងនឹងវែងណាស់កន្លែងនឹងអត់ចេះខះទឹកទេ គេដាក់អន្លង់វែងតាំងពីដើមមកចឹង ។

ដានី ៖ ពីដើមមកមានភូមិមានអីគេតាំងពីជំនាន់សម្តេច?

ភីន ៖ មានភូមិចាស់គេ ជំនាន់សម្តេចមុននឹងទៀតដឹង យើងក្មេងដែរ ប៉ុនមានតាំងពីនឹងមកហើយ ។ ដើមស្វាយគាត់នៅៗដើមស្វាយចាស់១០-២០ដើមឥឡូវនឹង សុទ្ធស្វាយចេកនៅកន្លែងសាលាស្រុក ប្អូនឯងមើល ។

ដានី ៖ អានឹងមានភូមិគេពីដើមមក?

ភីន ៖ បាទ! ពូដើមហើយអ្នកភូមិចាស់មិនហ៊ាននៅទេ រត់ទៅថៃអស់ហើយ ។

ដានី ៖ កាលនឹងពីដើមមកអន្លង់វែងមកមិនមែនជាស្រុកទេ គ្រាន់តែភូមិអី?

ភីន ៖ ទេ! គេហៅស្រុកតាំងពីជំនាន់សម្តេចសីហនុមកណា៎ ដាក់ស្រុក ។

ដានី ៖ ស្រុកអន្លង់វែង?

ភីន ៖ បាទ! ស្រុកអន្លង់វែង ប៉ុនអត់មានមនុស្សនៅទេ ។

ដានី ៖ អត់មានមនុស្សនៅទេ?

ភីន ៖ មនុស្សគាត់ឲ្យមកនៅ ឲ្យគោ ឲ្យក្របី ឲ្យផ្ទះ មកនៅនឹងបានប៉ុន្មានថ្ងៃរត់ទៅផ្ទះវិញអស់ហើយ អត់ចេះនៅក្នុងព្រៃ ។ ចុះបើទៅផ្សារសៀមរាបនោះដេកផ្លូវមួយអាទិត្យបានដល់ហើយគាត់អត់នៅទេ ចុះបរទេះគោពីសម័យនឹង ។ នៅតែពួកខិលខូចមួយចំនួនទាក់ទងថៃក្រៅច្បាប់ក្រៅអី រកស៊ីព្រំដែន សុទ្ធតែពួកលោកឆ័ត្រ ពួកនឹងឯងនៅបាន ។

ដានី ៖ ហើយមានថៃក្រហមថៃអីនឹងគេមកនៅ?

ភីន ៖ ហ៊ឺ! អាថៃក្រហមដល់ក្រោយទេមាន ។

ដានី ៖ មានក្រោយទៀតទេ?

ភីន ៖ អឺ! ពីដើមពីដែកក៏មិនមានថៃក្រហមណាដែរ យើងមិនដឹង ។

ដានី ៖ មានប៉ុន្មានឃុំស្រុកអន្លង់វែងនេះ?

ភីន ៖ ៥ ។

ដានី ៈ មានឃុំត្រពាំងប្រិយ៍ ឃុំត្រពាំងតាវ?

ភីន ៈ លំទង, ថ្លាត, ហើយឃុំអន្លង់វែងម៉ង ។

ដានី ៈ ឃុំថ្លាតអីនឹងសុទ្ធតែបង្កើតក្រោយ?

ភីន ៈ ឃុំថ្លាតនឹងគេបង្កើតមានក្រឹត្យនឹង ឃុំថ្លាតអត់មានប្រវត្តិអីពីយូរមកទេ ។

ដានី ៈ បង្កើតក្រោយឈ្មោះ ថ្លាត ម៉េចបានដាក់?

ភីន ៈ ឃុំលំទងនឹង គេហៅតាមភូមិលំទងចាស់ មានយូរហើយ ។

ដានី ៈ ប៉ុនគ្រាន់គេបង្កើតភូមិថែមទៀត?

ភីន ៈ បាទ! បង្កើតឃុំ ហៅឈ្មោះឃុំក្នុងភូមិនឹងម៉ង ។

ដានី ៈ ឃុំលំទង?

ភីន ៈ បាទ!

ដានី ៈ បើថ្លាតនេះ ក្រោយទេ?

ភីន ៈ ថ្លាតនេះ បង្កើតក្រោយខ្ញុំមិនដឹងថាគេហៅសារបែបម៉េចអានឹងខ្ញុំអត់ដឹង ឃុំនឹងមួយ ។

ដានី ៈ ចុះលោកពូដូចទាក់ទងពីរឿងឃ្លាំង ពីរឿងផ្ទះអីនឹង ចាប់ផ្តើមកើតពីអន្លក់មក ដូចរោងចក្រ រោងអីនោះ?

ភីន ៈ រោងចក្រអាឈើអីធ្វើផ្ទះឡកង់ទ័ព គ្រួសារទាហានដែលប្តីគេទៅមុខបាត់ទៅ នៅប្រពន្ធគេក្រោយ គាត់រាប់រងជួយចឹង ។ ហើយជួយនឹងការអោរនឹងដៃនឹងជួយមិនទាន់ទេ មនុស្សវាច្រើន ទាល់តែមានរោងចក្រ ។

ដានី ៈ រោងចក្រនៅកន្លែងណា?

ភីន ៈ រោងចក្រនៅវត្តសព្វថ្ងៃនឹង ប្អូនឯងទៅមើលនៅមានកស្តុតាងមួយចំនួនសសរអីនៅ សសរនៅតែមួយទេ គេកាត់យកធ្វើអីអស់ ។

ដានី ៈ រោងចក្រនឹងធំ?

ភីន ៈ រោងចក្រនៅស្រុកថៃមានតែ២ទេប្អូន លក់មកឲ្យខ្មែរមួយ នៅស្រុកគេមួយ នៅភូមា ទល់ដែនភូមា ។ ធណាស់រោងចក្រនេះ តម្លៃវា៣០-៤០លានបាត មិនថោកទេ ។

ដានី ៈ ៣០-៤០លានបាត?

ភីន ៈ បាទ!

ដានី ៈ ១លានដុល្លា ។

ភីន :	ហើយយើងចុះមកនេះ រដ្ឋាភិបាលយើងសមាហរណកម្មនៅល្អទាំងអស់ ប៉ុនទាហានរដ្ឋាភិបាលយកលក់អេតចាយទាំងអស់ រោងចក្រមួយនេះ អត់មានធ្វើអីយកទៅណាកើតទេ ព្រោះដែកវាធំៗណាស់ មិនដឹងយកធ្វើអី មានតែលក់ឲ្យអេតចាយ ។

ដានី :	បាទ! ចឹងឈើដូចថា យើងកាប់មកយកមកអារ?

ភីន :	អារនឹង ។

ដានី :	អារជរៀក ហើយបានយើង?

ភីន :	បានចែកតាមកងទៅធ្វើផ្ទះឲ្យប្រពន្ធឲ្យកូនគេទៅ ។

ដានី :	កើតពីឆ្នាំណា បើតាមពូចាំ?

ភីន :	ទេ! បើតាមឲ្យខ្ញុំដឹងច្បាស់មែនទែន ភ្លេចហើយប្អូន ប៉ុនមួយក្នុងអំឡុងកើតនឹង កើតមកមួយពេលយើងចុះ ប៉ុនក្រោយចុះមកអត់ទាន់មានទេ ។

ដានី :	យើងសន្មតថាចុះមកឆ្នាំ៩០ ចុះមកបានប៉ុន្មានឆ្នាំ?

ភីន :	បាទ! ហ្នឹងហើយ ២ឆ្នាំក្រោយមកដឹង ។ ខ្ញុំដឹងមិនច្បាស់ទេ គាត់រៀបរយបង្កើតអានឹងហើយ ព្រោះដែលកងទ័ពខ្វះខាតរឿងផ្ទះសម្បែង ។

ដានី :	ចឹងពូមានចាំអ្នកដែលគាត់ធ្លាប់ធ្វើប្រធាននៅកន្លែងរោងចក្រអារឈើនឹងនៅរស់ដែរ?

ភីន :	ទេ! ពីមុនគេមាននេះគេតើ ប្អូនឯងសួរពីម្សិលនឹង សម្លាស់ហើយៗ ពូហម នឹង ។

ដានី :	ពូហម គាត់ធ្វើប្រធាននៅនឹង?

ភីន :	នៅនឹង ។

ដានី :	ពូហម គាត់ធ្វើប្រធានភូមិស្រះឈូកនឹង?

ភីន :	ប្រធានភូមិស្រះឈូកនឹង គាត់នៅរោងចក្រនឹងពីអើយរបស់គាត់ តែគេរៀបចំអ្នកណាបន្ទាប់ៗមកទៀតខ្ញុំមិនដឹងច្បាស់ទេ ខ្ញុំស្គាល់ម្នាក់នឹង ។

ដានី :	ចុះដូចលោកពូថានៅឃ្លាំង នៅកាន់ឃ្លាំងនឹងចាប់ពីឆ្នាំណាមក?

ភីន :	ពីយើងចុះមកពីលើដែរ ។

ដានី :	ពីឆ្នាំ៩០នឹង?

ភីន :	បាទ!

ដានី :	ឃ្លាំងរបស់លោកពូគេហៅឃ្លាំងអីគេ?

ភីន :	គេហៅឃ្លាំងជើងភ្នំចឹងម៉ង ។

ដានី :	គេហៅឃ្លាំងជើងភ្នំ?

ភីន :	ធម្មតាគេហៅឈ្មោះខ្ញុំម៉ង មិនដឹងគេដាក់ឈ្មោះអី គេហៅឈ្មោះខ្ញុំ ។

ដានី ៈ យ៉ាំងដើងភ្នំឈ្មោះយ៉ាំង?

ភីន ៈ ឈ្មោះខ្ញុំនឹងម៉ង ។

ដានី ៈ យ៉ាំងតាភីន?

ភីន ៈ អឺ! ចៅហ្វាយស្រុកក៏ហៅចឹង មកដល់ចៅហ្វាយស្រុកក៏គេហៅចឹងដែរ ។ ខ្ញុំមិនដឹងគេដាក់ឈ្មោះអីមិនដឹង ។

ដានី ៈ យ៉ាំងតាភីន ចឹងពូអាចរៀបរាប់ថា មុនដំបូងដែលយើងចាប់ផ្តើមបង្កើតយ៉ាំង វាយ៉ាងម៉េចបានយើងបង្កើតយ៉ាំង គេហៅយ៉ាំងដើងភ្នំ?

ភីន ៈ អឺ! ចុះបើអីវ៉ាន់ដឹកមកមិនមានធ្វើយ៉ាំងដាក់ ដូចអីវ៉ាន់ចិនសព្វថ្ងៃ ដឹកមកគេមានផ្ទះដាក់ បើអត់មានផ្ទះដាក់ត្រូវទឹកភ្លៀងខូចអស់ គ្មានធ្វើអីកើត ។

ដានី ៈ យ៉ាំងនេះទីតាំងនៅម្តុំណាទៅ?

ភីន ៈ នៅខាងកើតផ្លូវប្អូនឯងទៅដល់ដើងភ្នំ វាមានផ្លូវមួយទៅកើត ប៉ុនខ្ញុំគ្រាន់ប្រាប់ប្អូនឯងម្សិលមិញថាទាហានគេនៅពេញហើយ ។

ដានី ៈ ដល់កន្លែងដាក់បារ៉ាសនឹង?

ភីន ៈ ផ្លូវចុះទៅកើត មាត់ស្រះមួយនឹង ។

ដានី ៈ មានផ្លូវចុះមកខាងស្តាំដៃ?

ភីន ៈ ខាងស្តាំដៃ ។

ដានី ៈ ហើយយ៉ាំងនឹងទំហំប៉ុនណាទៅ?

ភីន ៈ ទេ! ដីពីមុនធំណាស់ ឥឡូវនៅ១០០ម៉ែត្រទេ ។

ដានី ៈ ប៉ុនពីមុនមក និយាយពីកន្លែង?

ភីន ៈ ពីមុនមកដីម្តុំនឹងសឹងរាប់គីឡូ ធ្វើយ៉ាំង ប៉ុន្តែគាត់គ្មានឲ្យអ្នកណាទៅជិត ព្រោះធម្មតាកន្លែងយ៉ាំងគេលាក់ណាស់ គេមិនឲ្យអ្នកណាទៅជិតទេ ។

ដានី ៈ យ៉ាំងគេធ្វើប្រក់អីទៅ?

ភីន ៈ ប្រក់ស័ង្កសី ។

ដានី ៈ ប្រក់ស័ង្កសី?

ភីន ៈ ធ្វើពីឈើ ។

ដានី ៈ ប៉ុន្តែឈើរាប់រយម៉ែត្រ រាប់គីឡូ ប្រក់ស័ង្កសី?

ភីន ៈ មិនទេ ធ្វើតូចៗទេផ្ទះ ។

ដានី ៈ តូចៗ?

ភីន ៖ ផ្ទះ១០ម៉ែត្រៗ ។

ដានី ៖ ១០ម៉ែត្រៗ?

ភីន ៖ បាទ!

ដានី ៖ ប៉ុន្តែមានផ្ទះច្រើន?

ភីន ៖ មានផ្ទះ៥-៦ៗឃុំនៅប៉ុននឹងឯង ។

ដានី ៖ ៥-៦ឃុំ ចាប់ពីឆ្នាំ៩០មក?

ភីន ៖ ហ្នឹង ។

ដានី ៖ ពេលដែលចុះមកនឹងបង្កើតឃុំនៅនឹង?

ភីន ៖ បង្កើតធ្វើនៅនឹង ។

ដានី ៖ ចុះពីមុនចុះមក?

ភីន ៖ ពីមុនយើងនៅលើនោះទេ មានទៅធ្វើអីកើតអីនៅនេះ ។

ដានី ៖ បាទ! ប៉ុននៅលើមានឃុំដែរ?

ភីន ៖ នៅលើក៏មានដែរ ប៉ុនតែនៅយើងវាពិបាកថា យើងនៅតាមព្រៃកន្លែងខ្លះយើងមិនធ្វើផ្ទះផង នៅក្រោមដើមឈើ ប្រក់តង់ ប្រក់កៅស៊ូ ។

ដានី ៖ ប៉ុន្តែលោកពូធ្លាប់កាន់ឃុំតាំងពីនៅលើមក?

ភីន ៖ នៅលើនៅយាមតែផ្ទះនឹងឯង មិនមែនធ្វើមេគេទេ អ្នកយាម ។ មេគេមេធំនោះ ប៉ុនយើងអ្នកយាម ។

ដានី ៖ មេធំអ្នកណា?

ភីន ៖ មេគេតាម៉ុកយើងទៅ មេឃុំនោះ គាត់ម្ចាស់នោះ ហើយយើងកូនម្ចាស់ ។

ដានី ៖ ប៉ុន្តែដូចថា គ្រាន់ថាយើង?

ភីន ៖ គ្រាន់ថាយើងនៅជាប់ ។

ដានី ៖ នៅជាប់នៅឃុំ មើលខុសត្រូវនៅឃុំ?

ភីន ៖ បាទ! មើលថែ មិនមែនថៅកែមែនទែនទេ ថៅកែមែនទែនគេផ្សេង ។

ដានី ៖ ដូចថា តា ម៉ុក គាត់ប្រាប់ថានេះអី?

ភីន ៖ បាទ!

ដានី ៖ ប៉ុន្តែក្រៅពី តា ម៉ុក អត់ទេ?

ភីន ៖ ហេ៎! អត់ទេ អានឹងគេប្រើច្បាប់ដែរណាប្អូន មិនចេះថាខ្មែរក្រហមអត់ច្បាប់ម៉េច អត់ទេគេគោរពច្បាប់ដែរតើ ។

ដានី ៖ ប៉ុន្តែលោកពូ អ្នកទទួលមើលខុសត្រូវឃ្លាំង?

ភីន ៖ បាទ! ប៉ុនកាលនោះធូរតិចច្បាប់ ធូរដែរ អ្នកណាមកសុំអីចឹងបាន ប៉ុនឃ្លាំងឥឡូវនេះសុំមិនបានទេ សល់ទុកលក់ៗ ឃ្លាំងពីមុនអត់លក់ទេៗ

ដានី ៖ កាលពីមុនលក់អត់កើត?

ភីន ៖ អត់ៗ

ដានី ៖ យើងអត់មានទីផ្សារលក់?

ភីន ៖ លក់មិនបានទេ ខុសពីមុនគេរកខុសរកត្រូវអ្នកណាលក់ធ្វើអ្នកមានក៏លក់ទៅ ខ្ញុំខឹងបំផុតសុំអំបិលគេស៊ីមិនបាន អំបិលអត់បំផុតណា មិនឲ្យទេសល់ទុកលក់ៗ

ដានី ៖ ចឹងឃ្លាំងរបស់លោកពូនឹង នៅកន្លែងនឹង ឃ្លាំងដាក់សម្ភារៈអីខ្លះទៅ?

ភីន ៖ ស្បៀងអាហារសព្វបែបយ៉ាងសម្រាប់ប្រជាពលរដ្ឋ សម្រាប់ទាហាននឹងៗ

ដានី ៖ ដូចជាស្បៀងអាហារ ជាប្រភេទម៉េច ប្រភេតស្បៀងអីទៅ?

ភីន ៖ គេហៅស្បៀងម៉េចអានឹងរួចស្បៀង មានសព្វគ្រឿងមនុស្សហូបមានអីខ្លះៗ

ដានី ៖ មានអង្ករ មានសាច់ មានអំបិល មានគ្រឿងបរិភោគ ឧបភោគ សំលៀកបំពាក់អីនឹងៗ កាលនឹងយើងបានមកពីណាមក?

ភីន ៖ ទិញគេៗ

ដានី ៖ យើងទិញ យើងបានដូចរបស់របរលក់ឈើ លក់អីនឹងយើងទិញ?

ភីន ៖ ទេ! អារឿងលុយទិញនឹង ខ្ញុំមិនដឹងថាបានពីណាទេ ប៉ុនគ្រាន់ថាទិញៗ

ដានី ៖ ទិញពីខាងថៃមក?

ភីន ៖ ខាងថៃ នេះមួយខែអស់រាប់ម៉ឺនបាវ ហូប ហើយមិនមែនបាវប៉ុនៗនេះដូចឥឡូវៗ

ដានី ៖ ហើយចឹងពីឆ្នាំ៩០មក នៅខាងកងទ័ពខាងអង្គភាពផ្គត់ផ្គង់តាមគ្រួសារទេ យើងអត់ទាន់រកស៊ី តាមគ្រួសារខ្លួនឯងទេ?

ភីន ៖ ហ្នឹងហើយ មិនទាន់ឲ្យម្ចាស់ការខ្លួនឯងបានទេ រដ្ឋនៅចិញ្ចឹមទាំងស្រុក ចិញ្ចឹមតាំងពីបាតជើងដល់ក្បាលហើយនេះ និយាយឲ្យខ្លី តាំងពីត្រនាប់ជើងដល់មួក ចិញ្ចឹមទាំងអស់ៗ

ដានី ៖ ទាំងខោអាវ ទាំងអស់ ទាំងសំលៀកបំពាក់?

ភីន ៖ អឺ! ទាំងអស់ហើយ តាំងពីក្រពះក្រពោចទាំងអស់ៗ

ដានី ៖ ចឹងមកបើកនៅឃ្លាំងលោកពូរាល់ថ្ងៃ ឬក៏គេមានពេលបើកយ៉ាងម៉េច?

ភីន ៖ គេបើកខែ ដូចយើងឥឡូវដែរ មួយខែបើកម្តងៗ ប៉ុនអត់មានប្រាក់ទេ អត់មានប្រាក់ខែទេ មានតែស្បៀងនឹងឯងៗ

ដានី ៖ ស្បៀងនឹងប៉ុន្តែយើងបើកនឹងតាមអង្គភាពមួយៗមកបើក ឬក៏ប្រជាជនម្នាក់ៗទៅបើក?

ភីន ៖ ប្រជាជនគេហៅតាមភូមិគេមកបើក មកយកទៅ ឬក៏មានផ្លូវឡានចូលបានយើងដឹកទៅឲ្យគេទៀត ។

ដានី ៖ ដឹកឲ្យគេទៀត?

ភីន ៖ បាទ! កន្លែងណាពិបាកដឹកឲ្យទៀត ។

ដានី ៖ លោកពូទៅដឹកឲ្យគេទៀត?

ភីន ៖ មានកងដឹកជញ្ជូនគេ ពួកឡានពួកអីចឹងនៅទៅគេដឹកទៅ ។

ដានី ៖ ចុះនៅឃុំរបស់លោកពូនឹងប៉ុន្មាននាក់ទៅ?

ភីន ៖ ហ៊ឺ! នៅឃុំរបស់ខ្ញុំគេមិនយកគ្នាច្រើនទេ កាលនឹងនៅតិចគ្នា៤-៥នាក់ ។

ដានី ៖ ៤-៥នាក់?

ភីន ៖ បាទ!

ដានី ៖ ប៉ុន្តែមានកងដឹកជញ្ជូនអ្នកផ្សេងទៀត?

ភីន ៖ កងគេផ្សេងទៅ ។

ដានី ៖ ប៉ុន្តែលោកពូមានបញ្ជីមួយដូចថា កន្លែងនេះត្រូវបានរបបនេះ?

ភីន ៖ ហ៊ឺ! បញ្ជីមានតើ គេធ្វើបាត់របស់គេមិនបាន ។

ដានី ៖ បានន័យថាបញ្ជីនឹង យើងធ្វើបញ្ជីនឹងហើយ ដូចថាភូមិនេះត្រូវបានស្អីខ្លះៗ?

ភីន ៖ បាទ! ហ្នឹងហើយមាន ធ្វើខ្លួនឯងហើយបញ្ជូនឲ្យគេ ។

ដានី ៖ ពូអ្នកធ្វើខ្លួនឯង ឬក៏តាម៉ុក?

ភីន ៖ យើងធ្វើខ្លួនឯង បញ្ជូនទៅឲ្យគេអ្នកសរុបទៀតទៅ ។

ដានី ៖ ចុះលោកពូមានគិតថា ពេលដែលយើងធ្វើបញ្ជីនេះ ភូមិយើងចែកយ៉ាងម៉េច ដើម្បីឲ្យបានស្មើៗគ្នា ឬក៏លោកពូគិត?

ភីន ៖ គេបែងមកតែម្តង ភូមិនេះប៉ុន្មាននាក់ៗចែកតំរូវគ្នាចឹងម៉ង មិនមានឲ្យលើស ឲ្យខ្វះគ្នាទេ ។

ដានី ៖ ស្មើគ្នាម៉ង?

ភីន ៖ បាទ! អ្នកណាបានកូនច្រើន បានច្រើនជាងគេទៅ ។ ឥឡូវខ្ញុំនិយាយតែអង្ករមួយចុះ គេកំណត់មនុស្សដែលកើតប្រុចមក មានជាមនុស្សគេឲ្យមួយប៉ោតអង្ករ សម្រាប់មួយខែ ហើយហូបអត់អស់ទេ ។

ដានី ៖ ចុះមនុស្សធំ?

ភីន ៖ ធំក៏មួយប៉ោត ។

ដានី : ធំក៏មួយប៉ោត តូចក៏មួយប៉ោត?

ភីន : បាទ! ស្មើ ។

ដានី : ម៉េចស្មើគ្នា បើកូនតូចៗអត់ទាន់បេះហូបផង បានមួយប៉ោត?

ភីន : អត់បេះហូប ឲ្យម៉ែហូបឲ្យកូននឹងឆាប់ធំ ។

ដានី : ចុះម៉ែបានមួយប៉ោតដែរ?

ភីន : ម៉ែបានមួយប៉ោតដែរ សល់ចិញ្ចឹមជ្រូក តែចិញ្ចឹមជ្រូកអត់លក់ទៀត កាប់ចែកគ្នាហូប ។

ដានី : ចឹងលោកពូកាលនោះនៅភូមិចឹងលោកពូអត់គិតថាទុកភូមិឯងបានច្រើនជាងគេ?

ភីន : មិនទេ ទុកមិនបានទេ គេមើលដែរ ។

ដានី : គេមើលដែរ?

ភីន : អឺ! ដូចឥឡូវចឹង អាធ្វើអីមិនស្រួលគេដកសក្តិដកអីចឹងទៅ ប៉ុនយើងពីមុនមិនមានសក្តិមានយសអីទេ ប៉ុនគ្រាន់ធ្វើឲ្យល្អទៅព្រោះម៉ាអត់មានប្រាក់ដូចគ្នា គ្មានអ្នកណាជិះជាន់អ្នកណាផងហូបមួយឆ្អែតៗដូចគ្នា ។ អត់មានចង់បានកាលនោះ ចង់បានចិញ្ចឹមសត្វនឹងឯង មាន់ ទា ជ្រូក នេះពីកាលនោះ អង្គរគេបើកឲ្យតែមួយផ្ទះចិញ្ចឹមជ្រូក២ សួរអាគានេះមើលជ្រូក ២ ជ្រូក៣ ហើយហូបអត់អស់ទេ អង្គរគេបើកនឹង ។

ដានី : ព្រោះកាលនឹងយើងមិនសូវជាអីលោភលន់អីប៉ុន្មាន បើយើងបានចិញ្ចឹមមកកាប់ចែកគ្នាយើងគិតអត់មានបានគិតលុយ?

ភីន : អត់ទេ បាទ!កាប់ចែកគ្នាហូប ប៉ុនគេឲ្យចិពាំមដែរ អត់ឲ្យខ្ទះម្ហូបទេ គេឲ្យត្រីខឲ្យប្អូនឯងហូបបានរាល់ថ្ងៃអត់ទេ ត្រីខ ដូចពូអីហូបតែមួយថ្ងៃនឹងថុយបាត់ទៅហើយលែងហូបហើយ ។ ដូច្នេះមនុស្សយើងទាំងអស់ដូចគ្នា ចូលចិត្តហូបសាច់ស្រស់អីទៅ ។

ដានី : ប៉ុន្តែលោកពូដូចថាយើងឈប់ចែកគ្នាតាំងពីអង្កាល់នឹងទៅ?

ភីន : នេះឈប់មកសមាហរណកម្មនឹងម៉ង ឈប់ដាច់បាត់ម៉ង ។

ដានី : យើងឈប់ខ្លួនឯង ឬក៏?

ភីន : ឲ្យរដ្ឋាភិបាលចែកម្តងលើកនេះ ។

ដានី : បានន័យថាតាមភូមិតាមអី ដូចថាយើងប្រជាជនយើងធ្លាប់រស់នៅជាមួយគ្នា យើងប្រជាជនចាប់ពីសមាហរណកម្មមក យើងគ្រប់ៗគ្នាយើងឈប់ចែក ប្រឹងរកស៊ីខ្លួនឯងម៉ង?

ភីន : បាទ! ដឹងៗចូលមកទាំងអ្នកធំ ទាំងអ្នកតូច គ្មានអ្នកណានៅចែកទៀត គ្មានអ្នកណាទិញដូរអីពីសៀមមកទៀត អត់ទេ ។

ដានី : ចឹងយើងមានឃ្លាំងមានអី យើងចែករបស់របរនឹងតាំងពីឆ្នាំ៩០រហូតដល់សមាហរណកម្ម?

ភីន ៖ បាទ! បើតាមពិតគេធ្វើតាំងពីអើយមកនៅតាំងពីយួនចូលស្រុកយើងនោះ វាមានឃុំងនឹង រហូតហើយ ប៉ុន្តែយើងនៅក្នុងព្រៃលើនោះៗ យើងមិនអាចនិយាយកើតទេ ព្រោះមួយ ខែ ពីរខែទៅត្រង់នេះ មួយខែពីរខែទៅត្រង់នោះ ដែលមាននឹងនរ ដែលជាប់ ប្រវត្តិ សាស្ត្រ ដែលចុងក្រោយនេះ គឺត្រង់នឹងឯងៗ

ដានី ៖ ពូដែលគេហៅនិយាយឲ្យចំទៅ ថាប្រធានឃុំង?

ភីន ៖ អ្នកយាម ប្រធានគេមានមួយទៀតៗ

ដានី ៖ បើគេហៅឃុំងតាភីនហើយ មិនគ្រប់គ្រងឃុំង?

ភីន ៖ ចៅហ្វាយស្រុកគាត់អ្នកដាក់ឈ្មោះចឹងៗ ៗ

ដានី ៖ ចៅហ្វាយស្រុកណា?

ភីន ៖ ចៅហ្វាយស្រុកដាណាៗ

ដានី ៖ គាត់អ្នកដាក់?

ភីន ៖ គាត់ហៅទម្លាប់គាត់ហៅចឹង ស្គាល់គ្នាៗ យើងអ្នកយាម ចំបំផុតគឺអ្នកយាមៗ ខ្ញុំមិន ប្រកែកថា ខ្ញុំប្រធានទេ មិនប្រធានទេ តែបើហៅឲ្យចំទៅ អកយាមហ្នឹងម៉ង យាមមែន អត់មានអ្នកណាចូលបានទេៗ

ដានី ៖ ប៉ុន្មាននាក់ ក្រៅពីលោកពូមានពីណាខ្លះទៀត?

ភីន ៖ ទេ! ឥឡូវនឹង៥នាក់ៗ

ដានី ៖ ពីណាខ្លះ?

ភីន ៖ ឥឡូវសុទ្ធតែពិការនឹងៗ

ដានី ៖ ពីណា?

ភីន ៖ នេះនៅជើងភ្នំនេះមួយ តា ហឿង ចាស់ហើយ ឈ្មោះ ហឿងៗ

ដានី ៖ តា ហឿង?

ភីន ៖ អឺ!

ដានី ៖ នៅជើងភ្នំដែរៗ ពីណាទៀត?

ភីន ៖ តាលី នៅស្រះឈូកគ្នាសព្វថ្ងៃៗ

ដានី ៖ តា លី?

ភីន ៖ មិនតាទេ នៅក្មេងៗ

ដានី ៖ ឈ្មោះលី ស្រះឈូកៗ

ភីន ៖ បានប៉ុន្មានហើយ ហើយនឹងខ្ញុំមួយទៀត នៅបាត់២ទៀតៗ

ដានី ៖ បាទ! ហៀង ។

ភីន ៖ ពូ នេត ។

ដានី ៖ នេត គាត់?

ភីន ៖ ពិការជើងនឹង អាយុប្រហាក់ប្រហែលខ្ញុំ ។

ដានី ៖ នៅភូមិណា?

ភីន ៖ នៅទឹកជុំឥឡូវនឹង ។

ដានី ៖ នៅទឹកជុំ បាន៤នាក់ ។

ភីន ៖ ហ៎! អាម្នាក់ទៀតវាទៅណាចេះ មានតែអា វ៉េត ។

ដានី ៖ វ៉េត?

ភីន ៖ បាទ! នៅទួលត្បែងសព្វថ្ងៃ ។

ដានី ៖ ចឹង៥នាក់នឹង យើងមើលខុសត្រូវឃ្លាំងនឹងអត់ឲ្យបាត់ អត់ឲ្យអី ចែកអីយើងមានបញ្ជីកត់ថាបានប៉ុននេះប៉ុននោះ?

ភីន ៖ មានៗ ។

ដានី ៖ ឃ្លាំងនឹងដូចថាចាប់ផ្ដើមបាត់ ដូចថាបោះបង់ចោលពីឆ្នាំណាទៅ?

ភីន ៖ បោះបង់មែនទែន ពេលរដ្ឋាភិបាលវៃចូលអន្លង់វែង ដែលយើងឡើងទៅលើភ្នំនឹង ។

ដានី ៖ ឆ្នាំ៩៧?

ភីន ៖ បាទ! ចោលហើយអានឹង ។

ដានី ៖ ម៉េចខ្ញុំអត់ទាន់យល់ ម៉េចបានយើងឆ្នាំ៩៧ ម៉េចមានវៃម៉េច?

ភីន ៖ ចុះរដ្ឋាភិបាល មិនវៃយកអន្លង់វែងនេះ ក្រោយពីយើងរៀបចំឃ្លាំងនេះហើយ យើងមិនចូលបោះឆ្នោត ថាអត់ចូលបោះឆ្នោតទេប៉ុលពត ។ ក្រោយពីបោះឆ្នោតរួចហើយ មិនរដ្ឋាភិបាលគាត់វៃទៀតៗ វៃដណ្ដើមយកអន្លង់វែង ។ យើងទៅនៅលើភ្នំទៀត ទៅនៅជរហើយ

ដានី ៖ ឆ្នាំ៩៧ហ្នឹង?

ភីន ៖ ៩៧ ៩៨នឹង ។

ដានី ៖ ៩៨?

ភីន ៖ អឺ! នៅបានមួយឆ្នាំយើងមិនមកសមាហរណកម្មនឹង ជួបជុំគ្នាអស់ ឃ្លាំងមិនរលាយត្រឹមនឹងឯង ។

ដានី ៖ ឃ្លាំងរលាយពេលយើងវៃ ឡើងលើភ្នំនឹង?

ភីន ៖ បាទ! ហ្នឹងហើយ ហើយអីវ៉ាន់យើងមិនបានដឹកឡើងទៅវិញទេ ។

ដានី : ខាងគេមកយកទៅ?

ភីន : តា ម៉ុក គាត់ថាម៉េចបាច់ដឹកទេ ព្រោះច្បាំងគ្នាលើកនេះ អត់មានឃ្លួនទេ ខ្មែរគ្នាយើងទេ ទុកឲ្យគេយកទៅ ។ តាគយកមែន ម៉ាស៊ីនភ្លើងថ្មីៗ គាត់អត់មានយកទៅដាក់ទុកម៉ាស៊ីនភ្លើងវិញទេ ដោះលក់អេតចាយ ពូកែខាងអេតចាយ ។ ម៉ាស៊ីនភ្លើងទិញពីគេមកមួយប៉ុន្មានសែនបាត យកមកដាក់មួយស្រុកមួយម៉ាស៊ីនថ្មីៗ ។

ដានី : ចឹងចាប់ពីឆ្នាំ៩៧មក បាត់ហើយឃ្លាំងនឹង យើងបោះចោល?

ភីន : បាទ! រលាយខ្ទបងង់ត្រង់នឹង ។

ដានី : ដល់ពេលលោកពូចុះមកវិញឆ្នាំ?

ភីន : ចុះមកវិញយើងរកស៊ីធម្មតា ។

ដានី : ចុះមកវិញ ឃ្លាំងនឹងលែងឃើញមាន?

ភីន : លែងហើយ នៅតែឈ្មោះ ។

ដានី : ចុះដាខ្ទម ជាផ្ទះ?

ភីន : ខ្ទមអីនៅបានយូរតិច ក្រោយមកបានគេរូសយក ។

ដានី : រូសឆ្នាំណាទៅ?

ភីន : រូសក្រោយពីនឹងមក មិនដល់មួយឆ្នាំទេ គេរូសយកអស់ ទាហានគេនៅនឹង ។

ដានី : ប្រហែលជាឆ្នាំប៉ុន្មាន?

ភីន : ចុះមកវិញមិន៩៩ ។

ដានី : ចុះមកវិញឆ្នាំ៩៩?

ភីន : ហ្នឹងហើយ សមាហរណកម្ម៩៩ មកបានមួយឆ្នា មិនដល់មួយឆ្នាំផង គេរូសយកអស់ អារត់ អាភាយអស់ ។

ដានី : ពីឆ្នាំ២០០០ គេរូសអស់?

ភីន : បាទ! អស់ ។ ដល់ឆ្នាំ២០០០-២០០១មក ដីចាប់ផ្ដើមអស់ហើយ ។

ដានី : ចុះដីឃ្លាំង ឥឡូវទៅជាដីអីវិញហើយ?

ភីន : ដីឃ្លាំងនឹង វាទៅជាដីរបស់ក្រុមហ៊ុនរបស់អីណានោះ សល់តែ១០០ម៉ែត្រ៤ជ្រុងនៅដល់ គេទុកឲ្យទេសចរណ៍ប៉ុននឹងឯង ប៉ុន្តែឃើញទាហានមកនៅហើយ ឥឡូវនេះ ។

ដានី : បាទ! គេទុក១០០ម៉ែត្រនឹងគ្រាន់តែជាទីតាំង?

ភីន : ធ្វើផ្ទះធ្វើអីវិញ តាមគាត់និយាយ ។

ដានី : ឥឡូវគេមានដាក់បង្គោលថាជា?

ភីន ៖ បង្គោលពីមុនដាក់ម្តងហើយ ប៉ុនតែឡូវវាបាក់បែកអស់ ខាងទេសចរណ៍គេលែងគិតគូរអីទៅ វាទៅរលាយ ។ ចាំប្អូនមកនៅនេះវិញ ចាំគិតគូរធ្វើឡូវ ។

ដានី ៖ ចឹងកន្លែងឃ្លាំងនឹង ពីមុនមកឲ្យតែសម្ភារៈអីទាំងអស់ គឺទុកនឹងទាំងអស់?

ភីន ៖ ដាក់នឹងទាំងអស់ ។

ដានី ៖ សម្ភារៈ ចុះដូចជាកាំភ្លើងដូចជាអីដាក់នឹង?

ភីន ៖ នៅនឹង ។

ដានី ៖ ដាក់នឹង?

ភីន ៖ បាទ!

ដានី ៖ កាំភ្លើងអីដូចថា?

ភីន ៖ នេះរឿងកាំភ្លើង មានអាមេរិចកាំងសួរខ្ញុំថាដឹកមកពីណា? ខ្ញុំថា អឺ! នៅជាប់ព្រំដែនថៃៗ ដឹកឲ្យ ។ សួរខ្ញុំថាដឹកផ្លូវណា? ខ្ញុំថាដឹកផ្លូវថៃ ចង់ច្បាស់ទៅ សួរថៃៗ ខ្ញុំដឹងថាដឹកផ្លូវថៃ មិនដឹងពីណាគេ ។

ដានី ៖ អាមេរិចកាំងមកសួរលោកពូ?

ភីន ៖ សួរ ។

ដានី ៖ កាំភ្លើងប្រភេទអីខ្លះកាលនឹង?

ភីន ៖ កាំភ្លើងមានតែប្រភេទចិននឹង ។

ដានី ៖ មានកាំភ្លើងអាកា កាំភ្លើងធំ កាំភ្លើងតូច ឈ្មោះកាំភ្លើង?

ភីន ៖ អឺ! មានប៉ុនអាធំពេកមិនមានទេ មានតែត្រឹម៨០ចុះមក ធុនដេកា បើគ្រាប់កាំភ្លើងបាញ់ឆ្ងាយៗមិនសូវមានទេ ។

ដានី ៖ ដេកា ហើយនឹង៨០មីលីម៉ែត្រ កាំភ្លើងដៃ កាំភ្លើងអាកា កាំភ្លើងអីមាន?

ភីន ៖ មាន ។

ដានី ៖ ច្រើនកាលនឹង?

ភីន ៖ អឺ! ល្មមផ្គត់ផ្គង់កងទ័ពគេនឹង ។

ដានី ៖ ចុះពេលដែលយើងរត់ឡើងវិញឆ្នាំ៩៧នឹង យើងទុកកាំភ្លើងនឹងដែរ?

ភីន ៖ មិនមានយកទេ ។

ដានី ៖ ប៉ុន្តែយើងទុកកាំភ្លើងនឹងចោលនឹង ហើយក៏?

ភីន ៖ ចោលនឹងទៅ អ្នកណាទាហានគេកាន់ៗទៅ អ្នកណាមិនកាន់នៅក្នុងឃ្លាំងៗនឹង ហើយខ្ញុំអ្នកពិការតែ៥នាក់នឹង មានអ្នកណាទៅយក ។ បើ តា ម៉ុក គាត់មិនឲ្យដឹកទេ គាត់ថាសុទ្ធតែ

ខ្មែរយើងទេ ទុកឲ្យគេយកទៅ ។ រដ្ឋាភិបាលយកទៅណា ប៉ុនដឹងគេយកទៅទុកនៅឃ្លាំងណា ខ្ញុំមិនដឹងទៀតទេ ។

ដានី : ចុះអានឹងឃ្លាំងជើងភ្នំ ចុះក្រៅពីឃ្លាំងជើងភ្នំមានឃ្លាំងណាទៀត?

ភីន : ប្រូកនេះមានតែនឹងទេ ។

ដានី : ចុះថាឃ្លាំងកណ្ដាល?

ភីន : ឃ្លាំងកណ្ដាលអានឹងដែលពីមុននឹងទៀត កាលពីមុនអាយើងចុះមកប៉ុន្មានមួយភ្លែតៗ ប៉ុន គ្រាន់គេដាក់ឈ្មោះចឹងទៅ ។

ដានី : ចឹងកាលកើតឃ្លាំងកណ្ដាលនឹងគ្រាន់កើតមួយភ្លែតហើយទៅ រួចទៅក៏នេះឃ្លាំងរបស់តាភីន ក៏កើត?

ភីន : អានេះអាចុងបំផុតនឹង គេចាប់យកអាចុងក្រោយនេះឯង ដែលធ្វើកន្លែងទេសចរណ៍ ដូច នៅអន្លង់វែងដូចអីកន្លែងទេសចរណ៍មួយៗ កន្លែងលើ កន្លែង ប៉ុល ពត កន្លែងអីនឹង អា ចុងក្រោយនឹងហើយ បើអាមុនសាំញ៉ាំច្រើនណាស់ សួរនិយាយក៏វាមិនអស់ដែរ ច្រើន កន្លែងផ្លាស់ប្ដូរដល់គេយកចុងក្រោយបំផុត គឺអាអស់នឹងឯង ដូចខ្ញុំប្រាប់នឹង ។

ដានី : ចុះកន្លែងរោងចក្រអារឈើនឹង ពីឆ្នាំ?

ភីន : អានឹងរោងចក្រអារឈើនឹង ពីមុនមកហើយ វាមកអស់ត្រឹមដែលរដ្ឋាភិបាលវៃយកបាន កាល ។

ដានី : ៩៧?

ភីន : បាទ! ហ្នឹងហើយ ។

ដានី : ចុះកន្លែងផ្សេងៗទៀត ដូចផ្ទះ តា ម៉ុក នៅកន្លែងមាត់បឹងនឹង សង់ពីអង្កាល់ដែរ?

ភីន : អានឹងសង់មួយសំបក់សម្បាលធ្វើស្ពានធ្វើមន្ទីរពេទ្យនឹង តែគាត់ធ្វើក្រោយៗទេ ក្រោយ ស្ពាន ក្រោយមន្ទីរពេទ្យ ផ្ទះនឹង ។

ដានី : ស្ពាន មន្ទីរពេទ្យពេកអ៊ុនតាក់?

ភីន : បាទ!

ដានី : ៩៣ ធ្វើស្ពាន?

ភីន : បាទ! ធ្វើ៩៣ ។

ដានី : គាត់ធ្វើស្ពានបំណងអី?

ភីន : ធ្វើឆ្លងវាធ្វើឈើយូរទៅវាពិបាក យូរទៅវាមិនពុក ទិញស៊ីៗពីថៃមកធ្វើ អ្នកស្រុកយើង ធ្វើទេណា ។ ប៉ុនគ្រាន់ជួលអ្នកថៃម្ចាស់គេមកធ្វើ ។

ដានី : គ្រាន់តាម៉ុកផ្តើមគំនិតអ្នកធ្វើ?

ភីន : បាទ!

ដានី : គាត់ធ្វើនឹងសម្រាប់យើងឆ្លង ហើយក៏យើងត្រូវធ្វើត្រៀមសម្រាប់ដឹកសម្ភារៈអីសម្រាប់វ៉ៃ អីត្រៀម?

ភីន : អឺ! អានឹងឆ្លងសម្រាប់ចឹងតើ កាលនឹងនៅវ៉ៃគ្នា ។

ដានី : នៅវ៉ៃគ្នា?

ភីន : អឺ! កាលធ្វើស្ពានឈើវាពិបាក ឆាប់ខូច គាត់មានគំនិតមួយ គាត់ចេះដឹង ខ្ញុំឮនិយាយ នោះថា គាត់ធ្វើទុកប្រវត្តិសាស្ត្រដឹង គាត់ចាស់ហើយ គាត់និយាយចឹង ។

ដានី : គាត់ចាស់ហើយ?

ភីន : បាទ! គាត់ចាស់ហើយ អញមិនដឹងឆាប់ថ្ងៃណា ។

ដានី : គាត់ថាចឹងដែរ?

ភីន : ហ្នឹងហើយ និយាយចឹង គាត់ធ្វើចឹង ចាប់ផ្តើមគិតធ្វើអានឹង ធ្វើសាលារៀនមុនគេ ហើយ ក្មេងរៀនពេញ ហើយមន្ទីរពេទ្យៗហើយបានស្ពាននឹង ស្ពាននឹងបានក្រោយគេបំផុត រូប ចំលាក់នេះ ។

ដានី : រូបចំលាក់ ដែលយើងឡើងនឹង?

ភីន : បាទ! រូបចំលាក់នេះបើសិនជាកុំច្បាំងតទៅទៀត អាជំនៀវភ្នំខាងនេះឆ្លាក់ទាំងអស់ ដែន ការណ៍ គាត់ឆ្លាក់ទាំងអស់ ។

ដានី : អ្នកឆ្លាក់នៅដែរអត់?

ភីន : អ្នកឆ្លាក់ស្លាប់បាត់ហើយ ស្លាប់បាត់ទាំងអស់តាមមើល ៥-៦នាក់ស្លាប់បាត់ទាំងអស់ ។

ដានី : ម៉េចចឹង បានគាត់ស្លាប់?

ភីន : ឈឺ ។

ដានី : ឈឺស្លាប់ទាំងអស់?

ភីន : អាមេឆ្លាក់កំបុតជើងទេ ពិការ ។

ដានី : តែគាត់នៅ ហើយស្លាប់ហើយ?

ភីន : ស្លាប់ គាត់នៅនេះ ប៉ុនដល់ហើយទៅស្រុកៗឈឺស្លាប់នៅស្រុក ។ តែនៅអ្នកអត់កំបុត ជើងទេ នៅមន្ទីរពេទ្យ ប៉ុនឥឡូវគាត់ស្លាប់ទៅទៀត ទើបស្លាប់ឆ្នាំទៅ ។

ដានី : កាលនោះគាត់សង់មន្ទីរពេទ្យ សង់សាលារៀនមុនគេ?

ភីន : សាលារៀនមុន ។

ដានី ៖ ម៉េចបានគាត់គិតសង់សាលារៀន?

ភីន ៖ អត់មានអីឲ្យក្មេងរៀន ហើយស្រុកស្រួលបួល គាត់គិតថាស្រួលបួលអន្លង់វែងនឹង ថាសាលារៀនឈើក៏ពិបាក គាត់សង់អានឹងមួយ ។

ដានី ៖ សង់ឆ្នាំណា សាលារៀន?

ភីន ៖ សង់ៗសាលារៀនឆ្នាំមុនអ៊ុនគាក់មួយឆ្នាំ ។ សាលាឈើ តែធ្វើឈើដូចថាវាមិនដាប់ប្រវត្តិសាស្ត្រអីវែងឆ្ងាយទេ គាត់សុខចិត្តចំណាយលុយធ្វើអានឹង ។

ដានី ៖ ដល់ពេលធ្វើសាលារៀន ។

អ្នកជិតខាង ៖ កាលពីឆ្នាំ៩៥ យន្តហោះគេមកទម្លាក់មួង ប៊ិសង៉ាបសិស្ស ។

ភីន ៖ ទម្លាក់មុខនឹង ទម្លាក់កំទេចចោល ប៊ិសង៉ាប់សិស្សអស់ ប៉ុនអត់ត្រូវ ទម្លាក់បំពីមុខមិនទាន់លុបទេ គ្រឡុកនឹងនៅនឹងទេនៅកណ្ដាល ។

ដានី ៖ យន្តហោះរបស់ខាង?

ភីន ៖ របស់ខ្មែរយើង ភ្នំពេញ ។

ដានី ៖ ភ្នំពេញនឹងមក?

ភីន ៖ បាទ! អាកន្ទុំរុយ មិនស្រួលរួមជុំនឹងអ៊ុនគាក់ទៀតមកទម្លាក់នេះ អ៊ុនគាក់នេះមិនមែនអគ្គការល្អប៉ុន្មានទេ ។

ដានី ៖ គាត់សង់សាលារៀន ចុះគ្រូអីមកពីណាមក?

ភីន ៖ គ្រូរើសគ្នាយើង ។

ដានី ៖ គ្នាយើងអ្នកដែលចេះ?

ភីន ៖ គេចេះគ្រូពីមុនៗមិនមែន ។

ដានី ៖ សង់ហើយបានសង់មន្ទីរពេទ្យ?

ភីន ៖ បាទ!

ដានី ៖ មន្ទីរពេទ្យមានមុននឹងទៀត ហើយក៏សង់?

ភីន ៖ មន្ទីរពេទ្យមុនក៏មានដែរ អន្លង់វែង ប៉ុនមន្ទីរពេទ្យផ្ទះយួននៅផ្ទះដីផ្ទះអីនឹង ឈើដែរ ប៉ុនដល់ក្រោយមក អាឈើគេទើបនឹងរូសអស់ផង ។

ដានី ៖ ចឹងមន្ទីរពេទ្យថ្មនឹង តា ម៉ុក សង់ដែរ ហើយអត់ទេ?

ភីន ៖ បាទ! គាត់សង់ដែរ ស្ពាន ៣នឹង ហើយធ្វើចុងក្រោយដែលផ្ទះគាត់នេះនឹង ផ្ទះភ្នំ ។ ហើយស្ពាននឹងអត់មានគ្រឹះទេ អត់ឲ្យថៃបុកទេ ។

ដានី ៖ យើងម៉េច?

ភីន : គាត់ថាគ្រឹះអញចាក់រឹងជាងឯងធ្វើទៀត ។

ដានី : គាត់ចាក់ម៉េច?

ភីន : ពួកឯងវិស្វករ ប៉ុនធ្វើគ្រឹះមិនរឹងដល់អញ ភ្នំ២ជីកដាក់អូរថ្មសុទ្ធ ។

ដានី : ចឹងមិនបាច់ចាំចាក់?

ភីន : អត់ចាក់ទេ ហើយមើលប៉ុន្មានឆ្នាំហើយ អត់មានស្រុតទេ ឡានបរទំងន់ប៉ុន្មានអត់ស្រុតទេ ។

ដានី : បើគាត់ចាក់ថ្មពេញ?

ភីន : ថ្មសុទ្ធម៉ង់ក្នុងអូរ ភ្នំ២ អាខាងលើមានភ្នំមួយ ប្អូនឯងមើលទៅខាងកើតឃើញផ្ទះគេមួយ នៅហ្នឹង ភ្នំនឹងមួយ ហើយអាមាត់អូរខាងក្រោមកន្លែងលើអ្នកលាងឡាន ភ្នំនឹងមួយមួយ ជំនាវនឹងទៅលិចអមអូរនឹងកាយអស់ ចុះបានដាក់ទៅ ។ ហើយស្ពាននឹងថៃរកបុកគ្រឹះ គាត់ ថាឯងបុកគ្រឹះម៉េចចូល បើគ្រឹះអញវីដាក់រាប់រយម៉ែត្រទៅហើយចាំបុកគ្រឹះអីទៀត ធ្វើ ពីលើ មើលអត់មានស្រុតមានអីទេ ។ ហើយបច្ចេកទេសធ្វើស្ពាននឹង គឺមកពីគំនិតគាត់ នឹងទាំងអស់ ។ ហើយអ្នកបច្ចេកទេសថៃថាធ្វើនេះទៅមិនចាំបាច់ទប់ទឹកធ្វើអី គាត់ថាហ៊ើ! អញត្រូវការទឹក អញទប់ទឹក មើលឃើញគាត់ធ្វើស្ពានក្រោមទំនប់ឃើញទេ ទប់ទំនប់ពីមុខ ឲ្យសល់ទឹក ។

ដានី : ចុះអ្នកធ្វើសាលារៀននឹង ពូដឹងថាពីណាគេដូចថាជាង មេជាងអ្នកធ្វើ?

ភីន : ទេ! បើតាមខ្ញុំដឹង កាលនឹងមេជាងគេនឹងដែលអាចជួលថៃមក ។

ដានី : ជួលថៃ?

ភីន : បាទ! ប៉ុន្តែជាងនៅខ្មែរយើងនេះមិនមានទេ មានតែកម្លាំងកម្មករទេ ។

ដានី : ជួលថៃ សាលារៀន ស្ពានអីនឹង?

ភីន : បាទ! ហើយលុយៗជួលគេអស់តែថ្លៃជួលមេជាង ដែលធ្វើទាំងអស់យើងអ្នកស្រុកនឹងឯង ឯងមានកូនរៀនឯងទៅធ្វើ ។ ស្ពាននឹងកចឹង ឯងដើរកាត់ស្ពាននេះ ឯងធ្វើមួយម៉ោងសិន ចាំទៅទៀត ។

ដានី : ដើរកាត់ត្រូវធ្វើមួយម៉ោងបាន?

ភីន : បាទ! ធ្វើទៅទៀត ការងារគ្មានរឿងប្រញាប់ទេ តែកាត់ស្ពាននឹងធ្វើហើយៗយើងទៅ ទៀត ។

ដានី : ចុះផ្ទះគាត់ ជាងធ្វើផ្ទះគាត់?

ភីន ៖ ជាងធ្វើផ្ទះគាត់អានឹងជាងគេនៅទេ ម្តុំភូមិ ប៉ុនអ្នកចាស់ៗគាត់ស្លាប់បាត់អស់ ។ ប៉ុនអាអ្នកធ្វើលើកអីមែនទែនទៅនៅណាណាទាំងអស់ទៅទៀត ។ ឈើទាំងមូលហើយឈើ ។ ទៅឃើញ?

ដានី ៖ ឃើញៗ ។

ភីន ៖ ដើមទ្រាស ផ្ទះនឹងដើមទ្រាស ។

ដានី ៖ បាទ! ខ្ញុំចង់បើសិនជាមានជាងអ្នកធ្វើអានឹង ចង់ទៅសួរនាំថាពេលធ្វើផ្ទះដំបូងនឹងយ៉ាងម៉េចគា ម៉ុក គាត់ប្រាប់ថាឲ្យធ្វើយ៉ាងម៉េច?

ភីន ៖ គាត់ធ្វើទុកជាប្រវត្តិសាស្ត្រឲ្យកូនមើលតែម្តង ។ និយាយធ្វើសសរមូល យើងថាម៉េចមិនអារមិនអីឲ្យល្អ គាត់ថាតិចទៀតអស់ឈើហើយ ឥឡូវអញធ្វើឈើទាំងមូលទុកឲ្យកូនចៅឯងមើល តើឈើពីមុនស្រុកខ្មែរយើងមានឈើធំៗអត់ វាមាន ។

ដានី ៖ គាត់ប្រាប់ចឹង?

ភីន ៖ បាទ! ហើយឈើនេះមិនមែនលើកដៃមនុស្សរួច លើកអាអីស្ទូច ។

ដានី ៖ គាត់ដឹងដែរ គាតព្យាករណ៍ថា តិចទៀតអស់ឈើស្រុកខ្មែរ?

ភីន ៖ បាទ! សូម្បីតែសត្វ សត្វទន្សាយនេះ តែឃើញអ្នកណាសម្លាប់សត្វទន្សាយនេះរឿង គាត់ថាទន្សាយសត្វស្លូតបំផុតឯងសម្លាប់វាធ្វើអី ទុកឲ្យមនុស្សមើល តិចអស់ហើយសត្វក៏អស់ព្រៃក៏អស់ដែរ ។

ដានី ៖ គាត់ថាចឹង?

ភីន ៖ ប៉ុនដោយសារមនុស្សយើងវាច្រើន អ្នកណាទៅទប់បាន ។

ដានី ៖ ចឹងម៉េចបានគាត់គូររូបគូរអីក្នុងផ្ទះគាត់?

ភីន ៖ គូរទុកមើល ព្រោះមនុស្សភាគច្រើនមិនបានមកមើលព្រះវិហារផ្ទាល់ទេ ឲ្យមកមើលនឹង ។

ដានី ៖ ចុះជាងគំនូរអីនៅនឹង?

ភីន ៖ ជាងគំនូរនេះ ។

ដានី ៖ ណា?

ភីន ៖ តែគាត់នៅទាហានឥឡូវ ។

ដានី ៖ គាត់ឈ្មោះអីទៅ?

ភីន ៖ អេង ។

ដានី ៖ ឈ្មោះ អេង អីអេង?

ភីន ៖ ហ៎! ខ្ញុំអត់ស្គាល់ជីតាគាត់ ។

ដានី ៖ អេង គាត់ធ្វើទាហាននៅណា?

ភីន ៖ ទាហាននៅព្រះវិហារនោះ ។

ដានី ៖ ឥឡូវនៅព្រះវិហារ?

អ្នកជិតខាង៖ គាត់មកផ្ទះមួយអាទិត្យ ២អាទិត្យ ។

ភីន ៖ អឺ! មកផ្ទះម្ដងៗ មិនងាយជួបទេ ហ៎!មិនដឹងជានៅកងពលទីប៉ុន្មានទេ ។

ដានី ៖ ជាងគំនូរ ឈ្មោះ អេង ផ្ទះគាត់នៅណា?

ភីន ៖ ផ្ទះនេះ ផ្ទះស័ក្ដសីនេះ ។

ដានី ៖ នៅភូមិជើងភ្នំដែរ?

ភីន ៖ បាទ! ផ្ទះនេះ ដើមដូង ។

ដានី ៖ តែឥឡូវគាត់មកនៅធ្វើទាហាន ឬគាត់មកនៅផ្ទះ?

ភីន ៖ មិនទេ នៅបន្ទាយ ។

ដានី ៖ គាត់ឈ្មោះ អេង ហ្នឹងគាត់ជាងគំនូរព្រះវិហារ គូរ?

ភីន ៖ ជាងគូរ ។

ដានី ៖ ដល់ជាងធ្វើផ្ទះ?

ភីន ៖ ផ្ទះនឹង ជាងពិតប្រាកដខ្ញុំអត់ដឹងពីណាទេ ជាង ។

ដានី ៖ អ្នកដែលចូលរួមធ្វើដែរ?

ភីន ៖ អ្នកដែលចូលរួមធ្វើគឺសព្វមនុស្សចឹង អាចេះបើកមេខូអានឹងអ្នកទៅលើកទៅ អាចេះជាងឈូសទៅឈូស អាចេះជាងឈូសទៅឈូស អាណាចេះជាងដាប់ទៅដាប់ទៅ ។ តែក្រុមជាងគាត់មានក្រុមជាង ។

អ្នកជិតខាង៖ជិតផ្សារអន្លង់វែង អានឹងភូមិក្រុមជាងហើយ ។

ភីន ៖ ភូមិ ពូ ឌុល អានឹងភូមិក្រុមជាងហើយអានឹង ។

ដានី ៖ ភូមិអីគេ?

ភីន ៖ ឌុល ។

ដានី ៖ ឌុល?

ភីន ៖ តែឈ្មោះភូមិគេឥឡូវនេះ មិនដឹងឈ្មោះអី ។

អ្នកជិតខាង៖ឈ្មោះភូមិអូរចិញ្ចៀន ទល់មុខផ្លូវផ្សារអន្លង់វែងទៅលិច ។

ភីន ៖ ភូមិគេទៅលិច ជាប់ផ្ទះយាយប៉ក់ ផ្លូវទៅលិចភូមិនឹង៦៨ ។ ភូមិនឹងមួយភូមិសុទ្ធតែជាង ប៉ុនឥឡូវនេះ គាត់ឈប់ធ្វើជាងហើយ ។

ដានី ៖	ប៉ុន្តែពីមុនមកដាង?

ភីន ៖	ដាងទាំងអស់ ។

ដានី ៖	ចុះភូមិខាងសិល្បៈ?

ភីន ៖	សិល្បៈនឹង អាពួកសិល្បៈនឹងមិនមានភូមិទេ មនុស្សវាតិច វាដើរនៅនឹងគេនឹងឯង ។

ដានី ៖	ចុះនៅមិនមែននៅទឹកជុំ?

ភីន ៖	នៅទឹកជុំ ឥឡូវនេះ ចឹងបានខ្ញុំថាដើរនៅនឹងគេនឹងឯង មនុស្សគ្នាវាតិច វាអត់មានភូមិមួយតែឯងទេ ។

ដានី ៖	សិល្បៈគេច្រើនលេងអីកាលជំនាន់នឹង?

ភីន ៖	លេងដេរយួនដេរអីនឹង ដេរតែយួនសុទ្ធ អាមេរិចការំងឈប់ដេរហើយ ។

ដានី ៖	ម៉េចបានលេងតែដេរយួន?

ភីន ៖	អឺ! ថាយួនឈ្លានពានដីខ្មែរ ដេរតែយួននឹង ។

ដានី ៖	អត់តែថាយើងធ្វើម៉េច សើចកប្លែងអីមាន?

ភីន ៖	ហ៊ើ! មាន អានឹងគេមានផ្សេង ប៉ុនអត្ថបទអីគេត្រូវនិយាយត្រូវអីត្រេះតិជៀលគ្នាដេរតែយួននឹងហើយ ។

ដានី ៖	ចំរៀងក៏ដេរយួនដែរ?

ភីន ៖	ចំរៀងក៏មានដែរ ។

ដានី ៖	អត់មានចំរៀនស្នេហាអូនបងអី?

ភីន ៖	ហ៊ើ! អាស្នេហាអូនបងគេមិនទាន់និយាយទេកាលនោះ ព្រោះមនុស្សវាមានស្រាប់មិនបាចបង្ហាញវាចឹងទៀតទេ ។ នេះឥឡូវនេះអ្នកតែង មើលខ្ញុំសុំសំណូមពរតាមនឹងតិច ឲ្យតែងគិតពីដី ពីអីខ្វះទៅ តែងណាស្នេហាយូរទៅរដ្ឋាភិបាកទប់លែងឈ្នះ អាបុណ្យខួបកំណើត វាទៅបុណ្យអីណាស្នេហាទាំងអស់ មនុស្សទប់លែងបាន សង្គមវាទៅប្រែប្រួលខុសពីមនុស្សអស់ហើយមើលទៅ ។

ដានី ៖	ពូ តែងចំរៀងនេះ គេតែងលក់?

ភ់ន ៖	អានឹងហើយអ្នកតែងលក់នឹង ឲ្យគិតពីប្រទេសជាតិខ្វះទៅ លោកអើយ ។

ដានី ៖	តែងលក់ បើមិនមានស្នេហា លក់អត់សូវដាច់ អត់សូវចំណេញ ។

ភីន ៖	ហើយដាក់សុទ្ធតែស្រាតមក ហើយស្រាតនឹងគេចេះស្រាតខ្លួនគេហើយ ចាំបាច់ដាក់ធ្វើអីមែនណា អាក្រក់ណាស់ ។ ខ្ញុំសំណូមពរតាមនឹង ហើយអត់អាក្រក់ទេ ខ្ញុំនិយាយប្អូនឯងទុកសម្រាប់កូនសម្រាប់ចៅទៅថ្ងៃក្រោយទៀត ឥឡូវមានកូននៅ?

ដានី ៖ អត់ទាន់ ។

ភីន ៖ នៅចាំមើលមានកូនមានចៅពិបាកប្រដៅវាលេខមួយ ពិបាក ព្រោះវាឃើញសង្គមខាងក្រៅ ។

ដានី ៖ លោកពូខ្ញុំចង់ដឹងតិចទាក់ទងពីកាលយើងបែកបាក់គ្នា ដូចថាពីមុនមកយើងនៅរួបរួមគ្នា យើងនៅជុំគ្នា ក្រោយមកយើងមានការ យើងបែកបាក់ដូចខាងយើងបែកបាក់ផ្ទៃក្នុង យើងវ៉ៃគ្នាផ្ទៃក្នុងលោកពូមានដឹងរឿងនឹង មូលហេតុដំបូងម៉េចបានយើងបែកបាក់គ្នា យើងមានក្រុម?

ភីន ៖ មូលហេតុ អានឹងខ្ញុំនិយាយតិចចុះ ប៉ុនចំពោះខ្ញុំតួចតាចនេះមិនដឹងទេ អ្នកតូច គឺមិនដឹងទេ ដូចសង្គមឥឡូវចឹង រឿងរ៉ាវប្រទេសជាតិសួរសម្ដេច ហ៊ុន សែន សួរលោក ហេង សំរិន អីចឹង ។ ហើយគាត់បែកបាក់គ្នាគាត់នឹង ប្អូនឯងសួរ នួន ជា ដែលជាប់គុកបានដឹងរឿង ។

ដានី ៖ ប៉ុន្តែខ្ញុំចង់ដឹងពីអ្វីដែលលោកពូយល់ដឹងខ្លួនឯង បានឮបានអី ឬយល់ដឹងខ្លួនឯងទៀត ព្រោះរឿងខ្លះទៀត យើងចង់ដឹងពីអ្នកតូចតាចទៅ?

ភីន ៖ ពីតូចតាចទៅ ។

ដានី ៖ បាទ!

ភីន ៖ អាយើងតូចតាចនឹងវាដឹងរឿងគាត់មិនអស់ ។

ដានី ៖ ដូចថាដំបូងមក មូលហេតុចាប់ផ្ដើមមុនបែកបាក់ មុនបង្កមកវាយ៉ាងម៉េចបានវាមុនដំបូង?

ភីន ៖ អឺ! យើងមិនដឹងដែរ មិនដឹងគេនាំគ្នាថាទាស់គ្នានឹង មិនដឹងរឿងអី បើគេអ្នកធំៗគេមិនប្រាប់យើង ។ យើងស្រាប់តែឃើញគេចេញទ្រង់ទ្រាយធំមកហើយបានដឹងថា អូ!គេទាស់គាត់ ។ ប៉ុនអារឿងពីតូចមកយើងមិនដឹង មិនដឹងថា គាត់ទាស់រឿងអត់លុយ ឬក៏ទាស់ពីអីបុណ្យសក្តិអី ។ បើដូចបុណ្យសក្តិអីដូចមិនដណ្ដើមគ្នាអីទេ ។

ដានី ៖ បើគាត់ធំៗអស់?

ភីន ៖ អឺ! ប៉ុនតិចសំខាន់រឿងអត់លុយចាយ បើតាមខ្ញុំគិតមើលវាអស់ជំនួយ ។ បើអស់ជំនួយមិនបែកបាក់គ្នា ពួកនេះវាត្រូវការចាយលុយ ។

ដានី ៖ ដល់ពេលបែកបាក់គ្នា អត់ទុកចិត្តគ្នា?

ភីន ៖ អត់ទុកចិត្តគ្នា ម្យ៉ាងវាអត់លុយ ហើយគាត់ដោះស្រាយ ។

ដានី ៖ ដល់ពេលយើងរករៀងៗខ្លួន?

ភីន ៖ បាទ! សង្គ្រាមបញ្ចប់មិនបាន ហើយគាត់ចេះតែបន្ត ហើយលុយវាអត់ៗធ្វើម៉េចនឹងកើតចឹងបានសម្ដេច ហ៊ុន សែន គាត់សន្សំលុយណាស់ឥឡូវ មិនឲ្យខ្វះទេ ។

ដានី ៖ លោកពូដូចថា មុននឹង មានខាង តា ប៉ុល ពត គាត់ចាប់ តា ម៉ុក ចាប់តាសុន សេន ឃុំហើយអត់ទេ?

ភីន ៖ អារឿងនឹងហើយ ដែលខ្ញុំថាវាមិនដឹងអស់ ត្រង់គាត់ទាស់គ្នារឿងអី ដល់ទៅឃើញចាប់ប្រកែកប្រណាំងគ្នាចឹង បានយើងដឹងថាតាៗគាត់ទាស់គ្នា ប៉ុន្តែមិនដឹងថាមូលហេតុពីអីៗ

ដានី ៖ តែលោកពូដឹងថា ប៉ុល ពត ចាប់ តា ម៉ុក ហើយចាប់តា សុន សេន ឃុំអត់ទេ?

ភីន ៖ អឺ! របៀបដូចគេដាក់គុកសព្វថ្ងៃចឹង ដាក់តាៗ គេរបៀបថាដាក់ចាប់ដាននយោបាយ គេគ្រាន់មិនឲ្យដើរទៅណាទៅណាៗ តែយើងនៅផ្ទះនៅអីធម្មតាចឹងៗ

ដានី ៖ ពីអង្កាល់?

ភីន ៖ ហ៊ើ! មិនចាំឆ្នាំទៀត អាឆ្នាំមុនៗសមាហរណកម្មនឹងៗ មុនសមាហរណកម្ម៩៩ ៩៨ៗ នឹងហ៊ុយខ្លាំងៗ

ដានី ៖ ដល់ពេលកាលនឹងដូចថាយើងមានយ៉ាងម៉េច ដូចថាខាង ប៉ុល ពត គាត់មានកងទ័ពរបស់គាត់ដែរ ហើយខាងតា ម៉ុក គាត់មាន?

ភីន ៖ កងទ័ពតែមួយទេ ប៉ុន្តែដល់គាត់បែកគ្នាចឹងដូចថាអ្នកនេះកាន់នេះ អ្នកនោះកាន់នោះចឹងទៅណា រឿងចឹងទេៗ

ដានី ៖ ដល់ពេលគាត់ទាស់គ្នាទៅខាងប៉ុល ពត ខាងណាខ្លះទៅកាន់ជើងតា ប៉ុល ពត?

ភីន ៖ តា ប៉ុល ពត ឥឡូវនេះនៅយើងចូលរដ្ឋាភិបាលអស់ហើយៗ

ដានី ៖ ពីមុនមក?

ភីន ៖ ប៉ុន្តែនៅខាងដែលត្រពាំងប្រាសាទ មេៗមួយចំនួនៗ

ដានី ៖ មេៗនៅត្រពាំងប្រាសាទ?

ភីន ៖ តែមួយចំនួនក៏ស្លាប់បាត់ទៅហើយ មិនមាននៅ នៅតិចតួចៗ គាត់ទំនាស់គ្នា តាមមើលទៅ មិនទំនាស់ផលប្រយោជន៍អី សំខាន់លុយកាក់ខ្ញុំថាមិញវាល្អមទេ ប៉ុន្តែទំនាស់ដែលធំដែលគាត់ឲ្យបាក់បែកគ្នា តាមមើលរឿងនយោបាយដែរ រឿងចូលបោះឆ្នោត ឬក៏មិនចូលចឹង ឯងៗ ប៉ុល ពត គាត់មិនចូលទេៗ

ដានី ៖ ប៉ុល ពត អត់ចូល?

ភីន ៖ បាទ! ប៉ុន្តែ តាៗនោះចូលហើយ គាត់ថាលែងច្បាំងហើយ ព្រោះអស់យួនហើយ យួនគេនៅតិចតួច នៅជំនាញការនៅអីវាដូចថាខ្មែរយើងសុទ្ធហើយ គាត់មិនច្បាំងតទៅទៀតទេៗ ប៉ុល ពត គាត់ជាប់រឿងរ៉ាវរបស់គាត់ បើចូលទៅដូចថាវាជាប់ទាក់ទិនច្រើន គាត់មិនចង់ទេៗ បើដូច្នេះ គាត់ក៏មិនចង់បែកគ្នាដែរ មនុស្សចាស់ដូចគ្នា ចង់បែកទៅណាៗ

ដានី ៖ ធ្វើការជាមួយគ្នាយូរហើយ?

ភីន ៖ បាទ! ប៉ុន្តែដល់ចឹងទៅវាទៅចឹងៗ មកខ្លាំងនៅនេះហើយ ដែលមួយចូល មួយមិនចូល នឹងៗ តាមពិតមិនមែនតាជាណានេះ គាត់ចូលរដ្ឋាភិបាលនឹងមុនទេ តាៗគាត់រៀបចូលមុនហើយៗ ប៉ុនគាត់ថាវានៅទំនាស់គ្នាគាត់ដោះស្រាយមិនចេញ គាត់លែងចង់នៅច្បាំងនៅតទល់គ្នាអីទៀតហើយ ព្រោះគាត់និយាយមួយម៉ាត់ថាវានៅតែខ្មែរយើងហើយ មិនមានយួនណាទៀតទេៗ បើនៅយួនទៀត គាត់មិនឈប់មែន ពួកនេះ យី!ដូចស្នេហាជីវិតជាងគេណាស់ ទាល់តែងាប់ខ្លួនៗ

ដានី ៖ ដល់ពេលគាត់ឈ្លោះគ្នាយ៉ាងម៉េច បានមានការសម្លាប់ដូចក្រុមគ្រួសារលោកតា សុន សេន?

ភីន ៖ សម្លាប់នេះ មិនមែនស្លាប់អ្នកជម្លោះទាំងអស់សម្លាប់ទេ តាមមើលសម្លាប់ដោយបុគ្គលគំនុំទេៗ អានឹងបើច្បាប់ឥឡូវគេពិនិត្យចឹងៗ បុគ្គលសម្លាប់ ហើយបុគ្គលស្លាប់នឹង គឺគំនុំគ្នាពីយូរណាស់មកហើយៗ

ដានី ៖ ពីអង្កាល់មក?

ភីន ៖ ពីតាំងពីយើងធ្វើការអីមុនមកនោះៗ

ដានី ៖ តាំងពីជំនាន់ពាឆ្នាំ?

ភីន ៖ បាទ! ហ្នឹងហើយ ទំនាស់គ្នាធំណាស់ ពួកនេះៗ

ដានី ៖ លោកពូអាចមានប្រសាសន៍កន្លែងនឹងតិចមើលដែរ?

ភីន ៖ ជំនាន់ពាឆ្នាំ អ្នកនេះនឹង មិនគេធ្វើមេទ័ព មេទាហានៗ

ដានី ៖ តាសារឿន ០៥?

ភីន ៖ តា រឿន មេទ័ពនៅភូមិភាគឦសានៗ ហើយសុន សេន នឹង មិនគាត់មេបញ្ជាការធំៗ តែ រឿងគេឈ្លោះគ្នាមិនដឹងឈ្លោះគ្នារឿងអីទេ តែឈ្លោះគ្នាពីមុនមក ដែលខ្ញុំដឹងតែមេខាង លើគាត់ចេះសម្របសម្រួលបានធ្វើការមករហូតចឹងមក មិនទាស់ មិនខុសគ្នាអីទៀតទេៗ ប៉ុនដល់សម័យនឹង ដែលគាត់ចាប់ចំនុចមកម៉ង ហើយអ្នកប្រើមក ប្រើចំមនុស្សនឹងទៀត គេមិនមែនឲ្យសម្លាប់ទេ គេឲ្យមកហៅគាត់យកទៅ គេអត់មានបញ្ជាឲ្យសម្លាប់ទេៗ តែដល់សម្លាប់ហួសទៅ ប៉ុល ពត នឹង ក៏គាត់ហួសចិត្តដែរៗ គាត់ថាដោះលែងបានហើយ ដែលឯងធ្វើចឹងនោះៗ មនុស្សគេត្រូវដោះស្រាយគ្នា និយាយគ្នា ឯងទៅសម្លាប់គេទៅ ដោះម៉េចបានៗ

ដានី ៖ ចឹងកាលដំបូងមក តា ប៉ុល ពត បញ្ជា តាសារឿន តា០៥?

ភីន ៖ គាត់នឹងហើយ គាត់ឲ្យមកហៅអីនឹង ប៉ុន្តែប្រើមនុស្សគេចំទំនាស់គ្នានឹងឯង គាត់នឹកឃើញថា មនុស្សនឹងអាចគាត់ផ្សះផ្សាគ្នាបានហើយ យូរហើយៗ ដល់គេមិនផ្សះផ្សាគ្នាមិនបាន គេនៅគំនុំគ្នារហូតៗ ចឹងទេ បើតាមបញ្ជាមិនបញ្ជាឲ្យសម្លាបទេ ពួកនេះ វាអស់ពេលសម្លាប់ហើយ វាអស់ពេលៗ តែបើមកចំមនុស្សចឹង ហៅថាមនុស្សវាគំនុំអត់បេះបាត់ៗ

ដានី ៖ ចុះតាសារឿន តា០៥ គាត់យ៉ាងម៉េចដែរ ចរិតបុកពាររបស់គាត់?

ភីន ៖ ទេ! មនុស្សធម្មតា អ្នកស្រែស្លូតបូត មិនមានអ្នកដង់អីចេះជ្រៅជ្រះប៉ុន្មានទេ គាត់នឹងមនុស្សយើងពីដើមមានអ្នកណាបានរៀនអីប៉ុន្មានៗ

ដានី ៖ ខ្ញុំចង់ដឹងថាមនុស្សគាត់កាច គាត់គ្រប់គ្រង ស្លូតបូត គាត់ចេះគិតវែងឆ្ងាយដែរ?

ភីន ៖ បើពិនិត្យឲ្យពិតទៅ ខ្ញុំអត់ដឹងច្បាស់ទេ ព្រោះគាត់នៅកន្លែងផ្សេង កងទ័ពនៅឆ្ងាយៗពីគ្នា យើងគ្រាន់តែស្គាល់គាត់ថា គាត់ធ្វើមេទ័ពៗ ធម្មតាបើមនុស្សនឹងចរិតឃោរឃៅ វាចរិតប្រលើសបើសប្រឡោងខាំ អត់បានឡើងដល់ធ្វើមេទ័ពទេ ពួកខ្មែរក្រហមវាកសាងមនុស្សខុសគ្នា អាណាធ្វើល្អបានល្អ អាណាមិនល្អមិនឡើងទេៗ អានឹងចឹងឯង បើឥឡូវនេះមិនដឹងម៉េច ខ្ញុំមិនដឹងៗ

ដានី ៖ ចុះតា សាន ០៦?

ភីន ៖ តាសាននឹងខ្ញុំមិនស្តាប់ប្រវត្តគាត់បានទេ ព្រោះគាត់នៅភូមិភាគឦសាន១០០១ ខ្ញុំអត់ស្គាល់ទេៗ

ដានី ៖ ប៉ុនពេលដែលតា ប៉ុល ពត បញ្ជាឲ្យទៅហៅ សុន សេន ទៅតែតា០៥ ឬក៏តា០៦ទៅដែរ?

ភីន ៖ ទៅហៅនឹង ទៅតែម្នាក់ទេ ទៅម្នាក់ដែលនេះ០៥នេះឯង តែមានទាហានទៅៗ

ដានី ៖ កូនទាហានទៅជាមួយ?

ភីន ៖ បាទ!

ដានី ៖ ដល់ពេលនឹងទៅៗបាញ់បណ្តោយ ឬក៏ទៅហៅដែរ?

ភីន ៖ ទៅតាមខ្ញុំឃើញហេតុការណ៍ ខ្ញុំនៅក្រោមនេះ មិនដឹងគេបានហៅមិនហៅ តែឮសូរថាបាញ់ទៅយើងនៅក្រោយៗ

ដានី ៖ ឮសម្លេងកាំភ្លើង?

ភីន ៖ បាទ! ឮតែសម្លេងៗ ហើយមិនដឹងថាគេបាញ់គ្នាអីគ្នាទេ ដល់ភ្លឺឡើងបានដឹងៗ

ដានី ៖ កាលនឹងគេបាញ់នៅកន្លែងណា?

ភីន ៖ បាញ់នៅនោះ ត្រង់ផ្ទះ តា រួនៗ

ដានី ៖ កន្លែងពើយ តា រួន?

ភីន ៖ បាទ! មិនចំពើយនឹងទេ នៅខាងលិចផ្ទះនៅលិច ចុងចំការស្វាយ ផ្ទះនៅពើយភ្នំ។

ដានី ៖ កាលនឹងប៉ុន្មាននាក់ទៅសមាជិកក្នុងគ្រួសារដែលស្លាប់?

ភីន ៖ កាលនឹងប្រពន្ធគាត់ ខ្លួនគាត់ កូនមួយទៀត ហើយចៅទៀត ខ្ញុំដូចចាំមិនបានប៉ុន្មាននាក់ ១១ ហើយចុះឃើញដឹកមួយឡាន។

ដានី ៖ ១១នាក់ ហើយមានកូនចៅមាននៅរស់ ដែលអ្នកផុត អត់បាន?

ភីន ៖ កូនចៅសុន សេន ខ្ញុំស្គាល់ប្រវត្តិគាត់អត់ច្បាស់ មិនដឹងជាមានកូនប៉ុន្មានអត់ប៉ុន្មាន។ ខ្ញុំអត់ដឹងគាត់មានកូនប៉ុន្មាន តែនៅក្នុងឥឡូវនេះមិនមានទេ មិនឃើញ។ តែគាត់នៅប៉ៃលិន នៅខាងកោះកុងខ្ញុំមិនដឹង តែនៅនេះមិនមានទេ។

ដានី ៖ អត់មាន?

ភីន ៖ បាទ! អត់មាន។

ដានី ៖ ចុះបន្ទាប់ពីដូចថាគេបាញ់សម្លាប់តា សុន សេន អីទៅ ដល់ពេលមួយថ្ងៃបន្ទាប់មកយើងចាប់ផ្តើម?

ភីន ៖ តា ម៉ុក គាត់យកសពមកធ្វើបុណ្យធ្វើអីនៅនេះ តា ម៉ុក គាត់យកមកធ្វើបុណ្យ។

ដានី ៖ តា ម៉ុក គាត់អ្នកដឹកមក?

ភីន ៖ បាទ! តា ម៉ុក ក៏ផ្ទះគាត់នៅនឹង បើថ្ងៃនេះ ផែនការគេនឹង ហៅតាម៉ុកផង ជាមួយ សុន សេន ហៅតែពីរនាក់នឹងទេ។ តែតា ម៉ុក គាប់ជួនយប់នឹង គាត់ចុះមកដេកផ្ទះក្រោម អាផ្ទះទឹកនេះ។

ដានី ៖ ពេលនឹងនៅតែ សុន សេន?

ភីន ៖ នៅតែ សុន សេនម្នាក់ឯង។

ដានី ៖ បើគាប់ជួន បើតា ម៉ុក គាត់នៅនឹងដែរ ត្រូវគេបាញ់ដែរ ហើយក៏អត់ទេ?

ភីន ៖ ប៉េតា ម៉ុក នៅប្រហែលជាអត់បាញ់ទេ ព្រោះ០៥នឹង និរសា តា ម៉ុកនឹងទេ ហើយគាត់មិនខុសមិនទាស់អីគ្នាទេ មិនទាន់ខុសទាស់អីទេ។ ដែលថាមានគំនុំ ខ្ញុំនិយាយថា មានគំនុំតែ ២ នាក់នឹងទេ ដែលគំនុំគាត់ពីដើមមក។

ដានី ៖ ដល់ពេលស្លាប់តា សុន សេន ទៅចាប់ផ្តើមឈ្លោះគ្នាមែនទែនបណ្តោយ?

ភីន ៖ ហ្នឹងហើយ បែកសំបុក បែកនេះហើយអានឹងនោះ។

ដានី ៖ តា ម៉ុក គាត់ខឹង ឬក៏យ៉ាងម៉េច?

ភីន ៖ គាត់ខឹងសម្លាប់គ្នាឯង តាមខ្ញុំយល់ណា។

ដានី ៖ ចាប់ផ្ដើមឈ្លោះវៃគ្នាមែនទែនម៉ង?

ភីន ៖ វៃម៉ង បើមិនវៃ ពួកខាង ប៉ុល ពត វៃមកហើយ ពួកគាត់រៀបចំកម្លាំងមុន តា ម៉ុក នឹង ស្រេចទៅហើយ ។

ដានី ៖ គាត់ដឹងថាចឹងដល់ពេលសម្លាប់ហើយ តាម៉ុកគាត់ដឹងថា?

ភីន ៖ បាទ! ហ្នឹងហើយ ។

ដានី ៖ អូ! ប្រាកដជាវៃហើយ ចឹងគាត់ដឹងថាប្រាកដជាវៃហើយ ចឹងគាត់រៀបចំកម្លាំង?

ភីន ៖ បាទ! ពេលនោះកម្លាំងតាម៉ុកគាត់គ្មាននៅលើភ្នំទេ នៅតែគ្នាទេ ទាហានអីនៅក្រោមទាំងអស់ ។

ដានី ៖ ចឹងដល់ពេលរៀបចំកម្លាំងខាងតា ប៉ុល ពត គាត់មាន?

ភីន ៖ គាត់រៀបរួចហើយ ។

ដានី ៖ កម្លាំងគាត់ប៉ុន្មានទៅ?

ភីន ៖ មិនដឹងទេ យើងមិនដឹង ប៉ុនគ្រាន់តែមានៗត្រៀមសម្រាប់ទំនាស់គ្នានឹងហើយ ។

ដានី ៖ ទំនាស់ខាង ប៉ុល ពត ពីណាគេ តា០៥?

ភីន ៖ ស្លាប់អស់ហើយ ។

ដានី ៖ បាទ! ប៉ុន្តែកម្លាំងពេលនឹង កម្លាំងដែលពេលចាប់ផ្ដើមឈោះគ្នានឹងមាន?

ភីន ៖ កម្លាំងនៅសល់ខ្លះ នៅធ្វើទាហានសព្វថ្ងៃនៅព្រះប្រឡាយ ។

ដានី ៖ បាទ! ខ្ញុំគ្រាន់តែចង់ដឹងមេៗ?

ភីន ៖ អឺ! មេគេនឹងក៏នៅទាហានដែរ ឈ្មោះពូ កែវ នោះមួយ ពូអីទៀតទេៗ ខ្ញុំនៅចាំពូ កែវ នឹងមួយ ។

ដានី ៖ ជា កែវ?

ភីន ៖ ប្រហែលហើយ នៅកងពលលេខប៉ុន្មានទេ ឥឡូវនេះ ។

ដានី ៖ នៅខាងណា?

ភីន ៖ នៅព្រះវិហារ ។ នៅដូចកងពលលេខ៣ នៅជាមួយ ស្រី ដឹក ។

ដានី ៖ ហើយកាលនឹងតា០៥ ០៦ ខាងកម្លាំងតា ប៉ុល ពត កាលនឹងកាលពេលយើងវៃ?

ភីន ៖ ប្រទាញគ្នាកាលនោះ ប្រទាញគ្នាជាមួយតានឹង ជាមួយ តា ម៉ុក កម្លាំងនឹង មេៗនឹង ។ គាត់នៅរវែកដែរ គាត់នឹកឃើញថាចាស់ៗធ្លាប់នៅជាមួយគ្នាយូរហើយ ស្រាប់តែឈ្លោះគ្នា គាត់មិនដឹងទៅខាងណា ប្រទាញគ្នាទៅ ។

ដានី ៖ ប៉ុន្តែតា០៥ គាត់ទៅនោះម៉ង?

ភីន :	ប៊ុន ប៊ុល ពត ហៅទៅប្រើទៅ របៀបដូចគាត់នៅនោះ ប៊ុនតាមពិតមិនមែនទេ គាត់នៅស្រឡាញ់ទាំងសងខាងមនុស្សនេះ ដូចថានៅរារែក ។

ដានី :	០៥, ០៦ មានពីណាទៀតដែរកាលនោះ?

ភីន :	មនុស្សធំកងពលមានពីរនាក់នឹង ដែលឈរមុខនៅកន្លែងនេះ ។

ដានី :	ដល់ពេលខាងតាម៉ុកវិញ?

ភីន :	ខាងតាម៉ុកមាន កាលនឹងគ្មានអ្នកណា មានទាហានតូចតាចទេ កាលនឹងមានកងពលដែរ ប៉ុនថ្នាក់ទាបៗ ។

ដានី :	ចុះខាងលោកអភិបាលស្រុកគាត់បែក ហើយនៅ?

ភីន :	ក្រោយមកទៀតរអភិបាលស្រុកនេះ ។

ដានី :	អភិបាលស្រុក កាលនឹងគាត់ប្រធានកងពលដែរ?

ភីន :	កងពល គាត់មិនប្រធានទេ ប្រធានមែនទែន ដុម ឈុនលីទេ តែគាត់សមាហរណកម្មបាន មុន ដុម ឈុនលី ក្រោយវិញ ។

ដានី :	កាលនឹងគាត់រងកងពល?

ភីន :	បាទ! គាត់រង ។

ដានី :	រងកងពល ហើយ ដុម ឈុនលី គាត់ប្រធាន?

ភីន :	បាទ!ពូផាណានឹងតាមពិតទៅគាត់នៅកុំឈ្មោះគ្នាឈ្មោះអី ពូផាណានឹងគាត់ត្រូវធ្វើធំ ព្រោះមនុស្សគាត់នៅសៀមរាប គេយកមនុស្សនៅណា ឲ្យធ្វើធំនៅនឹងដែរ ។ គេរើសមនុស្សចឹងដែរដូចគ្នា នៅតំបន់ណា គេយកមនុស្សតំបន់នឹងធ្វើចឹង ។

ដានី :	លោកអភិបាលស្រុកគេហៅគាត់ពូផាន់ៗ(ផាណា) ?

ភីន :	ពូផាន់(ផាណា)ចឹង អត់ប្រែទេ ។

ដានី :	គាត់ឈ្មោះ យឹម ផាណា គេហៅគាត់ផាន់ៗ?

ភីន :	ផាន់ ពីមុនយើងមិនសូវដឹងត្រកូលគាត់ទេ គេហៅតែផាន់ៗទទេរ ដល់មកឥឡូវនេះ យើងគាត់ដាក់ត្រកូលអីត្រឹមត្រូវ ហៅ យឹម ចឹងទៅ ។

ដានី :	គាត់ចូលទៅសមាហរណកម្មមុនគេ?

ភីន :	មុន ។

ដានី :	ម៉េចកាលនឹងយើងបែកខ្ញែកគ្នាយ៉ាងម៉េច បានបែកអ្នកខ្លះទៅចូលសមាហរណកម្ម អ្នកអីកាលនឹង ខាងតាៗគាត់គ្រប់គ្រងលែងបាន ឬក៏មកវិញ?

ភីន : រឿងដែរ មិនមែនគ្រប់គ្រងលែងបានទេ គាត់ដឹងម៉ង គាត់នៅសមរភូមិគាត់ដឹង ព្រោះកម្លាំងធម្មតាតែឈ្លោះគ្នាគេខ្សោយ តែខ្សោយហើយគេអ្នកនៅមុខគេដឹង គេរកច្រកគេហើយ ។

ដានី : គាត់ដឹងថាមិនថិតថេរទេ?

ភីន : ហើយសមនឹងខាងរដ្ឋាភិបាលទាក់ទងបានផង ក៏គេទៅច្រុច រហូតដល់អត់ប្រាប់ពួកខ្ញុំផង ពិបាកចង់ងាប់ ។ បើប្រាប់ទៅវាមានទៅស្អីទៅផងគ្នា ទៅរកអ្នកណាឧស្សាហ៍នៅធ្វើនេះយូរ ចង់ងាប់ពិបាក ។

ដានី : អាចថាក្រែងលរគេប្រាប់ច្រើន ខ្លាចបែកការណ៍?

ភីន : អឺ! ដំណើរចឹងឯង ទុកឲ្យខ្ញុំពិបាក គាត់ធូរមុនខ្ញុំទៅ អ! ខឹងគាត់តើនិយាយលេង ជួបគាត់និយាយលេង យី!លោកអើយបើថាទៅមិនប្រាប់ផង អានេះស្រួលអានេះលំបាក ងាប់គ្នាទេណា អត់មានស្អីសើចហ៊ាស ធម្មតាទៅ ។ ធម្មតាគេធ្វើចឹង អ្នកណាគេប្រាប់អស់ ។

វណ្ណៈ : ពូសុំសួរកាត់កន្លែងនេះតិច ក្រោយពីតា០៥គាត់ចុះមកបង្ក្រាប់ តា សុន សេន ស្លាប់អីចឹង ក្រោយមក តា០៥ គាត់មានរឿងអីកើតឡើងចំពោះគាត់វិញ ក្រោយពីសម្លាប់ តា សុន សេន ទៅ?

ភីន : អឺ! មនុស្សនឹងដូចគេរបៀបថា បើយើងឥឡូវថាមានសាលាក្តីកាត់ទោសចឹង មនុស្សដែលត្រូវសម្លាប់គេ គឺយើងក៏មានទោសដែរ ។

ដានី : ចឹងពេលនឹង ពេលដែលយើងចាប់ផ្តើមពីហើយ តា ម៉ុក គាត់មិនរៀបចំកម្លាំងវ៉ៃជាមួយគាត់ក្រុមគាត់វិញ?

ភីន : បាទ! វ៉ៃបានប៉ុន្មានថ្ងៃ ។

ដានី : បានប៉ុន្មានថ្ងៃ ខាងនោះក៏ចាញ់ទៅ?

ភីន : បាទ! ចុះគាត់មិនមានកម្លាំងណាទៅវៃណា ។

ដានី : លែងដូចថា កងទ័ពក៏អត់មានទឹកចិត្តវ៉ៃគ្នា ធ្លាប់ស្គាល់គា?

ភីន : បាទ! វាមានតែអ្នកនៅស្មោះត្រង់នៅជិតៗនឹង តិចតួចនឹង ។

ដានី : រត់ទៅ គេចាប់បានត្រង់ណា ដូច ប៉ុល ពត?

ភីន : ទេ! អាកន្លែងចាប់បានៗច្រើនដំណាក់ណាស់ ខ្ញុំក៏អត់ដឹង ចាប់បានតាមអូរ តាមអីយើងបានដឹង គាត់រត់ទៅ ទ័ពខាងនោះស្ទាក់បានទៅៗលែងរួច ។

ដានី : ដល់ពេលនេះចាប់ដាក់ក្នុងទ្រុងដែកទាំងអស់?

ភីន ៖ ចាប់មកអត់ទេ មេៗនឹងអត់ដាក់ទេ អ៊ំខៀវ សំផន ក៏អត់ដាក់ នួន ជា ក៏ទៅជាមួយគ្នា ។ តា ម៉ុក នៅតែឯងទេ ទៅជាមួយគ្នាគាត់ ។

ដានី ៖ ប៉ុន្តែមេទ័ពៗដូចតា០៥អី?

ភីន ៖ តា០៥នឹង ដែលរឿងរ៉ាវនឹងដោះស្រាយរួចរាល់អស់ហើយ យកគាត់មកដាក់គុកជាមួយ ហ៊េ!ដាក់គុកកាលនឹងជាមួយកងបើយន្តហោះប៉ុន្មាននាក់ទៀត ។ ពួកបើកយន្តហោះនឹងរួចខ្លួនទាំងអស់ អត់ស្លាប់ទេ ។ ស្គាល់ទេ ជាមួយពួកបើកយន្តហោះកាលនឹង?

ដានី ៖ អត់ ។

ភីន ៖ ខ្ញុំក៏មិនស្គាល់ គ្រាន់តែពុកាលនឹងយន្តហោះ ។ ខ្ញុំនិយាយតិច យន្តហោះនឹងមកចរចាគ្នាដល់ហើយមនុស្សវាទំនាស់គ្នាអាមួយបាញ់ អាមួយអត់បាញ់ កើតសម្លាប់គ្នាអស់មួយចំនួន នៅសល់តែអ្នកបើកអត់សម្លាប់ទេ ។

ដានី ៖ ពួកយន្តហោះមកពីខាងណា មកពីខាងក្នុង?

ភីន ៖ ខ្មែរយើងនឹង ។

ដានី ៖ ខាងក្នុង ទាហានខាងក្នុង?

ភីន ៖ អឺ! ទាហានខាងក្នុង ។

ដានី ៖ ដល់ពេលបាញ់ៗដល់នេះខាងយើងចាប់យកមក?

ភីន ៖ តា ម៉ុក គាត់ឲ្យទៅចាប់យកមក មិនមែនសម្លាប់ទេ តែអាអ្នកសម្លាប់នឹងវាដូចខ្ញុំនិយាយមិញកូនទាហានតូចទេ មិនមានសក្តិអីទេ វាបាញ់គេយករបស់ ។ ហើយមេឲ្យទៅចាប់យកមកនិយាយគ្នា ហៅទៅនិយាយគ្នាទុកយន្តហោះនៅនឹង ទៅបាញ់គេសម្លាប់ហើយដុតទាំងយន្តហោះទៀត ។ បានតា ម៉ុក គាត់ដឹងគាត់ថា អឺ!ឯងមានអីសងគេ យន្តហោះឯងមានលុយ សង តែមនុស្សឯងបានអីសង ឯងផលិតមនុស្សកើតទេនឹង ។ គាត់និយាយតែប៉ុននឹង រឿងវាចឹង ។

ដានី ៖ កាលជំនាន់ដូចតាម៉ុក គាត់ចាប់បានចឹង ដូចថាតាខៀវ សំផន, តានួន ជា, អត់មានបញ្ហាអីទេ ប៉ុន្តែខាងមេទ័ពម៉េចបានគាត់សម្លាប់?

ភីន ៖ ពួកនឹងដៃដល់សម្លាប់គេនឹង សម្លាប់សុន សេន នឹង ។

ដានី ៖ សម្លាប់សុន សេន ប៉ុន្តែមិនមែនម្នាក់ណា កាលតាម៉ុក គាត់សម្លាប់ដូចគ្នាច្រើនដែរ?

ភីន ៖ តែ២ទេ ហើយប៉ុន្មាន ខ្ញុំអត់ដឹងច្រើន ពេលគេងាប់នឹង ពួកគេនៅកន្លែងនឹងខ្ញុំដឹងថា០៦, ០៥ ។

ដានី ៖ ហើយរងកងពល២-៣នាក់ទៀត?

ភីន : មិនដឹងទេ ខ្ញុំ ហើយតាលឿនៗនឹងរួចទេ គេអត់សម្លាប់ទេ នៅត្រពាំងប្រាសាទសព្វថ្ងៃ ធ្វើប៉ូលីសទៀត ។

ដានី : តា លឿន?

ភីន : អឺ!ខ្ញុំដឹងអត់អស់ទេ ត្រង់កន្លែងស្លាប់ប៉ុន្មាននាក់ៗ ខ្ញុំដឹងតែមេនឹងទេ មេធំៗឃើញថាបាត់ ដឹងថាស្លាប់ តែកូនចៅគាត់នៅទាំងអស់ ។

ដានី : យកគាត់ទៅសម្លាប់ណាទៅ?

ភីន : មិនដឹងទៀត យើងមិនដឹង បើកន្លែងគុកគេ កន្លែងអ្នកផ្សេង យើងអត់ស្គាល់ ។

វណ្ណៈ : ចឹងកាលនឹងបើសិនជាតា០៥ ផាកមកខាង តា ម៉ុក គាត់បានរស់បាត់ ដោយសារគាត់ បែកទៅខាងប៉ុល ពត?

ភីន : បាទ! ប្រហែលបើយើងយល់មើលចឹង ប៉ុនពួកនេះបើមកនេះ គំនិតថាមកនេះហើយបើ សម្លាប់មនុស្សចឹង បើទៅមិនរួចទេ ព្រោះពួកនេះពុតែសម្លាប់គ្នាឯង ។

ដានី : ចះ ប៉ុល ពត ព្រឹត្តិការណ៍រៀបចំកាត់ទោសអីនឹង កាលនឹងលោកពូបានចូលរួមដែរអត់?

ភីន : ខ្ញុំនៅនេះដែរ ប៉ុនមិនបានទៅទេ ។

ដានី : អត់បានទៅទេ?

ភីន : បាទ!គេមិនឲ្យទៅអស់ទេ ឲ្យនៅចាំកន្លែងខ្លះ គេមកហៅៗប្រជាជនយើងទាំងអស់នឹងទៅ ។

វណ្ណៈ : ប្រជាជនច្រើនដែរ?

ភីន : បាទ! នៅអន្លង់វែងទាំងអស់ ប៉ុន្មានម៉ឺន ទៅជួបជុំគ្នា កាត់ទោសគាត់នឹង ។

ដានី : តែប្រជាជនទាំងអស់នឹង យល់ឃើញថា ប៉ុល ពត គាត់ខុស ហើយក៏យ៉ាងម៉េច កាល ពេលដែលយើងកាត់ទោស ក្នុងចិត្តយើងមួយៗ? ពេលដែលយើងទៅ យើងគិតថា ប៉ុល ពត?

ភីន : ពេលនឹងមិនដឹងអ្នកណាថាខុស អ្នកណាថាត្រូវទេ ប៉ុនតាម៉ុក គាត់ហៅឲ្យទៅមើលទៅហើយ មិនទាន់ដឹងថា ប៉ុល ពត នឹង គាត់មានរឿងអី ហេតុអី ។ ប៉ុនសំខាន់គាត់អាចដឹងខ្លះកាល នោះ ដឹងត្រង់ថា វាមានហេតុភេទ សម្លាប់មេៗ អាចដឹងតិចតួចចឹងទេ ។ ប៉ុនពីមុនមក មិនមានទេ មិនដឹង ។

ដានី : ប៉ុនដល់ពេលយើងចូលទៅ ពេលដែលគេកាត់ទោសយើងប្រជាជនចូលរួមប៉ុននឹង យើង គ្រាន់តែទៅមើល ឬក៏យើងមានអារម្មណ៍ថា ខឹងនឹង ប៉ុល ពត ដែរ យើងចង់?

ភីន : គ្មានទេ ទៅមើលម៉ង ព្រោះមនុស្សទាំងអស់ទៅជាមួយគាត់ មិនសូវស្គាល់គាត់ទេ ពួកនេះ គេលាក់ណាស់ដូចខ្ញុំថាចឹង មនុស្សដែលអត់លាក់ខ្លួន គឺមានតែតាម៉ុកនឹងទេ មិនលាក់នឹងទេ

បើក្រៅពីនឹងគាត់លាក់ យើងស្គាល់មិនអស់ទេ គេស្គាល់ធម្មតាគេស្គាល់តែមេៗទេ គេស្គាល់ ។

ដានី : ចឹងប្រជាជនគ្រាន់តែទៅចូលរួម?

ភីន : គាត់ទៅចង់ឃើញ ចង់នេះចឹងម៉ង ។

ដានី : ប៉ុន្តែ អ្នកគាត់ទោសម៉េចៗ ខាងលើគេអ្នករៀបចំ?

ភីន : ខាងលើទេគេរៀបចំធ្វើ ។

ដានី : គាត់ទោសតែម្តង?

ភីន : តែម្តង កន្លែងផ្ទះគាត់ទោសនៅសព្វថ្ងៃ នៅតែសសរ ប៉ុនគេរូសអស់ហើយ ។

ដានី : បាទៗខ្ញុំឃើញដែរ ឃើញឥឡូវមានគេដាក់ផ្លាកទុកជាកន្លែងប្រវត្តិសាស្ត្រ ។

ភីន : បាទ! គេទុក!ៗវាតូចពេល ធ្វើស្អីក៏វា ។

ដានី : គេអត់ទាន់អភិវឌ្ឍន៍ផង គេគ្រាន់ថា ។

ភីន : អភិវឌ្ឍន៍កើត បើគេយកដីអស់ហើយ បើខាងរដ្ឋនឹងគេយកវិញអានឹងបាន ។

ដានី : ព្រោះដីប្រវត្តិសាស្ត្រនឹង ប្រហែលជាគេមិនឲ្យទៅខាងឯកជនទេ ។

ភីន : មិនឲ្យ ខ្លាចគេកំណត់ម៉ែត្រហើយ ។

ដានី : ហើយចុះកន្លែងផ្ទះ ប៉ុល ពត ដែលមុនគាត់ស្លាប់នោះ គាត់ទោសហើយ គាត់មិននៅក្នុងផ្ទះមួយ?

ភីន : ផ្ទះនឹងដែលនៅកន្លែងស្លាប់ កន្លែងដុតនឹងម៉ង ។

ដានី : កន្លែងដុតនឹង?

ភីន : បាទ! តា ម៉ុក គាត់ធ្វើផ្ទះឲ្យមួយនៅត្រង់នឹង ។

ដានី : ស្លាប់នឹងមូលហេតុគាត់ឈឺស្លាប់ខ្លួនគាត់ ឬមានបញ្ហាអី?

ភីន : គាត់នឹងកើតជម្ងឺបេះដូង ហើយគាត់គាំងបេះដូង ដេកជាមួយប្រពន្ធៗមិនដឹងគាត់ស្លាប់ផង ។ គាត់ដាក់អុកស៊ីសែន ហើយដល់រដ្ឋាភិបាលវ៉ៃថ្ងៃនោះ ដោងដាក់កន្លែងនឹង ដល់ហើយអ្នកទៅទិញអុកស៊ីសែនមិនទាន់ដោះស្រាយមិនទាន់ដែរណា សង្គ្រាមផងអីផង គាត់ស្លាប់នឹងទេ អស់ខ្យល់ដកដង្ហើម ។

ដានី : ឬមួយក៏គាត់ពិបាកចិត្ត គាត់ដូចថាគេបរាជ័យគេចាប់?

ភីន : អឺ! អារឿងពិបាកនោះ ពិបាកយូរណាស់មកហើយ បើគាត់មិនស្លាប់ទេ គាត់ប្រើខ្យល់នឹងរហូត ។ គាត់មិនស្លាប់អីរាប់ឆ្នាំ ។

ដានី : បានន័យថាគាត់មានជម្ងឺបេះដូង?

ភីន ៖ បាទ! ទាល់តែមកពេលនឹង វាអស់ខ្យល់នឹងទៅ ទោះបីថាមិនគិតអីច្រើនក៏ស្លាប់ដែរ ។

វណ្ណៈ ៖ គាត់ចាស់ផង?

ភីន ៖ ចាស់ ដើរឡើងគ្រា ប៉ុនមនុស្សធំៗ ស ។

ដានី ៖ ចុះតាម៉ុក ខាងរដ្ឋាភិបាលចាប់គាត់យ៉ាងម៉េចៗដឹងអត់?

ភីន ៖ អ! ចាប់ស្អីគេឲ្យប្រកាសថាចាប់ចឹងទៅ ប៉ុនគាត់មកធម្មតា រដ្ឋាភិបាលចិញ្ចឹមរាប់ខែនោះ ទម្រាំឲ្យគាត់ទៅនោះ ។

ដានី ៖ ពូអាចរៀបរាប់កន្លែងនឹងតិចបានទេ?

ភីន ៖ ខ្ញុំមិននៅជាមួយទេ ប៉ុនគ្រាន់ថា ពេលគាត់ទៅនឹង គាត់មិនបានប្រាប់បានអីយើងផង ព្រោះរដ្ឋាភិបាលគាត់គ្រប់គ្រងហើយពេលនោះ ប៉ុនគ្រាន់គាត់ជិះឡានតាមនឹងឲ្យយើងឃើញចឹង ។

ដានី ៖ គេឲ្យចិញ្ចឹមគាត់នៅផ្ទះគាត់នៅក្រោម?

ភីន ៖ ផ្ទះលើ ផ្ទះតារូននៅ ។

ដានី ៖ កន្លែងជិតអន់តែនមួយ ខាងលើ?

ភីន ៖ ប្អូនឯងចង់ដឹងច្បាស់ សួរកងពល១១ គាត់នៅផ្ទាល់នឹង ។

ដានី ៖ កងពលនៅណា?

ភីន ៖ កងពល១១ ពួកទាហានរដ្ឋាភិបាលចាស់ ដូចពួកពូលីប ពួកអីនឹងនៅនឹង ។

ដានី ៖ ឆ្នាំ៩៩គាត់គេនាំ?

ភីន ៖ ប្រកាសថាចាប់ ។

ដានី ៖ បាទ! ប្រកាសថាចាប់?

ភីន ៖ អឺ! ដែលតាមនេះ ៩៩នឹងហើយ សមាហរណកម្មមកបានប៉ុន្មានខែនោះ ។

ដានី ៖ ចឹងឆ្នាំ៩៩ចឹង បានគេចាប់?

ភីន ៖ បាទ! យូរ ដែលឲ្យគាត់សារភាព គាត់ថាសារភាពៗម៉េចវាច្រើនណាស់ និយាយពាឆ្នាំមិនចប់ទេ មិនបាច់ទេ ឥឡូវប្រកាសថាចាប់ទៅ ។ ចឹងឯងបានគាត់ឡើងយន្តហោះ ចប់ប៉ុននឹងឯងយើង ។

ដានី ៖ ចុះពូដោយសារពូធ្លាប់នៅជាមួយ តា ម៉ុក អីចឹង និយាយទៅតាំងពី៨០មក ពូនៅជាមួយគាត់ រហូតមក ដូចថាយើងនៅមានអារម្មណ៍ យើងមានមនោសញ្ចេតនាអីយ៉ាងម៉េចដែរ ជាមួយគាត់?

ភីន ៖ ទេ! អានឹងប្រៀបធៀបដូចមនុស្សចាស់នៅក្នុងភូមិហើយប្អូន ទាល់តែយូរទៅ យើងថាមនុស្សនៅក្នុងភូមិស្រុកគ្នាឯងចឹងទៅ ធ្វើបុណ្យ ។ កាលស្លាប់ខ្ញុំទៅធ្វើបុណ្យ វិទ្យុអាស៊ីសេរីមកសួរខ្ញុំៗថា សួរដូចប្អូនឯងថាមានអារម្មណ៍ម៉េចដែរ ដែលឃើញតាម៉ុកស្លាប់? ខ្ញុំថា ខ្ញុំចាត់ទុកដូចមនុស្សចាស់នៅក្នុងភូមិយើងម្នាក់ទៅហើយ ។ ឃើញគាត់ស្លាប់ហើយខ្ញុំមកជួយធ្វើបុណ្យធ្វើទានអីចឹងទៅទេ ។ ឲ្យមានពាក់ព័ន្ធអីខាងធំដុំអី វាគ្មានទេ ។

ដានី ៖ ដូចថាគាត់ជាមនុស្សល្អ គាត់ធ្លាប់បានជួយលោកពូ ឬក៏ជួយប្រជាជន ជួយកងទ័ពយើងដូចថាយើងគិតថា គាត់មានគុណបំណាច់ គាត់មានអីខ្លះដែលលោកពូនៅចងចាំនៅគិតថាគាត់នៅជា ដែលមិនអាចបំភ្លេចបានទាក់ទងពីរឿងតាម៉ុក?

ភីន ៖ ទេ! មិនអាចបំភ្លេច ឥឡូវយើងនិយាយចំនុចដែលសំខាន់ៗអាមួយចាត់ទុកថាចាស់ទុំទៅចុះប៉ុន២ទៀត ចាត់ទុកថាគាត់ជួយមនុស្ស ហើយយើងមើលកាលកសាងរបស់គាត់ដែរគាត់ស្រឡាញ់ណាស់ខាងការកសាង តាហ្នឹង ។ គាត់ធ្វើផ្លូវធ្វើស្ពានអីត្រង់ណា សុទ្ធតែមានទំនប់ទឹកហើយ នោះទំនប់ ប្អូនឯងមើលទំនប់មួយធំណាស់ ហើយចិញ្ចឹមមនុស្សបានច្រើនណាស់ ។ ហើយគាត់ចំណាយទុនចឹងទៅ លុយក្នុងសង្គ្រាមនឹង គាត់ចំនាយនឹងសង្គ្រាមខ្លះតែគាត់កសាងខ្លះ ។ តែបើកន្លែងផ្សេង មេដឹកនាំដូចគ្នាដែរ តែមិនមានទេ ។ អត់ទេ ក្នុងគ្រាលំបាកដូចគ្នាមិនមានអ្នកណាហ៊ានធ្វើទេ គាត់ហ៊ានធ្វើ ព្រោះគាត់ ខ្ញុំមើលទៅគាត់មិនសូវមានកម្មសិទទេ អីច្រើនទេ ។

ដានី ៖ ចុះគាត់មានចំនុចណាដែលថាមិនល្អ គិតថាគាត់មិនល្អធ្វើឲ្យប៉ះពាល់ដល់ប្រជាជនដែរអត?

ភីន ៖ បើអាចំនុចមិនល្អ អានឹងខ្ញុំនិយាយត្រឹមដំណាក់កាលដែលខ្ញុំស្គាល់ ។ ដំណាកកាលដែលខ្ញុំស្គាល់មែនទែនយើងមកនៅលើភ្នំនេះហើយ វាអស់ចំនុចអាក្រក់ហើយមកនៅលើភ្នំនេះគាត់ធ្វើល្អ ដែលនៅស្រុកនោះយើងមិនដឹងទេ ។ ខ្ញុំធ្វើតែទាហានសូម្បីតែបងប្អូនខ្លួនឯងក៏មិនដឹងដែរ ។

ដានី ៖ ហើយចុះគាត់មានកូនចៅ ដូចថាជាកូនជាក្មួយ?

ភីន ៖ កូនចៅគាត់នៅនេះខ្លះ កូនស្រីគាត់មានតែកូនស្រីតែកូនប្រុសអត់មាន ។

ដានី ៖ គាត់មានកូនស្រី?

ភីន ៖ បាទ!

ដានី ៖ មានប៉ុន្មាននាក់ដែរកូនគាត់?

ភីន ៖ កូននៅនេះ២ ដូចនៅប៉ៃលិននោះ១ ។

ដានី ៖ នៅប៉ៃលិន១?

ភីន ៖ បាទ! ស្រី សុទ្ធតែស្រី ។

ដានី ៖ ស្រី នៅនេះឈ្មោះអីគេ?

ភីន ៖ នៅនេះឈ្មោះ យាយ គ្រូ១ ហើយហ៊ាញ២ ស្រី នៅទឹកជុំ ។

ដានី ៖ ឈ្មោះ ហ៊ាញ មួយ ឈ្មោះ គ្រូ មួយ?

ភីន ៖ ហ៊ាញ, គ្រូ បាទ! ។

ដានី ៖ ស្រីទាំងពីរ?

ភីន ៖ ស្រី សុទ្ធតែស្រីកូនគាត់ កូនប្រុសមួយតែស្លាប់បាត់ មិនធំដងតូចស្លាប់ ។ កូនក្មួយគាត់ខ្ញុំស្គាល់មិនអស់ទេ ច្រើន ។

ដានី ៖ តា ម៉ុក គាត់មានប្រពន្ធប៉ុន្មាន?

ភីន ៖ ប្រពន្ធគាត់តែមួយ ចាស់ ប៉ុនក្រោយដែលគាត់ចាស់នេះហើយ គាត់យកប្រពន្ធមួយទៀត ប្រពន្ធ២ ។

ដានី ៖ ប៉ុនគាត់មានកូនទេ ប្រពន្ធក្រោយ?

ភីន ៖ អត់ទេ គាត់ចាស់ហើយ ។

ដានី ៖ គាត់ចាស់ហើយ?

ភីន ៖ បាទ! គាត់យកឲ្យតែមានគ្នា ជួយថែរក្សាគ្នាឯងតាមមេល ។

ដានី ៖ ចុះកូនគាត់ម៉េចដែរ សព្វថ្ងៃនឹងគាត់ដូចថា រស់នៅធម្មតា សប្បាយចិត្តដូចយើងធម្មតា ឬក៏មានបញ្ហាអីដែរ បើតាមលោកពូ?

ភីន ៖ មានអីគាត់រកស៊ីធម្មតាដូចយើង ធ្វើស្រែ ។

ដានី ៖ ធ្វើស្រែ?

ភីន ៖ បាទ!

ដានី ៖ មានអ្នកទៅសួរនាំគាត់ច្រើន ហើយអត់ទេ?

ភីន ៖ ទេ! ខ្ញុំមិនដឹង អាចសួរ មិនអត់ទេ ព្រោះអ្នកសួរមានប៉ុន្មានឈុតមកដែរហើយ អាចមិនអត់ទេ សររហូតនឹង កូនចៅគាត់នឹង ។ ប៉ុនកូនចៅគាត់មិនធ្វើអី ធ្វើស្រែចំការ ធម្មតាចឹងទៅ ។

ដានី ៖ គាត់អត់មានសល់អី?

ភីន ៖ មានប្ដីមួយនៅនេះ តែមួយមេម៉ាយដែរនឹង ។

ដានី ៖ ពីណាគេមេម៉ាយ?

ភីន ៖ មីគ្រូនឹងមេម៉ាយ អត់មានប្ដីស្លាប់ ។

ដានី ៖ ហ៊ាញ បានមាន?

ភីន ៖ ហ៊ាញនៅប្ដី ប៉ុនប្ដីពិការទៀត ភ្នាក់បុកជើង ។

ដានី ៖ ចុះមេដឹកនាំផ្សេងៗទៀត ដូចជាតាខៀវ សំផន, តានួន ជា, តាប៉ុល ពត, តាសុន សេន អីយ៉ាងម៉េចដែរ?

ភីន ៖ យើងតូចតាច ដឹងគាត់មិនអស់ទេ ។

ដានី ៖ ដូចថាលោកពូដឹងថា តា ម៉ុក គាត់មានគុណវិបត្តិអីចឹង គាត់បានកសាងអីចឹង ចុះតាផ្សេងៗទៀត?

ភីន ៖ តាផ្សេងៗទៀត ខ្ញុំគ្រាន់ដឹងថា គាត់រួមជាអ្នកដឹកនាំក្នុងបក្សនឹងប៉ុននឹង តែដឹងថាល្អអាក្រក់អីយើងអត់បាននៅជិតគ្នា យើងអត់បានដឹងចិត្ត ដឹងនេះទេ ។ បើនៅជិតគ្នាដូចតាម៉ុកចេះទៅ យើងដឹងថាគាត់ធ្វើចេះចុះ មានកម្មសិទ្ធិធ្វើចេះចុះទៅ ។

ដានី ៖ បើរឿងឈ្លោះគ្នា បើតាមដែលពូវិញ យោបល់របស់ពូគាត់ឈ្លោះគ្នាក្រោយនេះ គាត់គិតថាតាប៉ុល ពត អ្នកខុស ឬក៏តាម៉ុកអ្នកខុស ឬក៏យ៉ាងម៉េច?

ភីន ៖ ហ៉េ! ខ្ញុំមិនអាចកំណត់កើតទេអានឹង ព្រោះយើងមិនដឹងរឿងគាត់មែនទែនរឿងអី យើងវិនិច្ឆ័យមិនបានត្រឹមត្រូវ មែនទែនគាត់រឿងអីគ្នាគាត់ ។ ខ្ញុំគ្រាន់តែឃើញនិយាយថានិយាយគ្នាលេងថា យី!ចាស់ៗទៅហើយឈ្លោះគ្នាធ្វើអី នឹកឃើញនិយាយចឹង ។

ដានី ៖ ចុះលោកពូដូចថាកូនលោកពូគាត់កើតក្រោយៗនេះទេ?

ភីន ៖ កើតក្រោយ ។

ដានី ៖ ធំៗក្រោយនេះ?

ភីន ៖ វាមិនដឹងអីទេ ។

ដានី ៖ ចុះលោកពូដែលនិយាយរឿងរ៉ាវពីខ្សែជីវិតយើង ពិបាកវេទនា ពី៣ឆ្នាំ ក្រោយពីរត់យួន៧៩តាមព្រៃតាមផ្សៃ រស់នៅលើអីនឹង ឧស្សាហ៍និយាយប្រាប់កូនចៅដែរអត់?

ភីន ៖ និយាយឲ្យវាដឹងដែរតើវាពិបាកពេកបានយើងនិយាយ បើវាចង់ដឹងយើងនិយាយដែរ ។

ដានី ៖ មានគាត់សួរនាំដែរអត់?

ភីន ៖ កូន?

ដានី ៖ បាទ! កូន ។

ភីន ៖ កូនវាសួរចង់ដឹងដែរ យើងនិយាយទៅតាមដំណើររបស់យើងដឹង និយាយបានវាប្រាប់វាប៉ុន្នាន និយាយទៅ ។

ដានី ៖ ភាគច្រើនគាត់សួរពីរឿងអី?

ភីន : សួរពីរឿងយើងរស់នៅកន្លែងនេះ បើភូមិស្រុកមិនមែននៅនេះមែនទែនទេ ម៉េចក៏យើងមកនៅនេះ មូលហេតុអីចឹងណា ។ ហើយយើងនិយាយរឿងរាយរ៉ាប់ពីសង្គ្រាមចេះចុះ យើងខ្លាត់ព្រាត់មកដល់នេះដោយសារអីៗចឹងទៅ វាទៅដឹង ។

ដានី : គាត់ខស្សាហ៍សួរ ឬក៏សួរម្តងម្កាល?

ភីន : ទេ! វាមិនខស្សាហ៍សួរអីញឹកពេក ដឹងតែម្តងវាដឹងកូន ។

ដានី : កូនទាំង៣សួរ?

ភីន : អឺ! វាឆ្ងល់សួរដែរតើ ។

ដានី : ទាំង៣នាក់ សួរ?

ភីន : បាទ! វាសួរ ។

ដានី : សួរ ដល់ពេលលោកពូរៀបរាប់ប្រាប់ហូរហែលវែងឆ្ងាយ ឬក៏ប្រាប់ខ្លីមិនចង់និយាយអីទេ?

ភីន : ទេ! យើងប្រាប់ចំនុចខ្លីៗ យើងត្រូវប្រាប់ទេ រាយរាប់អាណាវែងដូចប្អូនឯងសួរនេះ វាយើងនៅមានពេលអីនិយាយវែងប្រាប់វា វាក៏មិនដឹងប៉ុន្មានផង ប្រាប់វាល្មមៗអាណាវាចាំបានប្រាប់ទៅ កន្លែងណាមិនត្រូវប្រាប់ ក៏យើងមិនប្រាប់វាធ្វើអី ។

ដានី : ហើយពេលដែលលោកពូនិយាយប្រាប់ទៅកូនៗជឿទេ?

ភីន : វាជឿ ការនិយាយរបស់យើង ឲ្យវាដឹងការលំបាក ចុះវាធ្លាប់ជួបលំបាកខ្លះដែរ វាដឹងខ្លះ

ដានី : ចុះលោកពូមានអារម្មណ៍ម៉េចពេលនិយាយប្រាប់កូន?

ភីន : អត់មានអារម្មណ៍អីវែងឆ្ងាយអីទេ គ្រាន់នឹកឃើញថាអីរឿងរ៉ាវរបស់យើងវាកើតមានចឹង យើងនិយាយប្រាប់ឲ្យវាដឹងខ្លះ ឲ្យវាយល់ពីបញ្ហាដែលកើតមានឡើង ។

ដានី : ចុះប្រពន្ធរបស់លោកពូ ធ្លាប់និយាយប្រាប់កូន?

ភីន : គាត់និយាយដូចគ្នា ។

ដានី : គាត់និយាយដែរ?

ភីន : រឿងពិបាករឿងអីរបស់គាត់ៗនិយាយ ។

ដានី : ចុះលោកពូដូចថាកាលពីមុនមក កាលពីលោកពូនៅក្មេងៗ លោកពូរស់នៅស្រុកកំណើតមានក្រុមគ្រួសារឪពុកម្តាយ បងប្អូនអីចឹងដែរ ។ បើលោកពូគិតមើលៗ ដូចថាការរស់នៅថាគ្រួសារកាលនឹង យើងរបៀបការរស់នៅទាក់ទងគ្នា ហើយក្រោយមកលោកពូបែកមកមានការទាក់ទងគ្នាខុសប្លែកគ្នាយ៉ាងម៉េចទៅ?

ភីន : វាពិបាកណាស់អានីងប្អូន យើងរស់នៅក្នុងស្រុកភូមិនៅជាមួយម៉ែឪបងប្អូនអានឹងយើងពឹងពាក់គ្នា ។ ដល់ពេលយើងចេញមកចេះ យើងយកញាតិចឹងឯង យើងពឹងពាក់គ្នាជាបងជាប្អូនវិញ ជួយគ្នាចឹងទៅ ទុក្ខធុរៈម្តងម្នាក់ជួយគ្នាទៅ ។ បើយើងគិតថាចាំតែបងប្អូនយើងដឹងបងប្អូនណា បើបែកមកអស់ហើយ ។

ដានី : វាពិបាកចឹង?

ភីន : បាទ! ដល់ពិបាកចឹង យកញាតិធ្វើបងប្អូន ។

ដានី : ឥឡូវនឹង?

ភីន : អឺ! ឥឡូវនឹងយើងបានរស់នៅបាន ភូមិនេះប្អូនឯងសួរមិនមានអ្នកនៅនេះអី សុទ្ធតែមកពីឆ្ងាយៗ ។ ដូចអ៊ីមុខនេះមេភូមិនេះ គាត់នៅកំពង់ចាម ហើយយើងមានទំនាក់ទំនងគ្នារស់នៅជាមួយគ្នា រាប់អានគ្នាទៅ នៅជាមួយគ្នាបាន ។ ដល់យូរៗទៅចង់ភ្លេចអាបងប្អូនឯងអ្នកនៅឆ្ងាយវាមិនសូវបានជិតដល់គ្នាទៅទៀត ស្រឡាញ់ជិតៗគ្នានេះទៅ ។

ដានី : បាទ! ដូចថាយើងសង្គ្រាម យើងបែកគ្នានេះទៅ ការទំនាក់ទំនងវាប្រែប្រួលដែរ?

ភីន : បាទ! ហ្នឹងហើយ វាដាច់ សូម្បីតែកូនយើងបង្កើតចឹង ដាច់គ្នាតែ៨-១០ឆ្នាំ អារម្មណ៍អត់សូវជាប់ទេ ។ វាគិតលែងវាស្គាល់ លែងវាដឹង ។

ដានី : ដូចកូនចឹង ដូចថាលោកពូរស់នៅឆ្ងាយពីបងប្អូននៅស្រុក ដល់ពេលកូនលោកមើលទៅដូចថាអារម្មណ៍បងប្អូនខាងនោះម៉េចដែរ?

ភីន : វាយើងដល់ចឹងយើងនាំវាទៅជួបគ្នាតើ វាស្គាល់គ្នាដើម្បីស្គាល់គ្នាកុំឲ្យដាច់ ដូចថាមនោសញ្ចេតនាបងប្អូន យើងនាំប្រាប់វាឲ្យស្គាល់បងស្គាល់ប្អូចឹងទៅ គេខាងនោះក៏ចឹង យើងខាងនេះក៏ចឹង ដើម្បីឲ្យវាស្គាល់បងប្អូនគ្នាតែប៉ុននឹងទេ ។ ហើយឲ្យរឿងរ៉ាវវែងឆ្ងាយទៀត ទោះយើងនិយាយប្រាប់វាក៏វាមិនដឹងដែរ ពួកនោះ វាដឹងតែកើតមកហើយវាស្រួលទៅហើយកើតមកចំអត់ ចំលំបាកអីអតទេ ។

ដានី : បើចន្លោះតាំងពីលោកពូចេញពីផ្ទះ ពីអាយុ១៨ឆ្នាំមក បែកពីផ្ទះរហូតអត់ដែលបានទៅលេងផ្ទះសោះ?

ភីន : ទៅពេលយើងសមាហរណកម្មនេះ បើពីមុនអត់ទាំងអស់ ។

ដានី : និយាយទៅតាំងពីឆ្នាំ៧១ អីមករហូតដល់សមាហរណកម្ម៩៨ ៩៩បានទៅ?

ភីន : បាទ!

ដានី : ចឹងកាលលោកពូរៀបការ បងប្អូននៅស្រុកអតដឹង?

ភីន : អត់ដឹងទេ ។

ដានី ៖ អត់ដែលបានទាក់ទងគ្នាដាច់ម៉ង?

ភីន ៖ មិនទេ ។

ដានី ៖ សុខទុក្ខបងប្អូននៅស្រុកនៅភូមិក៏អត់ដឹង?

ភីន ៖ អត់ដឹង ។ ខ្លះតាមរយៈអ្នកជិតខាង ស្គាល់គ្នាមកជួបជុំគ្នាម្តងម្កាលដឹង តែបើឲ្យមានគេអូគេលេហួននេះដូចរាល់ថ្ងៃនេះ មិនទេ ។

ដានី ៖ តាមលោកពូវិញ ព្រឹត្តិការណ៍ស្អីដែលធ្វើឲ្យលោកពូ ផ្តាច់ទំនាក់ទំនងរវាងគ្រួសារ កត្តាអីសំខាន់ដែលធ្វើឲ្យយើង?

ភីន ៖ ទេ! អានឹងមកពីសង្គ្រាម ថាមួយម៉ាត់ប៉ុននឹង បើមិនសង្គ្រាមអត់បែកបាក់គ្នាចឹងទេ ។

ដានី ៖ អានេះសំខាន់មកពីសង្គ្រាម?

ភីន ៖ បាទ!

ដានី ៖ ធ្វើឲ្យយើងផ្លាស់ប្តូររបៀបការរស់នៅជាគ្រួសារ?

ភីន ៖ បាទ! អានឹងសឹងថាដាស់ជាអចិន្ត្រៃយ៍ម៉ង បើស្រុកសង្គ្រាមចឹង អត់សង្គ្រាមមិនមានអ្នកណាសុខចិត្តបែកបាក់អីដល់ទៅរហូតចេះមិនមានទេ ។

ដានី ៖ ចុះម៉េចដែលគ្រួសាររបស់លោកពូសព្វថ្ងៃ?

ភីន ៖ អត់អីទេ បើរស់នៅមូលគ្នាធម្មតា ។

ដានី ៖ យើងរស់នៅជារបៀបគ្រួសារ ប្រពន្ធកូន វាផ្សេងពីគ្រួសារដែលលោកពូធ្លាប់រស់នៅកាលពី?

ភ៊ន ៖ វាប្រហាក់ប្រហែលដូចតែគ្នា ប្តីប្រពន្ធកូនចៅយើង បានគ្នា ប៉ុនត្រង់ថាមានពេលឈ្លោះទាស់គ្នាដូចមិនសូវមានដែរទេ ។ ការមិនមានអាចារ្យប្រដៅប៉ុនដូចអស់សូវឈ្លោះគ្នាទេ ការឥឡូវនេះអាចារ្យប្រដៅរឹកមាត់ ។

ដានី ៖ នៅក្នុងផ្ទះលោកពូ គ្រួសារលោកពូរស់នៅម៉េច ដូចថាប៉ុន្មាននាក់ទៅរស់នៅ?

ភីន ៖ ឥឡូវនឹងនៅតែ៣ទេ កូនគេបែកអស់២ហើយ ។

ដានី ៖ កូនបែក២?

ភីន ៖ បាទ! បែក២កូនគេមានប្តីមានប្រពន្ធគេទៅ នៅ៣អាមួយរៀននឹង ឥឡូវនៅតែ២នាក់យាយតាទេ ២នាក់ដូចពីដើមវិញហើយនេះ ។

ដានី ៖ ប៉ុន្តែទំនាក់ទំនងទៅកូនចៅ?

ភីន ៖ អឺ!អានឹងគ្មានស្អី កូនចៅយើងទៅណា ។

ដានី ៖ ចុះទាក់ទងជាមួយអ្នកជិតខាង ភូមិឃុំសហគមន៍យើងវិញ ការរាប់អានគ្នា ការរាក់ទាក់វា យ៉ាងម៉េចដែរ បើនិយាយប្រៀបធៀប?

ភីន ៖ ដូចខ្ញុំនិយាយពីដើមចឹង មកនៅនេះអត់មានបងប្អូនបង្កើតទេ មានតែញាតិ ហើយញាតិនឹង សុទ្ធតែស្រុកទេសដោយឡែកៗ ។ ដូច្នេះ មានតែយើងចងក្រងគ្នាសាមគ្គីគ្នា ស្គាល់គ្នាជួយ គ្នាទោះបីយើងមិនបានអីធំដុំក៏ដឹងចិត្តដឹងគំនិតគ្នា ជួយគ្នាខាងកម្លាំង ខាងស្មារតីអីចឹងទៅ បានរស់នៅជិតគ្នាបាន ។

ដានី ៖ យើងនៅរាប់អានគ្នាធម្មតាទេ?

ភីន ៖ បាទ! រាប់អានគ្នាធម្មតា បើចឹងយើងនៅមិនបាន បើយើងបែងចែកថាអ្នកនេះអ្នកនោះ នៅចុះ ។

ដានី ៖ អត់មានឈ្លោះគ្នាអីទេ?

ភីន ៖ អត់ទេ ។

ដានី ៖ រាប់អានស្រឡាញ់គ្នា?

ភីន ៖ បើយើងឈ្លោះគ្នា ក៏យើងនៅមូលគ្នា ជិតគ្នាក៏មិនកើត ។

ដានី ៖ នៅនេះយើងគោរពតាមសាសនាអីដែរទៅ វាមានច្រើន?

ភីន ៖ សាសនាព្រះពុទ្ធ តែមានសាសនាយេស៊ូ គេធ្វើផ្ទះធ្វើអីនៅនោះ ។

ដានី ៖ នៅនេះ មានសាសនាព្រះពុទ្ធ ប៉ុន្តែភាគច្រើន?

ភីន ៖ អូ! ភាគច្រើននិយាយរឿងព្រះពុទ្ធនឹងហើយ ។

ដានី ៖ ប៉ុន្មានភាគរយទៅ?

ភីន ៖ ហ៊ឺ! ស្ទើរតែទាំងអស់ មានឃើញយេស៊ូគេចូលមកអាចមានខ្លះ គេទៅយេស៊ូនោះប៉ុនតិច ណាស់ ។

ដានី ៖ យេស៊ូតិចទេ ចុះលោកពូៗព្រះពុទ្ធក៏យេស៊ូ?

ភីន ៖ ហ៊ឺ! ខ្ញុំក៏ព្រះពុទ្ធដែរ មិនមែនយេស៊ូទេ ខ្ជិលណាស់ ។

ដានី ៖ ស្រុកយើងស្រុកព្រះពុទ្ធ?

ភីន ៖ ឲ្យគេជឿទៅយេស៊ូនោះទៅ ខ្ញុំនៅព្រះពុទ្ធ ។

ដានី ៖ ចុះកាលពីមុនៗសង្គ្រាម?

ភីន ៖ ព្រះពុទ្ធ យើងក៏ព្រះពុទ្ធដែរ ។

ដានី ៖ ពីមុនសង្គ្រាមក៏ព្រះពុទ្ធ?

ភីន ៖ បាទ!

ដានី : ចុះជំនាន់កម្ពុជា ប្រជាធិបតេយ្យ?

ភីន : ក៏នៅព្រះពុទ្ធនឹងឯង ។

ដានី : ប៉ុន្តែកាលជំនាន់នឹងយើង?

ភីន : មានសាសនាដូចគ្នា មិនអត់ទេ ។

ដានី : មានដែរ?

ភីន : បាទ! អូ! អ្នកណាទៅចោល ។

ដានី : ចុះមានវត្តមានអី?

ភីន : វត្តអត់មានកាលសង្គ្រាម ដល់ចប់សង្គ្រាមមានដែរនឹង សង្គ្រាមវត្តអ្នកណាធ្វើបានអាមេរិចកាំផទម្លាក់ឆេះខ្ទេចខ្ទីអស់ ។

ដានី : ប៉ុន្តែកាលជំនាន់លោកពូនៅកំពង់សោម?

ភីន : កំពង់សោមៗមិនទាន់មានទេ កាលនោះ ប៉ុនយើងធ្វើកម្មវិធីអីក៏យើងគោរពតាមព្រះពុទ្ធសាសនាដែរ ។ អាចារ្យមានប៉ុនគ្រាន់មិនមានពាក់ស្បង់ក្រហមទេ ។

ដានី : អត់មានទេ?

ភីន : បាទ! អាចារ្យគេប្រដែរប្រដៅយើងអីមាន ។

ដានី : ចុះក្រោយមកពេលដែលលោកពូមកនៅជំនៀរតាមព្រំដែនឆ្នាំ៨០?

ភីន : អូ! អានឹងមានហើយ មានវត្តមានវ៉ារបស់គេ បើយើងយួនវៃច្រើនណាស់ ធ្វើវតមិនទាន់ យើងទៅវត្តថៃ ។

ដានី : ចឹងមានព្រះសង្ឃមានអីដែរ?

ភីន : មាន ថៃកាន់ព្រះពុទ្ធសាសនាដូចយើងដែរ ។

ដានី : ចឹងកាលជំនាន់ដូចជា ពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ កាលលោកពូនៅស្រុកដូចមានវត្តមានវ៉ា លោកពូធ្លាប់រស់នៅវត្ត?

ភីន : អឺ! បើខ្ញុំបួស ហើយនៅវត្ត៣ឆ្នាំ៤ឆ្នាំ ។

ដានី : ចុះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានព្រឹត្តិការណ៍អីខ្លះ ដែលយើងអាចគោរពតាមព្រះពុទ្ធសាសនា?

ភីន : យើងធ្វើកម្មវិធីអីដូចឥឡូវចឹង យើងគោរពតាមរបៀបនឹង ។

ដានី : ចុះមានពេលបុណ្យភ្ជុំបិណ្ឌ មានចូលឆ្នាំ?

ភីន : អ! សប្បាយដូចគ្នា ។

ដានី : កាលជំនាន់លោកពូនៅកំពង់សោម?

ភីន ៖ បាទ!មានដូចគ្នា អាប្រពៃណីអស់នឹងមានចោលណា អត់បាត់ទេ ។ ប៉ុនគេស្រែកថាបាត់ៗ គេថាអ្នកមួយចំនួនថាបាត់ មានអីប៉ុន្តែយើងដឹង ។

ដានី ៖ តែលោកពូម៉េចបានអត់ទៅផ្ទះកាលពីនៅកំពង់សោម?

ភីន ៖ ទេ! កាលនោះមិនទាន់មានច្បាប់អី នេះទៅផ្ទះសម្បែងមានច្បាប់ទម្លាប់គេ ។

ដានី ៖ គេមានច្បាប់ទម្លាប់?

ភីន ៖ បាទ!គេឲ្យទៅតែគេចាត់ចែងឲ្យទៅម្នាក់ៗចឹងទៅ ។ ហើយយើងត្រូវជាប់អានៅក្រោយគេ ក៏យើងមិនបានទៅ រហូតដល់យួនចូលស្រុកយើងមកក៏អត់ដាច់ប៉ាត់ទៅទៀត ។

ដានី ៖ ចុះក្រោយ៧៩ ពេលយើងនៅតាមនេះ យើងពេលមានបុណ្យទាន បើមិនមានវត្តខ្មែរ វត្តថៃ?

ភីន ៖ បាទ! យើងធ្វើខ្លួនយើងក៏បាន យើងទៅវត្តថៃក៏បាន បើយើងនៅជិតភូមិថៃ យើងទៅបានគេអត់ឃាត់ឃាំងអីទេ ។ ហើយយើងទៅ ។

ដានី ៖ ទៅវត្តពេលណាទៅភាគច្រើន?

ភីន ៖ ពេលមានបុណ្យទានធំៗ យើងទៅហើយ ។

ដានី ៖ បុណ្យអីគេ?

ភីន ៖ ភ្ជុំបិណ្ឌ ចូលឆ្នាំអីចឹង ។

ដានី ៖ ដូចគ្នានៅថៃ?

ភីន ៖ ដូចគ្នា ។

ដានី ៖ ថ្ងៃ?

ភីន ៖ ចុះខ្មែរដូចគ្នា ថ្ងៃដូចគ្នាទៀត អត់ខុសគ្នាទេ ។

ដានី ៖ ភាគច្រើនពេលចូលឆ្នាំ ហើយពេលភ្ជុំបិណ្ឌ យើងទៅវត្ត?

ភីន ៖ អឺ!បុណ្យធំៗអីយើងទំនាក់ទំនងគ្នាបាន ។ ហើយបើមានកន្លែងយើង កន្លែងណាដែលយើងនៅនឹងនរបានយូរយើងមានវត្តមានអី យើងទៅធ្វើវត្តយើង ។

ដានី ៖ ចុះចំពោះអ្នកកាន់សាសនាផ្សេង ដូចខាងយេស៊ូ ខាងនេះមានអ៊ីស្លាមដែរអត់?

ភីន ៖ អ៊ីស្លាមដូចមិនទាន់មានឃើញ ។

ដានី ៖ អត់មានទេ?

ភីន ៖ បាទ! ប៉ុនជនអ៊ីស្លាមមាន ប៉ុនមិនទាន់មានឃើញវិហារនៅទេ ។

ដានី ៖ មានតែខាងយេស៊ូ?

ភីន ៖ យេស៊ូគេមានវិហារ២-៣របស់គេ ។

ដានី ៖ តើយើងមានទំនាស់អី ដូចថាមិនត្រូវគ្នា ហើយអត់?

ភីន ៖ ទេ! គេនៅតែគេ យើងនៅតែយើង ។

ដានី ៖ យើងរាប់អានគានិយាយគ្នា?

ភីន ៖ បាទ! រាប់អានគ្នាធម្មតា អត់មានដែលទាស់គ្នាទេ ។

ដានី ៖ អត់មានដែលដូចថាខាងនេះល្អ?

ភីន ៖ បើខ្ញុំធ្លាប់មានពុទ្ធនិយាយចេះ យ៉េស៊ូប្រកាន់មកវិញ ថាយើងខ្មែរនឹងវាចេះចុះទៅ កាន សាសនា វាខុសគេ ប៉ុនថាបើឲ្យឈ្លោះគ្នាមែនទែនមិនមាន ។

ដានី ៖ ចុះលោកពូកាលពីក្មេងៗមានគិតចង់រៀនដលណា?

ភីន ៖ ទេ! ចង់រៀនឲ្យចេះដែរកាលនឹង ប៉ុនយើងរត់មិនរួចនឹងសង្គ្រាមក៏ចប់ត្រឹមប៉ុននឹង ។

ដានី ៖ កាលនឹងចង់?

ភីន ៖ ពេលចង់រៀនហើយកាលនោះ ។

ដានី ៖ ចង់រៀនដល់ថ្នាក់ណា ចង់ធ្វើអីដែលកាលនឹង?

ភីន ៖ អឺ! ចង់រៀនឲ្យបានខ្ពស់ៗដូចគេចឹង ឃើញគេរៀនខ្ពស់ៗទៅគេធ្វើការធ្វើងារទៅវាទំនង ជាងយើង ។

ដានី ៖ ដល់ពេលរៀនៗទៅវាមានឧបស័គ្គដែលមានសង្គ្រាមទៅក៏ឈប់ទៅ?

ភីន ៖ បាទ! ឧបសគ្គដោយសារសង្គ្រាមមិនមែនរឿងយើងទេ រឿងគេ ហើយវាទៅជាអាក់ សន្ទាក់ដល់យើងដែរ ។

ដានី ៖ កាលនឹងលោកពូយល់ឃើញថារៀនសូត្រនឹងមានសារៈសំខាន់អីយ៉ាងម៉េចខ្លះ?

ភីន ៖ អឺ! កាលនឹងដឹងហើយកាលនឹង ដឹងក្ដីហើយ ម៉ែឪជួយប្រាប់ជួយនាំ ។

ដានី ៖ គាត់ប្រាប់ថាម៉េច?

ភីន ៖ គាត់ថារៀនសូត្រទៅវាចេះដឹងទៅ យើងធ្វើការនេះនោះអីវាបានទំនងគេទៅ យើងធ្វើតែ ស្រែយ៉ាប់ មនុស្សល្ងង់គេមិនត្រូវការគាត់ប្រដៅចឹងឯងម៉ែឪ ។ តែយើងរត់មិនរួចត្រង់ ដល់ពេលយើងត្រូវការរៀនសូត្របានវាស្រុកអត់ស្រួលចប់ប៉ុននឹង ។ បើឥឡូវនេះវាមានអី ប្អូនអើយ មើលគេស្រុកស្រួលបួលទៅរៀនសូត្រ ចឹងហើយបានកូនខ្ញុំៗអត់ឲ្យឈប់ទេ រឿងចឹងតើ ។ ឪល្ងង់ កូនលែងឲ្យល្ងង់ហើយ ស្រុកឥឡូវរៀនបានហើយ អត់ពិបាកទេ ។

ដានី ៖ កូនលោកពូណែនាំថាម៉េចខ្លះទៅពេលរៀន?

ភីន ៖ បាទ! ណែនាំឲ្យវារៀនឲ្យចេះដឹងម៉ង អត់ឲ្យល្ងង់ដូចឪ ព្រោះឪវាកើតមកចំសង្គ្រាមល្ងង់ ហើយកូន ។ កូនឯងកើតមកអត់មានសង្គ្រាមរៀនចុះ ។

ដានី ៖ កូនទាំង៣នាក់រៀនបានខ្ពស់ៗទាំង៣?

ភីន ៖ អត់ទេ រៀនបានខ្ពស់មួយនឹងទេ អាក្រោយព្រោះអាមុននេះយើងសមាហរណកម្មមក វាមកដឹបូងអត់សាលាអត់អីៗ យើងទៅជាស្រីវាមានប្តីទៅ ហើយអាប្រុសនេះបានរៀនភាសាគេទៅវិញ រៀនអង់គ្លេសៗ បានវាចេះអង់គ្លេស ក្រៅពីនឹងខ្មែរយើងរៀនបានថ្នាក់ទី៥

ដានី ៖ គាត់រៀន ឥឡូវគាត់ធ្វើការអីដែរអត់?

ភីន ៖ អត់ទេ នៅផ្ទះ បង្រៀនក្មេងនាយអាយៗ

ដានី ៖ បង្រៀនអង់គ្លេសទៅ?

ភីន ៖ បាទ!

ដានី ៖ ចុះបើតាមការចងចាំរបស់លោកពូ លោកពូចងចាំស្អីដែលលោកពូគិតថា ចងចាំជាងគេតាំងពីមុនសង្គ្រាមៗ ហើយចប់ពីសង្គ្រាមមក លោកពូគិតថាស្អីដែលលោកពូចងចាំ?

ភីន ៖ អារឿងសង្គ្រាមខ្ញុំដូចថាវាចាស់ក៏ចាស់ហើយ សង្គ្រាមក៏វាចប់ ខ្ញុំលើកលែងចោល លែងគិត លែងគូរអីច្រើនៗ គិតគូរមកសម័យទំនើបនេះវិញហើយ សម័យកសាងនេះ សម័យអភិវឌ្ឍន៍ៗ

ដានី ៖ លោកពូបំភ្លេចចោលអស់?

ភីន ៖ បាទ! យើងនឹកក៏វាមិនបានប្រយោជន៍អីច្រើន យើងវាចាស់ ហើយគិតទៅក៏វាមិនបានចំណេញអី ហើយគិតអភិវឌ្ឍន៍នេះជាមួយសម្តេច ហ៊ុន សែន វិញ ពូកែជាង មែនខ្ញុំគិតចឹងៗ

ដានី ៖ ចុះលោកពូដូចថាលោកពូបើនិយាយពីរឿងសិល្បៈ ភ្លេង ចំរៀងអី កាលពីលោកពូពីមុនឬក៏សម័យសង្គ្រាម សម័យ៣ឆ្នាំ ក្រោយមកលោកពូចូលចិត្តសិល្បៈ ចូលចិត្តអីដែរអត់?

ភីន ៖ ចូល ដូចគ្នា ប៉ុនកាលនោះវានិយាយវាមិនសូវដូចឥឡូវទេ ខុសគ្នារបៀបគេខុសគ្នាៗ

ដានី ៖ ចុះកាលពីមុនសង្គ្រាម លោកពូចូលចិត្តអីគេ?

ភីន ៖ មុនសង្គ្រាមដែលសិល្បៈក៏មានដូចគ្នា កាលជំនាន់ចាស់នោះ ខ្ញុំចូលចិត្តណាស់ប្អូន ចូលចិត្តសិល្បៈ ចូលចិត្តស្តាប់ព័ត៌មានៗ

ដានី ៖ ចូលចិត្តសិល្បៈប្រភេទអីគេដែលលោកពូចូលចិត្ត?

ភីន ៖ ហ៊ើ! ពីមុនប្រភេទដូចមិនសូវមានច្រើនប៉ុន្មានទេ ដូចយើងឥឡូវទេៗ

ដានី ៖ ដូចចំរៀង ល្ខោន អាយៃ ឬក៏កុន?

ភីន ៖ អឺ! ចូលចិត្តស្តាប់ចាប៉ីជាងគេ ខ្ញុំ ពីដើមៗ

ដានី ៖ ចូលចិត្តស្តាប់ចាប៉ី?

ភីន ៖ បាទ! ពីដើម ឲ្យតែដល់ថ្ងៃចាប៉ីអត់ចេញទេពីផ្ទះតា ។

ដានី ៖ តាណា?

ភីន ៖ តានៅស្រុកពីដើម ។

ដានី ៖ ឈ្មោះអីគេ?

ភីន ៖ ហើយមួយភូមិមានតែមួយទេ វិទ្យុមនុស្សមួយភូមិទៅស្តាប់ ។

ដានី ៖ ស្តាប់ចាប៉ីៗដងវែង នឹង?

ភីន ៖ អឺ! ចាប៉ីដងវែង លោកតាប្រាជ ឈួននឹង ។

ដានី ៖ ចុះដល់ពេលជំនាន់ពតឆ្នាំ?

ភីន ៖ ពតឆ្នាំយើងមានបទចំរៀង យើងមានសិល្បៈផ្សេងមកទៀត ។

ដានី ៖ លោកពូចូលចិត្តអីគេ?

ភីន ៖ យ៉េងចូលចិត្តស្តាប់អាតាមរបៀបគេសន្តមគេនឹងផ្សេងទៅទៀត ។ ដល់មកនឹងហើយក៏ចូលចិត្តស្តាប់អាចាប៉ីនឹងទៀត ។

ដានី ៖ ជំនាន់ពតឆ្នាំនឹង?

ភីន ៖ អឺ! ជំនាន់ពតឆ្នាំមានហើយអាចាប៉ីនឹង ។

ដានី ៖ មានចាប៉ីដែរ?

ភីន ៖ មានដូចគ្នា ។

ដានី ៖ ចុះក្រោយៗមក?

ភីន ៖ សម័យពតឆ្នាំ ក៏យកតា ប្រាជ ឈួន នឹងឲ្យច្រៀងដូចគ្នា ។ ប៉ុនគាត់ស្លាប់នៅ?

ដានី ៖ លោកតាប្រាជ ឈួន នៅ គ្រាន់គាត់ចាស់ គាត់លើសឈាម គាត់នៅតាកែវ ។

ភីន ៖ សម័យនឹងគេយកតានឹងច្រៀងដែរ អាចាប៉ីដែលថាខ្ញុំចូលចិត្តស្តាប់នឹង ។

ដានី ៖ ចុះក្រៅពីចាប៉ីចូលចិត្តអីទៀត សម័យពតឆ្នាំ?

ភីន ៖ ហ៎! ក្រៅពីចាប៉ីក៏ចូលចិត្តដែរ ប៉ុននិយាយអាណាដែលយើងចូលចិត្តជាងគេ ។

ដានី ៖ ចុះក្រោយមកឥឡូវៗនេះ?

ភីន ៖ ក្រោយមកឥឡូវនេះ បើមានគេចាក់ចាប៉ីនេះ ស្តាប់ចាប៉ីនឹងទៀត អាចំរៀងៗអីៗនោះយើងស្តាប់ហើយ ប៉ុនមានឥទ្ធិភាពជាងគេ គឺអានឹងឯងខ្ញុំ ហើយនឹងស្តាប់ពត៌មានប៉ុននឹងឯង ។

ដានី ៖ អត់មានផ្សាស់ប្តូរ?

ភីន ៖ អឺ!

ដានី ៖ នៅដល់ឥឡូវ?

ភីន ៖ ផ្លាស់ចឹងបានខ្ញុំតែងនិយាយលេងមិញ បានខ្ញុំថាឲ្យអ្នកតែងអ្នកនេះអត្ថបទ គិតរឿងដីរឿងថ្មីខ្លះផង គិតតែស្នេហាច្រើនពេកពិបាកប្រដៅកូន តែប៉ុននឹងទេ តែអាសប្បាយៗហួស ។

ដានី ៖ ចឹងលោកពូគិតថា ឥឡូវនឹងវាមានការផ្លាស់ប្តូរខាងសិល្បៈ ដូចគេតែងចំរៀងអីមិនសូវជាគិតគូររឿងទឹកដីៗថ្មី ប្រទេសជាតិអីប៉ុន្មាន គិតតែរឿងសេហា?

ភីន ៖ បាទ! រឿងស្នេហា គេយកលុយគេធ្វើអ្នកមានៗអស់ ។

ដានី ៖ ចឹងពីមុនមកអត់សូវទេ?

ភីន ៖ អត់សូវទេ ។

ដានី ៖ ពីមុនមកលោកពូចង់សំដៅទៅលើពីសម័យណា?

ភីន ៖ សម័យមុន សម័យសម្តេចសីហនុ គាត់គិតរឿងដីថ្មីច្រើនដែរ ហើយគេតែងគេអីៗ ហើយបើមកសម័យពាន្ឆាំ អានឹងទាំងអស់ទាំងស្រុកហើយ មិនសូវមានស្នេហាទេ ។ មកសម័យនេះគេគិតដែរ ប៉ុនគិតដោយបុគ្គលខ្លះទេ ប៉ុនបើមេប្រាប់ឲ្យគិតបានគេគិត ។

ដានី ៖ បើមេអត់គិត?

ភីន ៖ មេអត់ប្រាប់អត់ទេ ។

ដានី ៖ ចុះការហូបចុកបើនិយាយពីការហូបចុកវិញ ចំពោះលោកពូវិញ ការហូបចុក ពីមុនសង្គ្រាមសម័យពាន្ឆាំ ហើយក្រោយមក មានការខុសគ្នាម៉េចដែរ?

ភីន ៖ ហបចុក បើតាមគិតខ្ញុំមកវិញ វាអាខ្វះខាតតិចតួចពេលសង្គ្រាម ខ្ញុំលើកលែងសឹងតែលែងនិយាយហើយ វាពិបាកក្នុងសង្គ្រាមវារឿងផ្សេង អត់មានបុគ្គលណាមួយចង់បង្អត់ទេ ។ តែវាកាលៈទេសៈវាចឹង យើងមិនដឹងចោទទៅលើអ្នកណា ។

ដានី ៖ កាលលោកពូនៅផ្ទះយើងហូបស្រួល?

ភីន ៖ មានម៉ែ មានឪ មានបងមានប្អូន ។

ដានី ៖ ដល់ពេលលោកពូចូលមកតស៊ូ?

ភីន ៖ បែកមកយើងគិតគូរខ្លួនយើង ដោះស្រាយខ្លួនឯង ។

ដានី ៖ សម័យពាន្ឆាំ?

ភីន ៖ សម័យពាន្ឆាំ កន្លែងខ្ញុំនៅក៏អត់មានពិបាកថាស៊ីបបរដូចគេដែរមិនមានទេ កន្លែងនឹង តែបើកន្លែងគេផ្សេង គេថាពិបាកដែរ ។

ដានី ៖ ចុះដល់ក្រោយមកពេលដែលយើងមកនៅតាមព្រំដែន?

ភីន ៖ បាទ! មកនៅតាមព្រំដែននេះក្រោយពីគេជួយ កាកបាទក្រហមគេជួយមក ហើយនឹងមានខាងយើងរស់នៅគេជួយ អត់មានពិបាកអីទេ ។

ដានី ៖ ដល់ពេលឥឡូវ?

ភីន ៖ ឥឡូវយើងធ្វើហូបខ្លួនយើងវិតតែអត់ពិបាក ៗ អ្នកមួយចំនួនដែលមិនធ្វើ គឺពិបាក ។

ដានី ៖ តែយើងធ្វើខ្លួនឯងអត់បញ្ហា?

ភីន ៖ បាទ! មិនពិបាកទេ ព្រោះរដ្ឋាភិបាលអត់មានគៀបកាតរឿងធ្វើដង ឲ្យយើងធ្វើមានបានម៉េចមានទៅ ។

ដានី ៖ ចឹងលោកពូគិតថា ការរបបហូបចុកចំពោះលោកពូ គ្រួសារលោកពូ មានការប្រែប្រួលអត់ បើគិតតាំងពីក្មេងមក សម័យ៣ឆ្នាំក្រោយមក ហើយនឹងបច្ចុប្បន្ននេះ វាខុសគ្នាម៉េច?

ភីន ៖ ទេ! ខ្ញុំបើគិតឲ្យខ្ញីទៅ វាហូបគ្រប់គ្រាន់រហូតហើយខ្ញុំ មិនខ្វះទេ ខំធ្វើទោះបពិការនឹងក៏នាំកូនចៅធ្វើកុំឲ្យខ្វះ ពិបាកណាស់ខ្វះ ។

ដានី ៖ លោកពូគិតថា ពីមុនមកយើងមានរបបក៏យើងបានហូបគ្រប់គ្រាន់?

ភីន ៖ បាទ!

ដានី ៖ ឥឡូវនឹងលោកពូពិការក៏លោកពូធ្វើការ បង្កបង្កើនផលខ្លួនឯង បានហូបក៏?

ភីន ៖ បាទ! ខំធ្វើ ហូបបានគ្រប់ដែរ តែមិនបានលក់ដូរអីគេធំដុំទេ ។

ដានី ៖ តែជីវភាពក៏វាមិន?

ភីន ៖ បាទ! មិនពិបាកប៉ុន្មានទេ យើងថាហូបគ្រប់បានហើយ តែវាមិនមានអីធំដុំប៉ុននឹងឯង ។

ដានី ៖ ចុះលោកពូមានរៀបចំជាដូចថាបុណ្យទាន យើងតាមប្រពៃណីអី យើងធ្វើបុណ្យយើងធ្វើបុណ្យមានម្ហូបអាហារអីដែរ ឬក៏ធ្វើ យើងរៀបចំធ្វើ?

ភីន ៖ មានតើ ។

ដានី ៖ ដូចជាពេលបុណ្យភ្ជុំបិណ្ឌ ឬមួយក៏ចូលឆ្នាំអី យើងធ្វើម្ហូបទៅវត្ត?

ភីន ៖ មាន ដួបជុំបងប្អូន ញាតិមិត្តជិតខាងទៅនាំគ្នាហូបទៅ ហ៎! បើមានគេអ្នកដឹកទៅគ្រៀវមួយយប់២យប់អីចឹងទៅ ។ នេះខ្ញុំនិយាយកាត់បន្តិច នាង១ដែលមកសួរថានេះនឹង គាត់ទៅចូលរួមជាមួយខ្ញុំធ្វើបុណ្យភ្ជុំ គាត់មកចំភ្ជុំ គាត់ឆ្ងល់គាត់ថាធ្វើបុណ្យច្រើនដងអ្នកអន្លង់វែង ខ្ញុំថាសាសនាដូចគ្នាតើនាង ។ ធ្វើចេះឯង គាត់ចូលរួមបុណ្យទៅហើយជាមួយខ្ញុំ ។

ដានី ៖ លោកពូទាក់ទងនឹងរឿងសុខភាពវិញ ។ ដូចថាកាលពីក្មេងមកលោកពូមិនទាន់ពិការ នៅផ្ទះហើយក្រោយមកជំនាន់៣ឆ្នាំ ហើយក្រោយមកពេលសង្គ្រាមវៀយួន ហើយក្រោយយើង

បានសន្តិភាពសមាហរណកម្មហើយ ។ សុខភាពលោកពូ បើលោកពូគិតមើលទៅវាយ៉ាងម៉េចដែរ?

ភីន ៖ សុខភាព អានឹងខ្ញុំជម្រាបតិច ព្រោះសម័យសង្គ្រាមយើងពិបាកណាស់ ឈឺជាៗឈឺវាវិលទៅវិលមកនឹងឯង ។ ដល់មកសម័យឥឡូវ បើប្រៀបធៀបថាមនុស្សជាលចឹងដូចប្អូនឯងចឹងវាអត់មានអីហើយ ប៉ុន្តខ្ញុំនៅតែឈឺៗ ។

ដានី ៖ លោកពូនៅឈឺ?

ភីន ៖ នៅតែឈឺ ជើងយើងពិការមានអីអត់បាត់ទេ ចុះធម្មតាដើរជើងពីរទ្រទ្រង់ខ្លួនមនុស្សមួយឥឡូវមកទ្រតែមួយ ឈឺរហូត ។

ដានី ៖ ឈឺជើងនឹង?

ភីន ៖ បាទ!

ដានី ៖ ឈឺជើងហើយក៏ឈឺកន្លែងផ្សេងទៀត?

ភីន ៖ ជើងតែម្តង កន្លែងផ្សេងមិនមានឈឺទេ ត្រូវគ្រាប់ដែរប៉ុនវាអត់ឈឺ វាឈឺតែកន្លែងនឹងជាងគេ ។

ដានី ៖ ចឹងលោកពូមានបញ្ហា បើយើងប្រៀបធៀបពីមុនសង្គ្រាម ហើយក្រោយសង្គ្រាម ជំនាន់សង្គ្រាម ហើយនឹងបន្ទាប់មក យើងបានសន្តិភាពនេះ សុខភាពលោកពូមានបញ្ហាខុសពីមុនចឹងលោកពូ?

ភីន ៖ ខុសត្រង់យើងពិការហើយវាខុសត្រង់នឹង ប្រែប្រួលវាឈឺប្រើថ្នាំរហូត បើពីមុនរបួសអត់មានអី មានធម្មតាដូចយើងដូចប្អូនឯង ពេលឈឺពេលជាធម្មតា ។

ដានី ៖ ក្រៅពីជើងនេះអត់មានបញ្ហាទេ?

ភីន ៖ មិនមានទេ មិនមានកើតអេដស៍កើតអីនឹងគេ ។

ដានី ៖ អត់ទេ ខ្ញុំចង់និយាយថា ដោយសារសុខភាពលោកពូ ជើងនឹងវាឈឺ ខស្សាហ៍ឈឺដែរជើង?

ភីន ៖ ឈឺអានឹងតើ ចុះបែកឆ្អឹងៗវាអត់ចេះជា ហើយយើងមនុស្សចាស់ហើយវាអត់ដុះទេ វាបែកម៉េចនៅចឹងហើយ ។ ហើយពេទ្យគេចងយើងចំណង២-៣គេមានកាត់ចេញណា ចងឆ្អឹង វានៅនឹងរហូត ។

ដានី ៖ លោកពូខស្សាហ៍ទៅពេទ្យ?

ភីន ៖ ដែល មិនសូវទៅដេកទេ បើទៅយកថ្នាំគេទៅ ។

ដានី ៖ ឥឡូវនឹង?

ភីន ៖ បាទ! ឥឡូវនឹងព្រោះយើងមាន ខ្ញុំអត់មានលុយកាក់អីប៉ុន្មានទេ ខ្ញុំចូលអាប័ណ្ណធានារ៉ាប់រងសុខភាពយើងទៅពេទ្យយើងអត់អស់លុយទេ យើងបង់លុយឲ្យគេមួយឆ្នាំ១០០០០យើងទៅបាន១ឆ្នាំ អត់អស់លុយ ។

ដានី ៖ លោកពូទៅពេទ្យនឹង យើងទៅប៉ុន្មាន ១ឆ្នាំទៅប៉ុន្មានដងទៅ?

ភីន ៖ បើឈឺពេលណាទ្រាំមិនបានយើងទៅពេលនោះហើយ ។

ដានី ៖ បើតាមប៉ាន់ស្មានទៅម៉េច?

ភីន ៖ បើយើងធ្វើការធ្ងន់ខ្លាំង ម៉ាឆ្នាំទៅ៤-៥ដង ចូលពេទ្យ ។ បើយើងមិនសូវធ្វើការ ការងារស្រាលអត់សូវឈឺទេ ។

ដានី ៖ ទៅពេទ្យនៅណា?

ភីន ៖ ពេទ្យយើងអន្លង់វែង ។

ដានី ៖ អត់មានដែលទៅពេទ្យខាងភ្នំពេញសៀមរាប?

ភីន ៖ នៅទេ មិនឈានដល់ត្រង់ហ្នឹងទេ ។

ដានី ៖ យើងទៅពេទ្យនឹង យើងទៅយកតែថ្នាំទេ មានទៅសម្រាកនៅពេទ្យដែរ?

ភីន ៖ មិនទេ យើងឈឺល្មមៗ យើងមិនបាច់សម្រាកទេ ។

ដានី ៖ ចុះសុខភាពផ្លូវចត្តវិញយ៉ាងម៉េចដែរ សុខភាពផ្លូវចិត្តលោកពូធម្មតា ឬក៏មានបញ្ហា?

ភីន ៖ អូ! លែងមានអីហើយ សុខភាពផ្លូវចិត្តគេចប់សង្គ្រាម អត់មានពិបាកអីទៀតទេ ។

ដានី ៖ ដូចអត់មាន ដូចថាយើងមានឱតដាមពីមុនមក ដែលធ្វើឲ្យយើងប៉ះពាល់សុខភាពផ្លូវចិត្តផ្នែកសតិអារម្មណ៍?

ភីន ៖ គ្មានទេប្អូន ពីមុនប៉ះពាល់ ប៉ុនដល់មកចប់ចេះទៅប៉ះពាល់អីទៀត អត់មានគិតអីច្រើនយករឿងគេមកគិតជាមួយដើម្បីឈឺខ្លួនឯង អត់ទេ ខ្ញុំ ។

ដានី ៖ អត់ទេ?

ភីន ៖ បាទ! អត់យករឿងគេមកគួបផ្សំ អានឹងងាប់ៗមុនអាយុ អត់ ។

ដានី ៖ លោកពូអត់ទេ កាត់ដាច់អត់មានគិតគូរ?

ភីន ៖ បាទ! មិនទេ ។

ដានី ៖ ចឹងអត់មានប្រែប្រួល កាលពីលោកពូនៅក្មេង ហើយសម័យ៣ឆ្នាំ ហើយក្រោយសម័យសង្គ្រាម ហើយមកដល់ឥឡូវនឹង លោកពូអត់មានប្រែប្រួលទេ សុខភាពផ្លូវចិត្តនៅធម្មតាអត់មានបញ្ហាអីទេ?

ភីន ៖ បាទ! មិនមានប្រែអីទេ ។

ដានី ៖ លោកពូធ្លាប់មានបញ្ហាដូចថាជាបញ្ហា ដូចថាយើងចងចាំនូវព្រឹត្តិការណ៍គួររន្ធត់ ឬក៏អាក្រក់អីពីមុនមកមានចងចាំជាប់ក្នុងចិត្ត?

ភីន ៖ រន្ធត់ខ្លាំងជាងគេ រន្ធត់ទម្លាក់គ្រាប់បែក អ! ភ័យណាស់ប្អូនអើយ គ្រាប់បែកមួយគ្រាប់ៗរន្ធើរដល់អន្លង់វែង ។

ដានី ៖ នៅណា?

ភីន ៖ នៅឆ្នាំ គេទម្លាក់គ្រាប់បែកឆ្នាំណា ៧៣ ។

ដានី ៖ នៅណា?

ភីន ៖ នៅស្រុកយើង ឯងកើតមិនទាន់ចឹង អត់ដឹង មិនមែននៅនេះ ។

ដានី ៖ កាលនៅ?

ភីន ៖ សម័យសង្គ្រាម ។

ដានី ៖ សម័យសង្គ្រាម?

ភីន ៖ បាទ! សង្គ្រាមអាមេរិចកាំងខ្លាំងណាស់ប្អូនអើយ រស់ដល់សព្វថ្ងៃនេះ ដូចថាមនុស្សរស់ពីងាប់ហើយ មនុស្សពេលប្រទេស ។ មើល មិនបាច់និយាយណាច្រើន គ្រាន់តែសម្ដេច ហ៊ុន សែន គាត់របួសដែរ សម័យនោះ ។

ដានី ៖ ចឹងលោកពូ អារម្មណ៍យើងរន្ធត់អីមានតាំងពី ជាពិសេសជំនាន់ទម្លាក់គ្រាប់បែក?

ភីន ៖ បាទ! រន្ធត់អានឹងម៉ង ដូចអ្នកនៅអាមេរិចអីគេថា គេរន្ធត់សម័យខ្មែរក្រហមសម្លាប់ អានោះវាជាងនឹងទៅទៀតលោកអើយ ។ ឥឡូវប្អូនឯងមិនជឿ សួរឪពុកម្ដាយដឹងហើយ ខ្ញុំនិយាយថាខ្ញុំកុហក់ អត់កុហកទេ ។

ដានី ៖ ការងារលោកពូ ដូចថាក្រៅពីការងារស្រែចំការ មានធ្វើការងារអីផ្សេងទៀត?

ភីន ៖ អត់មាន ខ្ញុំតែ២នាក់នៅ ផុតតែពីធ្វើស្រែហើយនៅហើយ ។

ដានី ៖ ចុះលក្ខខណ្ឌជីវភាពរស់នៅអី យើងក្រៅពីធ្វើស្រែចំការយើងអត់មានប្រកបអីទៀតទេ?

ភីន ៖ ទេ! វ៉ៃ ដូចរកស៊ីរបស់របរបន្ទាប់បន្សំចេះប្អូន រកថាមិនត្រូវ រកអានេះតិច អានោះតិច ប៉ុន្តែឲ្យមែនទែន យើងធ្វើស្រែនឹងមែន អានឹងមុខរបរយើងមែនទែន ។

ដានី ៖ ចុះលោកពូមើលឃើញថា ជាទូទៅនៅអន្លង់វែងយើង មានការខុសប្លែក មានការប្រែប្រួលមុខមាត់អីបន្ទាប់ពីសម័យមុនសមាហរណកម្ម ក្រោយសមាហរណកម្ម ហើយមកដល់ឥឡូវនឹង មានការប្រែប្រួលអីយ៉ាងម៉េច?

ភីន ៖ ទេ! វាប្រែហើយឥឡូវនេះ ឃើញអភិវឌ្ឍន៍បានច្រើន មានផ្លូវដើរ មានមន្ទីរពេទ្យ សាលារៀនអី វាច្រើនហើយ អភិវឌ្ឍន៍បានច្រើនហើយ ។

ដានី ៖ ចុះចំណែកផ្នែកជីវភាពប្រជាជនមានការប្រែប្រួលទេ?

ភីន ៖ ជីវភាពក៏ តែមានផ្លូវគមនាគន៍ល្អរីកចំរើនហើយ ជីវភាពក៏ឡើងតាមនឹងដែរប្អូន គេធូរធារច្រើនតើ ប៉ុនមិនទាន់មានស្អីដល់ទៅណាមែន ប៉ុនធូរធារភាគច្រើន ។

ដានី ៖ ចុះដូចជាផ្នែកក្រៅពីមន្ទីរពេទ្យ សាលារៀន ផ្លូវថ្នល់ មានដូចជាកន្លែង ជារោងចក្រដូចជាសហគ្រាសអីផ្សេងៗ មានបង្កើតអីនៅអន្លង់វែង?

ភីន ៖ អឺ! កន្លែងនេះយើងឃើញថា បើការងារអីធំដុំមែនទែនដូចភ្នំពេញអីយើងមិនទាន់ឃើញព្រោះយើងនៅព្រំដែន ។ ម្យ៉ាងគេអ្នកមានគេមិនទាន់ចាប់អារម្មណ៍អីប៉ុន្មាន ព្រោះយើងព្រំដែនពេក ។ បើតាមឲ្យថាមានអាក្រោមៗពីសហគ្រាសនឹងមក ការលក់ដូរលក់អីឃើញគេរីកចំរើនណាស់អន្លង់វែង ។

ដានី ៖ គេមានដូចជាការលក់ដូរ ដោះដូរទំនិញអីរីកចំរើនច្រើន?

ភីន ៖ ច្រើន ។

ដានី ៖ ប៉ុន្តែគេដូចជារបៀបទន់ខ្សោយ ជារោងចក្រ ជាអីបង្កើត?

ភីន ៖ អឺ! អានឹងមិនទាន់មានទេ ព្រោះយើងមើលឃើញវាជិតព្រំដែនពេក គេអ្នកបង្កើតគេមិនសូវហ៊ាន បើតាមថាឲ្យស្រុកស្រួលបួលគេត្រូវបង្កើតធ្វើល្អណាស់នៅនេះ ប៉ុនគ្រាន់ថាគេមិនទាន់ចិត្តដាច់ថាធ្វើ ។

ដានី ៖ ប៉ុន្តែគេមានកាស៊ីណូ ជាផលល្អ ឬក៏ជាផលអាក្រក់ម៉េច?

ភីន ៖ បើចំពោះគេអ្នកលេងសើចគេល្អរបស់គេ ។

ដានី ៖ បើអ្នកអត់លេងសើចម៉េចទៅ?

ភីន ៖ បើអ្នកអត់សូវលេងម៉េចនឹងសប្បាយ បើអត់បានទៅ ។

ដានី ៖ និយាយថា បើសិនជាការកើតកាស៊ីណូនឹងវាជាផលល្អ បានន័យថាវាអាចជួយឲ្យស្រុកទេសយើងចំរើន ហើយជួយឲ្យប្រជាជនមានការងារធ្វើ កូនចៅយើងជំនាន់ក្រោយមានការងារធ្វើ ឬយ៉ាងម៉េច ឬក៏វាអាចថាប៉ះពាល់ បង្កើតជាកាស៊ីណូទៅ ធ្វើឲ្យប្រជាជនចូលលេងល្បែង ហើយកាន់តែក្រ ហើយស្រុកទេសវាបាត់សណ្តាប់ធ្នាប់ដោយសារបញ្ហានឹង?

ភីន ៖ បាទ! អានេះខ្ញុំនិយាយឲ្យវែងតិច កាស៊ីណូនេះ បើគេនិយាយពីសម័យដើម ប្អូនឯងកើតមិនទាន់ ខ្ញុំទាន់តិចៗ ។ ពួកនៅកាស៊ីណូ សុទ្ធតែពួកកាប់ដាវហើយ ពួកហក់លោត បានទៅកាស៊ីណូបាន ព្រោះត្រូវកាប់ៗ កាស៊ីណូត្រូវចាក់ៗ របៀបដូចដណ្តើមផលគេ ។ ប៉ុនឥឡូវនេះគេមានច្បាប់ទម្លាប់គ្នាល្អ គេបង្កើតកាស៊ីណូដោះដូរ ពាណិជ្ជកម្មលុយកាក់អី ។ ហើយកាស៊ីណូនេះ បើប្រវត្តិវាបង្កើតមិនមែនល្អទេ ផលអាក្រក់ដែរតើ បើនៅប្រទេសគេ

កើតមុន ពួកនេះគេរកស៊ីរបស់អាក្រក់ៗ បានលុយច្រើន ធនាគារគេអត់ទទួលទេ យកមកដោះដូរគ្នានៅកន្លែងកាស៊ីណូត្រង់នេះ កន្លែងកាស៊ីណូនឹង ។ អានេះខ្ញុំនិយាយឲ្យវែងតិចចុះ ផលអាក្រក់របស់វាត្រង់នឹង ប៉ុនផលល្អរបស់វា រកការងារឲ្យមនុស្សធ្វើបានច្រើន កាស៊ីណូចឹងឯង ។

ដានី ៖ ប៉ុនកាស៊ីណូឥឡូវ កូនចៅយើងនៅស្រុកភូមិនេះ?

ភីន ៖ កូនចៅស្រុកភូមិនេះបានធ្វើត្រឹមកម្មករ ប៉ុនដល់ធ្វើមែនទែនអ្នកមកពីឆ្ងាយ មកពីស្រុកយើងក្នុងៗមក គេអ្នកចេះដឹងច្រើន យើងនៅនេះមិនសូវបានរៀនសូត្រស្អី មិនបានចូលបានទេ ធ្វើកម្មករគេ អានឹងធ្វើមែនហើយ ។

ដានី ៖ ចុះអ្នកចំណាកស្រុកចូលមកខាង?

ភីន ៖ ចំណាកស្រុកច្រើន បើចំពោះមនុស្សនៅនេះអត់សូវច្រើន បងប្អូនយើងមកពីក្នុង ច្រើន កំពង់ចាម កំពង់ធំ និយាយរួមយើងថាទាំងអស់ពេញប្រទេសហើយមកនៅកន្លែងនេះ ប៉ុនគ្រាន់ថាតិចច្រើនជាងគ្នា ។

ដានី ៖ មកពីច្រើនកន្លែង មកពីកំពង់ចាម កំពង់ធំ?

ភីន ៖ បាទ! មកពីច្រើនកន្លែង មករស់នៅនេះ ហើយច្រើនគេអ្នកគួរសមផង មិនមែនអ្នកអត់ទេ ប្អូនឯងមើលអ្នកណាអន់ៗសុទ្ធតែអ្នកនៅនេះកំណើតហើយ ។

ដានី ៖ លោកពូយល់ឃើញថាហេតុអីបានគេធ្វើចំណាកស្រុកមកនៅនេះ?

ភីន ៖ កន្លែងនេះស្រួលរកស៊ី ។

ដានី ៖ កន្លែងនេះស្រួលរកស៊ី?

ភីន ៖ បាទ! ស្រួល ចំពោះគេអ្នកធ្លាប់រកស៊ីផ្សារគឺថាស្រួលរបស់គេម៉ង មករកដឹងថាមានរបស់គេ ចំពោះយើងអ្នកនៅនេះមិនសូវប្រសព្វរកអត់ចេះ ដឹងថាធ្វើតែស្រែចំការមួយមុខ ពីរមុខប៉ុននឹង ។

ដានី ៖ ចំពោះលោក យើងគិតថាចុះពួកអ្នកចំណាកស្រុកមករកស៊ីនឹងផងល្អ ផលអាក្រក់ម៉េចដែរចំពោះយើង?

ភីន ៖ បើនិយាយពីមុនមក មិនមានអីទេ មកធម្មតាទេ ប៉ុនមកឥឡូវប៉ុន្មានឆ្នាំ ថាប៉ុន្មានខែចុះ និយាយប៉ុន្មានឆ្នាំវាយូរពេក ។ ប៉ុន្មានខែចុងក្រោយ ដូចថាមុខរបររកស៊ីវាមិនសូវស្របច្បាប់នឹងវាខ្លាំង ធ្វើឲ្យខូចសណ្តាប់ធ្នាប់ដែរតើ ។ ស្លាប់ច្រើនណាស់ណា លើភ្នំនេះ ។

ដានី ៖ ស្លាប់រឿងអីទៅ?

ភីន ៖ ដោយសារក្រញូងឈើ ស្លាប់រហូតអ្នកខ្លះអត់បានយកគ្នាទេ ខ្លះថៃគេបាញ់ចោលគេដឹកមកឡូ ខ្លះទៀតអត់ ។

ដានី ៖ យើងចូលទៅកាប់ក្រញូងហើយម៉េច?

ភីន ៖ កាប់ក្រញូងស្រុកគេ មិនរកតែស្រុកយើង រកស្រុកគេ ។ ហើយស្រុកគេអត់ចាប់ទេ គេបាញ់យើងចោល ផាប់ខ្ញុំអនោចអធម្ម រដ្ឋាភិបាលគេទប់ស្កាត់មិនបាន ទាហាននៅព្រំដែនមិនដឹងជាបែបម៉េច បានមនុស្សបេះតែចូលបាន ។

ដានី ៖ មានបញ្ហាបាត់សណ្តាប់ធ្នាប់?

ភីន ៖ បាទ! ច្បាំងគ្នាជាមួយថៃប៉ុន្មានឆ្នាំ អត់មានស្លាប់ដល់ប៉ុននឹង ច្បាំងជាមួយក្រញូងស្លាប់ស្ទើរតែភ័យ ហើយរួមអ្នកនៅនេះខ្លះផង អ្នកនៅពីឆ្ងាយនេះខ្លះផងបូកផ្សំគ្នា ។

ដានី ៖ អ្នកមកពីអន្លង់វែងមានពូកែប្រកាន់ក្រុមនេះក្រុមនោះ សាសនានេះសាសនានោះចូលមកចូលចិត្តមិនចូលចិត្តហើយអត់ទេ?

ភីន ៖ គ្មានទេ ។ ឃើញអ្នកណាគេមកឃើញដាក់ទៅ អ្នកណាគេមកដាក់សាសនាទៅ អត់ដែលឮថាម៉េច លោកចៅហ្វាយស្រុកក៏គាត់មិនដែលឮថាម៉េចដែរ បើយេស៊ូមកសុំដាក់យេស៊ូៗទៅ ។

ដាន់ ៖ ចុះទាក់ទងពីទំនាក់ទំនងជាមួយថៃវិញយ៉ាងម៉េចដែរ ដូចថាកាលពីមុនៗសម័យខ្មែរក្រហមក្នុងសម័យ៣ឆ្នាំ ហើយសម័យសង្គ្រាម ហើយក្រោយមកការទាក់ទងជាមួយថៃ នៅយើងជាមួយអន្លង់វែងនេះយ៉ាងម៉េចដែរ?

ភីន ៖ សម័យខ្មែរក្រហមខ្ញុំអត់ដឹងទេ នៅព្រំដែនថៃប៉ុនបើសម័យក្រោយពីយើងនេះមកនៅតាមព្រំដែន ឃើញថាទាក់ទងគេធម្មតា អត់មានទាស់ខុសអីគេទេ ។

ដានី ៖ ចុះទាក់ទងពីទស្សនៈរបស់អ្នកស្រុកអ្នកភូមិវិញ ជាមួយថៃយ៉ាងម៉េចដែរ ទស្សនៈអ្នកស្រុកអ្នកភូមិយើងនៅអន្លង់វែងជាមួយ?

ភីន ៖ ពីមុនមិនដែលឮនិយាយទេប្អូន មកដល់សង្គ្រាមឈ្លានពាននេះ នឹកឃើញខឹងតើ សង្គ្រាមឈ្លានពានទឹកដីនេះខឹង ។ ខឹងហើយ បើមកពីមុនមកអត់ទេ គ្មានអ្នកណានឹកឃើញចងកម្មចងពៀរអីជាមួយថៃ ប៉ុនមកឥឡូវនេះនឹកឃើញខឹង ដីនៅសុខៗគេថាដីគេចឹងទៅ សូម្បីតែលើនេះចង់អស់កន្លែងយើងនៅ នេះកុំធ្វើកាស៊ីណូបាំងថៃរុញមកដល់ពើយ ដេញធ្លាក់ពីពើយទៀត មិនធម្មតាទេ ។

ដានី ៖ យើងអត់ទប់ទល់បាន?

ភីន : ទេ! វាបានហើយឥឡូវនេះ ប៉ុនគ្រាន់ថា វានៅឈ្លោះរហូត មិនដឹងដោះអន្លាល់នឹងបាន ឈប់ឈ្លោះ ។

ដានី : វាចេះបន្តយើងឲ្យស្មុគស្មាញ?

ភីន : បាទ! យូរៗវាម្តងចឹងទៅ យូរៗវាកេះម្តងចឹងទៅ ប៉ុនគ្រាន់គាប់ជួនអីឈ្លោះនៅព្រះវិហារ នៅនេះវាអត់ច្បាំងទេ ។

ដានី : ចុះបើទាក់ទងពីប្រជាជនហើយប្រជាជនវិញយ៉ាងម៉េចដែរ?

ភីន : ធម្មតា ប្រជាជនហើយប្រជាជន ខូចតែមន្ត្រីរាជការគេមកថាដីគេតែប៉ុននឹង ហើយដីយើង សោះ ដីដែលយើងស្គាល់ថារបស់យើងហើយ ។

ដានី : ចុះទាក់ទងពីខាងនយោបាយវិញ បញ្ហានយោបាយដូចជាប្រជាជនយើង សហគមន៍យើង នៅអន្លង់វែង ដូចថាយល់ឃើញយ៉ាងម៉េចដែរ ទាក់ទងពីខាងនយោបាយ?

ភីន : ជាមួយថៃ ។

ដានី : អត់ទេ នយោបាយទូទៅយើង ទាំងក្នុងស្រុក ទាំងក្រៅស្រុកអី?

ភីន : ទេ! បើក្រៅស្រុកខ្ញុំមិនសូវដឹងទេ នយោបាយ លើមេៗគេទៅប៉ុនក្នុងស្រុកយើងមិនដែល ឮអ្នកណាទំនាស់ទាស់ទែងអីទៀតទេ គ្មាន ។

ដានី : ទាក់ទងនឹងរឿងគណបក្សអីអត់ទេ?

ភីន : ទេ! គណៈគេមាន ប៉ុន្តែដូចអត់មានឈ្លោះកាប់ចាក់គ្នាអីទេនេះ ។

ដានី : អត់មានព្រឹត្តការណ៍ បញ្ហានយោបាយអី ប៉ះពាល់ដល់យើងអ្នកស្រុកអ្នកភូមិ ឬក៏ស្រុក អន្លង់វែងទាំងមូល?

ភីន : អឺ! តាមខ្ញុំមើលទៅដូចមិនមាន គណបក្សគេមានដែរ ប៉ុន្តែដូចអត់មានឈ្លោះគ្នា អ្នកណា មកគណបក្សប្រជាជនមកៗ បើអ្នកណាទៅណា ក៏ទៅៗ ឃើញគណបក្សសមរង្ស៊ី ឃើញ គណបក្សហ៊ុនស៊ីនប៉ិចអីដែរ ប៉ុនដូចមិនមានដល់ទៅកាប់ចាក់គ្នា សម្លាប់គ្នាមិនមាន អត់មាន ដែលឃើញ ។

ដានី : ចុះដូចជាខាងអាជ្ញាធររដ្ឋបាល ដូចជាខាងស្រុក ខាងភូមិខាងឃុំអីដូចថា លោកពូនៅចាំថា ខាងអាជ្ញាធរណា អ្នកដឹកនាំនៅសហគមន៍មួយណា ដែលលោកពូគិតថាគាត់ជាអ្នកដឹកនាំ សំខាន់នៅក្នុងអន្លង់វែងយើងមក តាំងពីមុន ឬក៏សម័យ៣ឆ្នាំ ឬក៏សម័យសង្គ្រាម ឬក៏ ក្រោយមក?

ភីន : តំបន់នេះ ខ្ញុំអត់ស្គាល់ទេ ខ្ញុំទើបមកយើងឆ្នាំ៨០ ខ្ញុំអត់ដឹងទេ ពីមុនមកយើងរៀបចំអីៗ យើងអត់ដឹង យើងអត់ស្គាល់ទេ យើងទើបមកកាលសម័យសង្គ្រាមមកដល់ឥឡូវ ។

ដានី ៖ បាទ! ប៉ុន្តែចាប់ផ្តើមពីលោកពូមកដល់ឥឡូវ លោកពូគិតថា មេដឹកនាំមួយណាដែលសំខាន់ដែល?

ភីន ៖ ទេ! បើគិតអានឹងទាល់តែគិតតាមសង្គមវិញ តាមរបបវិញ យើងនៅពីមុនរបបផ្សេងទាល់មកដល់ឥឡូវនេះរបបផ្សេង អាអ្នកដឹកនាំក៏គេផ្សេងគ្នាចឹងទៅ ។

ដានី ៖ បាទ! អត់ទេ ខ្ញុំចង់ដឹងថា បើតាមដែលលោកពូឆ្លងកាត់មក ឆ្លងកាត់ពីមួយៗមក លោកពូគិតថា នៅអន្លង់វែងនេះ មេដឹកនាំមួយណា ដែលគិតថាជាសារៈសំខាន់ជាងគេ?

ភីន ៖ ឥឡូវយើងគិតបេះវិញបានដឹង គិតថា បើយើងជ្រើសរើសមួយណាល្អ មួយណាអាក្រក់ យើងមើលពីការអភិវឌ្ឍន៍វិញ បានយើងដឹង ។ មកសម័យនេះបានអភិវឌ្ឍន៍ច្រើនជាងគេ សម័យយើងមុននោះអភិវឌ្ឍន៍អីអត់បានធ្វើអីទេ ធ្វើបានតិចតួចណាស់ព្រោះវាក្នុងលក្ខណៈសង្គ្រាមផង ។ ដល់មកឥឡូវនេះ លក្ខណៈវាចប់សង្គ្រាមហើយ វាស្រួលបួលហ៎យ គ្មានអ្នកណាជាងសម្តេចហ៊ុន សែនទេ អភិវឌ្ឍន៍បានច្រើន ។

ដានី ៖ សម្តេចហ៊ុន សែន គាត់អ្នកដឹកនាំទូទាំងប្រទេស ។ ខ្ញុំចង់និយាយតែអន្លង់វែង តែមេដឹកនាំមួយណាលេចធ្លោរជាងគេ ដូចថាមិនប្រកាន់ថាគាត់ដឹកនាំឥឡូវនេះ ឬក៏ដឹកនាំពីមុនមក ចង់ដឹងក្នុងទស្សនៈប្រជាជនវិញ ទស្សនលោកពូជាបុគ្គលវិញ មេដឹកនាំមួយ ដែលគាត់លេចធ្លោរជាងគេនៅអន្លង់វែង ដែលប្រជាជនចងចាំ ចូលចិត្តគាត់ជាងគេ?

ភីន ៖ ឥឡូវយើងពីសមាហរណកម្មមក អត់ទាន់ផ្លាស់ទេមេនៅ អានឹងយើងនិយាយមេស្រុក មេឃើម ផាណាទេ គឺគាត់នៅធ្វើបានមករហូតរបស់គាត់ ។

ដានី ៖ ពីសមាហរណកម្មមក គាត់ជាគណៈស្រុករហូត ហើយក៏មានផ្សេងទៀត?

ភីន ៖ បាទ! អត់មានទេ មានតែគាត់ធ្វើមករហូតរបស់គាត់ ។ ហើយយើងកំណត់ថា ខ្ញុំមិនថាទេ បើធ្វើបានចឹង អាចថាគាត់គួរសមបាននៅបានយូរអី បើមិនគួរសមសម័យនេះសម័យគេបោះឆ្នោត អាចគាត់មិនបានធ្វើយូរចឹងទេ ។

ដានី ៖ អានឹងសម័យនឹងសម័យឥឡូវនឹង ចុះសម័យមុន?

ភីន ៖ សម័យមុន?

ដានី ៖ មុនសមាហរណកម្ម?

ភីន ៖ មុនសមាហរណកម្ម គ្មានអ្នកណា មានតា ម៉ុក គេមានរៀបចំដែរតូចៗ ។

ដានី ៖ ខ្ញុំមិនចង់និយាយថាគាត់អាក្រក់ ល្អអីទេ ប៉ុន្តែចំពោះប្រជាជនយើង គាត់មកអន្លង់វែងនឹងធ្វើឲ្យប្រជាជនចងចាំ ថាគាត់បានជួយអីធ្វើអីជាមេដឹកនាំសំខាន់?

ភីន ៖ មនុស្សបើយើងនិយាយទៅ ប្អូនឯងសួរដូចចេះ គេថានៅជាមួយអ្នកណាអឹមដោះអ្នកនឹងចឹងមែនឯង មិនខុសទេ ពាក្យស្លោកនឹង ។ សម័យនឹងនៅជាមួយតា ម៉ុក ហើយគាត់ចិញ្ចឹម គាត់អីទាំងអស់ដូចយើងដឹងឃើញយើងដឹង ហើយយើងភាគច្រើនយើងថាគាត់នឹងហើយល្អ មិនដឹងមានពីណាមកនៅពីលើគាត់ទៀតផង ។

ដានី ៖ ពីមុនមកគាត់នៅជាមួយតា ម៉ុក កសាងអី យើងឃើញថាគាត់ល្អ ដល់ពេលមកដល់សម័យឥឡូវនេះ?

ភីន ៖ សម័យនេះ យើងឃើញថា សម្តេច ហ៊ុន សែន យើងថាគាត់នឹងហើយ គាត់ដឹកនាំហើយគាត់ធ្វើចឹង ហើយយើងដឹង ។

ដានី ៖ ហេតុដូចថាសម័យឥឡូវ ម៉េចបានគិតថា សម្តេច ហ៊ុន សែន គាត់ល្អ គាត់សំខាន់?

ភីន ៖ អឺ! ល្អ ខ្ញុំថាត្រង់ថាបោះឆ្នោតជាប់រហូត ខ្ញុំក៏នៅក្នុងគណបក្សគាត់ដែរ ព្រោះឃើញគាត់ធំមែន ហើយខ្ញុំចេះនឹកឃើញស្រឡាញ់តាមការធ្វើនឹងហើយ ។ ទោះបីគាត់មិនបានថាជួយយើងតាមផ្ទះមែន ប៉ុនគាត់ជួយអីផ្សេងៗ កូនយើងមានលទ្ធភាពរៀនផ្លូវដើរយើងមាន មន្ទីរពេទ្យយើងមានទៅ ។

ដានី ៖ មិនមែនពូខ្លាចគាត់ ចេះតែនិយាយថាគាត់ល្អ?

ភីន ៖ ទេ! អត់មានទេ ព័ត៌មានគេនិយាយចឹងមែន ប៉ុនខ្ញុំឃើញផ្ទាល់ខ្លួនឯងដែរ ។

ដានី ៖ ផ្សេងពីនេះខ្ញុំសួរយោបល់ពីលោកពូទេ លោកពូចង់មានប្រសាសន៍ថាយ៉ាងម៉េចក៏បានដែរ ។

ភីន ៖ បាទ! ខ្ញុំឆ្លើយ ប្រាប់តាមយោបល់ខ្ញុំនឹង អត់មានខុសទេ ។

ដានី ៖ ទាក់ទងនឹងមេដឹកនាំសាសនា ដូចជាលោកពូខាងព្រះពុទ្ធសាសនា មានព្រះសង្ឃមានអីហើយចុះលោកពូគិតថាខាងព្រះសង្ឃវិញ ដូចថាមុនសមាហរណកម្ម ក្រោយសមាហរណកម្មហើយឥឡូវនឹង លោកពូគិតថា ព្រះសង្ឃ អ្នកដឹកនាំសានាស ចៅអធិការវត្ត ឬក៏មេគុណអនុគុណស្រុកអីចឹង បើតាមលោកពូចាំ ព្រះសង្ឃអង្គណាមួយដែលមានឥទ្ធិពល ដែលចូលរួមតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍សហគមន៍នៅក្នុងស្រុកអន្លង់វែងយើងនេះ?

ភីន ៖ អភិវឌ្ឍន៍ ខ្ញុំក៏ពិបាកកំណត់ដែរ ព្រះសង្ឃយើងឥឡូវនេះ ពិបាកកំណត់ចេះអន្លង់វែងវាអត់ទៀង អត់មានមួយណាមកគង់នៅបាន៣ឆ្នាំពិតប្រាកដមិនមាន គង់នៅហើយបានមួយរយៈទៅប្រយទៅបាត់ទៅ លោកសឹកទៅបាត់ទៅ ឬក៏ទៅណាទៅ រកត្រង់ណាមួយឲ្យនឹងនរមិនឃើញ ។ ឥឡូវកំណត់ខ្លួនខ្ញុំថាចេះ ឲ្យតែមានសង្ឃនៅវត្តចេះតែធ្វើបុណ្យទៅ លោកគង់នៅ

បានយូរក្តី ឆាប់ក្តីចេះតែធ្វើទៅ តែឲ្យពិកប្រាកដថាអន្តណានៅយូរជាងគេ កំណត់ថាល្អ អាក្រក់ កំណត់អត់កើតប្អូន ។

ដានី : ចុះបើនិយាយពី គិតថាខាងព្រះពុទ្ធសាសនាចូលរួមចំណែក ក្នុងការជួយកសាងសង្គម អភិវឌ្ឍន៍សង្គមដែរ ហើយក៏យ៉ាងម៉េច?

ភីន : បាទ! ចូលរួមតើព្រះពុទ្ធសាសនា គាត់ប្រដែលប្រដៅមនុស្សបានល្អ បើយើងធ់តាមល្អ មែនទែន តែបើយើងអត់ធ្វើ តាមមនុស្សពាលអត់ល្អទេ មនុស្សធ្វើតាមព្រះពុទ្ធសាសនា ល្អ ។

ដានី : ចុះសាសនាផ្សេង?

ភីន : សាសនាផ្សេងយើងអត់បានរៀន បើតាមដឹងខ្លះក៏គេប្រដៅដូចតែយើង ប៉ុនសាសនាបើ គិតទៅជម្លោះគ្នាសាសនាមាន អានឹងយើងប្រុងប្រយ័ត្នដែរ ។ យើងព្រះពុទ្ធយូរហើយ តែ ឥឡូវនេះវាមានសាសនាអីផ្សេង ចូលមកយើងប្រយ័ត្នដែរ អាចគេបង្កឲ្យឈ្លោះគ្នាក៏មាន ដែរ មកនៅស្រុកគេមានដែរ ឈ្លោះគ្នាសាសនានេះ ហើយធំណាស់អាសាសនាឈ្លោះ គ្នា ។

ដានី : សំនួរចុងក្រោយ ទាក់ទងពីកន្លែងនៅអន្លង់វែង កន្លែងណា កន្លែងតំបន់យុទ្ធសាស្រ្តសំខាន់ កន្លែងសមរភូមិ យុត្តិសាស្រ្តសំខាន់ជាងគេ ដែលលោកពូនៅចាំ?

ភីន : ទេ! អត់ទាន់មានអ្នកណាគេកំណត់ឲ្យយើងដឹងចឹងផង ខ្ញុំអត់ទាន់ដឹង បើប្អូនឯងកំណត់មក ខ្ញុំថា ។

ដានី : អត់ទេ លោកពូធ្លាប់រស់នៅនឹង ធ្លាប់យើងធ្វើសង្រ្គាមជាមួយយួន ជាមួយតា ម៉ុក អី ទីតាំងមួយណា ឬកន្លែងតំបន់ណា ដែលចាត់ទុកថាជាតំបន់យុទ្ធសាស្រ្ត សមរភូមិក្តៅ?

ភីន : អាក្តៅជាងគេដណ្តើមគ្នា អនង់វែងនឹងហើយ ត្រង់នឹងឯង ទីរួមស្រុកនឹងឯង ។

ដានី : កន្លែងទីរួមស្រុកនឹង?

ភីន : បាទ! ដើម្បីគេវ៉ៃយកដីនៅ យួនក៏គេមិនចង់ឲ្យយើង ហើយយើងក៏ខំថាយកដីត្រង់នឹងបាន ទៅវាមានសេដ្ឋកិច្ចយក ។

ដានី : កន្លែងដែលយើងចង់បានរៀងៗខ្លួន គឺទីរួមស្រុកអន្លង់វែងយើងរាប់ថ្ងៃ?

ភីន : បាទ! អានឹងមុខយើងនេះណា យើងនិយាយចំមុខយើងទេ ប៉ុនអាកន្លែងច្បាំងគ្នា យក ផ្តាច់ផ្តិលជីវិតខ្មែរយើងមែននោះ ភ្នំដងរែកទេ ។ គេអត់ចង់ឲ្យយើងនៅទេ ដែនការធ្វើរបង ស៊ីម៉ង់ត៍តែទៅមិនរួចដូចខ្ញុំនិយាយចឹង ប្រែមកក-៥ ។

ដានី ៖ បាទ! ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំលោកពូទៀតហើយ ចឹងលោកពូមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់ទាន់បានសួរនាំ?

ភីន ៖ ទេ! សួរនឹងវាអស់ទៅហើយ វាអត់មានអីនៅទៀតទេ បើសួរតាំងពីប្រវត្តិពីកើតមកអស់មានតែខ្ញុំនិយាយប្រាប់មិនអស់ផង វាចន្លោះដុំៗ ។

ដានី ៖ បាទ! ខ្ញុំអរគុណលោកពូច្រើន ដែលចំណាយពេលច្រើនម៉ោងដែរ ។

«ចប់»